សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ • ខែ កក្កដា ឆ្នាំ 2014

# លីអាហូណា



## ការធ្វើជាឪពុកម្តាយនៃពួកមជ្ឈិមវ័យវ័យក្មេង ទំព័រ 34

ប្រទេសប្រេស៊ីល ៖ សតវត្សនៃការរីកចម្រើន ទំព័រ 18

ការមើលព្រះអង្គសង្គ្រោះជានិមិត្តរូប ទំព័រ 52



*« ពេលខ្លះយើង បានក្លាយជាផ្ទាំងសីប ហើយយើងត្រូវតែ ‹ ស៊ូទ្រាំ › ចំពោះការកាន់ខ្ជាប់នឹងបទដ្ឋានរបស់ព្រះ និង ការធ្វើកិច្ចការរបស់ទ្រង់ ។ ខ្ញុំសូមថ្លែងទីបន្ទាល់ថា យើងមិនត្រូវភ័យខ្លាចថាតើយើងជាគ្រឹះមួយនៅក្នុងគោលលទ្ធិដែរឬអត់នោះទេ ។ យើងអាចមានបទពិសោធន៍នៃការយល់ខុស ការរិះគន់ ថែមទាំងការស្តីបន្ទោសខុសផងដែរ ប៉ុន្តែយើងមិននៅតែឯងឡើយ ។ ព្រះអង្គសង្គ្រោះរបស់យើង ‹ ត្រូវគេមើលងាយ ហើយត្រូវមនុស្សបោះបង់ចោល › [អេសាយ 53:3] ។ វាជាសិទ្ធិដ៏ពិសិដ្ឋរបស់យើងដើម្បីឈរជាមួយនឹងទ្រង់ ! »*

អែលឌើរ រ៉ូប៊ើត ឌី ហេល នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ « Stand Strong in Holy Places » *Liahona* ខែ ឧសភា ឆ្នាំ 2013 ទំព័រ 50 ។

# លីអាហូណា ខែ កក្កដា ឆ្នាំ 2014




## សារលិខិត


4 **សារលិខិតគណៈប្រធានទីមួយ សេចក្ដីសន្យានៃការបង្វែរដួងចិត្ត**
ដោយប្រធាន ហិនរី ប៊ី អាវរិង

7 **សារលិខិតបង្រៀនសួរសុខទុក្ខ បេសកកម្មដ៏ទេវភាពនៃព្រះយេស៊ូវគ្រីស្ទ ៖ ព្រះអង្គគាំទ្រ**


## អត្ថបទពិសេស។


18 **អ្នកត្រួសត្រាយផ្លូវនៅគ្រប់ដែនដី: សាសនាចក្រនៅប្រទេសប្រេស៊ីល ៖ នៅទីបំផុតអនាគតបានមកដល់**
ដោយ ម៉ាក អិល ហ្គ្រូវី
*សាសនាចក្រនៅក្នុងប្រទេសប្រេស៊ីលបានរីកចម្រើនពីគ្រួសារអន្តោប្រវេសន៍ដ៏តូចមួយ រហូតដល់មានសមាជិកច្រើនជាងមួយលាននាក់ ។*

24 **ព្រះគម្ពីរមរមន ការប្រមូលផ្ដុំនៃអ៊ីស្រាអែល និង ការយាងមកជាលើកទីពីរ**
ដោយអែលឌើរ រ័សុល អិម ណិលសុន
*ព្រះគម្ពីរមរមនគឺជាឧបករណ៍របស់ព្រះ ដើម្បីជួយសម្រេចគោលបំណងដ៏ទេវភាពចំនួនពីរ ។*

30 **ចូរធ្វើដូចជាអាំម៉ូន**
*តើដំណើររឿងរបស់អាំម៉ូនអាចជួយអ្នកដើម្បីធ្វើឲ្យសមាជិកនៅក្នុងវួដ ឬ សាខារបស់អ្នកបានសកម្មដែរទេ ?*

34 **សេចក្ដីណែនាំទាំងដប់សម្រាប់ឪពុកម្ដាយនៃពួកមជ្ឈិមវ័យវ័យក្មេង**
ដោយ វេនឌី អ៊ុលរីឆ
*សំណួមពរទាំង 5 និង សេចក្ដីណែនាំទាំង 10 នេះនឹងជួយអ្នកឲ្យដឹងពីកូនវ័យជំទង់របស់អ្នក ។*


## ផ្នែកទាំងឡាយ


8 **សៀវភៅកត់ចំណាំសន្និសីទខែ មេសា ឆ្នាំ 2014**

10 **អ្វីដែលយើងជឿ: យើងបង្រៀនដោយព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ**

12 **ការបម្រើនៅក្នុងសាសនាចក្រ: ការដឹកនាំដូចជាព្រះអង្គសង្គ្រោះ**
ដោយ រ៉ាយអិន ខា

14 **ពួកព្យាការីគម្ពីរសញ្ញាចាស់: អេលីយ៉ា**

15 **ការបង្រៀន*ដើម្បីកម្លាំងនៃយុវជន:*
ធ្វើការ និង ការពឹងផ្អែកលើខ្លួនឯង**

16 **ព័ត៌មានសាសនាចក្រ**

38 **សំឡេងពួកបរិសុទ្ធថ្ងៃចុងក្រោយ**

80 **លុះត្រាយើងជួបទៀត: ការសម្លឹងមើលទៅច្រាំងទន្លេ**
ដោយ រីឆាត អិម រ៉ូមនី
*ប៉ាមិនអាចទៅកន្លែងណាផ្សេងឡើយ បើប៉ាខំសម្លឹងមើលតែទឹករលកនោះ ។*


**នៅលើគម្រប**
ខាងមុខ ៖ រចនារូបថតដោយ កូឌី ប៉ែល ។ ខាងក្នុងគម្របខាងមុខ ៖ រូបថត © Robert Harding World Imagery/Corbis ។

## មជ្ឈិមវ័យវ័យក្មេង





**42 ការប្រែក្លាយជាល្អឥតខ្ចោះនៅក្នុងព្រះគ្រីស្ទ**
ដោយអែលឌើរ ហ្គេរីត ដបុលយូ ហ្គង់
*ភាពល្អឥតខ្ចោះរបស់ព្រះអង្គសង្គ្រោះអាចជួយយើងឲ្យយកឈ្នះលើផ្នត់គំនិតនៃសុក្រិត្យនិយម ការចាប់កំហុសខ្លួនឯង និង ភាពមិនពិតប្រាកដ ។*




*ចាំមើលថា តើអ្នកអាចរកឃើញរូបលីអាហូណាដែលលាក់នៅក្នុងលេខនេះដែរឬទេ ។ តម្រុយ ៖ រើសផ្កាពណ៌ស្វាយ ។*

## យុវវ័យ


**48 សេចក្ដីសញ្ញាដ៏ទេវភាពធ្វើឲ្យមានពួកគ្រីស្ទានដ៏រឹងមាំ**
ដោយអែលឌើរ ឌី ថត គ្រីស្តូហ្វឺសិន
*តើយើងទទួលអំណាចខាងសីលធម៌ និង ខាងវិញ្ញាណតាមរបៀបណា ?*

**52 តើអ្នកមើលឃើញអ្វីខ្លះ ?**
ដោយ ដេវីឌ អេ អេដវូដ
*សូមមើលឲ្យស៊ីជម្រៅចំពោះពិធីបរិសុទ្ធនៃដំណឹងល្អ ។ អ្នកអាចរៀននូវអ្វីមួយថ្មី ។*

**55 ទីកន្លែងរបស់យើង**

**56 ដើម្បីកម្លាំងនៃយុវជន ៖: ការងារ—តើនរណាត្រូវការវា ?**
ដោយ រ៉ានឌល អិល រីឌ

**58 ការប្ដូរបំពង់ទឹកទាំងស្បែកជើងសុទ្ធតែភក់**
បម៉ុន អិម អល់តុន
*ខ្ញុំទើបតែបានសម្រាកពីកិច្ចការនៅពេលព្រឹករបស់ខ្ញុំបន្តិច ខណៈពេលដែលប្រធានកូរ៉ុមរបស់ខ្ញុំបានបើកឡានចូលផ្លូវមុខផ្ទះខ្ញុំ ។*

**60 ទៅកាន់គោលដៅ**

**61 ប័ណ្ណប្រកាស ៖ រឿងទាំងឡាយមិនដូចជាអ្វីដែលបានគិតជានិច្ចទ្បើយ**

**62 ការបម្រើសម្រាប់មូលហេតុត្រឹមត្រូវ**
រ៉ាសេម ម៉ាឡេហ្វ
*ខ្ញុំមានការងារដ៏ល្អមួយនៅក្នុងកីឡាបាល់ឱប ។ តើខ្ញុំពិតជាត្រូវបម្រើបេសកកម្មមែនទេ ?*

**64 ពួកមរមន*ពិត*ជាជឿលើព្រះ**
ប្រេនដា ហ៊ើរណាន់ឌេស្ស រីស្ស
*នៅពេលខ្ញុំប្រាប់ទៅស្ត្រីម្នាក់ថា ខ្ញុំជាមរមន គាត់មិនចង់និយាយរកខ្ញុំទៀតទ្បើយ ។*





## កុមារ





**66 សាក្សីពិសេស ៖ តើយើងអាចធ្វើអ្វីខ្លះដើម្បីមានភាពសក្ដិសមនឹងព្រះវិញ្ញាណ ?**
ដោយប្រធាន បិយដ៏ ឃេ ផាកកឺ

**67 មេរៀនរបស់ខ្ញុំស្ដីពីសេចក្ដីជំនឿ**
ដោយ អិមម៉ា អ័រ
*គ្រាប់ត្រសក់ស្រូវបានបង្រៀនខ្ញុំពីសេចក្ដីជំនឿ ។*

**68 រូបកាយរបស់ខ្ញុំ គឺជាព្រះវិហារបរិសុទ្ធ**
ដោយ ម៉ារីស្សា វីដឌីសុន
*តើអ្នកមានសំណួរពីរូបកាយរបស់អ្នកដែរឬទេ ?*

**70 ការនាំថ្នាក់កុមារមកក្នុងលំនៅដ្ឋាន: យើងក្លាយជាសមាជិកនៃសាសនាចក្រតាមរយៈពិធីបុណ្យជ្រមុជទឹក និងពិធីបញ្ជាក់**
ដោយ ជែននីហ្វើ ម៉ាឌី

**72 ទំព័ររបស់យើង**

**73 បានរៀបចំខ្លួនដើម្បីបម្រើ**
ដោយ អែលឌើរ អេក្វាដូ ហ្គារ៉ាប៉ែត
*ទឹកនោះត្រជាក់ណាស់ ប៉ុន្តែខ្ញុំនៅតែចង់ទទួលបុណ្យជ្រមុជទឹក ។*

**74 ការបង្កើតមិត្តភាពនៅជុំវិញពិភពលោក: ខ្ញុំឈ្មោះ ផេដ្រូ មកពីប្រទេសប្រេស៊ីល**
ដោយ អេមី ជេន ឡីវិត

**76 សម្រាប់កុមារតូចៗ: សារ៉ាបានដើរហើយដើរទៀត**
ដោយ ហៃឌី ផូលម៉ែន

**81 រូបគំនូរព្យាការី: ថូម៉ាស អេស ម៉នសុន**

**ច្បាប់សម្រាប់ខែ កក្កដា ឆ្នាំ 2014 វ៉ុល 13 លេខ 4**
**លីអាហូណា 10987 258**
ទស្សនាវដ្ដីអន្ដរជាតិរបស់សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

**គណៈប្រធានទីមួយ ៖** ថូម៉ាស អេស. ម៉នសុន, ហិនរី ប៊ី. អាវរិង, ឌៀថើរ អេហ្វ. អុជដូហ្វ

**កូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖** ប៊យដ៍ ខេ. ផាកកឺ, អិល. ថម ភែរី, រ័សុល អិម. ណិលសុន, ដាល្លិន អេក. អូក, អិម. រ័សុល បាឡឺដ, រីឆាដ ជី. ស្កត, រ៉ូប៊ឺត ឌី. ហែល, ជែហ្វ្រី អ័រ. ហូឡិន, ដេវីឌ អេ. បែដណា, ឃ្វីនថិន អិល. ឃុក, ឌី ថត. គ្រីស្តូហ្វឺសិន, នែល អិល. អាន់ឌើរសិន

**អ្នកកែសម្រួល ៖** គ្រេក អេ. ខារដុន
**អ្នកប្រឹក្សា ៖** សមើរវីន ប៊ី អាណុល, ក្រេន អិម. យូរិន, ប្រ៊ែដលី ឌី. ហ្វូស្ទើរ, ចស អិល អាឡុនសូ, គ្រីស្តូហ្វែល ហ្គូលឌិន ជុញ្ញ័រ

**នាយកគ្រប់គ្រង ៖** ដេវីឌ ធី. វ៉ នើរ
**នាយកគាំទ្រគ្រួសារ និង សមាជិក ៖** វីនសេនត៍ អេ. វ៉ាញ
**នាយកទស្សនាវដ្ដីសាសនាចក្រ ៖** អាលែន អ័រ. ឡយបិច
**អ្នកគ្រប់គ្រងពាណិជ្ជកម្ម ៖** ហ្គាស្វ ខាណុន

**អ្នកគ្រប់គ្រងផ្នែកកែសម្រួល ៖** អ័រ. វ៉ាល ចនសុន
**ជំនួយការអ្នកគ្រប់គ្រងផ្នែកកែសម្រួល ៖** ឬរិន ខារ
**និពន្ធ និងកែសម្រួល ៖** ប្រ៊ីតថានី ប៊ីតធី, ដេវីដ ឌិកសុន, ដេវីដ អេ. អែដវ៉ដ, ម៉ាថាយ ឌី. ហ្វលិតតុន, មិនឌី ប៉ ហ្វ្រ៊ីដមែន, ហែរី អេច. ហ្គាហ្វ, ឡារិននេ ផតធើរ ហ្គន, ជេនីហ្វើរ ម្រេ្គស ហូលឡិន, ម៉ៃឃើល អ័រ. ម៉ូរីស, សាលី ចនសុន អូឌេឃឺក, យ៉ូស្វេ ជេ ភីគី, ជេន ភីនប៊ូរ៉ាហ្វ, រីឆាដ អិម. រ៉មនី, ប៉ុល វ៉ែនដិនបើជ, ម៉ារីស្សា វីឌីសុន

**នាយកគ្រប់គ្រងផ្នែកសិល្បៈ ៖** ជេ. ស្កត នូដសិន
**នាយកផ្នែកសិល្បៈ ៖** ចាត អ័រ. ភីធើរសុន
**រចនាម៉ូត ៖** ជីនិត អាន់ទ្រូ, ហ្វេ ភី. អាន់ត្រូស, មែនឌី អឹម. ប៉េនលី, ស៊ី. ឃីមប៊ីល បុត, ថូម៉ាស ឆាល, ណាត ហ្គីនេស, ខូលីន ហ៊ីងគ្លី, អេរិក ភី. ចនសិន, ស៊ូសាន ឡហ្វ្រ៊ិន, ស្កត អិម. ម៉ូយ, ម៉ាក ដបុលយូ. រ៉ូប៊ីសុន, ប្រាត ធៀរ, ឃេ. នីកូល វ៉ក់ឃិនហូស

**អ្នកសម្របសម្រួលកម្មសិទ្ធបញ្ញា ៖** ខូលែត នែបេឃើ អាន
**អ្នកគ្រប់គ្រងផ្នែកផលិតកម្ម ៖** ជេន អាន ភិធើរស៍
**ផលិតកម្ម ៖** ខេវិន ស៊ី បើងស៍, ខននី ប៊ូស្រូប ប្រ៊ីជ, ជូលី ប៊ើដេត, ប្រាយអែន ដបុលយូ. ជីគី, ដេនីស តើបៃ, ជិន្នីស ឌីប៊ី, ជីន្នី ហ្គីននី ជេ. នីលសុន, ហ្គេលី ថេត វ៉ាហ្វើធី
**អ្នកពិនិត្យមុនការបោះពុម្ព ៖** ជេហ្វ អិល. ម៉ាទីន

**នាយកផ្នែកបោះពុម្ព ៖** ក្រេហ្គ ខេ. សែតវីត
**នាយកផ្នែកចែកចាយ ៖** ស្តេហ្វិន អ័រ គ្រីស្ទិនសិន

ចំពោះការជាវ និង តម្លៃនៅខាងក្រៅសហរដ្ឋ និង កាណាដា សូមចូលទៅកាន់គេហទំព័រ store.lds.org ឬ សូមទាក់ទងមជ្ឈមណ្ឌលចែកចាយរបស់សាសនាចក្រក្នុងមូលដ្ឋានរបស់អ្នក ឬ ទាក់ទងអ្នកដឹកនាំវួដ ឬ សាខារបស់អ្នក ។

**សូមផ្ញើអត្ថបទ និងសំណួរទាំងឡាយ** តាមអិនធើរណិតនៅគេហទំព័រ liahona.lds.org តាមអ៊ីម៉ែលទៅកាន់ liahona@ldschurch.org ឬ តាមសំបុត្រទៅកាន់ Liahona, Rm. 2420, 50 E. North Temple St., Salt Lake City, UT 84150-0024, USA ។

*លីអាហូណា* ( ពាក្យក្នុងព្រះគម្ពីរមរមនមានន័យថា « ត្រីវិស័យ » ឬ « វត្ថុនាំផ្លូវ » ) ត្រូវបានបោះពុម្ពជាភាសា អាល់បានី, អាមេនី, ប៊ីស្លាមា, ប៊ុលហ្គារី, ខ្មែរ, សេប៊ូអាណូ, ចិន, ចិន ( ងាយស្រួល ), ក្រូអាត, ឆែក, ដាណាម៉ាក, ហូឡង់, អង់គ្លេស, អេស្តូអានី, ហ៊្វីជី, ហ្វាំងឡង់, បារាំង, អាល្លឺម៉ង់, ក្រិច, ហុងគ្រី, អាយឡែនឌិក, ឥណ្ឌូនេស៊ី, អ៊ីតាលី, ជប៉ុន, គីរីបាទី, កូរ៉េ, ឡាវៀន, លីទុយអានី, ម៉ាឡាហ្គាសី, ម៉ាស្ហែល, ម៉ុងហ្គោលី,នរវេ, ប៉ូឡូញ, ព័រទុយហ្គាល់, រ៉ូម៉ានី, រុស្ស៊ី, សាម័រ, ស្លូវ៉ានី, អេស្ប៉ាញ, ស្វាហ៊ីលី, ស៊ុយអែត, តាហ្គាឡុក, តាហ៊ីទី, ថៃ, តុងហ្គា, អ៊ុយក្រែន, អ៊ឺឌូ និង វៀតណាម ។ ( ការចេញញឹកញាប់ប៉ុនណា គឺប្រែប្រួលទៅតាមភាសា ) ។

© 2014 ដោយ Intellectual Reserve, Inc ។ រក្សាសិទ្ធិគ្រប់យ៉ាង ។ បោះពុម្ពនៅសហរដ្ឋអាមេរិក ។

អត្ថបទ និង សម្ភារដែលមើលឃើញ ដែលមាននៅក្នុង *លីអាហូណា* អាចថតចម្លងយកទៅប្រើប្រាស់ជាបន្ទាប់បន្សំ ដែលមិនមែនជាការធ្វើពាណិជ្ជកម្មតាមសាសនាចក្រ ឬ តាមគេហដ្ឋានឡើយ ។ សម្ភារដែលមើលឃើញ មិនអាចថតចម្លងបានឡើយ ប្រសិនបើមានដាក់បម្រាម ដែលបានចង្អុលបង្ហាញត្រង់បន្ទាត់សម្គាល់ ដែលនៅជាមួយនឹងរូបសិល្បៈ ។ សំណួរទាក់ទងនឹងការរក្សាសិទ្ធិ គួរតែសាកសួរទៅកាន់ Intellectual Property Office, 50 E. North Temple St., Salt Lake City, UT 84150, USA អ៊ីម៉ែល ៖ cor-intellectualproperty@ldschurch.org ។

**For Readers in the United States and Canada:**
July 2014 Vol. 13 No. 4. LIAHONA (USPS 311-480) Cambodian (ISSN 1538-4535) is published six times a year (January, April, June, July, October, and December) by The Church of Jesus Christ of Latter-day Saints, 50 E. North Temple St., Salt Lake City, UT 84150. USA subscription price is $5.00 per year; Canada, $6.00 plus applicable taxes. Periodicals Postage Paid at Salt Lake City, Utah. Sixty days' notice required for change of address. Include address label from a recent issue; old and new address must be included. Send USA and Canadian subscriptions to Salt Lake Distribution Center at address below. Subscription help line: 1-800-537-5971. Credit card orders (American Express, Discover, MasterCard, Visa) may be taken by phone or at store.lds.org. (Canada Post Information: Publication Agreement #40017431)

POSTMASTER: Send all UAA to CFS (see DMM 707.4.12.5). NONPOSTAL AND MILITARY FACILITIES: Send address changes to Distribution Services, Church Magazines, P.O. Box 26368, Salt Lake City, UT 84126-0368, USA.

# គំនិតទាំងឡាយសម្រាប់រាត្រីជួបជុំក្រុមគ្រួសារ

*ច្បាប់នេះមាននូវអត្ថបទ និង សកម្មភាពនានាដែលអាចយកទៅប្រើប្រាស់សម្រាប់រាត្រីជួបជុំក្រុមគ្រួសារ ។ នៅខាងក្រោមជាគំនិតចំនួនពីរ ។*



**« ការប្រែក្លាយជាល្អឥតខ្ចោះនៅក្នុងព្រះគ្រីស្ទ »** ទំព័រ 42 ៖ ដោយប្រើការបង្រៀនរបស់អែលឌើរ ហ្គង់ ស្ដីពីភាពល្អឥតខ្ចោះ សូមដាក់នូវសំណួរពិត ឬមិនពិតសម្រាប់គ្រួសាររបស់អ្នក ដើម្បីជួយពួកគេឲ្យដឹងថា តើពួកគេមាននូវនិន្នាការនៃភាពល្អឥតខ្ចោះ សុក្រិតភាពដែរឬទេ ។ អ្នកអាចប្រើឃ្លាដូចជា « ខ្ញុំអាចមានភាពរីករាយ ថ្វីបើពេលខ្លះខ្ញុំធ្វើខុសក្ដី » ឬ « ខ្ញុំពិបាកក្នុងការអត់ទោសឲ្យអ្នកដទៃណាស់ » នៅក្នុងសំណួររបស់អ្នក ។ សូមអានរួមគ្នានូវអ្វីដែលអែលឌើរ ហ្គង់ បង្រៀនស្ដីពីការពឹងផ្អែកទៅលើព្រះអង្គសង្គ្រោះ ។ អ្នកក៏អាចប្រើទំព័រ 149–50 នៅក្នុង *ប្រកាសដំណឹងល្អរបស់យើង ៖ សៀវភៅណែនាំសម្រាប់ការបម្រើរបស់អ្នកផ្សព្វផ្សាយសាសនា*ដើម្បីបង្រៀនពីរបៀបដាក់គោលដៅសមរម្យ ហើយយកឈ្នះលើភាពល្អឥតខ្ចោះ ។

**« រូបកាយរបស់ខ្ញុំគឺជាព្រះវិហារបរិសុទ្ធ »** ទំព័រ 68 ៖ ប្រើសំណួរនៅក្នុងអត្ថបទនេះដើម្បីបង្រៀនកូនចៅរបស់អ្នកពីរបៀបឲ្យតម្លៃ ហើយស្រឡាញ់រូបកាយខ្លួន ។ អ្នកអាចមានជាអាហារសម្រន់ល្អ។ ដូចជាផ្លែឈើ ឬបន្លែ ដើម្បីបង្រៀនកូនចៅរបស់អ្នកស្ដីពីទម្លាប់នៃការទទួលទានអាហារល្អ ។ អ្នកគួរលេងកីឡា ឬធ្វើសកម្មភាពមួយនៅខាងក្រៅផ្ទះ ដើម្បីជួយកូនចៅរបស់អ្នកឲ្យមានអំណរគុណចំពោះសុខភាពល្អ និងកម្លាំងមាំមួន ។ សូមលើកទឹកចិត្តកូនចៅរបស់អ្នកឲ្យជួយដល់កុមារ ឬក្មេងជំទង់ម្នាក់ដែលពិការនៅក្នុងវួដ សាខា ឬសាលារៀនរបស់ពួកគេ ។ អ្នកក៏អាចច្រៀងបទ « I'll Walk with You » ( *Children's Songbook* ទំព័រ 140 ) ផងដែរ ។

## ជាភាសារបស់អ្នក

*លីអាហូណា* និង ឯកសារផ្សេងទៀតរបស់សាសនាចក្រមានជាច្រើនភាសា សូមចូលទៅកាន់ **languages.lds.org** ។

**ប្រធានបទទាំងឡាយក្នុងច្បាប់នេះ**
*លេខទាំងឡាយគឺតំណាងឲ្យទំព័រទីមួយនៃអត្ថបទនេះ ។*

***ការធ្វើឲ្យសកម្ម*** *30, 38*
***ការបង្រៀន*** *10*
***ការបម្រើ*** *12, 56, 58, 62, 73*
***ការប្រែចិត្តជឿ*** *18*
***ការយាងមកជាលើកទីពីរ*** *24*
***ការហៅ*** *12*
***កិច្ចការផ្សព្វផ្សាយសាសនា*** *18, 30, 62, 64*
***ក្រុមគ្រួសារ*** *34, 39, 40, 41, 80*
***ដង្វាយធួន*** *7, 42*
***ទស្សនវិស័យអស់កល្បជានិច្ច*** *42, 80*
***ទីបន្ទាល់*** *64*
***ធ្វើការ*** *15, 56, 58*
***បទបញ្ញត្តិទាំងឡាយ*** *60*
***ពង្សប្រវត្តិ*** *4, 6, 14, 55*
***ពិធីបញ្ជាក់*** *52, 70*
***ពិធីបរិសុទ្ធទាំងឡាយ*** *52, 70*
***ពិធីបុណ្យជ្រមុជទឹក*** *52, 70, 73*
***ពិធីសាក្រាម៉ង់*** *52, 70*
***ព្យាការីទាំងឡាយ*** *14, 81*
***ព្រះគម្ពីរមរមន*** *24, 30, 38, 55*
***ព្រះគម្ពីរសញ្ញាចាស់*** *14*
***ព្រះយេស៊ូវគ្រីស្ទ*** *7, 12, 42*
***ព្រះវិញ្ញាណបរិសុទ្ធ*** *10, 40, 66*
***ព្រះវិហារបរិសុទ្ធ*** *18*
***ភាពជាឪពុកម្ដាយ*** *34*
***មជ្ឈិមវ័យវ័យក្មេង*** *34*
***រូបកាយ*** *68*
***សេចក្ដីជំនឿ*** *48, 67*
***សេចក្ដីសញ្ញាទាំងឡាយ*** *24, 48*
***អាពាហ៍ពិពាហ៍*** *41*
***អ្នកត្រួសត្រាយ*** *18, 76*

សារលិខិតគណៈប្រធានទីមួយ



**ដោយប្រធាន ហិនរី ប៊ី អាវរិង**
ទីប្រឹក្សាទីមួយក្នុងគណៈប្រធានទីមួយ

# សេចក្ដីសន្យានៃ ការបង្វែរដួងចិត្ត

អ្នកម្ដាយរបស់ខ្ញុំឈ្មោះ មៀលខ្រេដ ប៊េនញៀន អាយរិង បានធំដឹងក្ដីឡើងនៅក្នុងកសិដ្ឋាននៃទីក្រុង ប្រេ្ហគងជី រដ្ឋយូថាហ៍ ស.រ.អា. ។ បងប្អូនប្រុសរបស់គាត់ម្នាក់ឈ្មោះ រ៉យ បានបន្តធ្វើជំនួញរបស់គ្រួសារដោយការចិញ្ចឹមសត្វចៀម ។ កាលពីក្មេង រ៉យ បានចំណាយពេលជាច្រើនសប្ដាហ៍ឃ្លាតឆ្ងាយពីផ្ទះ ។ លុះយូរទៅគាត់មានចំណាប់អារម្មណ៍តិចទៅៗទៅលើសាសនាចក្រ ។ នៅទីបំផុត គាត់បានផ្លាស់ទៅរដ្ឋអៃដាហូ ស.រ.អា. បានរៀបការ ហើយមានកូនបីនាក់ ។ គាត់បានចែកឋានទៅក្នុងវ័យ 34 ឆ្នាំ នៅពេលភរិយារបស់គាត់មានវ័យ 28 ឆ្នាំ ហើយមានកូនតូចៗ ។

ទោះជាគ្រួសារដ៏តូចរបស់ រ៉យ នៅឯរដ្ឋអៃដាហូ ហើយអ្នកម្ដាយខ្ញុំបានផ្លាស់ទៅរដ្ឋ នូវជើស៊ី ចម្ងាយប្រមាណជា 4,025 គ.ម. ក្ដី ជារឿយៗគាត់តែងសរសេរសំបុត្រសម្ដែងពីស្រឡាញ់ និង ការលើកទឹកចិត្តទៅកាន់ពួកគេ ។ គ្រួសាររបស់ពូខ្ញុំបានហៅអ្នកម្ដាយខ្ញុំដោយសេចក្ដីស្រឡាញ់ថា « អ្នកមីង មិឌ » ។

ច្រើនឆ្នាំបានកន្លងផុតទៅ ហើយមានថ្ងៃមួយខ្ញុំបានទទួលទូរសព្ទពីបងប្អូនជីដូនមួយរបស់ខ្ញុំម្នាក់ ។ ខ្ញុំត្រូវបានប្រាប់ថា ភរិយាមេម៉ាយរបស់ រ៉យ បានចែកឋានហើយ ។ បងប្អូនជីដូនមួយរបស់ខ្ញុំបាននិយាយថា « អ្នកមីងមិឌចង់ឲ្យឯងដឹង » ។ អ្នកមីង មិឌ បានចែកឋានទៅយូរហើយ ប៉ុន្តែគ្រួសារនោះនៅតែទទួលអារម្មណ៍ពីសេចក្ដីស្រឡាញ់របស់គាត់ ហើយបានខំប្រាប់ដល់ខ្ញុំដែរ ។

ខ្ញុំមានចិត្តអស្ចារ្យពីតួនាទីដ៏សំខាន់ដែលម្ដាយខ្ញុំបានបំពេញនៅក្នុងគ្រួសាររបស់គាត់ ដែលវាស្រដៀងគ្នានឹងតួនាទីដែលព្យាការីសាសន៍នីហ្វៃបានបំពេញនៅក្នុងក្រុមគ្រួសាររបស់ពួកគាត់ផងដែរ ដោយការនៅជិតស្និទ្ធនឹងញាតិសន្តានដែលពួកគាត់ចង់នាំមកកាន់ដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ។ នីហ្វៃបានសរសេរកំណត់ត្រាមួយដែលគាត់សង្ឃឹមថា វានឹងជះឥទ្ធិពលទៅលើកូនចៅនៃបងប្អូនប្រុសរបស់គាត់ ឲ្យត្រឡប់មករកសេចក្ដីជំនឿនៃលោកអយ្យកោរបស់ពួកគេវិញ គឺលីហៃ ។ ពួកបុត្រារបស់ម៉ូសាយបានបង្ហាញសេចក្ដីស្រឡាញ់ដូចគ្នានោះ នៅពេលពួកគេផ្សាយដំណឹងល្អទៅកាន់កូនចៅរបស់លីហៃ ។

ព្រះអម្ចាស់បានប្រទានវិធីឲ្យយើងបានទទួលអារម្មណ៍នូវសេចក្ដីស្រឡាញ់ក្នុងគ្រួសារ ដែលបានបន្តមានជារៀងរហូត ។ យុវវ័យនៅក្នុងសាសនាចក្រសព្វថ្ងៃកំពុងទទួលអារម្មណ៍ថា ដួងចិត្តរបស់ខ្លួនងាកទៅរកក្រុមគ្រួសាររបស់ពួកគេ ។ ពួកគេកំពុងស្រាវជ្រាវរកឈ្មោះសមាជិកគ្រួសារដែលគ្មានឱកាសទទួលពិធីបរិសុទ្ធនៃសេចក្ដីសង្គ្រោះនៅក្នុងជីវិតនេះ ។ ពួកគេយកឈ្មោះទាំងនោះទៅព្រះវិហារបរិសុទ្ធ ។ នៅពេលពួកគេចូលទៅក្នុងទឹកនៃបុណ្យជ្រមុជទឹក ពួកគេមានឱកាសទទួលអារម្មណ៍នូវសេចក្ដីស្រឡាញ់របស់ព្រះអម្ចាស់ និង ពីសមាជិកគ្រួសារដែលពួកគេកំពុងធ្វើពិធីបរិសុទ្ធជំនួស ។

ខ្ញុំអាចនៅចាំពីសេចក្ដីស្រឡាញ់នៅសំឡេងរបស់បងប្អូនជីដូនមួយខ្ញុំដែលបានទូរសព្ទមកហើយនិយាយថា « អ្នកម្ដាយរបស់យើងបានចែកឋានហើយ ហើយអ្នកមីង មិឌ ចង់ឲ្យឯងបានដឹង » ។

អ្នករាល់គ្នាដែលបានធ្វើពិធីបរិសុទ្ធសម្រាប់សមាជិកគ្រួសារគឺកំពុងឈោងទៅជួយដោយសេចក្ដីស្រឡាញ់ ដូចដែលបុត្រារបស់ម៉ូសាយ និង ព្យាការីនីហ្វៃបានធ្វើផងដែរ ។ អ្នកនឹងទទួលអារម្មណ៍នូវសេចក្ដីអំណរចំពោះអស់អ្នកដែលទទួលយកការផ្ដល់ឲ្យរបស់អ្នកដូចជាពួកគាត់ផងដែរ ។ អ្នកក៏អាចរំពឹងទុក នឹងទទួលបាននូវអារម្មណ៍សោមនស្សយ៉ាងអស្ចារ្យដូចគ្នានឹង អាំម៉ូនដែរ ដែលបានលើកឡើងពីការបម្រើជាអ្នកផ្សព្វផ្សាយសាសនារបស់គាត់ នៅក្នុងចំណោមសមាជិកគ្រួសារនៅឆ្ងាយថា ៖

« ហេតុដូច្នេះហើយ ចូរយើងអួត មែនហើយ យើងអួតក្នុងព្រះអម្ចាស់ មែនហើយ យើងនឹងរីករាយព្រោះសេចក្ដីអំណររបស់យើងបានពោរពេញហើយ មែនហើយ យើងនឹងសរសើរតម្កើងដល់ព្រះរបស់យើងរហូតតទៅ ។ មើលចុះ តើនរណាអាចអួតហួសពេកនៅក្នុងព្រះអម្ចាស់ ? មែនហើយ តើនរណាអាចនិយាយច្រើនពេកអំពីព្រះចេស្ដាដ៏មហិមារបស់ទ្រង់ និង អំពីសេចក្ដីមេត្តាករុណារបស់ទ្រង់ និង អំពីសេចក្ដីអត់ធ្មត់របស់ទ្រង់ចំពោះកូនចៅមនុស្ស ? មើលចុះ ខ្ញុំសូមប្រាប់អ្នកថា ខ្ញុំមិនអាចនិយាយបាន ទោះជាមួយផ្នែកតូចបំផុតដែលខ្ញុំចាប់អារម្មណ៍ផង » ( អាលម៉ា 26:16 ) ។

ខ្ញុំសូមថ្លែងទីបន្ទាល់ថា អារម្មណ៍នៃសេចក្ដីស្រឡាញ់ដែលអ្នកមានចំពោះសមាជិកគ្រួសាររបស់អ្នក—មិនថាពួកគេនៅទីណានោះទេ—ជាការបំពេញនៃសេចក្ដីសន្យាមួយថា អេលីយ៉ានឹង



មក ។ គាត់ពិតជាបានមក ។ ដួងចិត្តរបស់កូនចៅនឹងបង្វែរទៅរកដូនតារបស់ពួកគេ ហើយដួងចិត្តរបស់ដូនតានឹងបង្វែរមករកកូនចៅរបស់ពួកគេ ( សូមមើល ម៉ាឡាគី 4:5–6, យ៉ូសែប ស្ម៊ីធ—ប្រវត្តិ 1:38–39 ) ។ នៅពេលអ្នកទទួលអារម្មណ៍នូវការជម្រុញចិត្តឲ្យស្វែងរកឈ្មោះដូនតារបស់អ្នក ហើយយកឈ្មោះទាំងនោះទៅព្រះវិហារបរិសុទ្ធ នោះអ្នកកំពុងទទួលបទពិសោធន៍នូវការបំពេញនៃការព្យាករណ៍នោះហើយ ។

វាជាពរជ័យមួយដើម្បីរស់នៅក្នុងគ្រាដែលសេចក្តីសន្យានៃការបង្វែរដួងចិត្តកំពុងត្រូវបានបំពេញ ។ មិលខ្រេដ បេ៊នញៀន អារីង បានទទួលអារម្មណ៍នូវការជម្រុញចិត្តនោះនៅក្នុងដួងចិត្តរបស់គាត់ ។ គាត់ស្រឡាញ់គ្រួសាររបស់បងប្អូនប្រុសគាត់ ហើយគាត់បានឈោងទៅជួយពួកគេ ។ ពួកគេបានទទួលអារម្មណ៍ថា ដួងចិត្តពួកគេបង្វែរក្នុងសេចក្តីស្រឡាញ់ ទៅរកអ្នកមីង មិឌ ដោយសារពួកគេបានដឹងថា គាត់ស្រឡាញ់ពួកគេ ។ ■

**ការបង្រៀនចេញពីសារលិខិតនេះ**

អ្នកគួរអានការព្យាករណ៍ស្តីពីវិញ្ញាណរបស់អេលីយ៉ាជាមួយនឹងសមាជិកដែលអ្នកទៅសួរសុខទុក្ខ ( សូមមើល ម៉ាឡាគី 4:5–6, យ៉ូសែប ស្ម៊ីធ—ប្រវត្តិ 1:38–39 ) ។ សូមពិភាក្សាពីវិធីដើម្បីចូលរួមនៅក្នុងពង្សប្រវត្តិរួមបញ្ចូលទាំងឧបករណ៍ដូចជាការធ្វើលិបិក្រមឈ្មោះមនុស្សស្លាប់ រូបថត និង ការធ្វើកំណត់ហេតុបណ្តាញ ។ ប្រសិនបើសមាជិកដែលអ្នកទៅសួរសុខទុក្ខមិនធ្លាប់ដឹងពីទេនោះFamilySearch.org សូមពិចារណាចំណាយពេលខ្លះដើម្បីបង្ហាញវាដល់ពួកគាត់ ។

# ការរៀនស្គាល់ពីជីដូនរបស់ខ្ញុំ

ដោយ ជូវ៉េលទ្បេន ខាធើរ



សម្រាប់គម្រោងមួយក្នុងថ្នាក់យុវនារីរបស់ខ្ញុំ ខ្ញុំបានស្ម័គ្រចិត្តជួយជីដូនរបស់យើងឲ្យស្វែងរកដូនតារបស់គាត់ ដោយមើលតាមផ្ទាំងមីក្រូហ្វីលនៅមជ្ឈមណ្ឌលពង្សប្រវត្តិនៅទីក្រុងមេសា រដ្ឋអារីហ្សូណា ស.រ.អ. ។ នៅពេលយើងអង្គុយក្បែរគ្នា ហើយស្រាវជ្រាវរកគ្រួសារយើង ខ្ញុំបានចាប់ផ្ដើមងឿងឆ្ងល់ថា ៖ « តើខ្ញុំពិតជាបានស្គាល់ជីដូនរបស់ខ្ញុំ ដែលអង្គុយនៅក្បែរខ្ញុំបានច្រើនប៉ុណ្ណា ? »

យើងរកឃើញសមាជិកគ្រួសារជាច្រើនបានរៀបចំព័ត៌មានរបស់ពួកគាត់ ហើយបានទៅព្រះវិហារបរិសុទ្ធមេសា អារីហ្សូណាដើម្បីធ្វើបុណ្យជ្រមុជទឹក និង ពិធីបញ្ជាក់សម្រាប់ពួកគាត់ ។ ក្រោយមកមិនយូរប៉ុន្មាន ជីដូនខ្ញុំបានឲ្យខ្ញុំនូវការប្រមូលផ្ដុំជាច្រើននៃពង្សប្រវត្តិរបស់គាត់ ។

ដោយសារគាត់មានជំងឺរលាកសន្លាក់រ៉ាំរ៉ៃ វាធ្វើឲ្យជីដូនឈឺនៅពេលគាត់ព្យាយាមវាយបញ្ចូលអក្សរ ។ ខ្ញុំរីករាយនឹងជួយគាត់ក្នុងការវាយបញ្ចូលក្នុងកុំព្យូទ័រ ។ យើងសរសេរដំណើររឿងជាច្រើនរួមគ្នាពីជីវិតរបស់គាត់ សម្រាប់ជាប្រយោជន៍ខាងវិញ្ញាណដល់គ្រួសារយើង ។ ខ្ញុំរីករាយដោយបានរួមចំណែកនៅក្នុងជីវិតគាត់ ហើយរៀនយ៉ាងច្រើនពីប្រវត្តិសាសនាចក្រ នៅពេលយើងសហការគ្នានៅក្នុងគម្រោងទាំងនេះ ។

*ឥឡូវនេះអ្នកនិពន្ធនេះរស់នៅក្នុងរដ្ឋ វីជីញ៉ា ស.រ.អ. ។*



## សេចក្ដីស្រឡាញ់នៅក្នុងផ្ទះ

*ព្រះសួគ៌ាញញឹមពីលើ*
*កាលស្រឡាញ់ក្នុងផ្ទះ*
*លោកិយពេញដោយក្ដីស្រឡាញ់*
*កាលស្រឡាញ់ក្នុងផ្ទះ ។*
( « ក្ដីស្រឡាញ់ក្នុងផ្ទះ » *ទំនុកដំកើងព្រះ និង ចំរៀងកុមារកុមារី ទំព័រ* 44 ។ )

ព្រះវរបិតាសួគ៌សព្វព្រះទ័យឲ្យយើងស្រឡាញ់ក្រុមគ្រួសារយើងដើម្បីយើងអាចមានភាពរីករាយ ។ កាលណាយើងបម្រើក្រុមគ្រួសារយើងកាន់តែច្រើន នោះយើងនឹងស្រឡាញ់ព្រះវរបិតាសួគ៌ និង សមាជិកក្រុមគ្រួសារយើងកាន់តែច្រើនផងដែរ ។




ខាងក្រោម ៖ រចនារូបភាពដោយ ណាថាលី ហ៊ូបស៍ ខាងឆ្វេង៖ រចនារូបភាពដោយ ខាធ្លីន ភីធើរសិន

*សូមសិក្សាឯកសារនេះដោយការអធិស្ឋាន ហើយព្យាយាមយល់ដឹងនូវអ្វីដែលត្រូវចែកចាយ ។ តើការយល់ដឹងពីឆាកជីវិត និង បេសកកម្មរបស់ព្រះអង្គសង្គ្រោះ នឹងពង្រឹងសេចក្ដីជំនឿរបស់អ្នកលើទ្រង់ ហើយប្រទានពរដល់អ្នកទាំងឡាយដែលមើលលើ ការបង្រៀនតាមផ្ទះដោយរបៀបណា ? ចំពោះព័ត៌មានបន្ថែម សូមចូលទៅ reliefsociety.lds.org ។*

# បេសកកម្មដ៏ទេវភាព នៃព្រះយេស៊ូវគ្រីស្ទ ៖ ព្រះអង្គគាំទ្រ

*នេះជាផ្នែកនៃគំរូមួយអំពីសារលិខិតបង្រៀនតាមផ្ទះ ដែលឆ្លុះបញ្ចាំង ពីទិដ្ឋភាពនៃបេសកកម្មរបស់ព្រះអង្គសង្គ្រោះ ។*



ព្រះយេស៊ូវគ្រីស្ទគឺជាព្រះអង្គគាំទ្ររបស់ យើងជាមួយនឹងព្រះវរបិតា ។ ពាក្យថា *ព្រះអង្គគាំទ្រ*ចេញមកពីភាសាឡាតាំងដែលមាន ន័យថា « ជនដែលអង្វរជំនួសឲ្យមនុស្សម្នាក់ ទៀត » ។[1] ព្រះអង្គសង្គ្រោះទូលអង្វរឲ្យយើង ដោយប្រើការយល់ចិត្ត យុត្តិធម៌ និង សេចក្ដីមេត្តា ករុណា ។ ដោយជ្រាបថា ការណ៍នេះអាច បំពេញក្នុងខ្លួនយើងនូវសេចក្ដីស្រឡាញ់ និង អំណរគុណចំពោះដង្វាយធួនរបស់ទ្រង់ ។

« ចូរស្ដាប់តាម [ព្រះយេស៊ូវគ្រីស្ទ] ដែលជាអ្នក គាំទ្រជាមួយនឹងព្រះវរបិតា ជាអ្នកដែលកំពុងអង្វរ ជំនួសអ្នករាល់គ្នានៅចំពោះទ្រង់—

« ដោយមានបន្ទូលថា ៖ ព្រះវរបិតាអើយ សូមទតមើលការរងទុក្ខទាំងឡាយ និង ការ សុគតរបស់អ្នកដែលពុំបានធ្វើបាបឡើយ ជាអ្នក ដែលព្រះអង្គសព្វព្រះហឫទ័យចុះ សូមទតមើល ព្រះលោហិតនៃព្រះរាជបុត្រារបស់ព្រះអង្គដែលបាន ច្រួច ជាព្រះលោហិតរបស់អ្នកដែលព្រះអង្គបាន ប្រទានឲ្យដើម្បីឲ្យព្រះអង្គបានតម្កើងឡើង

« ហេតុដូច្នោះហើយ ឱព្រះវរបិតាអើយ អ្នកផងទាំងនេះជាបងប្អូនរបស់ទូលបង្គំដែល ជឿដល់ព្រះនាមរបស់ទូលបង្គំ ដើម្បីឲ្យពួកគេ អាចមករកទូលបង្គំ ហើយមានជីវិតដ៏នៅអស់កល្ប ជានិច្ច » (គ. និង ស. 45:3–5) ។

អែលឌើរ ឌី ថត គ្រីស្ទហ្វឺសិន ក្នុង កូរ៉ុមនៃពួកសាវកដប់ពីរនាក់បានថ្លែងពី ព្រះគ្រីស្ទជាព្រះអង្គគាំទ្រថា ៖ « វាមាន សារៈសំខាន់ខ្លាំងណាស់ចំពោះខ្ញុំ ដែលខ្ញុំត្រូវ អធិស្ឋានទៅកាន់ព្រះបល្ល័ង្កនៃព្រះគុណនៅ គ្រប់គ្រា និងគ្រប់កាលៈទេសៈ ដើម្បីឲ្យ ព្រះវរបិតាសួគ៌របស់ខ្ញុំស្ដាប់ឮការទូលសុំរបស់ ខ្ញុំ ដើម្បីឲ្យព្រះអង្គគាំទ្ររបស់ខ្ញុំ ជាអង្គដែលគ្មាន អំពើបាប បានបង្ហូរព្រះលោហិតរបស់ទ្រង់ នឹងទូលអង្វរសម្រាប់បុព្វហេតុរបស់ខ្ញុំ » ។[2]

### *ព្រះគម្ពីរបន្ថែម*

ម៉ូសាយ 15:8–9, មរ៉ូណៃ 7:28, គោលលិទ្ធិ និង សេចក្ដីសញ្ញា 29:5, 110:4

### *សូមពិចារណាពីចំណុចនេះ*

តើការគាំទ្ររបស់ព្រះយេស៊ូវគ្រីស្ទអាចបំផុសគំនិតយើង ឲ្យផ្ដល់សេចក្ដីមេត្តាករុណា និង ការអត់ទោសដល់អ្នកដទៃ បានដោយរបៀបណា ?

**កំណត់ចំណាំ**

1. សូមមើល រ័សុល អិម ណិលសុន « Jesus Christ—Our Master and More » ( ការប្រជុំពិសេសនៅ សកលវិទ្យាល័យព្រិកហាំ យ៉ង់ នៅថ្ងៃទី 2 ខែ កុម្ភៈ ឆ្នាំ 1992 ) ទំព័រ 4, speeches.byu.edu ។
2. ឌី ថត គ្រីស្ទហ្វឺសិន « I Know in Whom I Have Trusted » *Ensign* ខែ ឧសភា ឆ្នាំ 1993 ទំព័រ 83 ។
3. សូមមើល *Daughters in My Kingdom ៖ The History and Work of Relief Society* ( ឆ្នាំ 2011 ), ទំព័រ 180 ។

## សេចក្ដីជំនឿ ក្រុមគ្រួសារ ការសង្គ្រោះ

### *ដកស្រង់ចេញពីព្រះគម្ពីរ*

ពេញប្រវត្តិសាស្ត្រនៃសាសនាចក្ររបស់ព្រះអម្ចាស់ ពួកសិស្សនៃព្រះយេស៊ូវគ្រីស្ទដែលជាស្ត្រីបានធ្វើតាម គំរូរបស់ទ្រង់ ។ នាងអេសធើរ ស្មោះត្រង់ ហើយ ក្លាហាន ។ បងប្អូនជីដូនមួយរបស់នាងឈ្មោះ ម៉ាដេកាយ បានធ្វើឲ្យនាងនូវច្បាប់ចម្លងនៃព្រះរាជក្រិត្យ របស់ស្ដេចដែលថា សាសន៍យូដាគួរបំផ្លាញចោល ហើយគាត់បានផ្ដាំឲ្យនាង « ចូលទៅទូលអង្វរចំពោះ [ស្ដេច] ថ្វាយពាក្យសំណូមពរជំនួសសាសន៍របស់ខ្លួន ផង » ។ គាត់បានបន្ថែមទៀតថា ៖ « ហើយប្រហែល ជាព្រះនាងបានតាំងឡើងក្នុងរាជ្យសម្រាប់ពេលនេះឯង ទេដឹង ? » ( នាងអេសធើរ 4:8, 14 ) ។

ដោយមិនខ្លាចពីគ្រោះថ្នាក់ នាងអេសធើរបាន យល់ព្រមថា ៖ « ខ្ញុំនឹងចូលទៅគាល់ស្ដេចដែលជា ការខុសច្បាប់ ៖ ហើយបើខ្ញុំត្រូវស្លាប់ក៏ស្លាប់ទៅចុះ » ( នាងអេសធើរ 4:16 ) ។

បន្ទាប់មកនាងអេសធើរបានទូលទៅកាន់ស្ដេច ដោយរាបសា ហើយ « ក្រាបនៅទាបព្រះបាទទ្រង់ អង្វរទាំងទឹកភ្នែក . . . ឲ្យលើកចោលសំបុត្រទាំង ប៉ុន្មាន . . . បង្គាប់ឲ្យបំផ្លាញសាសន៍យូដា » ។ នាង បានបន្ថែមទៀតថា « ធ្វើដូចម្ដេចឲ្យខ្ញុំម្ចាស់ទ្រាំមើល សេចក្ដីវេទនាដែលនឹងកើតដល់ជាតិរបស់ខ្ញុំម្ចាស់ ? » ( សូមមើល នាងអេសធើរ 8:3, 5–6 ) ។ ស្ដេចបាន ទន់ព្រះទ័យ ហើយបានធ្វើតាមការទូលសុំរបស់នាង ។[3]

# សៀវភៅកត់ចំណាំសន្និសីទខែ មេសា ឆ្នាំ 2014

*« អ្វីដែលយើងជាព្រះអម្ចាស់បានមានបន្ទូល នោះយើងបានមានបន្ទូលហើយ . . . ទោះជាដោយ សំឡេងរបស់យើងផ្ទាល់ ឬ ក៏ដោយសំឡេងនៃពួកអ្នកបម្រើរបស់យើងក្តី គឺដូចតែគ្នា » (គ. និង ស.1:38 ) ។*

*នៅពេលអ្នកមើលសន្និសីទទូទៅខែ មេសា ឆ្នាំ 2014 ឡើងវិញ នោះអ្នកអាចប្រើទំព័រទាំងនេះ ( និង សៀវភៅកត់ចំណាំសន្និសីទនៅក្នុងច្បាប់ទស្សនាវដ្ដីនាពេលខាងមុខ ) ដើម្បីជួយអ្នកឲ្យសិក្សា ហើយអនុវត្តតាមការបង្រៀនថ្មីៗរបស់ពួកព្យាការី និង ពួកសាវកទាំងឡាយ ព្រមទាំង អ្នកដឹកនាំសាសនាចក្រផ្សេងទៀតដែលកំពុងរស់នៅ ។*

**ការដកស្រង់គោលលទ្ធិ**



## អាពាហ៍ពិពាហ៍ និង ច្បាប់ព្រហ្មចារីភាព

« [ ថ្មីៗនេះ ] គណៈប្រធានទីមួយ និង កូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានចេញលិខិតមួយដល់ថ្នាក់ដឹកនាំក្នុងសាសនាចក្រនៅជុំវិញពិភពលោក ។ មានមួយផ្នែកបានចែងថា ៖ ‹ ការផ្លាស់ប្ដូរក្នុងច្បាប់ស៊ីវិល មិនអាចផ្លាស់ប្ដូរក្រិត្យវិន័យខាងសីលធម៌ ដែលព្រះបានបង្កើតឡើយ ។ ព្រះរំពឹងឲ្យយើងគាំទ្រ ហើយរក្សាព្រះបញ្ញត្តិរបស់ទ្រង់ មិនថាទស្សនៈ និង និន្នាការក្នុងសង្គមមានភាពខុសគ្នាយ៉ាងណានោះទេ ។ ច្បាប់ព្រហ្មចារីភាពរបស់ទ្រង់ បានបញ្ជាក់យ៉ាងច្បាស់ថា ៖ ទំនាក់ទំនងខាងផ្លូវភេទ ដែលត្រឹមត្រូវ មានតែរវាងបុរសម្នាក់ និង ស្ត្រីម្នាក់ ដែលបានរៀបការស្របតាមច្បាប់ជាប្ដីប្រពន្ធប៉ុណ្ណោះ › ។

« ទោះពិភពលោកនេះ ងាកចេញឆ្ងាយពីច្បាប់ព្រហ្មចារីភាពរបស់ព្រះក្ដី តែយើងមិនត្រូវធ្វើដូច្នោះឡើយ ។ . . .

« ទោះរដ្ឋាភិបាល និង មនុស្សល្អជាច្រើន បានកែនិយមន័យលើការរៀបការក្ដី តែព្រះអម្ចាស់មិនធ្វើដូច្នោះឡើយ ។ តាំងពីដំបូងមក ព្រះបានផ្ដើមការរៀបការរវាងបុរសម្នាក់ និង ស្ត្រីម្នាក់ គឺ—អ័ដាម និង នាងអេវ៉ា ។ ទ្រង់បានកំណត់គោលបំណងនៃការរៀបការ លើសលប់ជាងភាពរីករាយ និង ក្ដីអំណរផ្ទាល់ខ្លួនរបស់ពួកមនុស្សពេញវ័យទៅទៀត វាជាការអង្គភាពសំខាន់ជាង ដើម្បីបង្កើតបរិយាកាសដ៏ល្អមួយ សម្រាប់កុមារមកចាប់កំណើត ហើយទទួលការចិញ្ចឹមបីបាច់ ។ ក្រុមគ្រួសារ ជាទ្រព្យសម្បត្តិនៃស្ថានសួគ៌ » ។

**អែលឌើរ នែល អិល អាន់ឌើរសិន នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ « ខ្យល់គួចខាងវិញ្ញាណ »*Liahona*ខែ ឧសភា ឆ្នាំ 2014 ទំព័រ 19 ។**

អែលឌើរ អាន់ឌើរសិន ពិភាក្សាពីរបៀបដោះស្រាយចំពោះសំណួរ និង កង្វល់នានាអំពីប្រធានបទលំបាកៗនៅគេហទំព័រ lds.org/go/andersen714 ។

**ការសន្យារបស់ព្យាការី**



## សេចក្ដីក្លាហាន

« ដើម្បីឲ្យយើងធ្វើការសម្រេចចិត្តបានត្រឹមត្រូវ នោះតម្រូវឲ្យមានភាពក្លាហាន—ហ៊ាននិយាយថា ទេ នៅពេលយើងគួរនិយាយ ហ៊ាននិយាយថា បាទ ពេលដែលវាត្រឹមត្រូវ ហ៊ានធ្វើរឿងត្រឹមត្រូវ ដោយសារវាជារឿងត្រឹមត្រូវ ។ . . .

ភាពក្លាហានខាងក្នុងខ្លួននេះ ក៏រាប់បញ្ចូលទាំងការធ្វើរឿងត្រឹមត្រូវ ទោះជាយើងភ័យខ្លាច ការការពារជំនឿយើង ពេលប្រឈមនឹងការរិះគន់ ហើយនឹងការរក្សាជំនឿ ទោះជាពេលមានការគំរាមគំហែងដោយការបាត់បង់មិត្តភក្តិ ឬ ឋានៈក្នុងសង្គមក្ដី ។ . . .

នៅពេលយើងឆ្ពោះទៅមុខ ព្យាយាមរស់នៅដូចដែលយើងគួរតែរស់នៅ នោះយើងនឹងទទួលបានជំនួយពីព្រះយ៉ាងពិតប្រាកដ ហើយអាចរកបានការលួងលោមចិត្តក្នុងព្រះបន្ទូលរបស់ទ្រង់ » ។

**ប្រធាន ថូម៉ាស អេស. ម៉នសុន « ចូររឹងមាំ ហើយក្លាហាន » *Liahona* ខែ ឧសភា ឆ្នាំ 2014 ទំព័រ 66,67,69 ។**

ចូររៀនពីប្រធាន ម៉នសុន ពីរបៀបដែលយើងអាចបង្កើនភាពក្លាហាននៅ lds.org/go/monson2714 ។

# ការពន្លឿនកិច្ចការនៃសេចក្ដីសង្គ្រោះ

ប្រធានបទសំខាន់ៗបំផុតមួយចំនួនត្រូវបានថ្លែងលើសពីម្នាក់ ដោយអ្នកនិយាយក្នុងសន្និសីទទូទៅ ។ នេះគឺជាចំណុចមួយដែលអ្នកនិយាយបីរូបបានថ្លែង អំពីការពន្លឿនកិច្ចការនៃសេចក្ដីសង្គ្រោះ ៖

- « មិនថាអ្នកជា [ អ្នកផ្សព្វផ្សាយសាសនា ] មិនថាសារលិខិតអ្នកល្អប៉ុណ្ណានោះទេ អ្នកអាចនឹងគ្មានឱកាសដើម្បីបង្រៀនវាឡើយ បើគ្មានការតាមដានជាប់លាប់នោះ » ។[1] —អែលឌើរ អិម រ័សុល បាឡឺដ សូមរៀនបន្ថែមទៀតពីការអញ្ជើញរបស់អែលឌើរ បាឡឺដនៅlds.org/go/ballard714 ។
- « ព្រះវិហារបរិសុទ្ធ ហ្គីលប៊ឺត អារីហ្សូណា . . . បានក្លាយជាព្រះវិហារបរិសុទ្ធទី 142 ដែលដំណើរការ ។ . . . នៅពេលព្រះវិហារបរិសុទ្ធដែលបានប្រកាសប្រាប់ពីមុនៗទាំងអស់ ត្រូវបានសាងសង់ចប់ នោះយើងនឹងមានព្រះវិហារបរិសុទ្ធចំនួន 170 កំពុងដំណើរការនៅលើពិភពលោក » ។[2] —ប្រធាន ថូម៉ាស អេស ម៉នសុន សូមរៀនបន្ថែមទៀតនៅ lds.org/go/monson714 ។
- « យើងត្រូវ ‹ ទុកចោលរបស់ទាំងឡាយ [នៃ] ពិភពលោកនេះ . . . ហើយស្វែងកាន់ខ្ជាប់សេចក្ដីសញ្ញា [ របស់យើង ] ›[គ. និង ស.25:10,13] ហើយមករកព្រះគ្រីស្ទ និង ដើរតាមទ្រង់ ។ នោះជាអ្វីដែលពួកសិស្សធ្វើ ![3] —លីនដា ខេ បើតុន សូមមើលសុន្ទរកថារបស់ស៊ីស្ទើរ បើតុននៅ lds.org/go/burton714 ។

**កំណត់ចំណាំ**

1. « ការតាមដាន » *Liahona* ខែ ឧសភា ឆ្នាំ 2014 ទំព័រ 78 ។
2. « សូមស្វាគមន៍មកកាន់សន្និសីទ » *Liahona* ខែ ឧសភា ឆ្នាំ 2014 ទំព័រ 4 ។
3. « ប្រកាសរក ៖ ដៃ និង ដួងចិត្តដើម្បីជួយពន្លឿនកិច្ចការ » *Liahona* ខែ ឧសភា ឆ្នាំ 2014 ទំព័រ 122 ។



ដើម្បីអាន ទស្សនា ស្ដាប់ ឬ ចែកចាយសុន្ទរកថានានាពីសន្និសីទទូទៅសូមចូលទៅ **conference.lds.org**។

**របៀបដើម្បីរក្សា « ការប្រជុំអំពី Family Tree »**

« នៅទីបំផុត យើងមានគោលលទ្ធិ ព្រះវិហារបរិសុទ្ធ និង បច្ចេកវិទ្យាសម្រាប់ក្រុមគ្រួសារដើម្បីសម្រេចកិច្ចការនៃសេចក្ដីសង្គ្រោះដ៏រុងរឿងនេះបាន ។ ខ្ញុំសូមណែនាំដល់ . . . [ ក្រុមគ្រួសារនីមួយៗ ] សូមឲ្យរក្សា ‹ ការប្រជុំអំពី Family Tree › ។ នេះគួរតែជាសកម្មភាពទៀងទាត់មួយ » ។

**—អែលឌើរ ឃ្វីនថិន អិល ឃុក « ឫស និង មែក » *Liahona* ខែ ឧសភា ឆ្នាំ 2014 ទំព័រ 47 ។**

1. សូមប្រមូលផ្ដុំ ប្រវត្តិ ដំណើររឿង និង រូបថតគ្រួសារអ្នក រួមទាំងវត្ថុដែលជារបស់ជីដូនជីតា និង ឪពុកម្ដាយផងដែរ ។
2. សូមផ្ទុកដំណើររឿង និង រូបថតនានានៅក្នុង Family Tree ហើយភ្ជាប់ប្រភពឯកសារជាមួយនឹងដូនតា ។
3. សូមកំណត់ ថាតើដូនតាណាមួយ ដែលត្រូវការពិធីបរិសុទ្ធនៃព្រះវិហារបរិសុទ្ធ ហើយសូមចាត់តាំងវាដល់សមាជិកគ្រួសារ ។

សូមស្វែងរករបៀបផ្សេងទៀត ដែលអែលឌើរ ឃុក ថ្លែងអំពីអ្វីដែលយើងអាចទទួលបានពរជ័យតាមរយៈពង្សប្រវត្តិនៅ lds.org/go/cook714 ។

# យើងបង្រៀនដោយព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ

យើងជឿថា ការបង្រៀនដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទដោយព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធគឺជាកត្តាចាំបាច់ ចំពោះកិច្ចការនៃសេចក្ដីសង្គ្រោះរបស់ព្រះ ។ ការបង្រៀនដ៏មានប្រសិទ្ធភាពជួយមនុស្សឲ្យរីកចម្រើននៅក្នុងសេចក្ដីជំនឿ និង បំណងប្រាថ្នារបស់ពួកគេ ដើម្បីរស់នៅតាមដំណឹងល្អ ។ ការបង្រៀនអាចកើតឡើងនៅក្នុងមជ្ឈដ្ឋានជាច្រើន ដូចជាការផ្ដល់មេរៀន និង ការឡើងនិយាយនៅឯព្រះវិហារ ប៉ុន្តែយើងក៏អាចបង្រៀននៅពេលយើងពិភាក្សាពីបទគម្ពីរមួយជាមួយនឹងសមាជិកគ្រួសារម្នាក់ ឬនៅពេលយើងពន្យល់ទៅកាន់អ្នកជិតខាងពីអត្ថន័យនៃបព្វជិតភាព ។

« ពួកគ្រូក្នុងសាសនាចក្រនេះត្រូវបង្រៀនគោលការណ៍ទាំងឡាយនៃដំណឹងល្អរបស់យើង ដែលមាននៅក្នុងព្រះគម្ពីរប៊ីប និង ព្រះគម្ពីរមរមន គឺជាភាពពោរពេញនៃដំណឹងល្អ ។

« ហើយពួកគេត្រូវគោរពដើម្បីធ្វើតាមសេចក្ដីសញ្ញា និង មាត្រាទាំងឡាយនៃសាសនាចក្រ ហើយអ្វីៗទាំងនេះត្រូវទៅជាសេចក្ដីបង្រៀនរបស់ពួកគេ ដូចជាពួកគេនឹងត្រូវបានដឹកនាំពីព្រះវិញ្ញាណ ។

« ព្រះវិញ្ញាណត្រូវបានប្រទានដល់អ្នក ដោយពាក្យអធិស្ឋាននៃសេចក្ដីជំនឿ ហើយបើសិនជាអ្នករាល់គ្នាមិនបានទទួលព្រះវិញ្ញាណទេ នោះអ្នករាល់គ្នានឹងមិនត្រូវបង្រៀនឡើយ » ( គ. និង ស. 42:12–14 ) ។

សូមពិចារណានូវគោលការណ៍ទាំងបួននេះសម្រាប់ការបង្រៀនដ៏មានប្រសិទ្ធភាព ៖

- **ស្រឡាញ់អស់អ្នកដែលអ្នកបង្រៀន ។** រៀនស្គាល់ពួកគេ ។ សូមពិចារណាពីសេចក្ដីត្រូវការរបស់ពួកគេប្រកបដោយការអធិស្ឋាន នៅពេលអ្នករៀបចំបង្រៀន ។ សូមព្យាយាមប្រើវិធីសាស្ត្របង្រៀនផ្សេងៗគ្នា ៖ ការបង្រៀនផ្សេងគ្នាអាចជះឥទ្ធិពលដល់មនុស្សផ្សេងគ្នា ( សូមមើលគំនិតមួយចំនួននៅខាងស្ដាំដៃ ) ។
- **បង្រៀនដោយព្រះវិញ្ញាណ ។** នីហ្វៃបានបង្រៀនថា « កាលណាមនុស្សណាមួយនិយាយដោយព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ នោះព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធនឹងនាំពាក្យទាំងនោះចូលទៅក្នុងចិត្តនៃកូនចៅមនុស្ស » ( នីហ្វៃទី 2 33:1 ) ។ នៅពេលអ្នកបង្រៀន អ្នកអាចអញ្ជើញព្រះចេស្ដានៃព្រះវិញ្ញាណដោយការថ្លែងទីបន្ទាល់ និង ដោយការប្រើបទគម្ពីរ និង ការបង្រៀនរបស់ពួកព្យាការីនៅថ្ងៃចុងក្រោយ ។ សូមអធិស្ឋានសុំការដឹកនាំពីព្រះវិញ្ញាណបរិសុទ្ធនៅពេលអ្នករៀបចំបង្រៀន ។ ទ្រង់អាចបំផុសគំនិតអ្នកឲ្យដឹងពីរបៀបដ៏ល្អបំផុតដើម្បីបង្រៀន ។
- **បង្រៀនគោលលទ្ធិ ។** ឯកសារសម្រាប់ការសិក្សាដែលបានអនុម័តពីសាសនាចក្រ ដូចជា ព្រះគម្ពីរ សុន្ទរកថាក្នុងសន្និសីទទូទៅ និង សៀវភៅណែនាំ មាននូវគោលលទ្ធិ—ជាសេចក្ដីពិតអស់កល្បជានិច្ចពីព្រះ ។
- **អញ្ជើញឲ្យមានការរៀនសូត្រដោយឧស្សាហ៍ ។** នៅពេលអ្នកបង្រៀន សូមចងចាំថា អ្នកទាំងឡាយណាដែលស្ដាប់ មានទំនួលខុសត្រូវចំពោះការរៀនសូត្រផ្ទាល់ខ្លួនរបស់ពួកគេ ។ សូមលើកទឹកចិត្តពួកគេឲ្យសួរសំណួរ ចែកចាយគំនិតរបស់ពួកគេស្ដីពីប្រធានបទនោះ ហើយសញ្ជឹងគិតពីរបៀបដែលពួកគេអាចរស់នៅតាមគោលការណ៍ទាំងឡាយនៃដំណឹងល្អ ។ ទីបន្ទាល់របស់ពួកគេស្ដីពីគោលការណ៍ទាំងនោះនឹងរីកចម្រើន នៅពេលពួកគេរស់នៅតាមវា ( សូមមើល យ៉ូហាន 7:17 ) ។

ប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី ( 1910–2008 ) បានថ្លែងពីសារៈសំខាន់នៃការបង្រៀនដ៏ល្អថា ៖ « ជីវិតដ៏នៅអស់កល្បជានិច្ចនឹងកើតមានតែចំពោះបុរស និង ស្ត្រីដែលត្រូវបាន*បង្រៀនជាមួយនឹងគុណតម្លៃបែបនេះ* ប៉ុណ្ណោះ ដើម្បីពួកគេផ្លាស់ប្ដូរ ហើយគ្រប់គ្រងជីវិតរបស់ពួកគេដោយខ្លួនឯង ។ ពួកគេមិនអាចត្រូវបានគេបង្ខំឲ្យចូលទៅក្នុងសេចក្ដីសុចរិត ឬស្ថានសួគ៌បានឡើយ ។ ពួកគេត្រូវការការដឹកនាំ ហើយនោះមានន័យថាការបង្រៀន » ( ដកស្រង់ចេញពី ជែហ្វ្រី អ័រ ហូឡិន « A Teacher Come from God » *Ensign* ខែ ឧសភា ឆ្នាំ 1998 ទំព័រ 26 ) ។ ■

*សម្រាប់ព័ត៌មានបន្ថែម សូមមើល គោលលទ្ធិ និង សេចក្ដីសញ្ញា 50:13–22,* ក្បួនខ្នាត ភាគ 2៖ ការគ្រប់គ្រងសាសនាចក្រ *( ឆ្នាំ 2010 ) ចំណុច 5.5.4 ។*

**ទាំងនេះជាវិធីសាស្ត្របង្រៀនមួយចំនួនដែលអាចជួយអ្នកឲ្យជួយដល់មនុស្សទូទៅជាមួយនឹងរបៀបនៃការរៀនសូត្រផ្សេងៗពីគ្នា ៖**



*សូមលេង ឬ ច្រៀងតន្ត្រីពិសិដ្ឋ ។ ទំនុកតម្កើង និង ចម្រៀងថ្នាក់កុមារអាចបង្រៀនគោលលទ្ធិ ហើយអញ្ជើញព្រះវិញ្ញាណនៃព្រះអម្ចាស់ ។*



*សូមភ្ជាប់នូវដំណើររឿង និង ឧទាហរណ៍ដែលលើកតម្កើង រួមទាំងដំណើររឿងចេញពីព្រះគម្ពីរ និង ពីជីវិតរបស់អ្នកផ្ទាល់ ។*



*សូមសួរសំណួរដែលលើកទឹកចិត្តដល់មនុស្សដែលអ្នកបង្រៀនឲ្យសញ្ជឹងគិត ហើយចែកចាយពីគំនិត និង អារម្មណ៍របស់ពួកគេ ។*



*សូមបង្ហាញរូបភាព និង វត្ថុនានា ។ គោលការណ៍ទាំងឡាយនៃដំណឹងល្អអាចប្រៀបធៀបទៅនឹងគ្រាប់ពូជ ឬ កូនឈើ និង វត្ថុស្រដៀងគ្នានេះដទៃទៀត ។*



*សូមថ្លែងទីបន្ទាល់ពីគោលការណ៍ទាំងឡាយនៃដំណឹងល្អដែលអ្នកកំពុងបង្រៀន ។ ទីបន្ទាល់អញ្ជើញព្រះវិញ្ញាណបរិសុទ្ធឲ្យថ្លែងជាសាក្សីពីសេចក្តីពិត ។*

រចនារូបភាពដោយ ដេវីដ ហាប៊ិន

# ការដឹកនាំដូចជាព្រះអង្គសង្គ្រោះ

**ដោយ ហ៉យអិន ខា**
ទស្សនាវដ្ដីសាសនាចក្រ

មាន ភាពផ្ទុយគ្នាមួយដ៏ធំរវាងពួកអ្នកដឹកនាំដ៏អាក្រក់បំផុតនៅក្នុងពិភពលោកនេះ និង អ្នកដឹកនាំដ៏ល្អឥតខ្ចោះ ជាព្រះអង្គសង្គ្រោះនៃពិភពលោក ។ ប្រធាន ស្ពែនសើរ ដបុលយូ ឃឹមបឹល ( 1895–1985 ) បានពន្យល់ថា ៖ « ពួកអ្នកដឹកនាំទាំងនោះនៅក្នុងប្រវត្តិសាស្ត្រដែលធ្លាប់មានភាពសោកស្ដាយបំផុតនៅក្នុងការគ្រប់គ្រងរបស់ខ្លួនទៅលើមនុស្ស ពិតជាមានភាពសោកស្ដាយ ដោយសារពួកគេខ្វះស្ទើរតែគ្រប់អស់ទាំងគុណសម្បត្តិរបស់បុរសនៅស្រុកការលីឡេ ។ កាលព្រះយេស៊ូវមានចិត្តសទ្ធា ពួកគេមានភាពអាត្មានិយម ។ កាលព្រះយេស៊ូវខ្វល់ព្រះហឫទ័យពីសេរីភាព ពួកគេខ្វល់ខ្វាយពីការគ្រប់គ្រង ។ កាលព្រះយេស៊ូវខ្វល់ព្រះហឫទ័យពីការបម្រើ ពួកគេខ្វល់ខ្វាយពីឋានៈយសសក្ដិ ។ កាលព្រះយេស៊ូវបំពេញសេចក្ដីត្រូវការរបស់អ្នកដទៃដោយព្រះទ័យស្មោះ ពួកគេខ្វល់ខ្វាយតែពីសេចក្ដីត្រូវការ និង ការចង់បានរបស់ពួកគេ ។ កាលព្រះយេស៊ូវខ្វល់ខ្វាយពីការរីកចម្រើនរបស់ពួកសិស្សទ្រង់ ពួកគេបានស្វែងរកដើម្បីគ្រប់គ្រងជីវិតមែងស្លាប់ ។ កាលព្រះយេស៊ូវពោរពេញដោយសេចក្ដីមេត្តា និងយុត្តិធម៌ ពួកគេតែងពោរពេញដោយភាពគ្រោតគ្រាត និង ភាពអយុត្តិធម៌ » ។[1]

ដើម្បីមានជោគជ័យក្នុងនាមជាអ្នកដឹកនាំក្នុងសាសនាចក្ររបស់ព្រះអម្ចាស់ យើងត្រូវធ្វើតាមគំរូរបស់ទ្រង់ ។ គំនិតនៅខាងក្រោមអាចជួយយើងឲ្យប្រែក្លាយកាន់តែដូចជាព្រះគ្រីស្ទនៅក្នុងភាពជាអ្នកដឹកនាំរបស់យើង ។

អ្នកដឹកនាំដូចជាព្រះគ្រីស្ទបម្រើ « ដោយភ្នែកស្មោះត្រង់ទាំងស្រុងចំពោះសិរីល្អនៃព្រះ » ( គ. និង ស. 4:5 ) ដោយស្វែងរកធ្វើតាមព្រះហឫទ័យនៃព្រះវរបិតាសួគ៌ ។ ព្រះអង្គសង្គ្រោះបានមានបន្ទូលថា « ខ្ញុំបានចុះពីស្ថានសួគ៌មកមិនមែននឹងធ្វើតាមចិត្តខ្ញុំទេ គឺតាមបំណងព្រះហឫទ័យនៃព្រះវិញ ដែលបានចាត់ឲ្យខ្ញុំមក » ( យ៉ូហាន 6:38 ) ។

អ្នកដឹកនាំដូចជាព្រះគ្រីស្ទមិនពឹងផ្អែកទៅលើ « ដៃនៃមនុស្ស »ឡើយ ( នីហ្វៃទី 2 4:34 ) ។ ពួកគេអធិស្ឋានដោយរាបសាស្វែងរកការដឹកនាំ ។ ពួកគេរង់ចាំព្រះអម្ចាស់ ហើយ ស្វែងរកធ្វើនូវកិច្ចការរបស់ទ្រង់ក្នុងព្រះនាមទ្រង់ និងតាមរបៀបទ្រង់ជំនួសឲ្យការពឹងផ្អែកទៅលើទេពកោសល្យ និង សមត្ថភាពរបស់ពួកគេ ។

អ្នកដឹកនាំដូចជាព្រះគ្រីស្ទមិនស្វែងរកតួនាទីក្នុងសាសនាចក្រទេ ។ ពួកគេមើលទៅការហៅបម្រើជាឱកាសដើម្បីបម្រើ ពុំមែនជាការឡើងឋានៈនោះទេ ។ ឬមើលឃើញថាការដោះលែងជាការទម្លាក់ពីមុខតំណែងនោះឡើយ ។ ការដោះលែងកើតមានចំពោះរាល់ការហៅបម្រើ ។

អ្នកដឹកនាំដូចជាព្រះគ្រីស្ទជាអ្នកបម្រើ ។ ពួកគេជួយ បង្រៀន ហើយលើកទឹកចិត្តដល់អ្នកដែលពួកគេបម្រើ ។ ពួកគេស្វែងរកដើម្បីប្រទានពរដល់អ្នកដទៃ ដូចជាព្រះអង្គសង្គ្រោះបានធ្វើ ៖ « ទ្រង់មិនធ្វើការណ៍ណាឡើយលើកលែងតែការណ៍នោះមានប្រយោជន៍ដល់មនុស្សលោក » ( នីហ្វៃទី 2 26:24 ) ។ ពួកគេមើលឃើញខ្លួនឯងជាអ្នកតំណាងរបស់ព្រះអម្ចាស់ដើម្បីជួយអ្នកដទៃឲ្យត្រឡប់ទៅរកទ្រង់វិញ ។

អ្នកដឹកនាំដូចជាព្រះគ្រីស្ទស្វែងរកដើម្បីជួយអ្នកដទៃឲ្យរីកចម្រើន ។ ប្រធាន ឃឹមបឹល ក៏បានបង្រៀនផងដែរថា ៖

« ព្រះយេស៊ូវទុកចិត្តលើពួកអ្នកដើរតាមទ្រង់ល្មមគ្រប់គ្រាន់ ដើម្បីចែករំលែកកិច្ចការរបស់ទ្រង់ជាមួយនឹងពួកគេ ដើម្បីឲ្យ

**« ប៉ុន្តែខ្ញុំគ្មានបទពិសោធន៍ណាមួយជាអ្នកដឹកនាំផងហ្នឹង ! »**

សូមកុំប្រារព្ធប្រសិនបើអ្នកពុំទាន់មានបទពិសោធន៍ច្រើននៅឡើយ ។ អ្នកត្រូវបានហៅដោយការបំផុសគំនិត ដោយមនុស្សម្នាក់ដែលមានសិទ្ធិអំណាច ( សូមមើល មាត្រានៃសេចក្ដីជំនឿ 1:5 ) ។ ព្រះអម្ចាស់ទតឃើញពីអ្វីដែលអ្នកអាចប្រែក្លាយ ។ ការហៅរបស់អ្នកដើម្បីដឹកនាំអាចជាឱកាសមួយ ដើម្បីអភិវឌ្ឍភាពរឹងមាំរបស់អ្នក ហើយយកឈ្នះលើភាពទន់ខ្សោយ ។

នៅក្នុងពាណិជ្ជកម្ម ឬអង្គការផ្សេងទៀត ការអប់រំ និង បទពិសោធន៍របស់អ្នកដឹកនាំម្នាក់ជារឿយ។ គឺជាគុណសម្បត្តិដ៏សំខាន់ ប៉ុន្តែរបៀបរបស់ព្រះអម្ចាស់គឺខុសគ្នាពីនោះ ។ ប្រធាន ឡូរ៉េនសូ ស្នូ ( 1814–1901 ) បានបង្រៀនថា ៖ « ពួកសាវកដែលព្រះបានហៅ ដែលព្រះយេស៊ូវ ជាព្រះរាជបុត្រានៃព្រះបានហៅ . . . គ្មានចំណេះដឹងខ្ពង់ខ្ពស់នោះទេ ។ ពួកគាត់មិនយល់ពីវិទ្យាសាស្ត្រ ពួកគាត់មិនធ្លាប់មានតំណែងខ្ពស់នៅក្នុងយូដា—ពួកគាត់ជាមនុស្សក្រីក្រ ហើយខ្វះនូវចំណេះដឹង ហើយមានការហៅដ៏រាបសានៅក្នុងជីវិត. . . . មែនហើយ ព្រះអម្ចាស់មានភាពខុសប្លែកពីគេ ។ ទ្រង់ធ្វើឲ្យការហៅរបស់ទ្រង់ខុសពីការហៅទាំងនោះដែលបានបង្កើតឡើងដោយមនុស្ស » ។[1] ជាភ័ព្វសំណាងល្អ អ្នកដែលព្រះអម្ចាស់បានហៅទ្រង់ប្រទានសមត្ថភាពឲ្យ ![2]

**កំណត់ចំណាំ**

1. *Teachings of Presidents of the Church: Lorenzo Snow* ( ឆ្នាំ 2012 ) ទំព័រ 151 ។
2. សូមមើល ថូម៉ាស អេស ម៉នសុន « Duty Calls » *Liahona* ខែ កក្កដា ឆ្នាំ 1996 ទំព័រ 42 ។



*Woman Healed* ដោយ ជេ ខើក រិចឆ

ពួកគេអាចរីកចម្រើន ។ នោះជាមេរៀនដ៏អស្ចារ្យមួយស្ដីពីភាពជាអ្នកដឹកនាំរបស់ទ្រង់ ។ ប្រសិនបើយើងដាក់អ្នកដទៃឲ្យនៅដាច់ដោយឡែកដើម្បីមើលឃើញការងារមួយបញ្ចប់យ៉ាងលឿន ហើយមានប្រសិទ្ធភាពជាង នោះការងារនោះអាចបញ្ចប់ទៅក្នុងលក្ខណៈធម្មតា ដោយគ្មាននូវការរីកចម្រើន និង ការអភិវឌ្ឍដល់ពួកអ្នកដើរតាម ដែលវាជាកត្តាដ៏សំខាន់បំផុត ។ . . .

« ព្រះយេស៊ូវប្រទានសេចក្ដីពិត និង ការងារដល់មនុស្សស្របតាមសមត្ថភាពរបស់ពួកគេ ។ ទ្រង់មិនប្រទានឲ្យពួកគេលើសពីអ្វីដែលពួកគេអាចគ្រប់គ្រងបានឡើយ ប៉ុន្តែទ្រង់បានប្រទានដល់ពួកគេល្មមគ្រប់គ្រាន់ដើម្បីពង្រីកព្រលឹងរបស់ពួកគេ » ។[2]

ព្យាការីយ៉ូសែប ស្ម៊ីធ បានរៀបរាប់ពីរបៀបដែលលោកដឹកនាំមនុស្សផងដែរថា ៖ « ខ្ញុំបង្រៀនពួកគេតាមគោលការណ៍ត្រឹមត្រូវ ហើយពួកគេគ្រប់គ្រងខ្លួនឯងផ្ទាល់ »។[3] នេះជាកត្តាដ៏សំខាន់នៃរបៀបដោះស្រាយរបស់ព្រះអម្ចាស់ចំពោះភាពជាអ្នកដឹកនាំ ។ ■

**កំណត់ចំណាំ**

1. ស្ពែនស៊ើរ ដប្លុយ ឃឹមបឹល « Jesus: The Perfect Leader » *Ensign* ខែ សីហា ឆ្នាំ 1979 ទំព័រ 7 ។
2. ស្ពែនស៊ើរ ដប្លុយ ឃឹមបឹល « Jesus: The Perfect Leader » ទំព័រ 6 ។
3. *Teachings of Presidents of the Church: Joseph Smith* ( ឆ្នាំ2007 ) ទំព័រ 284 ។

## សម្រាបថ្នាក់ដឹកនាំដែលប្រឹក្សាជាមួយនឹងសមាជិកសាសនាចក្រ

នៅពេលអ្នកជួបសមាជិកសាសនាចក្រដែលត្រូវការជំនួយរបស់អ្នក ពួកគេប្រហែលជាចង់ឲ្យអ្នកដោះស្រាយបញ្ហាឲ្យពួកគេ ។ ប៉ុន្តែការធ្វើបែបនោះនឹងដកយកនូវការការរីកចម្រើនផ្ទាល់ខ្លួនចេញពីពួកគេ ។ ពួកគេប្រហែលជាមកដោយរំពឹងទុកថានឹងមានដំណោះស្រាយភ្លាមៗមួយ ប៉ុន្តែជារឿយៗបញ្ហារបស់ពួកគេត្រូវការពេលច្រើនដើម្បីដោះស្រាយដោយខ្លួនឯង ។ មានឧបសគ្គទូទៅមួយចំនួន ។ សំណួរនៅខាងក្រោមនេះដែលបានណែនាំពីពួកអ្នកដឹកនាំបព្វជិតភាព អាចជួយអ្នកនៅពេលអ្នករៀបចំប្រឹក្សាជាមួយនឹងសមាជិក ៖

- តើអ្នកបានប្រឹក្សា ហើយជួយសមាជិកតាមរបៀបណាមួយ ដែលពួកគេអាចឈ្នះលើឧបសគ្គរបស់ពួកគដោយខ្លួនពួកគេផ្ទាល់ដែរឬទេ ?
- តើអ្នកកំពុងដឹកនាំសមាជិកឲ្យស្វែងរកចម្លើយដោយខ្លួនឯងដែរឬទេ ?
- តើអ្នកបានតាមដាននូវកិច្ចការដែលពួកគេបានយល់ព្រមធ្វើដែរឬទេ ?
- តើអ្នកកំពុងជួយពួកគេឲ្យស្វែងរកធនធានដើម្បីដោះស្រាយបញ្ហាផ្ទាល់ខ្លួនរបស់ពួកគេដែរឬទេ ?
- តើអ្នកកំពុងលើកទឹកចិត្តពួកគេឲ្យអធិស្ឋានទៅកាន់ព្រះអម្ចាស់ដែរឬទេ ?
- តើការប្រឹក្សារបស់អ្នកលើកទឹកចិត្តសមាជិកឲ្យរីកចម្រើនដែរឬទេ ?

ពិតណាស់ ស្ថានភាពទាំងអស់មានសភាពខុសៗគ្នា ដូច្នេះវាជាការសំខាន់ដែលត្រូវធ្វើតាមការដឹកនាំពីព្រះវិញ្ញាណ ។ ការបម្រើដោយសេចក្ដីស្រឡាញ់ ការអត់ធ្មត់ និង ការស្ដាប់តាមព្រះវិញ្ញាណនឹងដឹកនាំទៅរកលទ្ធផលដ៏ល្អ ។

# អេលីយ៉ា

*« អេលីយ៉ាគឺជាព្យាការីម្នាក់ដ៏អស្ចារ្យបំផុត ហើយព្រះអម្ចាស់បានប្រទានអំណាចនៃការផ្សារភ្ជាប់ដល់លោក »* ។[1]—*ប្រធាន យ៉ូសែប ហ្វីលឌីង ស្ម៊ីធ ( ឆ្នាំ 1876–1972 )*

ខ្ញុំបានបម្រើជាព្យាការីម្នាក់នៅនគរអ៊ីស្រាអែលភាគខាងជើង ។[2] ដោយសារតែអំពើទុច្ចរិតរបស់សាសន៍អ៊ីស្រាអែល ខ្ញុំបានផ្សារភ្ជាប់ស្ថានសួគ៌មិនឲ្យមានភ្លៀង ដោយបណ្ដាលឲ្យមានគ្រោះទុរភិក្សនៅលើដែនដីនោះ ។ នៅអំឡុងពេលនៃគ្រោះទុរភិក្សនោះ ខ្ញុំបានរស់នៅក្បែរអូរតូចមួយ ហើយមានពួកសត្វក្អែកបាននាំយកអាហារមកឲ្យខ្ញុំ ប៉ុន្តែក្រោយមកអូរនោះបានរីងស្ងួតអស់ ។[3]

ព្រះអម្ចាស់បានត្រាស់បង្គាប់ឲ្យខ្ញុំទៅរកស្ត្រីមេម៉ាយម្នាក់ដែលរស់នៅឯទីក្រុង សារិបតា ហើយគាត់នឹងផ្ដល់អាហារដល់ខ្ញុំ ។ ខ្ញុំបានរកឃើញគាត់កំពុងរើសអុសដើម្បីរៀបចំអាហារចុងក្រោយសម្រាប់ខ្លួននាង និង កូនប្រុសរបស់នាង ។ ខ្ញុំបានប្រាប់នាងថា ប្រសិនបើនាងឲ្យអាហារខ្ញុំបរិភោគសិន នោះ « ម្សៅនៅក្នុងខាប់ [របស់នាង] នោះនឹងមិនដែលផុតទៅ ហើយប្រេងក្នុងដប់ក៏មិនដែលរលោះឡើយ ដរាបដល់ថ្ងៃដែលព្រះយេហូវ៉ានឹងបង្អុរភ្លៀងមកលើផែនដី » ។[4] នាងបានអនុវត្តសេចក្ដីជំនឿ ហើយព្រះអម្ចាស់បានបំពេញការសន្យារបស់ទ្រង់ ។

ខណៈដែលខ្ញុំបានរស់នៅជាមួយនឹងគ្រួសារនាង កូនប្រុសរបស់ស្ត្រីមេម៉ាយនោះបានស្លាប់ ។ ខ្ញុំបានទូលអង្វរថា « ឱ ព្រះយេហូវ៉ាជាព្រះនៃទូលបង្គំអើយ សូមឲ្យព្រលឹងរបស់កូននេះត្រឡប់ចូលមកក្នុងខ្លួនវាវិញចុះ » ។[5] ព្រះអម្ចាស់បានឮការទូលអង្វររបស់ខ្ញុំ ហើយកូនប្រុសនាងបានរស់នៅម្ដងទៀត ។[6]

ក្រោយទៀត ខ្ញុំបានបង្ហាញព្រះចេស្ដារបស់ព្រះអម្ចាស់ទៅកាន់ប្រជាជនអ៊ីស្រាអែលដោយសំណូមពរឲ្យសង្ឃនៃព្រះបាលធ្វើការប្រកួតប្រជែង ។ ពួកសង្ឃនោះបានរៀបចំការបូជាយញ្ញមួយ ហើយបានបួងសួងដល់ព្រះបាលពេញមួយថ្ងៃដើម្បីបញ្ជូនភ្លើងឲ្យចុះមក ប៉ុន្តែគ្មានភ្លើងលេចឡើងឡើយ ។ ខ្ញុំបានសង់អាសនាមួយដែលមានថ្ម 12 ដុំ ជាតំណាងឲ្យពូជអំបូរអ៊ីស្រាអែលទាំង 12 ហើយបានជីកប្រឡាយមួយព័ទ្ធជុំវិញអាសនានោះ ។ បន្ទាប់មកខ្ញុំបានមានអាសនានោះ ហើយការបូជារបស់វាដោយបានចាក់ទឹកយ៉ាងជោគជាំ 12 ធុង ដោយធ្វើឲ្យឈើនោះសើម ហើយបានបំពេញប្រឡាយនោះ ។ ខ្ញុំបានបួងសួងដល់ព្រះអម្ចាស់ ហើយទ្រង់បានបញ្ជូនភ្លើងឲ្យឆេះដង្វាយថ្វាយ អាសនា និង ទឹកនោះ ។ ក្រោយមកទៀត ខ្ញុំបានអធិស្ឋានទៅព្រះអម្ចាស់ ហើយទ្រង់បានបើកស្ថានសួគ៌បង្អុរភ្លៀងចុះមក ។[7]

នៅចុងបញ្ចប់នៃជីវិតរបស់ខ្ញុំ ខ្ញុំមិនបានស្លាប់ឡើយ ប៉ុន្តែត្រូវបាននៅទៅស្ថានសួគ៌នៅក្នុងភ្លើង ។[8] នៅក្នុងការបម្រើនៃជីវិតរមែងស្លាប់របស់ព្រះគ្រីស្ទ ខ្ញុំបានបង្ហាញខ្លួននៅភ្នំប្រែរូប ហើយបានប្រគល់កូនសោនៃបព្វជិតភាពដល់ពេត្រុស យ៉ាកុប និង យ៉ូហាន ។[9]

ខ្ញុំបានបង្ហាញខ្លួនម្ដងទៀតនៅក្នុងថ្ងៃចុងក្រោយ « ដើម្បីបង្វែរចិត្តពួកឪពុកមកឯកូន និងចិត្តកូនមកឯឪពុកវិញ » ដោយទៅព្រះវិហារបរិសុទ្ធខឺតឡង់នៅថ្ងៃទី 3 ខែ មេសា ឆ្នាំ 1836 ហើយស្ដារកូនសោរនៃអំណាចផ្សារភ្ជាប់ទៅឲ្យយ៉ូសែបស្ម៊ីធ និង អូលីវើរ ខៅឌើរី ។[10] ■

**កំណត់ចំណាំ**

1. យ៉ូសែប ហ្វីលឌិង ស្ម៊ីធ *Answers to Gospel Questions,*បាននិពន្ធដោយ យ៉ូសែប ហ្វីលឌិង ស្ម៊ីធ ជុញ្ញ័រ វ៉ុល 5 ។ ( ឆ្នាំ 1957–1966 ), 4:193 ។
2. សូមមើល សេចក្ដីណែនាំដល់បទគម្ពីរទាំងឡាយ « អេលីយ៉ា » , scriptures.lds.org ។
3. សូមមើល ពង្សាវតារក្សត្រទី 1 17:1–7 ។
4. សូមមើល ពង្សាវតារក្សត្រទី 1 17:8–16 ។
5. សូមមើល ពង្សាវតារក្សត្រទី 1 17:21 ។
6. សូមមើល ពង្សាវតារក្សត្រទី 1 17:8–24 ។
7. សូមមើល ពង្សាវតារក្សត្រទី 1 18 ។
8. សូមមើល ពង្សាវតារក្សត្រទី 2 2:11 ។
9. សូមមើល ម៉ាថាយ 17:3, សេចក្ដីណែនាំដល់បទគម្ពីរទាំងឡាយ « ការប្រែរូប », scriptures.lds.org ។
10. សូមមើល គោលលទ្ធិ និង សេចក្ដីសញ្ញា 110:13–16 ។

*Elijah Raises the Widow's Son from Death,* ដោយ រ៉ូប៊ឺត ធី បារ៉េត *Elijah Contends against the Priests of Baal* ដោយ ជើរី ហាស្តុន *Elijah Ascending into Heaven* ដោយ ដឺបុលយូ អេជ ម៉ាហ្គេស្ទុន ទទួលបានសិទ្ធិអនុញ្ញាតជាផ្លូវការពីសារមន្ទីរប្រវត្តិសាស្ត្រសាសនាចក្រ *The Transfiguration* ដោយ ខាល ហេនរីធ ប្លុក ទទួលបានសិទ្ធិអនុញ្ញាតជាផ្លូវការពីសារមន្ទីរប្រវត្តិសាស្ត្រជាតិនៅហ្វ្រេឌើរីកស៍បើក ក្នុងរដ្ឋហ៊ីលឡឺដ ប្រទេសដាណឺម៉ាក *Elijah Appearing in the Kirtland Temple* ដោយដានីយ៉ែល អេ លូវីស រូបភាពសត្វក្អែកដោយ Kozh/iStock/Thinkstock








# ធ្វើការ និង ការពឹងពាក់លើខ្លួនឯង



**បទគម្ពីរស្ដីពីប្រធានបទនេះ**

អេសាយ 55:2
នីហ្វៃទី 2 5:17, 27
ម៉ូសាយ 4:16–21
គោលលទ្ធិ និងសេចក្ដីសញ្ញា 58:26–29
យ៉ូសែប ស្ម៊ីធ—ប្រវត្តិ 1:55

នៅពេលយុវវ័យ និង កុមាររៀនខិតខំធ្វើការ ហើយមានភាពខ្លួនទីពឹងខ្លួន ពួកគេនឹងរៀបចំខ្លួនដើម្បី « បរិច្ចាគទៅកាន់ពិភពលោកដែល[ពួកគេ]រស់នៅ » ( *ដើម្បីកម្លាំងនៃយុវជន* [ឆ្នាំ 2011] ទំព័រ 40 ) ។

នៅទំព័រ 56–57 ក្នុងលេខចេញផ្សាយនេះ រ៉ានឌល អិល រិដ ជាទីប្រឹក្សាទីពីរនៅក្នុងគណៈប្រធានយុវជនទូទៅ បានចែកចាយពីអ្វីដែលគាត់រៀនធ្វើការសំណង់ជាមួយនឹងឪពុកគាត់ ។ គាត់បានពិភាក្សាពីសារៈសំខាន់នៃការខិតខំធ្វើការ ការមានអាកប្បកិរិយាល្អ និង ការស្ដាប់បង្គាប់របស់ព្រះអម្ចាស់ ។ បងប្រុសរិដ បានរំឭកយើងថា ៖ « ដូច្នេះតើនរណាខ្លះត្រូវធ្វើការ ? គឺយើងទាំងអស់គ្នា ! វាជាកត្តាដ៏សំខាន់ចំពោះភាពខ្លួនទីពឹងខ្លួន ភាពជោគជ័យ និងសេចក្ដីអំណរនៅក្នុងជីវិតនេះ ។ នៅពេលអ្នកចូលប្រឡូកក្នុងការងារដោយរីករាយ នោះមនុស្សនៅជុំវិញខ្លួនអ្នកនឹងទទួលបានផលយ៉ាងច្រើន ដោយសារតែគ្រាប់ពូជដែលអ្នកបានព្រួស » ។

### យោបល់ទាំងឡាយសម្រាប់បង្រៀនយុវវ័យ

- *ដើម្បីកម្លាំងនៃយុវជន*បានចែងថា « ដាក់គោលដៅដ៏ខ្ពស់សម្រាប់ខ្លួនឯង ហើយមានឆន្ទៈខិតខំធ្វើការដើម្បីសម្រេចបានគោលដៅទាំងនោះ » ( ទំព័រ 40 ) ។ អ្នកគួរមើលជាមួយនឹងកូនរបស់អ្នកនូវសារលិខិតមរមន ជាវីដេអូសម្រាប់យុវវ័យដែលមានចំណងជើងថា « A Work in Progress ( ការងារមួយកំពុងមានដំណើរការ ) » ( សូមមើលវីដេអូសម្រាប់អាពាហ៍ពិពាហ៍ និង គ្រួសារនៅ mormonchannel.org/come-follow-me ) ។ បន្ទាប់មកធ្វើការរួមគ្នាដើម្បីដាក់គោលដៅមួយចំនួន ហើយដាក់ផែនការ ដើម្បីសម្រេចគោលដៅទាំងនោះ ។
- ការធ្វើការនឹងមានភាពងាយស្រួលច្រើននៅពេលយើងឥរិយាបថវិជ្ជមាន ។ សូមអាន « ការប្ដូរបំពឹងទឹកទាំងស្បែកជើងសុទ្ធតែភក់ » នៅទំព័រ 58–59 ក្នុងលេខចេញផ្សាយនេះ ហើយពិភាក្សាពីរបៀបដែលឥរិយាបថរបស់អ្នកជះឥទ្ធិពលដល់កិច្ចការរបស់អ្នក ។
- « ទម្រង់មួយនៃភាពខ្ជិលច្រអូសគឺការចំណាយពេលហួសហេតុទៅលើសកម្មភាពទាំងឡាយដែលរារាំងអ្នកពីកិច្ចការដែលមានប្រយោជន៍ ដូចជាការប្រើអ៊ីនធឺណែត លេងវីដេអូហ្គេម និង មើលទូរទស្សន៍ជាដើម » ( *ដើម្បីកម្លាំងនៃយុវជន* ទំព័រ 40 ) ។ សូមសួរកូនរបស់អ្នកពីអត្ថប្រយោជន៍ និងគ្រោះថ្នាក់របស់អ៊ិនធើរណែត វីដេអូហ្គេម និង ទូរទស្សន៍ ។ តើនៅពេលណាដែលឧបករណ៍ទាំងនេះបានក្លាយទៅជាការអូសទាញ ? តើពរជ័យអ្វីខ្លះដែលកើតចេញពីការងារល្អ ? សូមពិចារណាជួយកូនរបស់អ្នកឲ្យភ្លក់ពិសោធន៍នូវពរជ័យទាំងនេះដោយដាក់រាល់បច្ចេកវិទ្យាទុកដោយឡែកសម្រាប់រយៈពេលខ្លីមួយ ហើយធ្វើការលើគម្រោងមួយរួមគ្នា ។

### យោបល់ទាំងឡាយដើម្បីបង្រៀនកុមារ

- កិច្ចការផ្សព្វផ្សាយសាសនាគឺជាកិច្ចការលំបាក ហើយការរៀនដើម្បីមានភាពខ្លួនទីពឹងខ្លួននឹងជួយកុមារឲ្យរៀបចំខ្លួនធ្វើកិច្ចការនោះ ។ សូមធ្វើបញ្ជីកិច្ចការផ្ទះមួយជាមួយកូនរបស់អ្នក ដែលពួកអ្នកផ្សព្វផ្សាយសាសនាគួរដឹងពីរបៀបធ្វើវា ( ឧទាហរណ៍ ការបោកខោអាវ ការចំអិនអាហារ និង ការបោសសម្អាតផ្ទះ ) ។ បន្ទាប់មកធ្វើកិច្ចការទាំងនោះមួយចំនួនរួមគ្នា ។
- នៅក្នុងអត្ថបទរបស់គាត់ បងប្រុស រិដ បានរំឭកយើងថា « កិច្ចការដ៏សំខាន់បំផុតគឺជាកិច្ចការរបស់ព្រះ » ។ តើគ្រួសារអ្នកអាចធ្វើកិច្ចការរបស់ព្រះអម្ចាស់បន្ថែមទៀតបានដោយរបៀបណា ? សូមគិតពីសកម្មភាពមួយដែលអ្នកអាចធ្វើរួមគ្នា ដែលវានឹងជួយនាំអ្នកដទៃឲ្យខិតមកជិតព្រះគ្រីស្ទ ។
- ផ្នែកនៃភាពខ្លួនទីពឹងខ្លួនគឺជាការរៀនពីរបៀបគ្រប់គ្រងលើប្រាក់កាក់ ។ សូមបង្រៀនកូនរបស់អ្នកពីគោលការណ៍នៃការគ្រប់គ្រងថវិកា និង ពីសារៈសំខាន់នៃការធ្វើឲ្យដង្វាយមួយភាគក្នុងដប់ក្លាយជាផ្នែកមួយនៃគម្រោងថវិការបស់ពួកគេ ។ ■

# អង្គការសប្បុរសធម៌ អិល. ឌី.អេស.ដែលបានបង្ហាញនៅឯព្រឹត្តិការណ៍អង្គការសហប្រជាជាតិ

កិច្ចការនៃអង្គការសប្បុរសធម៌ អិល. ឌី. អេស គឺជាប្រធានបទមួយនៃការពិភាក្សាតុមូលនាពេលថ្មីៗនេះនៅឯទីស្នាក់ការអង្គការសហប្រជាជាតិក្នុងទីក្រុងនូវយ៉ោក សហរដ្ឋអាមេរិក ។ ព្រឹត្តិការណ៍នេះឈ្មោះថា « ការរកឃើញពួកមរមន និង តួនាទីរបស់ពួកគេនៅក្នុងជំនួយមនុស្សធម៌ » គឺជាផ្នែកមួយនៃការផ្ដោតលើក្រុមជំនឿដែលឧបត្ថម្ភដោយស្ថាប័នអង្គការក្រៅរដ្ឋាភិបាលនៃការិយាល័យផ្នែកព័ត៌មានសាធារណៈរបស់អង្គការសហប្រជាជាតិ ។

អន្តរការីឈ្មោះ ហ្វិលិព ខេវ្ពូ ដែលធ្វើជាអ្នកជំនួយការខាងសារព័ត៌មានសាធារណៈនៅឯអង្គការសហប្រជាជាតិ ដែលជាសមាជិកម្នាក់នៃសាសនាចក្រមកពីប្រទេសអេស្ប៉ាញ បានពន្យល់ថា « ក្រុមនេះមានគោលបំណងដើម្បីផ្ដល់ការយល់ដឹងកាន់តែទូលំទូលាយអំពីរបៀបដែលស្ថាប័នជំនឿខុសគ្នាជាច្រើន ចែកចាយគោលការណ៍គ្រឹះទូទៅដូចជាការអត់ឱន ការគោរពគ្នាទៅវិញទៅមកចំពោះមនុស្សខុសពីយើង និង ការតាំងចិត្តដើម្បីផ្សះផ្សាគ្នា និង ការដោះស្រាយជម្លោះទាំងឡាយដោយសន្តិវិធី » ។

ស្ប៉ារុន អូបែន ជានាយកចាត់ចែងនៃអង្គការសប្បុរសធម៌ អិល. ឌី. អេស. ដែលបានចូលរួមក្នុងកិច្ចពិភាក្សានេះ បានមានប្រសាសន៍ថា « ការមើលថែជនក្រីក្រ គឺជាកាតព្វកិច្ចមូលដ្ឋានរបស់បុគ្គលទាំងឡាយណាដែលគោរពបូជាដល់ព្រះ និង ភាតរភាពជាបងប្អូនប្រុសស្រីទាំងអស់—ដើម្បីបម្រើ លើកស្ទួយ ប្រទានពរ និង ជួយសម្រាលទុក្ខដោយគ្មានផ្អែកទៅលើជំនឿខាងសាសនា ទស្សនៈសង្គម សញ្ជាតិ កុលសម្ព័ន្ធ ភេទ ឬ ជីវប្រវត្តិឡើយ » ។

ក្នុងប្រសាសន៍គាត់ គាត់ក៏បានថ្លែងអំពីគោលបំណងដែលបានចែងពីអង្គការសប្បុរសធម៌ អិល. ឌី. អេស.ថា ៖ ជួយសម្រាលទុក្ខ ចិញ្ចឹមបីបាច់ឲ្យមានភាពខ្លួនទីពឹងខ្លួន និង ផ្ដល់ឱកាសទាំងឡាយ ដើម្បីបម្រើដល់គ្រួសារនៃមនុស្សគ្រប់ជាតិទាំងអស់ ។ គាត់បានមានប្រសាសន៍ថា គំនិតផ្ដួចផ្ដើមសំខាន់របស់អង្គការគឺ ទឹកស្អាត ការសង្គ្រោះបន្ទាន់ដល់ទារក ការថែទាំភ្នែក ការចែករទេះរុញជនពិការ ការចាក់ថ្នាំវ៉ាក់សាំង ម្ហូបអាហារ និងការឆ្លើយតបក្នុងគ្រាបន្ទាន់ ។

ពួកបរិសុទ្ធថ្ងៃចុងក្រោយដទៃទៀតដែលបានចូលរួម មានរួមទាំងអាសម៉ាត អេស. ខ័របិត ជានាយកចាត់ចែងនៃការិយាល័យសាសនាចក្រអំពីកិច្ចការសាធារណៈ និង អន្តរជាតិប្រចាំនៅទីក្រុងនូវយ៉ោក និង ចន ភី. (ភីល) ខលតុន ដែលកំពុងបម្រើជាមួយភរិយារបស់គាត់ បាបារ៉ា ក្នុងនាមជាអ្នកតំណាងឲ្យអង្គការសប្បុរស អិល. ឌី. អេស. ក្នុងអង្គការសហប្រជាជាតិ ។

បងប្រុសខ័របិត បានមានប្រសាសន៍ថា មាន « មនុស្សដែលមានឆន្ទៈល្អ មាននៅក្នុងសាសនាទាំងអស់លើពិភពលោកនេះ » ដោយសង្កត់ធ្ងន់ទៅលើសារសំខាន់នៃការធ្វើការរួមគ្នា ។ បងប្រុសខលតុន បានពន្យល់ពីមធ្យោបាយដែលអង្គការសប្បុរស អិល. ឌី.អេស.បានផ្ដល់ជំនួយដល់មនុស្សជិតពីរលាននាក់ក្នុងបណ្ដាប្រទេស 132 អំឡុងឆ្នាំ 2013 ។ ■

*អ្នកតំណាងសាសនាចក្រទាំងឡាយ ចូលរួមក្នុងការពិភាក្សាជាក្រុមមួយនៅឯអង្គការសហប្រជាជាតិ ។*



### ប្រធានបេសកកម្មថ្មីទាំងឡាយដែលត្រូវបានហៅបម្រើ

គណៈប្រធានទីមួយបានហៅប្រធានបេសកកម្មថ្មីចំនួន 122 នាក់ និង ភរិយារបស់ពួកគាត់ ឲ្យទៅបម្រើនៅទីតាំងដែលបានចាត់តាំងដោយចាប់ផ្ដើមនៅខែ កក្កដា ឆ្នាំ 2014 ។ សម្រាប់ព័ត៌មានអំពីប្រធានបេសកកម្មថ្មី សូមចូលទៅកាន់ lds.org/church/news/church-announces-2014-mission-president-assignments.

### ពួកអ្នកដឹកនាំបានផ្ដល់ការលួងលោម និង ការគាំទ្រនៅក្នុងប្រទេសហ្វីលីពីន ។

នៅខែកុម្ភៈ ក្នុងរយៈពេល 100 ថ្ងៃ បន្ទាប់ពីខ្យល់ព្យុះហៃយ៉ាន បានបំផ្លិចបំផ្លាញទីក្រុងតាខ្លូបាន ស៊ិស្ទើរ លីនដា ខេ. ប៊ឺតុន ប្រធានសមាគមសង្គ្រោះទូទៅ និង ស៊ិស្ទើរ ខារូល ហ្វេសម៉ាកខុងគី ជាទីប្រឹក្សាទី 1 នៃគណៈប្រធានយុវនារីទូទៅ បានធ្វើដំណើរទៅកាន់តំបន់គ្រោះមហន្តរាយដើម្បីផ្ដល់ការគាំទ្រ និង ការលួងលោម ។

ស៊ិស្ទើរ ប៊ឺតុន បានមានប្រសាសន៍ថា « ខ្ញុំដឹងថា ខ្ញុំត្រូវការឱបបងប្អូនស្រីទាំងឡាយ ។ « ខ្ញុំដឹងថា ខ្ញុំមិនអាចធ្វើអ្វីបានច្រើនទេ ប៉ុន្តែខ្ញុំដឹងថា ខ្ញុំត្រូវមកកាន់ទីក្រុងតាខ្លូបាន ហើយឱបមនុស្ស ដែលខ្ញុំអាចធ្វើបាន » ។

ខ្យល់ព្យុះហៃយ៉ានបានបំផ្លាញផ្ទះចំនួនជាង 1.1 លាន នៅត្រង់ចំណុចកណ្ដាលនៃប្រទេសហ្វីលីពីន ដោយបន្សល់ទុកអ្នកស្លាប់ជាង 6,100 នាក់ ដោយមានរួមទាំងពួកបរិសុទ្ធថ្ងៃចុងក្រោយចំនួន 42 នាក់ផងដែរ ។ ក្រោយពីព្យុះបានបញ្ចប់ សាសនាចក្របានបញ្ជូនសម្ភារផ្គត់ផ្គង់ចាំបាច់ ហើយសហការជាមួយអង្គការក្នុងមូលដ្ឋាន និង អន្តរជាតិ ដើម្បីជួយផ្នែកម្ហូបអាហារ ទឹកជម្រក ទឹកស្អាត ការប្រមូលចោលកាកសំណល់ និង ការស្ដារជីវភាពរស់នៅឡើងវិញ ។

ទាំងស៊ិស្ទើរ ប៊ឺតុន និង ស៊ិស្ទើរ ម៉ាកខុងគី បានរាយការណ៍ថា ពួកគេរកឃើញក្ដីសង្ឃឹម និង សុទិដ្ឋិនិយមក្នុងចំណោមពួកបរិសុទ្ធ ដែលកំពុងសាងសង់ផ្ទះរបស់ពួកគេឡើងវិញ និង ការពង្រឹងទីបន្ទាល់របស់ពួកគេ តាមរយៈការបម្រើគ្នាទៅវិញទៅមក ។

*ស៊ិស្ទើរ ខារូល ហ្វេសម៉ាកខុងគី ទៅសួរសុខទុក្ខកុមារតូចៗ នៅមជ្ឈមណ្ឌលស្តេកហ្វីលីពីនទីក្រុងតាខ្លូបាន ។*





*អែលឌើរ ជែហ្វ្រី អ័រ ហូឡិន មានប្រសាសន៍ទៅកាន់សមាជិកទាំងឡាយនៅតៃវ៉ាន់ ។*

# ពួកសាវកបម្រើដល់ជាតិសាសន៍ជាច្រើន

សមាជិកទាំងឡាយនៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានបន្តធ្វើកិច្ចការបម្រើក្នុងសាសនាចក្រទូទាំងពិភពលោក ។ អំឡុងពេលការចាត់តាំងទាំងឡាយពេលថ្មីៗនេះ ៖

- អែលឌើរ រ័សុល អិម. ណិលសុន និង អែលឌើរ នែល អិល. អាន់ឌើរសិន បានផ្ដល់ប្រឹក្សា និង ការណែនាំដល់ពួកបរិសុទ្ធនៅអូស្ត្រាលី, នូវែលសេឡង់, ហ្វ្រែន ប៉ូលីនេស្យា, ហ្វីជី, នូវខាលីដូនា, តុងហ្គា, និង ប៉ាពូ នូហ្គីណេ ។ អែលឌើរ ណិលសុន បានមានប្រសាសន៍អំពីតម្រូវការក្នុងការពង្រឹងក្រុមគ្រួសារ ហើយអែលឌើរ អាន់ឌើរសិន បានរំឭកដល់សមាជិកទាំងឡាយឲ្យមានសង្ឃឹមឡើង ។ ក្នុងការចាត់តាំងដាច់ដោយឡែកមួយ អែលឌើរ អាន់ឌើរសិន បានជួបជាមួយសមាជិកទាំងឡាយ និង ពួកអ្នកដឹកនាំសហគមន៍ក្នុងតំបន់ទាំងឡាយនៃប្រទេសហ្វីលីពីន ដែលត្រូវបានបំផ្លាញដោយការរញ្ជួយដី និង ព្យុះត្រូពិកទាំងឡាយ ។
- អែលឌើរ ដាល្លិន អេក. អូក បានឧទ្ទិសឆ្លងមជ្ឈមណ្ឌលបំពាក់បំប៉នអ្នកផ្សព្វផ្សាយសាសនានៅទីក្រុងម៉ិកស៊ីកូ ។ លោកបានលើកទឹកចិត្តដល់អ្នកផ្សព្វផ្សាយសាសនាឲ្យខិតខំសិក្សា និង ថ្វាយខ្លួនដល់ព្រះអម្ចាស់ ។
- អែលឌើរ រ័សុល អិម ណិលសុន បានប្រាប់ដល់ពួកបរិសុទ្ធទាំងឡាយក្នុងតំបន់ខាងត្បូងនៃអាមេរិកភាគខាងត្បូង ថា « ថ្ងៃនៃពួកកូនប្រុសស្រីទាំងឡាយរបស់លោកលីហៃកំពុងរីកចម្រើន » ដោយមានសមាជិកចំនួន 4.5 លាននាក់ និងព្រះវិហារបរិសុទ្ធចំនួន 14 នៅក្នុងអាមេរិកខាងត្បូង ។ ការណ៍នេះបំពេញការព្យាករណ៍ដែលធ្វើឡើង ដោយតាទួតរបស់លោក អែលឌើរ មេលវិន ជី បាឡាដ ( ឆ្នាំ 1873–1939 ) ដែលថា អាមេរិកខាងត្បូង នឹងក្លាយជាអំណាចមួយក្នុងសាសនាចក្រ ។
- អែលឌើរ ជែហ្វ្រី អ័រ ហូឡិន បានលើកទឹកចិត្តសមាជិកទាំងឡាយនៅតៃវ៉ាន់ និង ហុងកុងឲ្យយកព្រះវិហារបរិសុទ្ធក្លាយជាផ្នែកមួយនៃជីវិតរស់នៅ តាមរយៈការចូលរួមឲ្យបានញឹកញាប់ តាមដែលពួកគេអាចធ្វើបាន ។
- អែលឌើរ ដេវីឌ អេ. បេដណា បានរំឭកដល់ពួកបរិសុទ្ធថ្ងៃចុងក្រោយក្នុងប្រទេសអ៊ុយក្រែនថា ពួកគេគឺជាអ្នកត្រួសត្រាយផ្លូវក្នុងការកសាងសាសនាចក្រក្នុងប្រទេសរបស់ពួកគេ ។ លោកបានរំឭកសមាជិកទាំងឡាយក្នុងប្រទេសកេនយ៉ាពីសារសំខាន់នៃការបង្ហាញសេចក្ដីស្រលាញ់យ៉ាងជាប់លាប់នៅក្នុងគេហដ្ឋាន ។
- អែលឌើរ ឃ្វីនថិន អិល. ឃុក បានបង្រៀនដល់សមាជិកទាំងឡាយនៅអាមេរិកកណ្ដាលអំពីសារសំខាន់នៃការបម្រើដល់ព្រះ ដល់គ្នាទៅវិញទៅមក និង ដល់អ្នកជិតខាងពួកគេ ។

ដើម្បីរៀនបន្ថែមទៀតអំពីការបម្រើនៃពួកសាវក សូមចូលទៅកាន់lds.org/prophets-and-apostles ។ ■










NOITE
DE
NOVOS



# សាសនាចក្រនៅ ប្រទេសប្រេស៊ីល នៅទីបំផុតអនាគតបានមកដល់

**ដោយ ម៉ាក អិល គ្រូវី**
សាស្ត្រាចារ្យចូលនិវត្តន៍ផ្នែកការសិក្សាស្ដីពីអេមរិកឡាតាំង សាកលវិទ្យាល័យ ព្រិកហាំ យ៉ង់

ទាំងទំហំ និង ចំនួនប្រជាជន ប្រទេសប្រស៊ីល គឺជាប្រទេសធំជាងគេបង្អស់លំដាប់ថ្នាក់លេខប្រាំលើពិភពលោក ។ ប៉ុន្តែកាលពី 100 ឆ្នាំមុន ប្រជាជននៅក្នុងប្រទេសនេះមានចំនួនតិច ហើយមានមនុស្សតិចតួចណាស់ដែលបានទទួលផលពីធម្មជាតិ ៖ មានអាកាសធាតុត្រូពិច ដីសម្បូរជីវជាតិ និងរ៉ែធម្មជាតិនៅក្រោមដី និង ក្នុងទឹក ។

ម៉ាក្ស និង អាម៉ាលី ហ្សាប មានចំណាប់អារម្មណ៍នឹងប្រទេសេប្រេស៊ីល ហើយបានសម្រេចចិត្តរស់នៅទីនោះ ។ ពួកគេបានចូលរួមក្នុងសាសនាចក្រនៅប្រទេសអាល្លឺម៉ង់នាឆ្នាំ 1908 ហើយបានធ្វើអន្តោប្រវេសន៍ទៅប្រទេសប្រេស៊ីលនៅខែ មិនា ឆ្នាំ 1913 ។ ក្នុងនាមជាសមាជិកសាសនាចក្រដំបូងដែលរស់នៅប្រទេសប្រេស៊ីល ពួកគាត់មានចិត្តរីករាយរស់នៅក្នុងប្រទេសមួយដែលមាននូវឱកាសជាច្រើនបែបនេះណាស់ ។ ប៉ុន្តែសាសនាចក្រមិនទាន់បានស្ថាបនានៅអាមេរិកខាងត្បូងនៅឡើយ ហើយរំពេចនោះ ម៉ាក្ស និង អាម៉ាលី បានស្គាល់ពីអារម្មណ៍ឯកោដែលពួកគាត់គ្មានឱកាសទៅព្រះវិហារ ហើយមានទំនាក់ទំនងនឹងសមាជិកដទៃទៀត ។[1]

បន្ទាប់ពីបានរស់នៅប្រទេសប្រេស៊ីលបាន 10 ឆ្នាំមក ម៉ាក្ស និង អាម៉ាលី បានស្គាល់សមាជិកសាសនាចក្រដ៏ស្មោះត្រង់ម្នាក់ទៀតឈ្មោះ អូហ្គាស្តា លីពប៉េល ដែលបានធ្វើអន្តោប្រវេសន៍មកពីប្រទេសអាល្លឺម៉ង់នៅឆ្នាំ 1923 ជាមួយនឹងកូនរបស់នាងបួននាក់ រួមនឹងស្វាមីដែលពុំមែនជាសមាជិកទៅកាន់រដ្ឋភាគខាងត្បូងប្រទេសប្រេស៊ីល ឈ្មោះថា សាន់តា កាតារីណា ។ គ្រួសារហ្សាបស៍បានផ្លាស់ទៅសាន់តា កាតារីណា ដើម្បីបានរស់នៅជិតនឹងគ្រួសារលីពប៉េល ។

ពីរឆ្នាំក្រោយមក បេសកកម្មអាមេរិកខាងត្បូងបានបើកនៅរដ្ឋ ប៊ុយណូស អៃរេស ប្រទេសអាហ្សង់ទីន ។ ប្រធានបេសកកម្មទីពីរឈ្មោះ យេ ប៊ី រ៉ាញហូលដ៍ ស្ទូស ដែលមកពីប្រទេសអាល្លឺម៉ង់ផងដែរ ត្រូវបានបំផុសគំនិតឲ្យស្ថាបនាសាសនាចក្រនៅក្នុងចំណោមប្រជាជនអន្តោប្រវេសន៍សញ្ជាតិអាល្លឺម៉ង់នៅភាគខាងត្បូងប្រទេសប្រេស៊ីល ។ នៅឆ្នាំ 1928 គាត់បានចាត់អ្នកផ្សព្វផ្សាយសាសនាពីរនាក់ឈ្មោះ វិល្លាម ហ្វ្រេឌ ហែនស៍ និង អេមៀល អេ ជេ ហ្សិនទ្បឺ ទៅទីក្រុងជ័ញ្ញវិល ជាទីក្រុងមួយដែលមានចំនួនប្រជាជនអាល្លឺម៉ង់ធ្វើអន្តោប្រវេសន៍ដ៏ច្រើន ។ នៅឆ្នាំ 1930 ប្រធាន ស្ទូស បានទៅលេងនឹងគ្រួសារហ្សាបស៍ និង គ្រួសារលីពប៉េល ហើយបានស្ថាបនាសាខាមួយ ជាទីកន្លែងដែលក្រុមគ្រួសារទាំងពីរអាចទៅព្រះវិហាររួមគ្នា ហើយទទួលទានសាក្រាម៉ង់ ។

ក្នុងរយៈពេល 100 ឆ្នាំ វាមានភាពខុសប្លែកខ្លាំងណាស់ ។ ពីមុនគ្រួសារហ្សាបស៍បានមកដល់នៅឆ្នាំ 1913 ប្រទេសប្រេស៊ីលគ្មានសមាជិក គ្មានពួកអ្នកផ្សព្វផ្សាយសាសនា និងគ្មានអង្គការសាសនាចក្រឡើយ ។ សព្វថ្ងៃ



*ពួកអ្នកផ្សព្វផ្សាយសាសនាទាំងនេះបានបម្រើនៅរីអូ ឌឺ ចានីរ៉ូ ក្នុងចុងឆ្នាំ 1930 រួមមាន ដានីយ៉ែល ហ្សិប៉េ ដែលបានជួយបកប្រែព្រះគម្ពីរមរមនជាភាសាព័រទុយហ្គាល់ផងដែរ ។*

មានមនុស្សតិចតួចចូលក្នុងសាសនាចក្រនៅឆ្នាំដំបូងដែលបេសកកម្មប្រេស៊ីលបានបើកនៅឆ្នាំ 1935 ។ សាសនាចក្របានប្រើជាភាសាអាល្លឺម៉ង់ជាចម្បងរហូតដល់ឆ្នាំ 1940 ជាពេលដែលបានផ្លាស់ប្តូរទៅជាភាសាព័រទុយហ្គាល់ ជាភាសាផ្លូវការរបស់ប្រទេស ។ ពួកអ្នកផ្សព្វផ្សាយសាសនាបានបម្រើនៅក្នុងទីក្រុងជាច្រើនពេញផ្ទៃប្រទេស រហូតដល់សង្គ្រាមលោកលើកទីពីរ ដែលបានតម្រូវឲ្យពួកគេចាកចេញពីប្រទេសនេះ ។ ក្រោយពីសង្គ្រាមនោះ ពួកអ្នកផ្សព្វផ្សាយសាសនាបានត្រឡប់មកវិញ ហើយកិច្ចការនេះបានចាប់ផ្តើមម្តងទៀត ។

នៅទីក្រុង ខាំពីណាស ក្នុងរដ្ឋសៅ ផាឡូ មានយុវជនយុវនារីមួយចំនួនបានចូលរួម ហើយបានបន្តស្មោះត្រង់ ។ សមាជិកម្នាក់ក្នុងចំណោមសមាជិកពីដើមទាំងនោះមាន អានតូនីញ៉ូ កាឡូស ខាម៉ាហ្គូ ។ គាត់បានចូលរួមកាលនៅវ័យជំទង់ក្នុងឆ្នាំ 1947 បានដើរលេងជាគូរ ហើយបានរៀបការនឹងសមាជិកសាសនាចក្រម្នាក់ ហើយនៅឆ្នាំ 1954 បានទៅរៀននៅសាកលវិទ្យាល័យ

**កាលប្បវត្តិ**

1928 ៖ ពួកអ្នកផ្សព្វផ្សាយសាសនាដំបូងបានបញ្ជូនទៅប្រទេសប្រេស៊ីលក្នុងចំណោមប្រជាជននិយាយភាសាអាល្លឺម៉ង់នៅជ័ញ្ញវិល

1930 ៖ សាខាដំបូងបានរៀបចំនៅជ័ញ្ញវិល

▼ 1931 ៖ សាលាប្រជុំរបស់សាសនាចក្រដំបូងគេនៅអាមេរិកខាងត្បូង ត្រូវបានឧទ្ទិសឆ្លង នៅជ័ញ្ញវិល



► 1935 ៖ បេសកកម្មដំបូងបានបង្កើតឡើង មានទីស្នាក់ការកណ្តាលនៅសៅ ផាឡូ



ព្រិកហាំ យ៉ង់ ហើយក្រោយមកទៀតនៅសាកលវិទ្យាល័យយូថាហ៍ ។ គាត់ និង ភរិយាបានត្រឡប់មកប្រទេសប្រេស៊ីលវិញក្នុងឆ្នាំ 1963 ដោយធ្វើការឲ្យក្រុមហ៊ុនក្រណាត់មួយ ហើយមានការភ្ញាក់ផ្អើលចំពោះការរីកចម្រើនរបស់សាសនាចក្រ ។ នៅពេលពួកគេបានចាកចេញទៅក្នុងឆ្នាំ 1954 មានតែសាខាតូចៗពីរបីកន្លែងប៉ុណ្ណោះ ដែលគ្រប់គ្រងដោយពួកអ្នកផ្សព្វផ្សាយសាសនាជនជាតិអាមេរិក ។ ប៉ុន្តែ រយៈពេលប្រាំបួនឆ្នាំនៃអវត្តមានរបស់ពួកគេ មានប្រជាជនប្រេស៊ីលជិត 16,000 នាក់បានចូលរួមនឹងសាសនាចក្រ រួមបញ្ចូលទាំងក្រុមគ្រួសារវ័យក្មេងជាច្រើន ដែលមានសមត្ថភាពដឹកនាំដ៏រឹងមាំ និង ការតាំងចិត្តដ៏ស្មោះត្រង់ ។ អានតូនីញ៉ូបានថ្លែងថា « ពួកគេជាវិញ្ញាណដ៏អស្ចារ្យ ហើយថ្លៃថ្នូរដែលព្រះអម្ចាស់បានជ្រើសរើសនៅក្នុងសៅ ផាឡូនេះ » ។[3]

នៅឆ្នាំ 1966 គឺ 31 ឆ្នាំក្រោយពីបេសកកម្មប្រេស៊ីលបានបើក នោះស្តេកដំបូងគេនៅអាមេរិកខាងត្បូងត្រូវបានរៀបចំឡើងនៅសៅ ផាឡូ ។ អែលឌើរ ស្ពែនស៊ើរ ដបុលយូ ឃីមបឹល ( 1895–1985 ) នៅពេលនោះជាសមាជិកក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានរៀបចំស្តេកនោះដោយមានវ៉លធើរ ស្ប៉ាតជាប្រធាន ហើយអានតូនីញ៉ូជាទីប្រឹក្សារបស់លោក ។

មានថ្នាក់ដឹកនាំថ្មីពីរបីនាក់ប៉ុណ្ណោះដែលធ្លាប់ឃើញស្តេកមួយដំណើរការ ។ ប៉ុន្តែព្រះអម្ចាស់បានរៀបចំអានតូនីញ៉ូ ដែលមានបទពិសោធន៍សំខាន់ជាមួយ

នេះមានសមាជិកច្រើនជាងមួយលាននាក់រស់នៅប្រទេសប្រេស៊ីល ដោយធ្វើឲ្យវាក្លាយជាប្រទេសដែលមានចំនួនសមាជិកសាសនាចក្រច្រើនជាងគេបំផុតលំដាប់ទីបី ( បន្ទាប់ពីសហរដ្ឋអាមេរិក និង ប្រទេសម៉ិកស៊ិក ) ។ ឥឡូវសាសនាចក្រមានក្រុមជំនុំនៅគ្រប់រដ្ឋ និង ក្នុងទីក្រុងធំៗនៃប្រទេសប្រេស៊ីល ។ កូនចៅរបស់ម៉ាក្ស និង អាម៉ាលីរីកាយនឹងអត្ថប្រយោជន៍នៃសាសនាចក្រមួយដ៏រឹងមាំ ហើយសកម្មដែលមាននូវប្រវត្តិសាស្ត្រដែលគួរឲ្យចាប់អារម្មណ៍ជាពិសេស ។

### ការរីកចម្រើនប្រៀបបាននឹងដើមឈើអូក

ការព្យាករណ៍មួយដែលបានធ្វើឡើងនៅប្រទេសអាហ្សង់ទីនក្នុងឆ្នាំ 1926 ដោយអែលឌើរ មេលវិន ជេ បាឡឹដ ( 1873–1939 ) ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានណែនាំថា តំបន់នេះនឹងមានការលូតលាស់យឺតនៅពេលដំបូង គឺប្រយោជន៍ឲ្យវាមានភាពខ្លាំងក្លានៅថ្ងៃណាមួយ ។ លោកបានព្យាករណ៍ថា ៖ « កិច្ចការរបស់ព្រះអម្ចាស់នឹងលូតលាស់បន្តិចម្តងក្នុងរយៈពេលមួយនៅតំបន់នេះ ដូចជាដើមឈើអូកលូតលាស់បន្តិចម្តងៗចេញពីគ្រាប់របស់វាដែរ ។ វានឹងមិនលូតលាស់តែក្នុងមួយថ្ងៃដូចជាផ្កាឈូករតន៍ រួចហើយក៏ស្វិតស្រពោននោះទេ » ។[2]

នឹងសាសនាចក្រនៅសហរដ្ឋអាមេរិក ហើយមានលទ្ធភាពដើម្បីជួយដល់គណៈប្រធានស្ដេក ។ ថ្នាក់ដឹកនាំនៅក្នុងវួដ និង សាខានៃស្ដេកដំបូងនោះបានក្លាយជាអ្នកដឹកនាំសម្រាប់ស្ដេកជាច្រើនបន្ថែមទៀត ។ ឥទ្ធិពលរបស់ពួកគេត្រូវបានជះពាសពេញផ្ទៃប្រទេស នៅពេលការរៀបចំស្ដេកបានចាប់ផ្ដើមរីកចម្រើនយ៉ាងលឿន ។

### យុគសម័យនៃការរីកចម្រើន

សេចក្ដីប្រកាសដែលមិនបានរំពឹងទុកមួយបានបំផុសឲ្យមានការរីកចម្រើនដ៏ធំធេងក្នុងសាសនាចក្រនៅប្រទេសប្រេស៊ីល ៖ អគារព្រះវិហារបរិសុទ្ធ ។ សមាជិកបានដឹងពីសារៈសំខាន់នៃព្រះវិហារបរិសុទ្ធ ប៉ុន្តែភាគច្រើនពួកគេធ្លាប់ឃើញព្រះវិហារបរិសុទ្ធតែតាមរូបថតប៉ុណ្ណោះ ។ ព្រះវិហារបរិសុទ្ធដែលនៅជិតបំផុតគឺនៅសហរដ្ឋអាមេរិក ដែលមានចម្ងាយរាប់ពាន់គីឡូម៉ែត្រ ។ ប្រធាន ឃីមបឹល បានទៅទស្សនកិច្ចនៅប្រទេសប្រេស៊ីលក្នុងខែ មិនា

▶ *1939 ៖ ព្រះគម្ពីរមរមនបានបោះពុម្ពជាភាសាព័រទុយហ្គាល់*




*1954 ៖ លើកដំបូងដែលប្រធានសាសនាចក្រ ដេវីឌ អូ មិកឃេ ធ្វើទស្សនកិច្ចនៅប្រទេសនេះ*

*1959 ៖ បេសកកម្មទីពីរបានបង្កើតឡើង*

*1966 ៖ ស្ដេកដំបូងបានបង្កើតឡើងនៅអាមេរិកខាងត្បូង គឺស្ដេក សៅ ផាឡូប្រេស៊ីល*

▶ *1978 ៖ ព្រះវិហារបរិសុទ្ធដំបូងបានឧទ្ទិសឆ្លងនៅអាមេរិកខាងត្បូង នៅសៅ ផាឡូ ។*



សង្គមដែលបានធ្វើឲ្យមានការរីកចម្រើន ។ មានប្រជាជនប្រេស៊ីលជាច្រើនបានផ្លាស់ប្ដូរទៅតំបន់ជន់បទ ហើយបានបើកដួងចិត្តចំពោះសាសនាថ្មី ។ ក្នុងពេលជាមួយគ្នានោះ ប្រធាន ឃីមបឹល បានសុំឲ្យប្រធានស្ដេកសញ្ជាតិប្រេស៊ីលឲ្យដាក់គោលដៅបង្កើនចំនួនយុវជនប្រេស៊ីលចេញបម្រើបេសកកម្ម ។ មិនយូរប៉ុន្មាន ពួកអ្នកផ្សព្វផ្សាយសាសនាលើសពាក់កណ្ដាលនាក់ ដែលបម្រើនៅប្រទេសប្រេស៊ីលគឺជាជនជិតប្រេស៊ីល ។ ក្រោយមក ពួកអ្នកផ្សព្វផ្សាយសាសនាទាំងនេះបានត្រឡប់មកវិញ បានក្លាយជាពួកអ្នកដឹកនាំក្នុងមូលដ្ឋានរបស់សាសនាចក្រ ។

ប៉ុន្តែការរីកចម្រើនរបស់សាសនាចក្របានគូសបង្ហាញនូវឧបសគ្គមួយ ៖ ការខ្វះបទពិសោធន៍របស់សមាជិក ។ ប៉ុន្តែ ឧបសគ្គនេះមានលទ្ធផលវិជ្ជមានមួយ ៖ វាតម្រូវឲ្យមានការបង្កើនសេចក្ដីជំនឿ និង ការដឹកនាំខាងវិញ្ញាណនៅក្នុងចំណោមសមាជិក ។ ឧទាហរណ៍ នៅខែ វិច្ឆិកា ឆ្នាំ 1992 ស្ដេកថ្មីមួយត្រូវបានរៀបចំឡើងនៅ អ៊ុយរុយហ្គែអាណា នៅភាគខាងលិចប្រទេសប្រេស៊ីល

ឆ្នាំ 1975 ហើយនៅសន្និសីទក្នុងតំបន់មួយ នោះលោកបានប្រកាសការសាងសង់ព្រះវិហារបរិសុទ្ធមួយនៅសៅ ផាឡូ ។ សេចក្ដីសង្ឃឹម និង ការលះបង់ខាងហិរញ្ញវត្ថុដ៏អស្ចារ្យបានដឹកនាំទៅរកការសង់បញ្ចប់ព្រះវិហារបរិសុទ្ធក្នុងឆ្នាំ 1978 ។ សមាជិកបានជួយបង់ថ្លៃសាងសង់ព្រះវិហារបរិសុទ្ធតាមរយៈដង្វាយការបរិច្ចាគ ។ ពួកគេជាច្រើនបានលក់រថយន្ត គ្រឿងអលង្ការ និង ដីដើម្បីមានមូលនិធិ សម្រាប់ការបរិច្ចាគរបស់ពួកគេ ។

ការឧទ្ទិសឆ្លងព្រះវិហារបរិសុទ្ធនោះនៅខែ តុលា និង ខែ វិច្ឆិកា ឆ្នាំ 1978 ត្រូវបានចាប់ផ្ដើមឡើងនៅខែ មិថុនា ដោយវិវរណៈស្ដីពីបព្វជិតភាព ( សូមមើលសេចក្ដីប្រកាសជាផ្លូវការទី 2 ) ។ វិវរណៈនេះមានន័យថា រាល់សមាជិកដែលសក្តិសមនៅក្នុងប្រទេសប្រេស៊ីលអាចចូលរួមនៅក្នុងការឧទ្ទិសឆ្លង និង ពរជ័យទាំងឡាយនៃព្រះវិហារបរិសុទ្ធបាន ។

វិវរណៈបព្វជិតភាព និង ការឧទ្ទិសឆ្លងព្រះវិហារបរិសុទ្ធនេះគឺជាកាលើកស្ទួយសម្រាប់ជោគជ័យនៃការផ្សព្វផ្សាយសាសនាដ៏អស្ចារ្យមួយដែលពុំធ្លាប់មាននៅក្នុងសាសនាចក្រ ៖ មានប្រជាជនប្រេស៊ីលច្រើនជាង 700,000 នាក់បានចូលរួមក្នុងសាសនាចក្រនៅពីរទសវត្សរ៍ក្រោយមក ។

ព្រឹត្តិការណ៍បន្ថែមទៀតបានបណ្ដាលឲ្យមានការរីកចម្រើននេះ ។ ប្រទេសនេះបានឆ្លងកាត់នូវការផ្លាស់ប្ដូរយ៉ាងសំខាន់ខាងនយោបាយ និង ខាង

នៅឆ្ងាយពីស្ដេករបស់សាសនាចក្រដែលបានស្ថាបនា ។ នៅពេលសមាជិកសាសនាចក្រដ៏យូរ ហើយស្មោះត្រង់ម្នាក់ឈ្មោះ ចូសេ ខានឌីឌូ ហ្វើរៀរ៉ា ដូស សានតូស ត្រូវបានហៅជាលោកអយ្យកោសម្រាប់ស្ដេកបង្កើតថ្មី គាត់មានចិត្តខ្វល់ខ្វាយ ។ គាត់បានពន្យល់ទៅអ្នកមានសិទ្ធិអំណាចទូទៅថា ៖ « ខ្ញុំមិនអាចធ្វើជាលោកអយ្យកោបានទេ ។ ខ្ញុំមិនដឹងថា លោកអយ្យកោជាអ្វីនោះទេ ។ ខ្ញុំមិនចាំពីការជួបនឹងលោកអយ្យកោ ហើយគ្មានពររបស់លោកអយ្យកោរបស់ខ្ញុំ » ។ អ្នកមានសិទ្ធិអំណាចទូទៅម្នាក់នោះបានណែនាំនូវដំណោះស្រាយមួយ ។ នៅទីក្រុងក្បែរនោះឈ្មោះទីក្រុង អាឡេប្រេហ្គេតេ លោកអយ្យកោថ្មីម្នាក់ឈ្មោះ រូអ៊ី អានតូនីញ៉ូ ដាវីឡា ដែលទើបបានហៅថ្មីៗនេះក៏មានស្ថានភាពស្រដៀងគ្នានេះដែរ ។ លោកអយ្យកោទាំងពីរនាក់ត្រូវផ្ដល់ពរជ័យរបស់លោកអយ្យកោឲ្យគ្នាទៅវិញទៅមក ។

នៅពេលបងប្រុសសានតូសបានទទួលពរជ័យរបស់គាត់ពីបងប្រុស ដាវីឡា គាត់មានការភ្ញាក់ផ្អើលនៅពេលគាត់ឮពរជ័យដែលបានប្រកាសទាក់ទងនឹងអតីតកាលគាត់ និង បំណងប្រាថ្នាផ្ទាល់ខ្លួនរបស់គាត់ដែលលោកអយ្យកោនោះពុំធ្លាប់បានដឹងសោះ ។ នៅពេលដល់វេនបងប្រុសសានតូសប្រកាសពរជ័យដល់បងប្រុស ដាវីឡា វិញ ទឹកភ្នែកបានស្រក់ចុះមកខណៈដែលបទពិសោធន៍ដូចគ្នានេះបានកើតឡើងម្ដងទៀត ។ ក្រោយមក បុរសទាំងពីររូបនេះបាន







ឱបគ្នាដោយមានការយល់ដឹងដ៏ជ្រាលជ្រៅមួយពីអ្វីដែលទើបកើតឡើង ។[4] ដូចជាព្រះវិញ្ញាណបានបំផុសគំនិតដល់ពួកគាត់ឲ្យផ្ដល់ពររបស់លោកអយ្យកោដំបូងរបស់ពួកគាត់ដែរ ព្រះវិញ្ញាណបានបំផុសគំនិតពួកគាត់នៅពេលពួកគាត់ផ្ដល់ពរនេះរាប់រយបន្ថែមទៀត ។ ព្រះអម្ចាស់បានប្រទានពរខាងវិញ្ញាណបែបនេះជាច្រើន នៅក្នុងប្រទេសមួយដែលបទពិសោធន៍សាសនាចក្រមានស្ដួចស្ដើង ។

**មូលនិធិអប់រំដែលមានជាបន្តបន្ទាប់**

ការខ្វះការអប់រំនៅក្នុងចំណោមសមាជិកគឺជាឧបសគ្គមួយផ្សេងទៀត ។ ជារឿយៗ នៅពេលពួកអ្នកផ្សព្វផ្សាយសាសនាត្រឡប់មកផ្ទះវិញ ពួកគេបានរៀបចំខ្លួនខាងវិញ្ញាណ ប៉ុន្តែខ្វះនូវការអប់រំដើម្បីទទួលបានការងារដែល សក្តិសម ។ ក្មេង បញ្ចប់ការអប់រំរបស់ពួកគេ ហើយមានការងារល្អ ប៉ុន្តែជោគជ័យដ៏ពិតនៃកម្មវិធីនេះគឺដើម្បីមើលឃើញពីកម្រិតនៃការជឿជាក់នៅក្នុងខ្លួនពួកគេមានការកើនឡើង ។ ពួកគេមានសេចក្ដីសង្ឃឹមច្រើនជាងមុន » ។[5]

**សមាជិកដែលមានការលះបង់**

កម្លាំងនៃសាសនាចក្រនៅក្នុងប្រទេសប្រេស៊ីលពុំមែនគ្រាន់តែជាចំនួនសមាជិកប៉ុណ្ណោះទេ ប៉ុន្តែវាក៏ជាការលះបង់របស់ពួកគេចំពោះដំណឹងល្អផងដែរ ។ ឧទាហរណ៍ ហ្គេលសុន ពីហ្សីរ៉ានី ជាអ្នករដ្ឋបាលចូលនិវត្តន៍នៅក្រុមហ៊ុនអាកាសចរណ៍មួយ ត្រូវបានផ្ដល់ឲ្យនូវការងារមួយដ៏លំបាក តែមានអត្ថប្រយោជន៍ច្រើន ៖ ជួយសាងសង់អាកាសចរណ៍ថ្មីនៅប្រទេសប្រេស៊ីល ។ នៅពេលដូចគ្នានោះ



*◄ 1985 ៖ អែលឌើរ ហេលីយ៉ូ អេ ខាម៉ាហ្គូ ត្រូវបានហៅធ្វើជាអ្នកមានសិទ្ធិអំណាចទូទៅមុនគេមកពីប្រទេសប្រេស៊ីល*

*1986 ៖ ប្រទេសប្រេស៊ីលក្លាយជាប្រទេសទីបួនដែលមានស្តេកច្រើនជាង 50*

*1987 ៖ តំបន់ប្រេស៊ីលត្រូវបានបង្កើតឡើង*

*1993 ៖ ប្រទេសប្រេស៊ីលបានក្លាយជាប្រទេសទីបីដែលមានស្តេក 100*



*◄ 1997 ៖ មជ្ឈមណ្ឌលបំពាក់បំប៉នអ្នកផ្សព្វផ្សាយសាសនាធំជាងគេទីពីររបស់សាសនាចក្រ ត្រូវបានសាងសង់នៅសៅ ផាទ្បូ*







វីណាល់ដូ បារ៉េតូ ជាប្រធានស្តេកនៅសៅ ផាទ្បូ បានពន្យល់ថា « វាគឺជាឧបសគ្គដ៏សំខាន់មួយដើម្បីស្វែងរកការងារធ្វើ ។ ពួកអ្នកផ្សព្វផ្សាយសាសនាជាច្រើនបានអស់សង្ឃឹមពីការរីកចម្រើន ថែមទាំងបាត់បង់នូវកម្លាំងខាងវិញ្ញាណដែលពួកគេមាននៅក្នុងបេសកកម្មទៀតផង » ។ ជារឿយៗ ការអប់រំគឺជាគន្លឹះដើម្បីយកឈ្នះឧបសគ្គនេះ ។

ដូច្នេះ ការស្ថាបនានូវមូលនិធិអប់រំដែលមានជាបន្តបន្ទាប់ដោយប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី ( 1910–2008 ) ក្នុងឆ្នាំ 2001 បានប្រទានពរដល់ពួកអ្នកផ្សព្វផ្សាយសាសនាដែលបានត្រឡប់មកវិញដែលជាសញ្ជាតិប្រេស៊ីល រាប់ពាន់នាក់ ។ វាផ្ដល់ឱកាសបំពាក់បំប៉នដល់ពួកគេដែលធ្វើឲ្យពួកគេមានការងារប្រសើរជាង ។ សមាជិកមានលទ្ធភាពប្រសើរជាងមុនដើម្បីផ្គត់ផ្គង់ដល់គ្រួសារ ហើយថែមទាំងចាប់យកការអប់រំតទៅទៀត ។ ប្រធាន បារ៉េតូ ដែលបានក្លាយជាអ្នកគ្រប់គ្រងកម្មវិធីភី.អ៊ី.អេស. នៅប្រទេសប្រេស៊ីលបានថ្លែងថា « វាជាពរជ័យមួយដោយមើលឃើញសមាជិកវ័យ

*ចាប់តាំងពីឆ្នាំ 1999 សមាជិកប្រេស៊ីលរាប់ពាន់នាក់បានបម្រើនៅក្នុងសហគមន៍របស់ខ្លួនជាផ្នែកមួយនៃកិច្ចការរបស់ដៃសប្បុរសធម៌មរមន ។*



គាត់ និងភរិយាឈ្មោះ មីរៀម ត្រូវបានហៅឲ្យគ្រប់គ្រងលើបេសកកម្ម ប្រេស៊ីល ប្រេស៊ីល ។ គាត់មិនដឹងត្រូវធ្វើអ្វីនោះទេ ។ ចាប់តាំងពីបុណ្យជ្រមុជទឹករបស់ពួកគាត់តាំងពីនៅជាក្មេងជំទង់មក ពួកគាត់បានលះបង់ជីវិតសម្រាប់សាសនាចក្រ ។ ពីមុនពួកគាត់រៀបការ បងប្រុស ពីហ្សីរ៉ានី ត្រូវបានហៅឲ្យបម្រើជាប្រធានសាខា ។ គាត់ត្រូវបានហៅឲ្យធ្វើជាប្រធានស្តេកនៅអាយុ 25 ឆ្នាំ ហើយបានទទួលការហៅច្រើនផ្សេងទៀត រួមទាំងពួកចិតសិបនាក់ប្រចាំតំបន់ផងដែរ ។ បងស្រី ពីហ្សីរ៉ានី ធ្លាប់បម្រើនៅក្នុងការហៅនៃសមាគមសង្គ្រោះ យុវនារី និង អង្គការបឋមសិក្សាស្តេក និង វួដ ។ គាត់បានសម្តែងអារម្មណ៍ខ្វល់ខ្វាយពីពរជ័យនៃដំណឹងល្អថា ៖ « ជីវិតខ្ញុំមានពរជ័យច្រើនណាស់ ដោយសារខ្ញុំបានព្យាយាមគោរពតាមព្រះបញ្ញត្តិ ។ ត្បិតរាល់ព្រះបញ្ញត្តិដែលខ្ញុំគោរពតាម ខ្ញុំទទួលបានពរជ័យ » ។[6]

បន្ទាប់ពីបញ្ចប់បេសកកម្មរបស់ពួកគេនៅប្រេស៊ីលមក ផែនការរបស់ពួកគាត់នៅផ្ទះត្រូវបានរំខានដោយការហៅរយៈពេលខ្លីដើម្បីបម្រើជាប្រធានបេសកកម្ម ខាំពីណាស់ប្រេស៊ីល ។ បន្ទាប់ពីសម្រាកបានពីរបីខែក្រោយមក ពួកគេបានទទួលយកការហៅមួយនៅឆ្នាំ 2013 ធ្វើជាប្រធាន និង មើលថែស្ត្រីក្នុងព្រះវិហារបរិសុទ្ធនៅព្រះវិហារបរិសុទ្ធជ័រស៊ីហ្វេ ប្រេស៊ីល ។ អ្នកផ្សព្វផ្សាយម្នាក់ដែលបានជ្រមុជទឹកឲ្យបងប្រុស ពីហ្សីរ៉ានី ដែលទើបបានហៅជាមួយនឹងភរិយាគាត់ឲ្យបម្រើនៅក្នុងព្រះវិហារបរិសុទ្ធជ័រស៊ីហ្វេ ជាកន្លែងដែលអ្នកផ្សព្វផ្សាយសាសនា និង អ្នកប្រែចិត្តជឿនឹងបម្រើរួមគ្នា ។

គំរូរបស់គ្រួសារពីហ្សីរ៉ានីលះបង់ឱកាសការងារដើម្បីបម្រើព្រះអម្ចាស់គឺមានការបំផុសគំនិតណាស់ ប៉ុន្តែវាពុំមែនជារឿងធម្មតានៅក្នុងចំណោមសមាជិកស្មោះត្រង់ក្នុងប្រទេសប្រេស៊ីលឡើយ ។

100 ឆ្នាំ ចាប់តាំងពីគ្រួសារហ្សាបស៍បានមកដល់ប្រទេសប្រេស៊ីលបានឃើញការផ្លាស់ប្តូរវិជ្ជមានជាច្រើន ប៉ុន្តែក៏មានឧបសគ្គម្តងម្កាលដែរ ។ ប៉ុន្តែពួកព្យាការីដែលបានទៅធ្វើទស្សនកិច្ចពុំដែលស្ទាក់ស្ទើរ ដើម្បីបង្ហាញសេចក្តីជំនឿ ចំពោះអនាគតរបស់ប្រទេសនេះឡើយ ។ ការព្យាករណ៍ទាំងនោះកំពុងផ្តល់ជាផលផ្លែល្អ នៅពេលប្រទេសប្រេស៊ីលជាប់ចំណាត់ថ្នាក់ក្នុងពិភពលោកជាប្រទេសនាំមុខផ្នែកការរីកចម្រើន និង ការអភិវឌ្ឍខាងសេដ្ឋកិច្ច ។ កូនចៅរបស់គ្រួសារហ្សាបស៍—ទាំងពួកគេផ្ទាល់ និង ពួកអ្នកដែលបានដើរតាមដានជើងរបស់ពួកគេនៅក្នុងដំណឹងល្អ—កំពុងទទួលបានផលផ្លែនៃការខិតខំធ្វើការ និង ការអត់ធ្មត់នៃកិច្ចខិតខំទាំងនោះ កាលពីមុនដើម្បីបណ្តុះគ្រាប់ពូជនៃដំណឹងល្អ ។ ផ្នែកទីពីរនៃការព្យាករណ៍របស់អែលឌើរ មេលវិន ជេ បាឡឺដ ដែលបានធ្វើឡើងនៅឆ្នាំ 1926 បានកើតមានឡើងថា ៖ « មានមនុស្សរាប់ពាន់នាក់នឹងចូលរួមក្នុងសាសនាចក្រនៅទីនេះ ។ វានឹងបានបែងចែកជាច្រើនបេសកកម្ម ហើយនឹងក្លាយជាប្រទេសមួយដ៏រឹងមាំក្នុងសាសនាចក្រ » ។ ■






▲ 2000 ៖ ព្រះវិហារបរិសុទ្ធជ័រស៊ីហ្វេ និង ព័រតូ អាលេហ្គ្រី ប្រេស៊ីល ត្រូវបានឧទ្ទិស

2002 ៖ ព្រះវិហារបរិសុទ្ធ ខាំពីណាស់ត្រូវបានឧទ្ទិសឆ្លង

2002 ៖ ដែលប្រសេដ៍របស់មមនទទួលបានការទទួលស្គាល់ថ្នាក់ជាតិជាអង្គការស្ម័គ្រចិត្តដ៏សំខាន់បំផុតរបស់ប្រទេសប្រេស៊ីល



◀ 2008 ៖ ព្រះវិហារបរិសុទ្ធ ឃើរីទីបាត្រូវបានឧទ្ទិសឆ្លង



▲ 2012 ៖ ព្រះវិហារបរិសុទ្ធ ម៉ាណាអ៊ុស ត្រូវបានឧទ្ទិសឆ្លង

**កំណត់ចំណាំ**

1. ស៊ីប៊ីឡា ហាក់ នុយណេស ( ចៅស្រីរបស់ម៉ាក្ស និង អាមេលី ហ្សាបស៍ ) សម្ភាសន៍ដោយម៉ែខល ឡេនឌិន ឃើរីទីបា ប្រទេសប្រេស៊ីល ថ្ងៃទី 30 ខែ កក្កដា ឆ្នាំ 2004 បណ្ណាល័យប្រវត្តិសាស្ត្រសាសនាចក្រ ។
2. មេលវិន ជេ បាឡឺដ នៅក្នុង ប្រាយអិន អេស ហ៊ិងគ្លី *Sermons and Missionary Services of Melvin Joseph Ballard* ( ឆ្នាំ 1949 ) ទំព័រ 100 ។
3. អានតូនីញ៉ូ ខាឡូស ខាម៉ាហ្គូ សម្ភាសន៍ដោយ ម៉ាក អិល ក្រូរើរ សៅ ផាឡូ ប្រទេសប្រេស៊ីល ថ្ងៃទី 27 ខែ មិថុនា ឆ្នាំ 2006 Harold B. Lee Library ទំព័រ 22 ។
4. ចូសេ ខានឌីឌូ ហ្វើរៀរ៉ា ដូស សានតូស សម្ភាសដោយ ម៉ាក អិល ក្រូរើរ រីយ៉ូ ហ្គ្រង់ដេ ដូ ស៊ុល ប្រទេសប្រេស៊ីល ថ្ងៃទី 4 ខែ ឧសភា ឆ្នាំ 2010, Harold B. Lee Library ។ រូអ៊ី អានតូនីញ៉ូ ដាវីឡា សម្ភាសដោយ ម៉ាក អិល ក្រូរើរ រីយ៉ូ ហ្គ្រង់ដេ ដូ ស៊ុល ប្រទេសប្រេស៊ីល ថ្ងៃទី 5 ខែ ឧសភា ឆ្នាំ 2010, Harold B. Lee Library ។,
5. អានតូនីញ៉ូ ខាឡូស ខាម៉ាហ្គូ សម្ភាសន៍ដោយ ម៉ាក អិល ក្រូរើរ សៅ ផាឡូ ប្រទេសប្រេស៊ីល ថ្ងៃទី 16 ខែ មិថុនា ឆ្នាំ 2006 Harold B. Lee Library ទំព័រ 14 ។
6. មីរៀម ដា ស៊ិលវ៉ា ស៊ុយឡេ ពីហ្សីរ៉ានី សម្ភាសដោយ ម៉ាក អិល ក្រូរើរ សៅ ផាឡូ ប្រទេសប្រេស៊ីល ថ្ងៃទី 21 ខែ មិនា ឆ្នាំ 1982 Harold B. Lee Library ទំព័រ 7 ។

រូបថតរបស់អែលឌើរ ខាម៉ាហ្គូ ទទួលបានសិទ្ធិអនុញ្ញាតជាផ្លូវការពីបណ្ណាល័យប្រវត្តិសាស្ត្រសាសនាចក្រ ។ ខាងលើ ៖ រូបថតនៃព្រះវិហារបរិសុទ្ធព័រតូ អាលេហ្គ្រី ប្រេស៊ីលដោយ ម៉ាកូ អានជ្រាស ។ ខាងស្តាំ ៖ រូបថតនៃព្រះវិហារបរិសុទ្ធឃើរីទីបា ប្រេស៊ីលដោយ ចន លូក ។ រូបថតនៃព្រះវិហារបរិសុទ្ធម៉ាណូស ប្រេស៊ីល ដោយ ម៉ាថាយ រៀ



# ព្រះគម្ពីរមរមនការប្រមូលផ្ដុំនៃអ៊ីស្រាអែល និង ការយាងមកជាលើកទីពីរ

**ដោយ អែលឌើរ រ័សុល អិម ណិលសុន**
ក្នុងកូរ៉ុមនៃពួកសាវក ដប់ពីរនាក់

*ការលេចមកនៃព្រះគម្ពីរមរមនគឺជាសញ្ញាពិតមួយទៅកាន់ពិភពលោកនេះថា ព្រះ អម្ចាស់បានចាប់ផ្ដើមប្រមូលសាសន៍អ៊ីស្រាអែល ហើយបំពេញតាមសេចក្ដីសញ្ញាដែលទ្រង់បានធ្វើនឹង អ័ប្រាហាំ អ៊ីសាក និង យ៉ាកុប ។*

ជំពូកទី 5 នៃ*ប្រកាសដំណឹងល្អរបស់យើង ៖ សៀវភៅណែនាំសម្រាប់ការបម្រើរបស់អ្នកផ្សព្វផ្សាយសាសនា*ត្រូវបានផ្ដោតទាំងស្រុងទៅលើព្រះគម្ពីរមរមន ។ ជំពូកនេះបង្រៀនថា ព្រះគម្ពីរមរមន ៖

- គឺជាសិលាគ្រឹះនៃសាសនារបស់យើង ។
- ធ្វើទីបន្ទាល់ពីព្រះយេស៊ូវគ្រីស្ទ ។
- គាំទ្រព្រះគម្ពីរប៊ីប ។
- ឆ្លើយសំណួរខាងព្រលឹងវិញ្ញាណ ។
- នាំមនុស្សឲ្យខិតជិតព្រះ ។



រាល់ការប្រកាសទាំងនេះគឺពិតប្រាកដ ប៉ុន្តែវាត្រូវបានធ្វើឡើង ចេញពីទស្សនៈរបស់យើងក្នុងនាមជាមនុស្សរមែងស្លាប់ ។ តើអ្វីទៅនឹងក្លាយជាទស្សនៈរបស់ព្រះវរបិតាយើង ដែលគង់នៅស្ថានសួគ៌ និង បុត្រាដ៏ជាទីស្រលាញ់របស់ទ្រង់ ព្រះយេស៊ូវគ្រីស្ទស្ដីពីព្រះគម្ពីរមរមន ?

ទស្សនៈរបស់ទ្រង់នឹងប្រាកដជាត្រូវបានពង្រឹងដោយការសន្យាដ៏រឹងមាំជាយូរមកហើយពីអ្វី ដែលទ្រង់បានធ្វើនឹងមនុស្សលោក ។ ការសន្យាទាំងពីរនេះមានទំនាក់ទំនងនឹងគ្នា ត្រូវបានកត់ទុកយ៉ាងល្អ នៅតែមានឥទ្ធិពល ហើយមិនទាន់បានបំពេញនៅឡើយ ។ ការសន្យាទីមួយគឺជាការសន្យាពីបុរាណរបស់ទ្រង់ដើម្បីប្រមូលសាសន៍អ៊ីស្រាអែលដែលបានខ្ចាត់ព្រាត់ ។ ការសន្យាទីពីរគឺជាការសន្យាដ៏រឹងមាំជាយូរមកហើយរបស់ទ្រង់ ស្ដីពីការយាងមកជាលើកទីពីររបស់ព្រះអម្ចាស់ ។

### សេចក្ដីសញ្ញាអ័ប្រាហាំ និង វង្សអ៊ីស្រាអែល

នៅក្នុងគ្រាកាន់កាប់ត្រួតត្រារបស់អ័ប្រាហាំ ព្រះបានធ្វើសេចក្ដីសញ្ញាមួយនឹងអ័ប្រាហាំថា តាមរយៈពូជពង្សរបស់គាត់ មនុស្សអស់ទាំងនឹងមានពរជ័យ ។ កត្តាដ៏សំខាន់ផ្សេងទៀតនៃការសន្យានោះក៏ត្រូវបានធ្វើឡើងផងដែរ ។ ការសន្យាទាំងនេះ ដំបូងត្រូវបានប្រទានឲ្យទៅអ័ប្រាហាំ ហើយក្រោយមកត្រូវបានបញ្ជាក់ម្ដងទៀតទៅអ៊ីសាក និង យ៉ាកុប រួមមាន ៖

- ការរីកចម្រើនដ៏ធំ ។[1]
- គ្រប់គ្រងដែនដីដ៏ពិតប្រាកដ ។[2]
- ពូជពង្សរបស់អ័ប្រាហាំនឹងកាន់បព្វជិតភាពនៅគ្រប់អស់ទាំងប្រជាជាតិ រហូតដល់មនុស្សទាំងអស់អាចមានពរតាមរយៈពូជពង្សរបស់អ័ប្រាហាំ ។[3]
- អ្នកដែលពុំមែនជាពូជពង្សរបស់អ័ប្រាហាំ ដែលបានទទួលយកដំណឹងល្អនឹងក្លាយជាពូជពង្សរបស់អ័ប្រាហាំតាមរយៈការយកមកចិញ្ចឹម ។[4]
- ព្រះអង្គសង្គ្រោះនៃពិភពលោកនឹងយាងមកតាមរយៈពូជពង្សរបស់អ័ប្រាហាំ ។[5]

កូនចៅរបស់អ័ប្រាហាំជាច្រើន—ពូជអម្បូរអ៊ីស្រាអែលពីបុរាណ—នៅទីបំផុតបានបដិសេធការបង្រៀនរបស់ព្រះអម្ចាស់ ហើយបានសម្លាប់ពួក



ព្យាការី ។ ពូជអម្បូរទាំងដប់ត្រូវបានយកទៅធ្វើជាឈ្លើយនៅស្រុកអាសស៊ើរ ។ ចាប់តាំងពីពេលនោះមកពួកគេបានបាត់បង់ចេញពីកំណត់ត្រារបស់មនុស្សលោក ប៉ុន្តែមិនត្រូវបានបាត់វង្វេងចំពោះព្រះអម្ចាស់ឡើយ ។ ពូជអម្បូរពីរបាននៅសេសសល់ក្នុងរយៈពេលមួយខ្លី ប៉ុន្តែដោយសារការបះបោររបស់ពួកគេ ពួកគេត្រូវបានចាប់ទៅធ្វើជាឈ្លើសនៅបាប៊ីឡូន ។ នៅពេលពួកគេត្រឡប់មកវិញ ពួកគេបានក្លាយជាប្រជាជនសំណប់របស់ព្រះអម្ចាស់ ប៉ុន្តែពួកគេបានបដិសេធទ្រង់ជាថ្មីម្តងទៀត !

**ការខ្ចាត់ព្រាត់ និង ការប្រមូលផ្តុំនៃអ៊ីស្រាអែល**

ព្រះវរបិតាជាទីស្រឡាញ់ ប៉ុន្តែមាន ព្រះហឫទ័យទុក្ខសោកបានធ្វើឲ្យអ៊ីស្រាអែលខ្ចាត់ព្រាត់ពីគ្នាដោយព្រះទ័យសោកសៅ ប៉ុន្តែទ្រង់បានសន្យាថា នៅថ្ងៃមួយអ៊ីស្រាអែលដែលបានខ្ចាត់ព្រាត់នឹងត្រូវបានប្រមូលផ្តុំមកវិញចូលក្នុងក្រោលតែមួយ ។ ការសន្យានេះមានការសង្កត់ធ្ងន់ ដូចជាការសន្យានៃការខ្ចាត់ព្រាត់អ៊ីស្រាអែលដែរ ។[6] ឧទាហរណ៍ អេសាយបានមើលឃើញជាមុនថា នៅថ្ងៃចុងក្រោយព្រះអម្ចាស់នឹងបញ្ជូន « ពួកបម្រើយ៉ាងលឿន » ទៅកាន់ប្រជាជនទាំងនេះ ដែល « មានរូបខ្ពស់ ហើយសាច់រលីង » ( អេសាយ 18:2, 7 ) ។

ដូចដែលបានព្យាករណ៍ រឿង*ទាំងអស់*ត្រូវបានស្តារឡើងវិញនៅគ្រាកាន់កាប់ត្រួតត្រានេះ ។ ហេតុដូច្នេះហើយ ការប្រមូលផ្តុំដែលបានរង់ចាំយ៉ាងយូរនៃអ៊ីស្រាអែលដែលបានខ្ចាត់ព្រាត់ត្រូវតែកើតមានជាផ្នែកមួយនៃការស្តារឡើងវិញនោះ ។[7] ការប្រមូលផ្តុំនៃអ៊ីស្រាអែលជាប់ពាក់ព័ន្ធនឹងការសន្យាទីពីរ ពីព្រោះការប្រមូលផ្តុំនោះគឺជាការចាប់ផ្តើមដ៏ចាំបាច់មួយចំពោះការយាងមកជាលើកទីពីររបស់ព្រះអម្ចាស់ ។[8] ជាថ្មីម្តងទៀត ទស្សនៈពីសួគ៌ានោះគឺជាភស្តុតាងជារៀងរហូត ។



ជំហាននៃការប្រមូលផ្តុំនេះគឺជាការបង្រៀនមួយដ៏សំខាន់របស់សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ។ ព្រះអម្ចាស់បានប្រកាសថា « យើងឲ្យដល់អ្នករាល់គ្នានូវទីសម្គាល់មួយ. . . . គឺយើងនឹងប្រមូលរាស្ត្រយើងមកវិញ បន្ទាប់ពីគេត្រូវបានខ្ចាត់ព្រាត់អស់ពេលដ៏យូរ ឱវង្សអ៊ីស្រាអែលអើយ ហើយនឹងតាំងក្រុងស៊ីយ៉ូនរបស់យើងឡើងវិញនៅក្នុងចំណោមពួកគេ » ( នីហ្វៃទី 3 21:1 ) ។

ការចេញមកនៃព្រះគម្ពីរមរមនគឺជាសញ្ញាពិតមួយទៅកាន់ពិភពលោកនេះថា ព្រះអម្ចាស់បានចាប់ផ្តើមប្រមូលសាសន៍អ៊ីស្រាអែល ហើយបំពេញតាមសេចក្តីសញ្ញាដែលទ្រង់បានធ្វើនឹងអ័ប្រាហាំ អ៊ីសាក និង យ៉ាកុប ។[9] យើងមិនគ្រាន់តែបង្រៀនពីជំហាននេះប៉ុណ្ណោះទេ ប៉ុន្តែយើងក៏ចូលរួមចំណែកនៅក្នុងកិច្ចការនេះដែរ ! យើងធ្វើដូច្នេះ នៅពេលយើងជួយប្រមូលអ្នករើសតាំងរបស់ព្រះអម្ចាស់នៅផ្នែកទាំងសង្ខាងនៃវាំងនន ។

ការអញ្ជើញដែលពោរពេញដោយសេចក្តីមេត្តាករុណាឲ្យ « មករកព្រះគ្រីស្ទ » ( យ៉ាកុប 1:7 )[10] ក៏អាចមានចំពោះជនដែលបានចែកឋានទៅដោយគ្មានចំណេះដឹងនៃដំណឹងល្អផងដែរ ។[11] ផ្នែកនៃការរៀបចំខ្លួនដើម្បីជាប្រយោជន៍ដល់ជនដែលរស់នៅផ្នែកម្ខាងទៀតនៃវាំងនន តម្រូវឲ្យមានការខិតខំនៅលើផែនដីពីសំណាក់ជនដែលកំពុងមានជីវិតរស់នៅសព្វថ្ងៃនេះ ។ យើងប្រមូលបញ្ជីពង្សាវលី បង្កើតតារាងក្រុមគ្រួសារ ហើយធ្វើកិច្ចការព្រះវិហារបរិសុទ្ធ ដើម្បីប្រមូលមនុស្សទាំងឡាយទៅរកព្រះអម្ចាស់ និង ក្រុមគ្រួសាររបស់ពួកគេ ។[12]

សម័យកាន់កាប់ត្រួតត្រានៃពេលពេញកំណត់នេះត្រូវបានទតឃើញជាមុនដោយព្រះ ថាជាគ្រានៃការប្រមូលផ្តុំនោះ ទាំងនៅស្ថានសួគ៌ និង លើផែនដី ។ សាវកពេត្រុសបានដឹងថា បន្ទាប់ពីគ្រានៃការក្បត់សាសនាមួយមក ការស្តារឡើងវិញនឹងកើតមានឡើង ។ លោកបានប្រកាសថា ៖

« ចូរប្រែចិត្ត ហើយវិលមកចុះ ដើម្បីឲ្យបាបរបស់អ្នករាល់គ្នាបានលុបចេញ ប្រយោជន៍ឲ្យមានពេលលំហែរមកពីចំពោះព្រះអម្ចាស់ . . .

« ដែលស្ថានសួគ៌ត្រូវទទួល ដរាបដល់គ្រាតាំងរបស់ទាំងអស់ឡើងវិញ ដែលព្រះបានមានបន្ទូលប្រាប់ពីគ្រានោះ ដោយសារមាត់នៃពួកហោរាបរិសុទ្ធរបស់ទ្រង់តាំងពីបុរាណមក » ( កិច្ចការ 3:19, 21 ) ។

នៅជំនាន់របស់យើង ពេត្រុស យ៉ាកុប និង យ៉ូហាន ត្រូវបានចាត់ដោយព្រះអម្ចាស់ដោយមាន « កូនសោទាំងឡាយនៃនគររបស់ [ទ្រង់] និងនៃការកាន់កាប់ត្រួតត្រានៃដំណឹងល្អ សម្រាប់ពេលចុងក្រោយបង្អស់ និងសម្រាប់កំណត់កាលដ៏ពោរពេញ » ដែលទ្រង់នឹង « ប្រមូលរបស់របរទាំងអស់ទៅតែមួយគឺរបស់នៅលើស្ថានសួគ៌ ព្រមទាំងរបស់នៅលើផែនដីផង » ( គ. និង ស. 27:13 ) ។[13]

កត្តាជាច្រើននៃសេចក្តីសញ្ញាអ័ប្រាហាំត្រូវបានបំពេញរួចរាល់ហើយ ។ ព្រះអង្គសង្គ្រោះនៃពិភពលោកពិតជាបានយាងមកតាមរយៈពូជពង្សរបស់អ័ប្រាហាំមែន តាមរយៈកូនប្រុសរបស់យ៉ាកុបម្នាក់ឈ្មោះយូដា ។ ដែនដីត្រូវបានចាត់ឲ្យប្រជាជនមួយជាយូរមកហើយ ។ ផែនទីមួយនៅក្នុងកំណែព្រះគម្ពីរប៊ីប អិល.ឌី.អែស. បានបង្ហាញពីរបៀបដែលដែនដីនោះត្រូវបានគ្រងមរតកដោយ



ពូជអម្បូរនានាត្រូវបានបែងចែកនៅក្នុងចំណោមកូនចៅរបស់ រូបេន, ស៊ីម្មាន, យូដា, អ៊ីសាខារ, សាប់យូល៉ូន, ដាន់, ណែបថាលី, កាឌ់, អេស៊ើរ, បេនយ៉ាមីន និង យ៉ូសែប ( បានបែងចែករវាងកូនប្រុសគាត់ អេប្រាអិម និង ម៉ាន៉ាសេ ) ។[14] លើសពីកេរមរតករបស់យ៉ូសែបនៅដែនដីបរិសុទ្ធ យើងក៏រៀនពីព្រះគម្ពីរមរមនថា ដែនដីដែលបានរក្សាទុកសម្រាប់ពូជនៃវង្សយ៉ូសែបគឺជាដែនដីអាមេរិក ។[15]

ការសន្យាដ៏អស្ចារ្យដែលថា ប្រជាជាតិ*ទាំងអស់* នឹងមានពរដោយកូនចៅរបស់អ័ប្រាហាំ, អ៊ីសាក និង យ៉ាកុប មិនទាន់បានបំពេញនៅឡើយទេ ។ ប៉ុន្តែការសន្យានៃការប្រមូលផ្តុំនេះ ដែលបានចារទុកនៅគ្រប់ព្រះគម្ពីរ នឹងត្រូវបានបំពេញយ៉ាងពិតប្រាកដដូចជាការសន្យានៃការការខ្ចាត់ព្រាត់នៃអ៊ីស្រាអែលដែរ ។[16]

## ការប្រមូលផ្តុំជាសេចក្តីផ្តើមមួយចំពោះការការយាងមកជាលើកទីពីរ

ហេតុអ្វីបានជាការសន្យានៃការប្រមូលផ្តុំនេះមានសារៈសំខាន់ម៉្លេះ ? ដោយសារការប្រមូលនៃអ៊ីស្រាអែលគឺជារឿងចាំបាច់ ដើម្បីរៀបចំពិភពលោកនេះសម្រាប់ការយាងមកជាលើកទីពីរ ! ហើយព្រះគម្ពីរមរមនគឺជាឧបករណ៍ដ៏ចាំបាច់របស់ព្រះ ដើម្បីសម្រេចបានគោលបំណងដ៏ទេវភាព*ទាំងពីរ*នេះ ។[17]

ព្រះគម្ពីរមរមនគឺជាអំណោយទានមួយមកពីព្រះសម្រាប់ពិភពលោកទាំងមូល ។ វាគឺជាព្រះគម្ពីរតែមួយគត់ដែលព្រះអម្ចាស់បានថ្លែងទីបន្ទាល់ថា ពិត ។[18] វាជាអំណោយមួយមកពីនីហ្វៃ, យ៉ាកុប, មរមន, មរ៉ូណៃ និង អ្នកបកប្រែដែលបានបំផុសគំនិត ហើយត្រូវបានគេសម្លាប់ គឺព្យាការីយ៉ូសែបស៊្មីធ ។ ព្រះគម្ពីរមរមនបានលើកឡើងជាគោលបំណងយ៉ាងចំទៅកាន់ពូជពង្សនៃវង្សអ៊ីស្រាអែល ។[19]

ស្តីពីការយាងមកជាលើកទីពីរ យើងដឹងថា វា « នៅជិតដៃបង្កើយ និងនៅពេលខាងមុខ » ( គ. និង ស. 63:53 ) ។ ហើយនៅពេលព្រះអង្គសង្គ្រោះយាងមកម្តងទៀត វានឹងមិនស្ថិតនៅក្នុងភាពសម្ងាត់ឡើយ ។[20] ក្នុងពេលដដែលនេះ មានកិច្ចការជាច្រើនដែលត្រូវបានធ្វើឡើង ដើម្បីប្រមូលពង្សអ៊ីស្រាអែល ហើយរៀបចំពិភពលោកសម្រាប់ការយាងមកជាលើកទីពីរដ៏រុងរឿងនោះ ។

## ការប្រមូលផ្តុំនៃអ៊ីស្រាអែលនៅគ្រាកាន់កាប់ត្រួតត្រានេះ

សូមអរគុណចំពោះព្រះគម្ពីរមរមន ដែលជួយឲ្យយើងដឹងពីពេលវេលានៃការប្រមូលផ្តុំដែលបានសន្យានេះនឹងកើតឡើង ៖ « ហេតុដូច្នោះហើយ ឪពុកយើងមិនបាននិយាយអំពីពូជយើងតែប៉ុណ្ណោះទេ តែលោកព្រមទាំងបាននិយាយអំពីវង្សអ៊ីស្រាអែលទាំងអស់ដែរ ដោយចង្អុលដល់សេចក្តីសញ្ញាដែលនឹងត្រូវបានបំពេញ*នៅគ្រាចុងក្រោយ* គឺជាសេចក្តីសញ្ញាដែលព្រះអម្ចាស់ទ្រង់បានធ្វើជាមួយនឹងលោកអ័ប្រាហាំ ជា

*ពួកបរិសុទ្ធនៅគ្រប់ដែនដីមានសិទ្ធិស្មើគ្នាដើម្បីទទួលពរជ័យរបស់ព្រះអម្ចាស់ ។ សុវត្ថិភាពខាងវិញ្ញាណនៃពឹងផ្អែកទៅលើរបៀបដែលយើងរស់នៅជាជាងកន្លែងដែលយើងរស់នៅនោះទេ ។*



*យើងទទួលពរជ័យដ៏ខ្ពស់បំផុតរបស់យើង នៅក្នុងព្រះវិហារបរិសុទ្ធ ដូចដែលបានសន្យាទៅដល់ពូជពង្សរបស់អ័ប្រាហាំ, អ៊ីសាក និង យ៉ាកុប ។*

អយ្យកោរបស់យើងថា ៖ ដោយសារពូជអ្នក នោះគ្រប់ទាំងពូជមនុស្សនៅផែនដីនឹងបានពរ » ( នីហ្វៃទី 1 15:18 ការគូសបញ្ជាក់បានបន្ថែម ) ។

ប្រាំមួយរយឆ្នាំមុនពេលព្រះយេស៊ូវបានប្រសូតមកនៅភូមិបេថ្លេហិម ពួកព្យាការីបានដឹងថា ការប្រមូលផ្ដុំនៃអ៊ីស្រាអែលនេះនឹងកើតមានឡើង « នៅថ្ងៃចុងក្រោយ » ។

ចំពោះពួកបរិសុទ្ធថ្ងៃចុងក្រោយ ឈ្មោះដ៏មានកិត្តិយស *អ័ប្រាហាំ*គឺមានសារៈសំខាន់ ។ សមាជិកសាសនាចក្រម្នាក់ៗមានតំណភ្ជាប់នឹងអ័ប្រាហាំ ។[21] ព្រះអម្ចាស់បានបញ្ជាក់ពីសេចក្ដីសញ្ញារបស់អ័ប្រាហាំនៅជំនាន់របស់យើងតាមរយៈព្យាការីយ៉ូសែប ស្ម៊ីធ ។[22] នៅក្នុងព្រះវិហារបរិសុទ្ធ យើងទទួលពរជ័យដ៏ខ្ពស់បំផុតរបស់យើង ដូចដែលបានសន្យាទៅដល់ពូជពង្សរបស់អ័ប្រាហាំ, អ៊ីសាក និង យ៉ាកុប ។[23]

យើងត្រូវទទួលបាននូវទស្សនៈសួគ៌ានោះ ។ យើងត្រូវដឹងពីសេចក្ដីសញ្ញាអ័ប្រាហាំ ហើយយល់ពីទំនួលខុសត្រូវរបស់យើង នៅក្នុងការជួយធ្វើឲ្យប្រមូលផ្ដុំនៃអ៊ីស្រាអែលដែលបានសន្យានោះកើតមានឡើង ។ យើងត្រូវដឹងពី*ហេតុផល*ដែលយើងមានសិទ្ធិដើម្បីទទួលពររបស់លោកអយ្យកោ ហើយរៀនពីទំនាក់ទំនងរបស់យើងនឹងពួកអយ្យកោពីបុរាណ ។ យើងត្រូវដឹងថា កូនប្រុសរបស់យ៉ាកុបឈ្មោះយ៉ូសែប បានក្លាយទៅជាកូនប្រុសដែលមានអំណាចកូនច្បង បន្ទាប់ពីរូបេនបានបាត់បង់អំណាចនោះ ។[24] យ៉ូសែប និង ពួកកូនប្រុសគាត់ អេប្រាអិម និង ម៉ាន៉ាសេ បានក្លាយជាពូជពង្សដើម្បីដឹកនាំនៅក្នុងការប្រមូលផ្ដុំនៃអ៊ីស្រាអែលនេះ ។[25] ពូជអម្បូរផ្សេងទៀតត្រូវដើរតាម ។

សូមគិតពីទូតសួគ៌ាទាំងនោះដែលបាននាំមកនូវកូនសោនៃបព្វជិតភាពដ៏មានតម្លៃមកកាន់សាសនារបស់ព្រះអម្ចាស់ដែលបានស្ដារឡើងវិញ ។ នៅថ្ងៃទី 3 ខែ មេសា ឆ្នាំ 1836 បន្ទាប់ពីព្រះអម្ចាស់បានទទួលយកព្រះវិហារបរិសុទ្ធខឺតឡង់ ម៉ូសេ ជាអ្នកដែលបានស្ដារ « កូនសោនៃការប្រមូលផ្ដុំនៃអ៊ីស្រាអែល » មកវិញ ( គ. និង ស. 110:11 ) ។ បន្ទាប់មក « លោកអេលីយ៉ាបានលេចមក ហើយបានប្រគល់គ្រាកាន់កាប់ត្រួតត្រានៃដំណឹងល្អរបស់លោកអ័ប្រាហាំដោយប្រាប់ថា នៅក្នុងយើង និងពូជរបស់យើង នោះអស់ទាំងតំណរមនុស្សបន្ទាប់ពីយើងមកនឹងបានពរ » ( គ. និង ស. 110:12 ) ។ ដូច្នេះ សេចក្ដីសញ្ញាអ័ប្រាហាំនេះត្រូវបានរំឭកឡើងវិញជាផ្នែកមួយនៃការស្ដារឡើងវិញ ! បន្ទាប់មកលោកអេលីយ៉ាបានលេចមក បានស្ដារកូនសោនៃសិទ្ធិអំណាចការផ្សារភ្ជាប់ ដូចដែលម៉ាឡាគីបានព្យាករណ៍ ។[26] កូនសោទាំងនោះចាំបាច់ដើម្បីផ្សារភ្ជាប់ក្រុមគ្រួសារនៃវង្សអ៊ីស្រាអែលដែលបានប្រមូលផ្ដុំ ហើយអនុញ្ញាតឲ្យពួកគេរីករាយនូវពរជ័យដ៏ធំបំផុត នោះគឺជីវិតដ៏នៅអស់កល្បជានិច្ច ។

តើអ្វីទៅជាទស្សនៈរបស់ព្រះវរបិតា និង ព្រះរាជបុត្រា

ស្តីពីព្រះគម្ពីរមរមន ? ទ្រង់មើលឃើញព្រះគម្ពីរនេះជាភស្តុតាងនៃការហៅ ជាអ្នកព្យាករណ៍របស់យ៉ូសែប ស៊្មីធ ។ ទ្រង់មើលឃើញព្រះគម្ពីរជាឧបករណ៍ដែលមនុស្សអាចរៀនពីព្រះយេស៊ូវគ្រីស្ទ ជឿលើដំណឹងល្អទ្រង់ ហើយចូលរួមនឹងសាសនាចក្រទ្រង់ បន្ថែមទៀត ។ ទ្រង់មើលឃើញព្រះគម្ពីរនេះជាអត្ថបទដើម្បីគូសបញ្ជាក់ពីទំនាក់ទំនងរបស់យើងនឹងវង្សអ៊ីស្រាអែល ក្នុងព្រះគម្ពីរប៊ីប ។ ព្រះគម្ពីរមរមនប្រកាសពីការចាប់ផ្ដើមនៃការប្រមូលផ្ដុំនេះ[27] ហើយព្រះគម្ពីរនេះគឺជាឧបករណ៍របស់ព្រះ ដើម្បីធ្វើឲ្យការប្រមូលផ្ដុំនេះកើតឡើង ។ បើគ្មានព្រះគម្ពីរមរមន ក៏គ្មានការប្រមូលផ្ដុំនៃអ៊ីស្រាអែលឡើយ ។[28]

ព្រះគម្ពីរមរមនមាននូវភាពពេញលេញនៃដំណឹងល្អ ។ បើគ្មានព្រះគម្ពីរមរមនទេ នោះយើងនឹងបានដឹងស្ដួចស្ដើងណាស់ពីដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ ។[29] ដោយសារព្រះគម្ពីរនេះបង្រៀនពីដង្វាយធួន ព្រះគម្ពីរមរមនជួយយើងឲ្យប្រែចិត្ត ឲ្យធ្វើ ហើយរក្សាសេចក្ដីសញ្ញាពិសិដ្ឋ ហើយឲ្យតម្លៃទៅលើពិធីបរិសុទ្ធនៃសេចក្ដីសង្គ្រោះ និង ភាពតម្កើងឡើង ។ ព្រះគម្ពីរនេះដឹកនាំយើងទៅព្រះវិហារបរិសុទ្ធ ជាទីកន្លែងដែលយើងអាចមានគុណសម្បត្តិគ្រប់គ្រាន់សម្រាប់ជីវិតដ៏នៅអស់កល្បជានិច្ច ។

នៅលើផែនដីនេះ យើងអាចមានទស្សនៈសួគ៌ានេះនៅគ្រប់កិច្ចការដែលយើងធ្វើ ។ ដោយមានទស្សនៈនោះ យើងមើលឃើញថា កិច្ចការផ្សព្វផ្សាយសាសនាគឺជារឿងសំខាន់ចំពោះការប្រមូលផ្ដុំនៃអ៊ីស្រាអែល ។ នៅក្នុងប្រជាជាតិជាច្រើន ពួកអ្នកផ្សព្វផ្សាយសាសនារបស់យើងបានស្វែងរកពួកអ៊ីស្រាអែលទាំងនោះដែលបានខ្ចាត់ព្រាត់ ។

ស៊ីយ៉ូនកើតមាននៅទីកន្លែងណាដែលពួកបរិសុទ្ធសុចរិតប្រមូលផ្ដុំគ្នា ។[30] ការបោះពុម្ព ការទំនាក់ទំនង និង ក្រុមជំនុំទាំងឡាយផ្ដល់សិទ្ធិដល់សមាជិកសាសនាចក្រស្ទើរតែគ្រប់រូប ឲ្យមានសិទ្ធិរៀនពីគោលលទ្ធិ កូនសោ ពិធីបរិសុទ្ធ និង ពរជ័យនៃដំណឹងល្អ មិនថានៅទីណានោះទេ ។ ដើម្បីមានភាពងាយស្រួលដល់ពួកបរិសុទ្ធនៅជុំវិញសាកលលោក ព្រះវិហារបរិសុទ្ធចំនួន 143 កន្លែងត្រូវបានដាក់ឲ្យដំណើរការ ហើយនឹងមានច្រើនទៀត ។[31]

ពួកបរិសុទ្ធនៅគ្រប់ដែនដីមានសិទ្ធិស្មើគ្នា ដើម្បីទទួលពរជ័យរបស់ព្រះអម្ចាស់ ។ សុវត្ថិភាពខាងវិញ្ញាណតែងពឹងផ្អែកទៅលើ*របៀប*ដែលយើងរស់នៅជានិច្ច ពុំមែនជា*ទីកន្លែង*ដែលយើងរស់នៅនោះទេ ។

ការប្រមូលផ្ដុំនៃវង្សអ៊ីស្រាអែល*ពុំមែន*ជាចំណុចបញ្ចប់ទាំងស្រុងនោះទេ ។ វាគ្រាន់តែជាការចាប់ផ្ដើមប៉ុណ្ណោះ ។ ចុងបញ្ចប់ចំពោះអ្វីដែលយើងស៊ូទ្រាំរួមបញ្ចូលទាំងអំណោយទានពិសិដ្ឋ និង ពិធីបរិសុទ្ធនៃការផ្សារភ្ជាប់ក្នុងព្រះវិហារបរិសុទ្ធ ។ វារួមបញ្ចូលទាំងការចូលទៅក្នុងទំនាក់ ទំនងសេចក្ដីសញ្ញារបស់យើងជាមួយនឹងព្រះ ទោះជាតាមពូជពង្ស ឬតាមការចិញ្ចឹមក្ដី ហើយបន្ទាប់មកគឺការរស់នៅជាមួយទ្រង់ និង ក្រុមគ្រួសារយើងជារៀងរហូត ។ នោះគឺជាសិរីល្អរបស់ព្រះ—ជីវិតអស់កល្បជានិច្ចសម្រាប់កូនចៅទ្រង់ ។[32]

ព្រះវរបិតាជាទីស្រឡាញ់នៃយើងដែលទ្រង់គង់នៅស្ថានសួគ៌សព្វព្រះហឫទ័យចង់ឲ្យកូនចៅរបស់ទ្រង់ត្រឡប់ទៅរកទ្រង់វិញ ពុំមែនដោយការបង្ខំនោះទេ ប៉ុន្តែដោយការជ្រើសរើសរបស់បុគ្គលម្នាក់ៗ និង ការរៀបចំផ្ទាល់ខ្លួន ។ ហើយទ្រង់សព្វព្រះហឫទ័យចង់ឲ្យពួកគេបានផ្សារភ្ជាប់ជាក្រុមគ្រួសារអស់កល្បជានិច្ច ។

នោះគឺជាទស្សនៈរបស់ព្រះវរបិតាសួគ៌យើង ។ នោះគឺជាទស្សនៈរបស់បុត្រាដ៏ជាទីស្រលាញ់ ។ ហើយវាក៏អាចជាទស្សនៈរបស់យើងផងដែរ ។ ■

*ដកស្រង់ចេញពីសុន្ទរកថាដែលបានធ្វើឡើងនៅក្នុងសិក្ខាសាលាសម្រាប់ប្រធានបេសកកម្មថ្មី នៅមជ្ឈមណ្ឌលបំពាក់បំប៉នអ្នកផ្សព្វផ្សាយសាសនាប្រូវ៉ូ នៅថ្ងៃទី 26 ខែ មិថុនា ឆ្នាំ 2013 ។*

**កំណត់ចំណាំ**

1. សូមមើល លោកុប្បត្តិ 13:16, 22:17, អ័ប្រាហាំ 3:14 ។
2. សូមមើល លោកុប្បត្តិ 12:1, 7, អ័ប្រាហាំ 2:6 ។
3. សូមមើល អ័ប្រាហាំ 2:9; 11 ។
4. សូមមើល កាឡាទី 3:26–29, អ័ប្រាហាំ 2:10 ។
5. សូមមើល លោកុប្បត្តិ 49:10, 24 ។
6. សូមមើល អេសាយ 11:12, 22:16–18, នីហ្វៃទី 3 15:20–22, អ័ប្រាហាំ 2:10–11 ។
7. សូមមើល នីហ្វៃទី 1 15:18 សូមមើលផងដែរ ទំព័រចំណងជើងនៃព្រះគម្ពីរមរមន ។
8. សូមមើល គោលលទ្ធិ និង សេចក្ដីសញ្ញា 133:8–17 ។
9. សូមមើល លោកុប្បត្តិ 12:2–3, 26:3–4, 35:11–12 សូមមើលផងដែរ ក្បាលជំពូក នីហ្វៃទី 3 21 និង 29 ។
10. សូមមើលផងដែរ អោមណៃ 26, ម៉ូរ៉ូណៃ 10:30, 32, គោលលទ្ធិ និង សេចក្ដីសញ្ញា 20:59 ។
11. សូមមើល គោលលទ្ធិ និង សេចក្ដីសញ្ញា 137:5–8 ។
12. សូមមើល កូរិនថូសទី 1 15:29, ពេត្រុសទី 1 4:6 ។
13. ប៉ុលក៏បានព្យាករណ៍ពីជំនាន់យើងដែរ ៖ « សម្រាប់ការកាន់កាប់ត្រួតត្រាក្នុងកាលដែលពេលពេញកំណត់ [ព្រះអម្ចាស់] នឹងបំព្រួមគ្រប់ទាំងអស់ក្នុងព្រះគ្រីស្ទ ទាំងរបស់នៅស្ថានសួគ៌ និង របស់នៅផែនដីផង » ( អេភេសូរ 1:10 ) ។
14. សូមមើល លោកុប្បត្តិ 35:23–26, 41:50–52 ។ ពូជអម្បូរលេវីបានផ្ដល់ឲ្យពួកសង្ឃក្នុងចំណោមប្រជាជន ហើយត្រូវបានរាប់បញ្ចូលជាពូជអម្បូរមួយ ឬត្រូវបានទទួលមរតកជាពូជអម្បូរមួយ ។ កូនប្រុសពីរនាក់របស់យ៉ូសែប ម៉ាន៉ាសេ និង អេប្រាអិម ត្រូវបានផ្ដល់ឲ្យដែនដីជាមរតក ហើយត្រូវបានរាប់បញ្ចូលក្នុងចំណោមពូជអម្បូរជំនួសឲ្យឪពុករបស់លោក ។ ដូច្នេះ ចំនួនពូជអម្បូរទាំងដប់ពីរត្រូវបានថែរក្សា ។
15. សូមមើល អេធើរ 13:8 សូមមើលផងដែរ លោកុប្បត្តិ 49:22 ។
16. សូមមើល លេវីវិន័យ 26:44, ចោទិយកថា 4:27–31, 28, 29, 30:1–10, នេហេមា 1:9, អេសាយ 11:11–12, យេរេមា 31:7–12, អេសេគាល 37:21–22, អេម៉ុស 9:14–15, ម៉ាថាយ 24:31, យ៉ាកុប 6:2 ។ សូមមើលផងដែរ រ័សុល អិម ណិលសុន « The Exodus Repeated » *Ensign* ខែ កក្កដា ឆ្នាំ 1999 ឆ្នាំ 6–13 ។ ការប្រមូលផ្ដុំនៃអ៊ីស្រាអែលគឺជាការទស្សន៍ទាយយ៉ាងជាក់លាក់នៅក្នុង អេសាយ 49–51 និង យ៉ាកុប 5 ។
17. សូមមើល ម៉ាថាយ 24:14 គោលលទ្ធិ និង សេចក្ដីសញ្ញា 133:17 ។
18. សូមមើល គោលលទ្ធិ និងសេចក្ដីសញ្ញា 17:6 ។
19. សូមមើល មរមន 7:10, 9:37, ម៉ូរ៉ូណៃ 10:31–34 ។
20. សូមមើល អេសាយ 40:5 ។
21. សេចក្ដីសញ្ញាក៏អាចត្រូវបានទទួលដោយការចិញ្ចឹមផងដែរ ( សូមមើល ម៉ាថាយ 3:9, លូកា 3:8, កាឡាទី 4:5–7 ) ។
22. សូមមើល គោលលទ្ធិ និង សេចក្ដីសញ្ញា 124:58, 132:31–32 ។
23. សូមមើល គោលលទ្ធិ និង សេចក្ដីសញ្ញា 84:33–40, 132:19, អ័ប្រាហាំ 2:11 ។
24. សូមមើល របាក្សត្រទី 1 5:1 ។
25. អេប្រាអិមត្រូវបានផ្ដល់ឲ្យនូវអំណាចរបស់កូនច្បងក្នុងអ៊ីស្រាអែល ដើម្បីនាំយកសារលិខិតនៃការស្ដារឡើងវិញទៅគ្រប់ប្រជាជាតិ និង ដើម្បីដឹកនាំការប្រមូលផ្ដុំនៃអ៊ីស្រាអែលដែលបានខ្ចាត់ព្រាត់ ( សូមមើល យេរេមា 31:7–9, គោលលទ្ធិ និង សេចក្ដីសញ្ញា 64:36, 133:32–34 ) ។
26. សូមមើល គោលលទ្ធិ និង សេចក្ដីសញ្ញា 110:13–16 សូមមើលផងដែរ ម៉ាឡាគី 4:5–6 ។
27. គោលលទ្ធិដែលទាក់ទងនឹងការខ្ចាត់ព្រាត់ និង ការប្រមូលផ្ដុំនៃវង្សអ៊ីស្រាអែលគឺនៅក្នុងចំណោមមេរៀនដំបូងបង្អស់ ដែលបានបង្រៀននៅក្នុងព្រះគម្ពីរមរមន ( សូមមើល នីហ្វៃទី 1 10:14 ) ។
28. សូមមើល ប្រ៊ូស អ័រ ម៉ាក់ខន់ឃី *A New Witness for the Articles of Faith* ( ឆ្នាំ 1985 ) ទំព័រ 554 ។
29. ពាក្យ*ដង្វាយធួន*នៅគ្រប់រូបភាពរបស់វា វាលេចឡើងតែនៅក្នុងបទគម្ពីរមួយក្នុងព្រះគម្ពីរសញ្ញាថ្មីនៃកំណែរបស់ស្ដេចជេមស៍ប៉ុណ្ណោះ ( សូមមើល រ៉ូម 5:11 ) ។ វាមាន 24 បទគម្ពីរនៅក្នុងព្រះគម្ពីរមរមន ។
30. សូមមើល គោលលទ្ធិ និងសេចក្ដីសញ្ញា 97:21 ។
31. គិតត្រឹមខែ ឧសភា ឆ្នាំ 2014 ។
32. សូមមើល ម៉ូសេ 1:39 ។



# ចូរធ្វើដូចជា
# អាំម៉ូន

*វិរបុរសនេះនៅក្នុងព្រះគម្ពីរមរមនអាចបង្រៀនយើងយ៉ាងច្រើន ពីកិច្ចការផ្សព្វផ្សាយសាសនា និងការធ្វើឲ្យសកម្ម នៅសព្វថ្ងៃនេះ ។*



អាំម៉ូនជាវិរបុរសម្នាក់នៅក្នុងព្រះគម្ពីរមរមន ដែលត្រូវបានគេស្គាល់ដោយការបម្រើដ៏ក្លាហានរបស់លោក ដែលរួមបញ្ចូល ការការពារហ្វូងចៀមរបស់ឡាម៉ូណៃ ជាស្តេចសាសន៍លេមិនផងដែរ ( សូមមើល អាល់ម៉ា 17:25–39, 18:1–10 ) ។ ដំណើររឿងរបស់អាំម៉ូន ដូចជាដំណើររឿងព្រះគម្ពីរជាច្រើនផ្សេងទៀត នៅក្នុងព្រះគម្ពីរមរមនផងដែរ វាអាចបង្រៀនយើងយ៉ាងច្រើនពីរបៀប ដើម្បីឱបក្រសោបឱកាស ហើយយកឈ្នះលើឧបសគ្គដែលយើងជួបនៅសព្វថ្ងៃនេះ ។

**បេសកកម្មមួយដ៏មានអត្ថន័យ**

ស៊ូសិន អ៊ី តាវ៉ាសេវិច នៅមិលវាល ញ៉ូជើស៊ី ស.រ.អា. បានរៀនមេរៀនមួយចំនួនពីអាំម៉ូន ខណៈពេលកំពុងបម្រើបេសកកម្មពេញម៉ោងជាមួយនឹងស្វាមីរបស់គាត់ អាដ័ម្ស ។

គាត់បាននិយាយថា « នៅពេលស្រោមសំបុត្រធំពណ៌សដែលមានការហៅបម្រើបេសកកម្មរបស់យើង បានមកដល់ក្នុងប្រអប់សំបុត្ររបស់យើង ស្វាមីខ្ញុំ និងខ្ញុំមានចិត្តរំភើបយ៉ាងខ្លាំង ។ យើងបានតមអាហារ ហើយបានអធិស្ឋានពីការហៅរបស់យើង ។ ពុំមែនដោយសារយើងខ្វល់ខ្វាយពី*ទីកន្លែង*នៃចំណាត់ការនោះទេ ប៉ុន្តែយើងប្រាថ្នាចង់បានដ៏ជ្រាលជ្រៅនៃការបញ្ជាក់មួយថា យើងនឹងមានសមត្ថភាពដើម្បីបំពេញការហៅរបស់យើងប្រកបដោយភាពជោគជ័យ ។

« ក្រោយមកទៀតនៅល្ងាចនោះ ដោយមានកូនចៅរបស់យើងបានមកជួបជុំគ្នា យើងបានបើកស្រោមសំបុត្រនោះ ហើយអានការហៅរបស់យើងដែលត្រូវទៅបម្រើ បេសកកម្មនៅ វ៉ិរស្ស៉ រ ប៉ូឡូញ ។ នៅពេលយើងធ្វើដូច្នេះ យើងបានទទួលអារម្មណ៍សុខសាន្តក្នុងចិត្តថា ចំណាត់ការនេះពិតជាការចាត់តាំងមួយសម្រាប់យើងមែន ។ យើងទាំងពីរនាក់មានចិត្តរំភើបជាខ្លាំង » ។

ប៉ុន្តែ លុះមកដល់បេសកកម្ម ស៊ិស្ទើរ តាវ៉ាសេវិច បានរកឃើញថា គាត់ពិបាកនឹងយល់ថា តើអ្វីទៅ ដែលគាត់អាចជួយបាន ។ គាត់បាននិយាយថា « ស្វាមីខ្ញុំបានទទួលកាតព្វកិច្ចភ្លាមៗ ជាមួយនឹង ឱកាសភាពជាអ្នកដឹកនាំដែលជួយឲ្យគាត់រីកចម្រើន » ។ « ទោះជាក្នុងចំណោមយើងទាំងពីរនាក់គ្មាននរណាម្នាក់ចេះភាសាប៉ូឡូញក្តី ប៉ុន្តែការបម្រើរបស់គាត់ហាក់ដូចជាទទួលបានជោគជ័យថ្វីបើមានការពិបាកខាងភាសាក្តី » ។ ម៉្យាងវិញទៀត គាត់បាននិយាយថា « ជារឿយ ៗ ខ្ញុំមានការពិបាកជាមួយនឹងអារម្មណ៍ថាខ្លួនឯងឥតប្រយោជន៍ហើយឯកា ។ ខ្ញុំបានសង្ស័យពីសារៈសំខាន់នៃកិច្ចការផ្សព្វផ្សាយសាសនារបស់ខ្ញុំ » ។

**ពួកអ្នកផ្សព្វផ្សាយសាសនាដ៏អង់អាច**

ស៊ិស្ទើរ តាវ៉ាសេវិច បានសញ្ជឹងគិតពីពួកអ្នកផ្សព្វផ្សាយសាសនាដ៏អស្ចារ្យនៅក្នុងព្រះគម្ពីរមរមន ។ « ក្នុងនាមជាគ្រូបង្រៀនថ្នាក់កុមារអស់រយៈពេលជាច្រើនឆ្នាំ ជារឿយៗខ្ញុំទទួលបានឥទ្ធិពលដ៏បំផុសគំនិត ហើយលើកទឹកចិត្តពីដំណើររឿងរបស់អាលម៉ា និងបុត្រារបស់ម៉ូសាយនៅក្នុងការបង្រៀនដល់កុមារពីកិច្ចការផ្សព្វផ្សាយសាសនា ។ នៅពេលណាដែលខ្ញុំគិតពីពួកអ្នកផ្សព្វផ្សាយសាសនា រូបភាពដ៏មាំមួន ហើយមានអំណាចរបស់អាំម៉ូនបានផុសឡើងក្នុងគំនិតខ្ញុំ ហើយខ្ញុំអាចស្រមើស្រមៃឃើញយ៉ាងងាយ ពីពួកអ្នកផ្សព្វផ្សាយសាសនាវ័យក្មេងដ៏អង់អាច ក្នុងបេសកកម្មរបស់យើងថា ជាបុត្រារបស់ម៉ូសាយនាសម័យទំនើប ។ ប៉ុន្តែ

រូបភាពគំនូរដោយ ដេន ប៊ឺ



### ស្វែងរកអ្នកដែលបាត់

« វាជាការសំខាន់ដែលយើងម្នាក់ៗត្រូវសញ្ជឹងគិតថា តើអារម្មណ៍វង្វេងនោះមានសភាពបែបណា ហើយថា តើមានវាមានអត្ថន័យយ៉ាងណាដើម្បីធ្វើជាអ្នកគង្វាលចៀម ‹ ខាងវិញ្ញាណ › ដែលនឹងទុកចៀម 99 ហើយទៅស្វែងរកចៀមមួយដែលបាត់នោះ ។ ពួកអ្នកគង្វាលចៀមបែបនោះអាចត្រូវការជំនាញ និងជំនួយពីក្រុមស្វែងរក ហើយសង្គ្រោះ ប៉ុន្តែពួកគាត់មានវត្តមាន ទទួលខុសត្រូវ ហើយឡើងនៅក្បែរអ្នកទាំងនោះ ដើម្បីសង្គ្រោះជនដែលមានតម្លៃដ៏ពិតប្រាកដនៅក្នុងព្រះនេត្រនៃព្រះ ត្បិតពួកគេជាកូនចៅរបស់ទ្រង់ » ។

**អែលឌើរ អិល ថម ភែរីនៃកូរ៉ុមនៃសាវកដប់ពីរនាក់ « Bring Souls unto Me » *លីអាហូណា* ខែ ឧសភា ឆ្នាំ 2009 ទំព័រ 112 ។**

ខ្ញុំបានគិតថា វាបានបង្ហាញពីការខ្វះនូវសេចក្ដីរាបសាសម្រាប់យាយសក់សម្នាក់ដូចជាខ្ញុំដើម្បីធ្វើកិច្ចការបែបនេះ » ។

គាត់បាននិយាយថា កាលដែលគាត់កំពុងគិត នោះមានសម្លេងនៅក្នុងចិត្តមួយបានផ្ដើមសួរគាត់ដោយទន់ភ្លន់ ។

« តើអ្វីទៅជាការចាត់តាំងដំបូងគេរបស់អាំម៉ូន ? »

គាត់បានតបថា « ធ្វើជាអ្នកបម្រើម្នាក់ គឺត្រូវមើលថែហ្វូងចៀម ហើយប្រមូលចៀមដែលវង្វេងបាត់ » ។

« អញ្ចឹង ចូរធ្វើដូចជាអាំម៉ូនចុះ » ។

## បានរៀបចំខ្លួនដើម្បីបម្រើ

គំនិតទាំងនេះបានផ្ដល់ការយល់ដឹងដល់ស៊ិស្ទើរតារ៉ាសេវិច ។ គាត់បាននិយាយថា « រំពេចនោះ ខ្ញុំបានយល់យ៉ាងពិតប្រាកដពីលក្ខណៈពិតនៃកិច្ចការរបស់ខ្ញុំ » ។ « ខ្ញុំបានដឹងថា ខណៈដែលខ្ញុំពុំទាន់ចេះស្ទាត់ខាងភាសាដែលចាំបាច់សម្រាប់ការផ្សព្វផ្សាយក៏ដោយ បទពិសោធន៍ជាច្រើនឆ្នាំក្នុងសមាគមសង្គ្រោះបានរៀបចំខ្ញុំឲ្យបម្រើដល់អ្នកដទៃ—ដើម្បីស្រាវជ្រាវ ស្វែងរក ហើយស្រឡាញ់ដល់ជនដែលមានអារម្មណ៍ថាត្រូវបានគេបំភ្លេចចោល ហើយឯកា » ។

គាត់បានចាប់ផ្ដើមមើលការងារផ្សព្វផ្សាយសាសនារបស់គាត់តាមរយៈទស្សនវិស័យថ្មី ។ គាត់បាននិយាយថា « ខ្ញុំបានដឹងនូវរបៀបជាច្រើនដែលគោលការណ៍ផ្ដោតសំខាន់លើព្រះគ្រីស្ទអាចយកឈ្នះលើការខ្វះខាតខាងភាសាបាន » ។ « ខ្ញុំបានចាប់ផ្ដើមមើលឃើញពីអ្វីដែលខ្ញុំអាចធ្វើ ដើម្បីមើលថែហ្វូងសត្វ ហើយប្រមូលចៀមដែលវង្វេងបាត់ » ។

ក្រោយមក គាត់បាននិយាយថា « ជីវិតជាអ្នកផ្សព្វផ្សាយសាសនាវ័យចំណាស់ម្នាក់បានក្លាយជា ពេលវេលានៃការរៀនសូត្រ និង ការបម្រើមួយដ៏អស្ចារ្យ ពេលយើងមាននូវអភ័យឯកសិទ្ធិ ដើម្បីមើលឃើញដំណឹងល្អ ផ្លាស់ប្ដូរ ហើយធ្វើឲ្យជីវិតជនដែលព្រមទទួលដំណឹងល្អបានប្រសើរឡើង » ។ ជារឿយៗ គាត់មានអារម្មណ៍ចង់ច្រៀងចម្រៀងដែលគាត់បានហៅថាជាទំនុកតម្កើងរបស់អាំម៉ូន ៖ « មើលចុះ សេចក្ដីអំណររបស់ខ្ញុំបានពោរពេញហើយ មែនហើយ បេះដូងខ្ញុំហូរហៀរទៅដោយសេចក្ដីអំណរ ហើយខ្ញុំនឹងអររីករាយនៅក្នុងព្រះរបស់ខ្ញុំវិញ » ( អាលម៉ា 26:11 ) ។

## ការសង្គ្រោះដល់កូនចៀម

ផេហ្គី វ៉លឡេស ផូល នៅរីប៊ីខាងត្បូង រដ្ឋយូថាហ៍ បានទទួលចំណេះដឹងរបស់នាងពីអាំម៉ូន នៅពេលគាត់បានចាត់ឲ្យ

*ការចិញ្ចឹមបីបាច់មនុស្សគ្រប់រូបដោយសេចក្ដីស្រឡាញ់គឺជារបៀបមួយដ៏អស្ចារ្យ ដើម្បីធ្វើតាមគំរូរបស់អាំម៉ូន ។*



ទៅបង្រៀនពីការសង្គ្រោះ និងការធ្វើឲ្យសកម្មឡើងវិញ ក្នុងការប្រជុំបំពាក់បំប៉នភាពជាអ្នកដឹកនាំបព្វជិតភាព និងអង្គការជំនួយប្រចាំស្ដេកមួយ ។

គាត់បាននិយាយថា « ការអានរឿងសដៀងគ្នារបស់អាំម៉ូន ខ្ញុំបានកត់សម្គាល់ឃើញអ្វីមួយថ្មី » ។ « សូមចាំថា អាំម៉ូនកំពុងបម្រើបេសកកម្មនៅក្នុងចំណោមសាសន៍លេមិន ។ គាត់បានទទួលការងារមួយដើម្បីថែទាំ ចៀមរបស់ស្ដេច ។ មានពួកអ្នកបម្រើផ្សេងទៀតនៅជាមួយនឹងលោកដែរ ហើយនៅពេលពួកគេបាននាំចៀមទៅផឹកទឹកនៅឯសីប៊ុស នោះមានពួកចោរបានដេញបង្អើលហ្វូងចៀមនោះ ។ ហេតុការណ៍នេះបានធ្វើឲ្យពួកអ្នកបម្រើផ្សេងទៀតមានការភិតភ័យជាខ្លាំង ។ តាមពិតទៅ អ្នកផ្សេងដែលបណ្ដាយឲ្យចៀមបាត់ ត្រូវមានទោសដល់ស្លាប់ ហើយឥឡូវនេះពួកគេនឹងទទួលជោគវាសនាដូចគ្នានោះយ៉ាងពិតប្រាកដ ។ ( សូមមើល អាលម៉ា 17:25 30 ) ។

ស៊ិស្ទើរ ផូល បាននិយាយថា « ប៉ុន្តែ អាំម៉ូនបានឃើញឱកាសមួយ » ។ « លោកបានប្រាប់ទៅពួកអ្នកបម្រើផ្សេងទៀតកុំឲ្យភ័យអី ដោយសារលោកមានផែនការមួយ ។ សូមអាន អាលម៉ា 17:31–33 ហើយអ្នកនឹងឃើញផែនការនោះស្តែងចេញយ៉ាងច្បាស់ ៖

1. ដឹងកាន់តែឆាប់កាន់តែល្អថា ចៀមកំពុងតែបាត់ ។
2. ‹ បានរត់ទៅយ៉ាង [ លឿន ] › ។
3. ប្រមូលហ្វូងចៀមមកវិញ ។
4. នាំចៀមត្រឡប់មកកាន់ក្រោលចៀមវិញដោយសុវត្ថិភាព ។
5. ទ័ព្ធវា រក្សាវាឲ្យមានសុវត្ថិភាព ហើយមើលថែវាដោយសេចក្ដីស្រឡាញ់ » ។

ស៊ិស្ទើរ ផូល និយាយថា គាត់មានចំណាប់អារម្មណ៍នឹងរបៀបដែលដំណើររឿងនេះអាចអនុវត្តចំពោះការធ្វើឲ្យសកម្មឡើងវិញ ៖ « វាអាចធ្វើទៅបានដោយមើលពីដំណើររឿងរបស់អាំម៉ូនជានិមិត្តរូបនៃពួកអ្នកដឹកនាំសាសនាចក្រសព្វថ្ងៃ ដោយសង្គ្រោះសមាជិកដែលវង្វេង ។ នៅក្នុងពិភពលោកនេះមាននូវឥទ្ធិពលជាច្រើនដូចជាពួកចោរទាំងនោះដែរ ដែលវាអាចដឹកនាំសមាជិកឲ្យឃ្លាតឆ្ងាយពីព្រះបន្ទូលល្អនៅក្នុងដំណឹងល្អ ។ យើងត្រូវតែប្រុងប្រយ័ត្ន ហើយផ្លាស់ទីឲ្យបានឆាប់ នៅពេលព្រលឹងដ៏មានតម្លៃមួយរបស់ទ្រង់បានបាត់ចេញពីហ្វូង » ។

គាត់បានដកស្រង់ប្រសាសន៍របស់ប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី ( ឆ្នាំ 1910–2008 ) ដែលលោកបានលើកឡើងថា « ខ្ញុំសង្ឃឹម ហើយអធិស្ឋានថា យើងម្នាក់ៗ . . . នឹងមានដំណោះស្រាយដើម្បីស្វែងរកជនដែលត្រូវការជំនួយ ជនដែលឯកោ ហើយស្ថិតនៅក្នុងស្ថានភាពដ៏លំបាក ហើយលើកពួកគេឡើងនៅក្នុងវិញ្ញាណនៃសេចក្ដីស្រឡាញ់ ចូលទៅក្នុងការឱបក្រសោបនៃសាសនាចក្រជាទីកន្លែងដែលមានដៃដ៏រឹងមាំ និងចិត្តដែលពេញដោយក្ដីស្រឡាញ់នឹងធ្វើឲ្យពួកគេមានភាពកក់ក្ដៅ លួងលោមពួកគេ គាំទ្រពួកគេ ហើយដាក់ពួកគេនៅលើផ្លូវនៃជីវិតរីករាយ ហើយមានន័យ » ។[1] ■

**កំណត់ចំណាំ**

1. ហ្គរដុន ប៊ី ហ៊ិងគ្លី « Reach with a Rescuing Hand » *Ensign* ខែ វិច្ឆិកា ឆ្នាំ 1996 ទំព័រ 86 ។



## អាមូលេកអាចបង្រៀនយើងផងដែរ

អាមូលេកគឺជាវិរបុរសដ៏អស្ចារ្យម្នាក់ទៀតនៅក្នុងព្រះគម្ពីរមរមន ។ លោកបង្ហាញពីអ្វីដែលមនុស្សអាចប្រែក្លាយបាន នៅពេលពួកគេត្រឡប់មករកផ្លូវសុចរិតវិញ ។

ដោយមានទ្រព្យសម្បត្តិច្រើន ហើយមានកេរ្ដិ៍ឈ្មោះល្បី អាមូលេកបានទទួលស្គាល់ថាលោកបានឃើញពីអាថ៌កំបាំង និងព្រះចេស្ដានៃព្រះ ប៉ុន្តែលោកបានធ្វើចិត្តរឹងរូស ។ លោកមានប្រសាសន៍ថា « ខ្ញុំត្រូវបានហៅជាច្រើនដង តែខ្ញុំធ្វើជាមិនឮ ហេតុដូច្នេះហើយ ខ្ញុំបានដឹងអំពីការណ៍ទាំងនេះ តែខ្ញុំធ្វើជាមិនដឹង » ( អាលម៉ា 10:6; សូមមើលផងដែរខទី 4–5 ) ។

ប៉ុន្តែព្រះអម្ចាស់បានបញ្ជូនទេវតាមួយអង្គទៅប្រាប់អាមូលេកឲ្យទទួលអាលម៉ា ជាព្យាការីចូលក្នុងផ្ទះរបស់លោក ។ អាមូលេកបានរៀបអាហារសម្រាប់អាលម៉ា ហើយអាលម៉ាបានប្រទានពរ ហើយបង្រៀនអាមូលេក និងគ្រួសាររបស់លោក ។ ក្រោយមកអាមូលេកបានចូលរួមនឹងអាលម៉ាក្នុងការបម្រើ ដោយប្រែក្លាយជាសាក្សីទីពីរដ៏មានឥទ្ធិពលពីសេចក្ដីពិតនៃដំណឹងល្អ ។ ( សូមមើល អាលម៉ា 10:7–12 ) ។

អាមូលេកបានក្លាយជាដៃគូរបស់អាលម៉ាក្នុងការហៅប្រជាជនឲ្យប្រែចិត្ត ហើយលោកបានផ្សាយដំណឹងល្អដោយកម្លាំងរឹងមាំ និងសិទ្ធិអំណាចរហូតដល់ប្រជាជនទាំងនោះមានការភ្ញាក់ផ្អើល ( សូមមើលអាលម៉ា 11:46 ) ។ នៅពេលត្រូវបានគេចាប់ចងដាក់ទៅក្នុងគុក អាលម៉ា និង អាមូលេកបានរួចខ្លួនវិញដោយអព្ភូតហេតុ ហើយបានស្ថាបនាសាសនាចក្រនៅដែនដីសែដុម រួចហើយបានបង្រៀនដំណឹងល្អនៅពាសពេញដែនដីនោះ ( សូមមើល អាលម៉ា 14, 15, 31 ) ។

ដូចជាអាមូលេកដែរ មានមនុស្សជាច្រើននៅក្នុងសាសនាចក្រសព្វថ្ងៃនេះដែលនឹងរកឃើញថា ព្រះអម្ចាស់នឹងប្រទានពរដល់ពួកគេ ហើយថាពួកគេអាចក្លាយជាសាក្សីនៃសេចក្ដីពិតដ៏មានឥទ្ធិពល នៅពេលពួកគេវិលត្រឡប់មកសកម្មវិញ ។

# សេចក្ដីណែនាំទាំងដប់សម្រាប់ឪពុកម្ដាយនៃពួកមជ្ឈិមវ័យវ័យក្មេង

**ដោយ វេនឌី អ៊ុលរីឆ**
គ្រូពេទ្យផ្នែកចិត្តសាស្ត្រ

នៅពេលស្វាមីខ្ញុំ និង ខ្ញុំបានជួយកូនយើងឲ្យផ្លាស់ទៅស្នាក់នៅឯមហាវិទ្យាល័យ ឬចូលទៅមជ្ឈមណ្ឌលបំពាក់បំប៉នអ្នកផ្សព្វផ្សាយសាសនា យើងបានទទួលអារម្មណ៍លាយលំគ្នាមួយនៃភាពសោកសៅ និង ភាពធូរស្រាលក្នុងចិត្ត ដោយគិតថា នៅទីបំផុតកិច្ចការរវាងពួកគេ—និងយើង—បាន « បញ្ចប់ » ។ ប៉ុន្តែមិនយូរប៉ុន្មានយើងបានដឹងថា រួមជាមួយនឹងការកើននូវសមត្ថភាព និង សេរីភាពថ្មី កូនចៅយើងនឹងត្រូវប្រឈមមុខនឹងឧបសគ្គបន្ថែមទៀត ។ ខណៈដែលការគ្រប់គ្រងរបស់យើងទៅលើជីវិតរបស់ពួកគេបានបញ្ចប់ទៅ សេចក្ដីត្រូវការរបស់ពួកគេសម្រាប់ការគាំទ្រ—ជាការគាំទ្រមួយប្រភេទទៀត—ពិតជាមានការកើនឡើង ។



## ឧបសគ្គនៅសព្វថ្ងៃនេះ

នេះជាឧបសគ្គមួយចំនួនដែលពួកមជ្ឈិមវ័យវ័យក្មេងប្រឈមមុខនៅក្នុងពិភពលោកសព្វថ្ងៃ រួមជាមួយនឹងសំណួរដែលឧបសគ្គទាំងនោះបង្កើតឡើងសម្រាប់ឪពុកម្ដាយផងដែរ ។





**ជីវិតនៅលីវដ៏យូរ ។** និន្នាការរបស់សង្គមស្ដីពីការចាប់ផ្ដើមក្រុមគ្រួសារនៅពេលមានវ័យចំណាស់ អាចទុកឲ្យពួកមជ្ឈិមវ័យវ័យក្មេងមួយចំនួននូវអារម្មណ៍ដូចជាពួកគេនៅក្មេងជារៀងរហូត ។ មានអ្នកផ្សេងទៀតមានកង្វល់ជាខ្លាំង ដោយងឿងឆ្ងល់ថា តើពួកគេនឹងរៀបការ ឬ មានកូនដែរឬទេ ។ ក្នុងនាមជាឪពុកម្ដាយ តើយើងអាចជួយពួកគេឲ្យមានទស្សនៈអស់កល្បជានិច្ចមួយបានដោយរបៀបណា ?

**ភាពមិនប្រាកដប្រជាខាងហិរញ្ញវត្ថុ ។** ពួកមជ្ឈិមវ័យវ័យក្មេងជាច្រើនសព្វថ្ងៃនេះ អាចនឹងគ្មាននូវទ្រព្យសម្បត្តិដូចជាឪពុកម្ដាយរបស់ពួកគេឡើយ ។ ពួកគេអាចរកឃើញថា មានការលំបាកក្នុងការរកការងារធ្វើ—សូម្បីតែការបញ្ចប់ការសិក្សានៅមហាវិទ្យាល័យ—ឬការផ្គត់ផ្គង់ដល់គ្រួសារ ។ ក្នុងនាមជាឪពុកម្ដាយ តើយើងគួរជួយគេខាងផ្នែកហិរញ្ញវត្ថុ ឬតើយើងគួរសន្មតថាកូនចៅរបស់យើងនឹងរីកចម្រើនពីការដោះស្រាយបញ្ហាខាងហិរញ្ញវត្ថុរបស់ពួកគេដោយរបៀបណា ?



*ថ្វីបើមានឧបសគ្គជាច្រើននៅក្នុងពិភពលោកសព្វថ្ងៃនេះក្តី ឪពុកម្តាយអាចបន្តប្រទានពរដល់កូនចៅរបស់ខ្លួនដែលជាមជ្ឈិមវ័យវ័យ ក្មេងបានដែរ ដោយការផ្តល់ការគាំទ្រ និង ការណែនាំដោយសុចរិត ។*



**ជម្រើសដ៏លើសលប់ ។** ពួកមជ្ឈិមវ័យវ័យក្មេងសព្វថ្ងៃអាចមានជម្រើសការងារច្រើនប្រភេទជាងមុន ។ ប៉ុន្តែពេលខ្លះរាល់ជម្រើសទាំងអស់នោះ គឺហាក់ដូចជាលើសលប់ពេក ។ តើឪពុកម្តាយអាចជួយកូនចៅដែលជាពួកមជ្ឈិមវ័យវ័យក្មេងឲ្យរកជម្រើសនានា ប៉ុន្តែក៏ត្រូវសម្រេចចិត្តចំពោះការងារមួយដែលពេញចិត្តផងដែរបែបណាទៅ ?

**ការរស់ជាមួយឪពុកម្តាយ ។** មិនថាពួកគេរៀបការ ឬនៅលីវនោះទេ ចំនួននៃពួកមជ្ឈិមវ័យវ័យក្មេងដែលមានអាយុចន្លោះពី 18 ដល់ 34 ដែលកំពុងរស់នៅជាមួយនឹងឪពុកម្តាយមានការកើនឡើង ។ នៅពេលកូនចៅដែលជាមនុស្សពេញវ័យរស់នៅជាមួយនឹងឪពុកម្តាយរបស់ខ្លួន តើឪពុកម្តាយគួរតែសម្របសម្រួលបញ្ហានានាឲ្យបានត្រឹមត្រូវដោយរបៀបណា ដូចជាតើនរណាបង់ថ្លៃសម្រាប់អាហារ និង ការលុតដំចៅដោយរបៀបណាជាដើម ?





**សកម្មភាពខាងសាសនា ។** សព្វថ្ងៃនេះ ពួកមជ្ឈិមវ័យវ័យក្មេងនៅគ្រប់ជំនឿសាសនា ទំនងដូចជាមិនសូវចង់សកម្មនៅក្នុងព្រះវិហារ ដូចកាលជំនាន់មុនឡើយ ។ តើយើងជាឪពុកម្តាយអាចលើកទឹកចិត្តឲ្យកូនចៅយើងដែលជាមនុស្សពេញវ័យ បន្តសកម្មនៅក្នុងសាសនាចក្រតាមរបៀបណា ? តើយើងអាចជួយពួកគេខាងវិញ្ញាណតាមរបៀបណា ទោះជាពួកគេមិនជ្រើសធ្វើជាសមាជិកសកម្មនៅក្នុងសាសនាចក្រក្តី ?



# សេចក្ដីណែនាំសម្រាប់ឪពុកម្ដាយ

ទោះជាកូនចៅយើងដែលជាមនុស្សពេញវ័យអាចមានសមត្ថភាព ឬជោគជ័យច្រើនជាងយើងក្ដី ពួកគេនៅតែត្រូវការ ហើយសក្ដិសមនឹងទទួលការគាំទ្រពីឪពុកម្ដាយដើម្បីមានជីវិតមួយដ៏ជោគជ័យ ។ ខាងក្រោមនេះជាសេចក្ដីណែនាំទាំងដប់ដែលគួរពិចារណា ។

**1. ស្វែងរកអ្វីដែលកូនចៅរបស់អ្នកចង់បាន ហើយស្រឡាញ់ ។** ជាជាងការប្រាប់ដល់កូនចៅរបស់អ្នកដែលជាមជ្ឈិមវ័យវ័យក្មេងពីរបៀបទទួលបានអ្វីដែល*អ្នក*ចង់ឲ្យ ពួកគេមានបាន សូមគិតពិចារណាអំពីគុណតម្លៃ គោលដៅ និង ក្ដីស្រមៃ*របស់ពួកគេ* ។ ពួកគេអាចនឹងសុំឲ្យអ្នកជួយពួកគេដាក់ផែនការដើម្បីសម្រេចគោលដៅនោះ ។ ប្រសិនបើពួកគេសុំ ចូរឲ្យក្ដីស្រមៃ*របស់ពួកគេ*ដឹកនាំការសន្ទនារបស់អ្នក ។ សូមពិភាក្សាទាំងកត្តាវិជ្ជមាន និង អវិជ្ជមាន អធិស្ឋានសម្រាប់ការដឹកនាំ និង បន្តពិភាក្សា ។ ប្រសិនបើពួកគេមិនដឹងថា ពួកគេចង់បានអ្វីនោះទេ សូមលើកទឹកចិត្តពួកគេ ឲ្យជួបនឹងអ្នកប្រឹក្សាយោបល់ ធ្វើការសាកល្បងដើម្បីឲ្យពួកគេដឹងថាពួកគេចូលចិត្តការងារអ្វី ឬទទួលបទពិសោធន៍ច្រើនតាមរយៈការងារ និង ការស្ម័គ្រចិត្ត ។

**2. សូមសិក្សាគោលលទ្ធិ និង សេចក្ដីសញ្ញា 121:34–46 ប្រកបដោយការអធិស្ឋាន ។** បទគម្ពីរទាំងនេះពិតជាសំខាន់ណាស់ចំពោះឪពុកម្ដាយ ។ វាបង្រៀនពីគោលការណ៍ត្រឹមត្រូវស្ដីពីរបៀប ដើម្បីផ្ដល់ការដឹកនាំដ៏សុចរិតទៅកូនចៅរបស់អ្នកដែលជាមនុស្សពេញវ័យ ។

**3. ពង្រឹងទំនាក់ទំនងជាមួយនឹងពួកមជ្ឈិមវ័យវ័យក្មេងឲ្យបានច្រើន ។** អ្នកអាចនឹងរកឃើញថា កូនចៅរបស់អ្នកដទៃទៀតក៏មានចំណាប់អារម្មណ៍នឹងរបៀបដែលអ្នកបានរស់នៅយ៉ាងជោគជ័យក្នុងវ័យ 20 ឆ្នាំ និង 30 ឆ្នាំរបស់អ្នកផងដែរ ។ ពួកមជ្ឈិមវ័យវ័យក្មេងចង់ដឹងពីរបៀបដែលមនុស្សវ័យចំណាស់ធ្វើឲ្យមានតុល្យភាពក្នុងអាទិភាពសំខាន់នានា ក្នុងជីវិតរបស់ពួកគេ ឬដឹងពីពេលដែលពួកគេបានជួបនឹងស្វាមី ឬភរិយារបស់ពួកគេ ។ នៅពេលអ្នកមានទំនាក់ទំនងនឹងពួកមជ្ឈិមវ័យវ័យក្មេងទាំងនេះ អ្នកនឹងយល់កាន់តែច្រើនពីឧបសគ្គដែលជំនាន់របស់ពួកគេកំពុងជួបប្រទះ ។



**4. ចង្អុលបង្ហាញពីអំណោយទានរបស់ពួកគេ ។** ការជួយពួកមជ្ឈិមវ័យវ័យក្មេងឲ្យរកឃើញនូវទេពកោសល្យ និងចំណង់ចំណូលចិត្តរបស់ពួកគេអាចជួយពួកគេឲ្យស្រមើស្រមៃពីអនាគតមួយដ៏រីករាយ ។ សូមចង្អុលបង្ហាញថា មនុស្សគ្រប់រូបកម្ររីករាយនឹងអ្វីមួយណាស់ លុះត្រាតែពួកគេខិតខំយ៉ាងខ្លាំងដើម្បីទទួលបានជោគជ័យ ។ សូម្បីតែអ្នកដែលមានទេពកោសល្យក្មេងខ្ចីច្រើនក្ដី អ្នកត្រូវចំណាយពេលដើម្បីបណ្ដុះបណ្ដាលដើម្បីទទួលបានជោគជ័យ ។



**5. ទុកចិត្តពួកគេចំពោះការសម្រេចចិត្តរបស់ពួកគេ ។** ការណ៍នេះពុំមែនមានន័យថា ជាការជឿជាក់ថាពួកគេនឹងធ្វើការសម្រេចចិត្តដ៏ល្អឥតខ្ចោះជានិច្ចនោះទេ ។ វាមានន័យថាជាការទុកចិត្តថាពួកគេអាចមានភាពរឹងមាំ ថាព្រះកំពុងប្រទានការអត់ឱនទោស ហើយថាជីវិតអាចមានអត្ថន័យកាន់តែជ្រាលជ្រៅ ទោះជាមានការយកឈ្នះលើភាពបរាជ័យ ឬ ការសាកល្បងមិនចេះចប់មិនចេះហើយក្ដី ។ *ក្មេងតូចៗ*អាចភ័យខ្លាចដោយព្រោះតែដំណើរភ័យស្លុតណាមួយ រីឯ*ពួកមជ្ឈិមវ័យ*វ័យក្មេងវិញពួកគេរីកចម្រើនមកពីការយកឈ្នះលើឧបសគ្គជាជាងការគេចវេសពីវា ។ សូមផ្ដល់ការគាំទ្រខាងផ្លូវចិត្ត និង ការអនុវត្ត សូមលើកទឹកចិត្តឲ្យសម្រាកពីភាពថប់បារម្ភ សូមអធិស្ឋានជាមួយពួកគេ និងសម្រាប់ពួកគេ ហើយដាក់បញ្ចូលនូវភាពសើចសប្បាយបន្តិចបន្តួច ។

**6. សូមសរសើរពួកគេចំពោះការខិតខំរបស់ពួកគេ ។** ការសរសើរពួកមជ្ឈិមវ័យវ័យក្មេងសម្រាប់ការខិតខំ និង ភាពអត់ធ្មត់ ជួយពួកគេឲ្យ

តោងជាប់នឹងកិច្ចការនានាបានយូរ ប្រឈមមុខនឹងឧបសគ្គបានច្រើន ហើយរកឃើញសេចក្ដីអំណរកាន់តែច្រើននៅក្នុងការងាររបស់ពួកគេ ។ រូបមន្តមួយដែលបានចែកចាយដោយប្រធាន ថូម៉ាស អេស ម៉នសុន បានថ្លែងថា « ការធ្វើការងារនឹងបានជោគជ័យ រីឯបំណងមិនដាច់ស្រេចនឹងបានបរាជ័យវិញ » ។[1]

**7. ស្វែងរកការបំផុសគំនិត ។** ការអធិស្ឋាន និង សេចក្ដីជំនឿរបស់យើងជួយយើងឲ្យបើកដួងចិត្តរបស់យើងដោយអនុញ្ញាតឲ្យព្រះផ្លាស់ប្ដូរយើង ។ មានស្ត្រីម្នាក់ដែលខ្ញុំស្គាល់មានអារម្មណ៍ខ្វល់ខ្វាយពីកម្មវិធីទូរទស្សន៍ដែលកូនពេញវ័យរបស់គាត់អនុញ្ញាតឲ្យកូនចៅរបស់ពួកគេមើល ។ គាត់មានអារម្មណ៍ថាកម្មវិធីទាំងនោះបានបង្រៀនពីការខ្វះគារវភាព និង ជម្លោះ ទោះជាពួកគេត្រូវបានចាត់ទុកថាមានអាយុសមរម្យក្ដី ។ ដោយសារមិនចង់បំពានលូកដៃលូកជើង គាត់បានអធិស្ឋាន ហើយតមអាហារម្ដងហើយម្ដងទៀតអំពីអ្វីដែលត្រូវធ្វើឬនិយាយ ។ មានព្រឹកមួយកូនប្រសារស្រីរបស់គាត់បានទូរសព្ទមកសុំការណែនាំស្ដីពីរបៀបដើម្បីគ្រប់គ្រងការខ្វះគារវភាព និង ជម្លោះនៅក្នុងចំណោមកូនៗរបស់នាង ។ មិត្តរបស់ខ្ញុំបានចែកចាយពីការសង្កេតឃើញរបស់ខ្លួនស្ដីពីកម្មវិធីទូរទស្សន៍ ជាឥទ្ធិពលមួយដែលកូនប្រសារស្រីរបស់គាត់មិនបានសង្កេតឃើញ ។ ឪពុកម្ដាយវ័យក្មេងរូបនោះបានលើកឡើងពីបញ្ហានេះជាមួយកូនៗរបស់ពួកគេ ។ ការផ្លាស់ប្ដូរត្រូវបានព្រមព្រៀងគ្នា ហើយបរិយាកាសនៅក្នុងផ្ទះមានភាពប្រសើរឡើង ។

**8. និយាយពីប្រាក់កាក់ ។** ដោយដឹងពីស្ថានភាពរបស់អ្នក និងពីភាពចាស់ទុំរបស់កូនម្នាក់ៗ សូមសម្រេចចិត្តប្រកបដោយ



ការអធិស្ឋាននូវជំនួយខាងហិរញ្ញវត្ថុបែបណាដើម្បីជួយដល់កូនចៅរបស់អ្នក ។ ប្រហែលជាពួកគេគ្រាន់តែត្រូវការជំនួយពីអ្នកដើម្បីនឹងរៀបចំថវិកាមួយប៉ុណ្ណោះ ។ ប្រសិនអ្នកជួយពួកគេខាងផ្នែកហិរញ្ញវត្ថុ ត្រូវមានភាពច្បាស់លាស់តាំងពីដំបូងថាតើអ្នកចង់បានសំណងពីប្រាក់នោះវិញ ឬត្រូវសងតាមរបៀបមួយដ៏ត្រឹមត្រូវ ។ បន្ទាប់មកផ្ដល់ទំនួលខុសត្រូវដើម្បីគ្រប់គ្រងប្រាក់របស់ពួកគេ ហើយរៀនពីកំហុសដោយក្ដីរីករាយ រួមទាំងកំហុសនៃការគ្មានប្រាក់សម្រាប់អនាគត ប្រសិនបើពួកគេចំណាយលើស ។



**9. ចូរមានចិត្តរាបសា ។** នៅពេលអ្នកមានអារម្មណ៍ថាចង់ស្ដីបន្ទោសឲ្យខ្លួនឯងដោយសារតែកំហុសក្នុងនាមជាឪពុកម្ដាយ សូមព្យាយាមធ្វើឲ្យចិត្តរបស់អ្នកបានរាបសា ជាជាងប្រមាថខ្លួនឯង ។ សូមធ្វើការសុំទោសដោយចិត្តមេត្តា ដោយនិយាយនូវអ្វីដែលអ្នកនឹងធ្វើឲ្យបានប្រសើរ រួចហើយដើរឆ្ពោះទៅមុខដោយភាពជឿជាក់ ។ ចូរឲ្យកូនចៅរបស់អ្នកធ្វើការតាំងចិត្តដោយសង្កេតមើលទៅលើអ្នកថា កំហុសពុំមែនជាទីបញ្ចប់ ការសុំទោសពុំមែនជាសញ្ញានៃភាពទន់ខ្សោយនោះទេ ហើយ ការអភ័យទោសឲ្យអ្នកដទៃ ព្រមទាំងខ្លួនឯងផងដែរនឹងនាំមកនូវសេចក្ដីសុខសាន្ត ។

**10. វាស់វែងជោគជ័យពិត ។** នៅពេលយើងផ្ដោតចិត្តខ្លាំងពេកទៅលើរបៀបដែលអ្នកដទៃនឹងវិនិច្ឆ័យដល់យើងចំពោះការជ្រើសរើសរបស់កូនយើង ( មិនថាល្អ ឬអាក្រក់នោះទេ ) យើងនឹងបាត់បង់នូវភាពឯករាជ្យ ហើយជារឿយៗយើងនឹងបាត់បង់ព្រះវិញ្ញាណ ។ សូមចងចាំថា ជោគជ័យរបស់យើងក្នុងនាមជាឪពុកម្ដាយពុំមែនកំណត់ដោយការដែលកូនចៅរបស់យើងរស់នៅស្របតាមគោលការណ៍របស់យើងបានល្អប៉ុណ្ណានោះទេ ប៉ុន្តែដោយការដែលយើងរស់នៅតាមគោលការណ៍ទាំងនោះបានទៀងទាត់ ហើយគ្មានភាពអាត្មានិយមបានប៉ុណ្ណាវិញទេ ។

នៅពេលយើងគិតពិចារណាប្រកបដោយការអធិស្ឋានពីសេចក្ដីត្រូវការ និងបុគ្គលិកលក្ខណៈនៃកូនចៅរបស់យើងម្នាក់ៗដែលជាមជ្ឈិមវ័យវ័យក្មេង នោះព្រះវិញ្ញាណអាចជួយយើងឲ្យដឹកនាំដោយគ្មានការរិះគន់ ឬគាំទ្រដោយទទឹងទទែងហើយដោយទុកចិត្តថាគេនឹងអនុវត្តបានដោយគ្មានការបោះបង់ចោល ។ នៅពេលយើងធ្វើដូច្នេះ នោះកូនចៅយើងដែលជាមជ្ឈិមវ័យវ័យក្មេងនឹងមានទំនុកចិត្តថា ទាំងយើង និង ព្រះអម្ចាស់នៅខាងពួកគេដែរ ។ ■

*អ្នកនិពន្ធរស់នៅក្នុងរដ្ឋ យូថាហ៍ ស.រ.អា. ។*

**កំណត់ចំណាំ**

1. ថូម៉ាស អេស ម៉នសុន « Great Expectations » ( ការប្រជុំពិសេសប្រពន្ធ័អប់រំសាសនាចក្រសម្រាប់ពួកមជ្ឈិមវ័យវ័យក្មេងនៅថ្ងៃទី 11 ខែ មករា ឆ្នាំ 2009 ) ទំព័រ 6 speeches.byu.edu ។

# នីហ្វៃបានឆ្លើយនឹងសំណួរខ្ញុំ

ខ្ញុំបានកើតមកនៅក្នុងសាសនាចក្រ ប៉ុន្តែគ្រួសាររបស់ខ្ញុំកម្រទៅព្រះវិហារណាស់ កាលខ្ញុំបានធំដឹងក្តី ។ ទោះជាបែបនេះក្តី ខ្ញុំតែងរកវិធីមួយដើម្បីទៅព្រះវិហារដោយខ្លួនឯង ។ នៅដើមឆ្នាំ 1970 ខ្ញុំបានបម្រើជាគ្រូបង្រៀនថ្នាក់សិក្ខាសាលាក្នុងទីក្រុងផីតស៍ប៊ឺក រដ្ឋខាន់សាស ស.រ.អា. ។ នៅពេលសិក្សាព្រះគម្ពីរមរមន ខ្ញុំបានសំណូមពរឲ្យសិស្ស—រួមទាំងខ្លួនខ្ញុំផ្ទាល់—អានព្រះគម្ពីរនោះទាំងមូល ។ មានថ្ងៃមួយកាលខ្ញុំកំពុងអាន ខ្ញុំបានទទួលទីបន្ទាល់មួយដ៏អស្ចារ្យថា វាពិត ។

ពីរបីឆ្នាំក្រោយមក ឪពុកម្តាយខ្ញុំបានមកលេងនឹងខ្ញុំ ។ កាលពួកគាត់បានមកលេង ឪពុកខ្ញុំបានលើកឡើងពីប្រធានបទមួយចំនួនដែលយើងមិនយល់ស្របគ្នារហូតធ្វើឲ្យខ្ញុំមិនចង់ពិភាក្សានឹងគាត់ ។ ប៉ុន្តែគាត់បានបន្តរហូតដល់ខ្ញុំរៀបនឹងទប់កំហឹងរបស់ខ្ញុំមិនបាន ។ ខ្ញុំបានសុំដកខ្លួនចេញទៅបន្ទប់ដេករបស់ខ្ញុំមួយភ្លែត ហើយខ្ញុំបានលុតជង្គង់អធិស្ឋានទៅព្រះវរបិតាសួគ៌ ហើយទូលសុំជំនួយពីទ្រង់នៅក្នុងការដោះស្រាយបញ្ហានឹងឪពុករបស់ខ្ញុំ ។ ចម្លើយបានប្រាកដឡើងជាគំនិតមួយ ៖ ជាដំណើររឿងរបស់នីហ្វៃ និង ធ្នូដែលបាក់ ។

ខ្ញុំបានបើកមើលរឿងនោះនៅក្នុងនីហ្វៃទី 1 ជំពូក 16 ។ ខ្ញុំបានគិតពីនីហ្វៃមានចិត្តរាបសាល្មមដើម្បីទៅរកឪពុករបស់គាត់ ដែលបានត្អូញត្អែរទាស់នឹងព្រះអម្ចាស់ ដើម្បីសួរពីកន្លែងដែលគាត់គួរទៅដើម្បីទទួលបានអាហារ ( សូមមើល ខ 23 ) ។ ដោយមានគំនិតនោះ ខ្ញុំមានអារម្មណ៍បំផុសគំនិតឲ្យទៅរកឪពុកខ្ញុំ ហើយសុំការណែនាំរបស់គាត់ក៏ដូចជាការប្រសិទ្ធពរបព្វជិតភាពផងដែរ ។

នៅពេលខ្ញុំត្រឡប់ទៅបន្ទប់ទទួលភ្ញៀវវិញ ខ្ញុំបានសុំឲ្យឪពុកខ្ញុំធ្វើការប្រសិទ្ធពរមួយ ហើយវាបានប៉ះដល់ដួងចិត្តគាត់ ហើយគាត់បានចាប់ផ្តើមយំ ។ គាត់បានពោលថា « ចាំប៉ាគិតមើលសិន » ។

លុះពីរបីថ្ងៃក្រោយមកទៀតគាត់បានតមអាហារ ហើយអធិស្ឋាន ។ បន្ទាប់មក មុនពេលប៉ា និង ម៉ាក់បានចាកចេញទៅ គាត់បានផ្តល់ការប្រសិទ្ធពរមួយដ៏មានអត្ថន័យដល់ខ្ញុំ ។

ក្រោយពីបទពិសោធន៍នោះមក ឪពុកខ្ញុំបានចាប់ផ្តើមផ្លាស់ប្តូរជីវិតរបស់គាត់ ។ នៅពេលពួកគាត់ធ្វើដំណើរត្រឡប់ទៅផ្ទះវិញពីរដ្ឋខាន់សាស ឪពុកម្តាយខ្ញុំបានទៅលេងភ្នំ អ័ដាម-អុនតៃ-អាម៉ាន រដ្ឋ មិសសួរី ស.រ.អា. ជាទីកន្លែងដែលឪពុករបស់ខ្ញុំមានបទពិសោធន៍ខាងវិញ្ញាណដ៏អស្ចារ្យមួយ ។

មិនយូរប៉ុន្មាន ឪពុកម្តាយខ្ញុំបានក្លាយជាពួកបរិសុទ្ធថ្ងៃចុងក្រោយដ៏សកម្ម និងស្មោះស្ម័គ្រ ។ លុះប៉ុន្មានឆ្នាំក្រោយមក ពួកគាត់បានបម្រើបេសកកម្មចំនួនពីររួមគ្នា—មួយនៅប្រទេសអាល្លឺម៉ង់ និងមួយទៀតនៅវិសាលដ្ឋាននៃព្រះវិហារបរិសុទ្ធក្នុងទីក្រុងសលត៍ លេក ។ ឪពុករបស់ខ្ញុំបានបម្រើជាលោកអយ្យកោស្តេកនៅពេលគាត់បានចែកឋានទៅក្នុងឆ្នាំ 1987 ។

ព្រះអម្ចាស់បានជ្រាបថា ឪពុករបស់ខ្ញុំគឺជាមនុស្សល្អ ។ ខ្ញុំបានទទួលចម្លើយរបស់ខ្ញុំតាមរយៈព្រះគម្ពីរមរមន ហើយស្របតាមការធ្វើតាមការបំផុសគំនិតនោះទើបធ្វើឲ្យឪពុករបស់ខ្ញុំបានដឹងខ្លួនថា គាត់ត្រូវធ្វើជាអ្នកដឹកនាំសម្រាប់គ្រួសារយើង ។ បទពិសោធន៍នេះបានផ្លាស់ប្តូរអ្វីៗគ្រប់យ៉ាងសម្រាប់យើង ។

ខ្ញុំបានរៀនថា ព្រះគម្ពីរមរមនពិតជាសក្ខីបទមួយទៀតនៃព្រះយេស៊ូវគ្រីស្ទ ហើយថា វាត្រូវបានសរសេរឡើងសម្រាប់ជំនាន់របស់យើង ។ ខ្ញុំដឹងថា ខ្ញុំអាចងាកទៅរកព្រះគម្ពីរនោះនៅពេលណាខ្ញុំបាក់ទឹកចិត្ត និងនៅគ្រប់ស្ថានភាព ។ ចម្លើយគឺមាននៅទីនោះ ។

ពិតណាស់ « បន្ទូលទាំងឡាយនៃព្រះគ្រីស្ទនឹងប្រាប់ដល់[យើង]នូវគ្រប់អ្វីទាំងអស់ដែល[យើង]ត្រូវធ្វើ » ( នីហ្វៃទី 2 32:3 ) ។ ■

ជូឌី អិម ស្មីធ រដ្ឋខាន់សាស ស.រ.អា.

ខ្ញុំបានងាកទៅរកដំណើររឿងរបស់នីហ្វៃ និង ធ្នូដែលបាក់ ខ្ញុំបានទទួលអារម្មណ៍បំផុសគំនិតឲ្យទៅរកឪពុករបស់ខ្ញុំ ហើយសុំការដឹកនាំ និងការប្រសិទ្ធពរនៃបព្វជិតភាព ។



គំនូរដោយ ប្រេដលី ក្លាក

# សំបុត្រពីរមកពីអ្នកម្ដាយ

នៅឆ្នាំ 1996 ភរិយារបស់ខ្ញុំ និង ខ្ញុំមានកូនប្រុសពីរនាក់ អាយុបួនឆ្នាំ និងប្រាំពីរឆ្នាំ ។ យើងគឺជាគ្រួសារថ្មោងថ្មីដែលមានការរវល់ខ្លាំង ។ លុះយប់មួយភរិយារបស់ខ្ញុំបានឆ្លៀតពេលដើម្បីសរសេរសំបុត្រមួយទៅក្មួយប្រុសរបស់ខ្ញុំឈ្មោះគ្លេន ដែលនៅពេលនោះកំពុងបម្រើបេសកកម្មនៅប្រទេសហ្វាំងឡង់ ។

ដោយមានហេតុផលមួយចំនួន គាត់បានទទួលអារម្មណ៍ថាគាត់ត្រូវសរសេរសំបុត្រមួយយ៉ាងវែង—ជាសំបុត្រមួយដែលមានព័ត៌មានលម្អិតស្ដីពីអ្វីដែលសមាជិកគ្រួសារម្នាក់ៗកំពុងធ្វើ តើជីវភាពខាងវិញ្ញាណរបស់ពួកគេស្ថិតនៅត្រង់កម្រិតណា តើមានអ្វីកើតឡើងនៅក្នុងការហៅបម្រើក្នុងសាសនាចក្ររបស់ខ្ញុំ និងការហៅរបស់គាត់ ដំណើររឿងពីការផ្លាស់ប្រែចិត្តជឿរបស់គាត់ ពីអារម្មណ៍របស់គាត់អំពីកិច្ចការផ្សព្វផ្សាយសាសនា និងទីបន្ទាល់របស់គាត់អំពីដំណឹងល្អ ។

វាជាសំបុត្រយ៉ាងអស្ចារ្យ ប៉ុន្តែខ្ញុំបានងឿងឆ្ងល់ថាតើក្មួយប្រុសរបស់ខ្ញុំពិតជាត្រូវការព័ត៌មានច្រើនបែបនោះមែនទេ ។ ក្រោយមកគាត់បានសរសេរទៅក្មួយប្រុសខ្ញុំម្ដងទៀត ។

លុះប្រាំមួយឆ្នាំក្រោយមក កាលខ្ញុំបម្រើជាប៊ីស្សព ហើយកូនប្រុសរបស់យើងមានអាយុ 10 ឆ្នាំ និង 13 ឆ្នាំ ជីវិតរបស់ខ្ញុំបានផ្លាស់ប្ដូរមួយរំពេច ។ នៅថ្ងៃទី 2 ខែ មករា ឆ្នាំ 2002 ភរិយារបស់ខ្ញុំ ដែលមានអាយុទើបតែ 42 ឆ្នាំ បានចែកឋានដោយសារជំងឺគាំងបេះដូង ។

នៅពេលនោះខ្ញុំបានព្យាយាមបន្តធ្វើតាមគោលការណ៍នៅក្នុង « ក្រុមគ្រួសារ ៖ ការប្រកាសដល់ពិភពលោក » នៅក្នុងផ្ទះ ។[1] ខ្ញុំបានរកឃើញថា ខ្ញុំអាចគ្រប់គ្រង ហើយផ្គត់ផ្គង់ដល់គ្រួសារខ្ញុំបាន ប៉ុន្តែខ្ញុំមានអារម្មណ៍ថាខ្វះចន្លោះនូវការផ្ដល់ឲ្យនូវការចិញ្ចឹមបីបាច់ដែលពួកកូនប្រុសរបស់ខ្ញុំត្រូវការ ។ ទោះជាយ៉ាងណា យើងបានបន្តឆ្ពោះទៅមុខតាមលទ្ធភាពដែលយើងអាចធ្វើបាន ។

នៅខែមិថុនា ឆ្នាំ 2012 កូនប្រុសពៅរបស់ខ្ញុំឈ្មោះ សែម នៅពេលកំពុងបម្រើបេសកកម្មពេញម៉ោងនៅបេសកកម្មខូឡូរ៉ាដូ ឌេនវើរខាងត្បូង បានផ្ញើអ៊ីម៉ែលមួយមកខ្ញុំ ។ គាត់បានសរសេរថា « មានអ្វីមួយយ៉ាងអស្ចារ្យបានកើតឡើងនៅសប្ដាហ៍នេះ » ។ « កូនបានទទួលសំបុត្រពីរមកពីម៉ាក់ » ។

គាត់បានពន្យល់ថា គាត់បានទទួលកញ្ចប់មួយពីបងប្អូនជីដូនមួយគាត់ឈ្មោះគ្លេន ហើយនៅក្នុងនោះមានសំបុត្រដែលភរិយាខ្ញុំធ្លាប់សរសេរទៅគាត់ពេលគាត់នៅប្រទេសហ្វាំងឡង់ ។

សែម បានសរសេរថា « គាត់បានប្រាប់ខ្ញុំថាសំបុត្រទាំងពីរដែលម៉ាក់បានផ្ញើឲ្យគាត់នៅក្នុងបេសកកម្មពិតជាដូចជាសំបុត្រដែលបានសរសេរសម្រាប់កូននៅក្នុងបេសកកម្មរបស់កូន » ។ « ដូច្នេះគាត់បានផ្ញើវាមកឲ្យកូន ហើយវាអស្ចារ្យណាស់ ! »

សែមបានសរសេរថា ការរៀនសូត្រពីការផ្លាស់ប្រែចិត្តជឿ ទីបន្ទាល់ និង អារម្មណ៍របស់ម្ដាយគាត់ចំពោះកិច្ចការផ្សព្វផ្សាយសាសនាគឺជា « ការគាំទ្រមួយដ៏អស្ចារ្យសម្រាប់ពេលនេះ » ។ គាត់បាននិយាយថាគាត់មានផែនការថតចម្លងសំបុត្រនេះ ហើយផ្ញើច្បាប់ដើមមកផ្ទះ ។

សែម បានសរសេរថា « កូនពុំធ្លាប់ដឹងថា ប៉ាធ្លាប់បម្រើជាប្រធានក្រុមអែលឌើរ ឬ

វាមានភាពអស្ចារ្យ ផ្ទាល់ខ្លួន ហើយមានខ្លឹមសារយ៉ាងខ្លាំងពេលសរសេរនៅឆ្នាំ 1996 ប៉ុន្តែដោយសារព្រឹត្តិការណ៍ដែលកើតឡើងនៅប៉ុន្មានឆ្នាំក្រោយមកទៀត វាកាន់តែមានភាពអស្ចារ្យថែមទៀត ។

ជាអ្នកដឹកនាំបេសកកម្មវួដនោះទេ » ។ គាត់បានដឹងនៅពេលគាត់មានអាយុបួនឆ្នាំ គាត់ « បានលោតនៅលើគ្រែក្រោយពីការអធិស្ឋាន ហើយស្រែកថា ‹ ខ្ញុំចង់ក្លាយជាអ្នកផ្សព្វផ្សាយសាសនា › » ។

បន្ទាប់មកគាត់បានបន្ថែមនូវអ្វីមួយដែលគាត់បានរៀនពីម្ដាយរបស់គាត់ថា ៖ « ម៉ាក់បានដឹងថា ខ្ញុំនឹងក្លាយជាអ្នកបោកចំបាប់ដោយសារគាត់បានពោលថាខ្ញុំមានរូបរាងមាំមួនដែលសក្ដិសមក្លាយជាអ្នកបោកចំបាប់ម្នាក់ ។ :) »

ខ្ញុំបានរំភើបរហូតដល់ស្រក់ទឹកភ្នែកដោយសារប្រតិកម្មរបស់សែមចំពោះសំបុត្រនោះ ។ លុះពីរបីសប្ដាហ៍ក្រោយមកគាត់បានផ្ញើសំបុត្រនោះមកផ្ទះ ។ លិខិតទាំងពីរនេះពិតជាអស្ចារ្យ ផ្ទាល់ខ្លួន ហើយមានខ្លឹមសារយ៉ាងខ្លាំងពេលសរសេរនៅឆ្នាំ 1996 ប៉ុន្តែដោយសារព្រឹត្តិការណ៍ដែលកើតឡើងនៅប៉ុន្មានឆ្នាំក្រោយមកទៀត វាកាន់តែមានភាពអស្ចារ្យថែមទៀត ។

សំបុត្ររបស់ភរិយាខ្ញុំបានពង្រឹងដល់ក្មួយប្រុសរបស់ខ្ញុំ ប៉ុន្តែដូចជា « បោះនំប៉័ងទៅលើទឹក » ដូច្នោះដែរ ( សូមមើលសាស្ដា 11:1 ) ប៉ុន្មានឆ្នាំក្រោយមកវាបានប្រទានពរដល់កូនប្រុសគាត់ដែលជាអ្នកផ្សព្វផ្សាយសាសនា និង ស្វាមីពោះម៉ាយ ។ ■

**ខេន ពីនណេហ្គា រដ្ឋកាលីហ្វ័រញ៉ា ស.រ.អា.**

**កំណត់ចំណាំ**

1. សូមមើល « ក្រុមគ្រួសារ ៖ ការប្រកាសដល់ពិភពលោក » *Liahona* ខែ វិច្ឆិកា ឆ្នាំ 2010 ទំព័រ 129 ។



# ខ្ញុំបានឃើញមុខម្ដាយរបស់ឯង

មានថ្ងៃអាទិត្យមួយនារដូវក្ដៅក្នុងឆ្នាំ 2002 ខ្ញុំបានក្រោកឡើងដោយគិតពីម្ដាយរបស់ខ្ញុំ ដែលទើបតែចែកឋានទៅថ្មីៗ ។ ខ្ញុំបានទៅលេង វួដចាស់របស់ខ្ញុំនៅទីក្រុងប៉ាស៊ីហ្វិកប៉ាលីសាដេស រដ្ឋកាលីហ្វ័រញ៉ា ស.រ.អា. ជាកន្លែងដែលម្ដាយរបស់ខ្ញុំបានទៅថ្វាយបង្គំជិត 50 ឆ្នាំ ។

ខ្ញុំបានលុតជង្គង់អធិស្ឋានដើម្បី ប្រាប់ព្រះអម្ចាស់ថាខ្ញុំនឹកម្ដាយខ្ញុំខ្លាំងណាស់ ហើយទូល សូមបទពិសោធន៍ខាងវិញ្ញាណ មួយនៅថ្ងៃនោះ ។

នៅរសៀលនោះ ខ្ញុំបានមានគម្រោង ទៅចូលរួមការចាក់ផ្សាយពីការឧទ្ទិសឆ្លងឡើងវិញ នៃព្រះវិហារបរិសុទ្ធណេវ៉ូ អិលលីណោយ នៅអគារស្តេកក្នុងទីក្រុងសានតាម៉ូនីកា រដ្ឋកាលីហ្វ័រនីញ៉ា ។ ជាអកុសល ខ្ញុំបានទៅ ដល់យឺតពេកដើម្បីចូលរួមសម័យប្រជុំ នោះ ។ ខ្ញុំបានបត់ឡានខ្ញុំមកវិញហើយ បើកចូលទៅមហាវិថីផ្លូវជាតិ ។

ពេលខ្ញុំកំពុងបើកឡាន ខ្ញុំបានឮសំឡេងមួយ ពោលថា « រ៉ែនឌី ទៅលេងម៉ារី ! » ម៉ារីគឺជាមិត្តជិតស្និទ្ធម្នាក់របស់គ្រួសារយើង ហើយជាសមាជិក ដ៏ស្មោះត្រង់ម្នាក់នៃព្រះវិហារផ្សេងទៀត ។ គាត់ និង កូនស្រីឈ្មោះណាតាស្សារស់នៅក្បែរផ្ទះមីង របស់ខ្ញុំឈ្មោះ រូប៊ី ច្រើនជាង 25 ឆ្នាំមកហើយ ។ ដោយសារពួកគេគ្មានគ្រួសារនៅក្បែរ ពួកគេបាន ក្លាយជាផ្នែកនៃគ្រួសារយើង ។ បន្ទាប់ពីមីងខ្ញុំបាន ចែកឋានទៅនៅឆ្នាំ 1984 ម្ដាយខ្ញុំជារឿយៗបាន ទៅលេងម៉ារី ហើយតែងមានអំណោយបន្តិចបន្តួច ឬអ្វីមួយដែលគាត់បានធ្វើយកទៅជាមួយ ។

ដំបូងឡើយខ្ញុំបានបដិសេធចំពោះការ បំផុសគំនិតនោះ ។ ខ្ញុំមិនអាចទៅដោយ មិនប្រាប់ឲ្យគេដឹងជាមុននោះទេ ហើយខ្ញុំគ្មាន ទូរសព្ទដើម្បីទូរសព្ទទៅគាត់ទៀត ។ រំពេចនោះ សំឡេងនោះបានកើតមានម្ដងទៀត នៅពេល នេះឮខ្លាំងជាងមុន ៖ « រ៉ែនឌី ទៅលេងម៉ារី ! » នៅពេលនេះខ្ញុំបានស្ដាប់តាមការប្រឹក្សានោះ ទោះខ្ញុំមានពេលមិនសូវច្រើន ដើម្បីបើកចុះពីផ្លូវ មហាវិថីផ្លូវជាតិនោះក៏ដោយ ។

នៅពេលខ្ញុំបានទៅដល់ផ្ទះរបស់ម៉ារី គាត់បាន មករាក់ទាក់ខ្ញុំ ប៉ុន្តែគាត់មើលទៅដូចជាមានជំងឺ ។ ខ្ញុំអាចដឹងថា គាត់បានយំ ។ ខ្ញុំបានសួរគាត់ថាតើ មានអ្វីកើតឡើង ។ គាត់បានតបថា គាត់បាន ឈឺយូរហើយ ហើយមានការឈឺចាប់ពីរបួស នៅត្រង់-ករបស់គាត់ ។ គាត់ក៏គ្មានអាហារច្រើន ផងដែរ ។ គាត់បានពោលថា គាត់ឈឺរហូតដើរទៅ ឱសថស្ថាន ឬ ផ្សារមិនបានផង ។

នៅពេលខ្ញុំសួរថាហេតុអ្វីបានជាគាត់មិនទូរសព្ទ ទៅនរណាម្នាក់ក្នុងគ្រួសារយើង គាត់បានពោលថា « ខ្ញុំបានអធិស្ឋាន ហើយទូលសុំព្រះវរបិតាសួគ៌ឲ្យ បញ្ជូននរណាម្នាក់ឲ្យមកជួយខ្ញុំ » ។

ខ្ញុំបានប្រាប់គាត់ថា ព្រះវរបិតាសួគ៌បាន ឮការអធិស្ឋានរបស់គាត់ ហើយបានចាត់ខ្ញុំ ឲ្យមក ។ យើងបានឱបគ្នា រួចហើយគាត់បាន ប្រាប់ខ្ញុំពីអ្វីមួយដែលខ្ញុំមិនអាចបំភ្លេចបាន ឡើយ ។ គាត់បានពោលថា « នៅពេលឯងមក ដល់មាត់ទ្វារ ខ្ញុំបានឃើញមុខម្ដាយរបស់ឯង មិន មែនជាឯងនោះទេ » ។

រំពេចនោះខ្ញុំមានអារម្មណ៍ថា វិញ្ញាណរបស់ ម្ដាយខ្ញុំនៅក្បែរខ្ញុំ ហើយខ្ញុំបានទទួលអារម្មណ៍ បំផុសគំនិតឲ្យបម្រើដូចដែលម្ដាយខ្ញុំបានបម្រើ ។ នៅទីបំផុត ជីវិតរបស់គាត់បានពោរពេញដោយការ បម្រើដល់អ្នកដទៃ ។

ខ្ញុំសង្ឃឹមថា ខ្ញុំនឹងមិនភ្លេចពីសារៈសំខាន់ នៃការស្ដាប់តាមសំឡេងនៃព្រះវិញ្ញាណ និងគំរូ ដែលម្ដាយខ្ញុំបានបង្ហាញដល់ខ្ញុំស្ដីពីការបម្រើដល់ អ្នកដទៃនោះទេ ។ ■

រ៉ែនឌី រ៉ៃណុល អាឡិន រដ្ឋកាលីហ្វ័រញ៉ា ស.រ.អា.



នៅពេលខ្ញុំបានទៅដល់ផ្ទះរបស់ម៉ារី គាត់បានមករាក់ទាក់ខ្ញុំ ប៉ុន្តែគាត់មើលទៅដូចជាមានជំងឺ ។ ខ្ញុំអាចដឹងថា គាត់បានយំ ។

# អ្នកបានជួយសង្គ្រោះអាពាហ៍ពិពាហ៍របស់ខ្ញុំ

នៅពេលខ្ញុំធ្វើការសំណង់នៅអូម៉ង់ពីឆ្នាំ 1979 ដល់ឆ្នាំ 1986 ខ្ញុំបានធ្វើការឲ្យក្រសួងការពារជាតិ ។ ក្រសួងនោះបានឲ្យគម្រោងខ្ញុំជាច្រើនជាផ្នែកនៃប្រទេស ដែលស្ទើរតែមិនអាចចូលទៅបាន ហើយភាគច្រើនខ្ញុំជាអ្នកគ្រប់គ្រងតែម្នាក់គត់ដែលមើលគម្រោងទាំងនោះ ។ ខ្ញុំក៏ជាសមាជិកសាសនាចក្រតែម្នាក់គត់ដែលធ្វើការឲ្យក្រសួងនេះផងដែរ ។

មានថ្ងៃមួយនៅឯងទីស្នាក់ការកណ្ដាលរបស់ក្រុមហ៊ុនយើង ខ្ញុំបានជួបនឹងវិស្វករផ្នែកអេឡិចត្រូនិកម្នាក់ដែលកាលពីមុនគាត់ធ្លាប់មានយោបល់អវិជ្ជមានអំពីសាសនាចក្រ ។ ខ្ញុំមិនបានតបនឹងយោបល់របស់គាត់ ព្រោះអីជាទូទៅខ្ញុំនៅទីស្នាក់ការកណ្ដាលរយៈពេលខ្លីពីមុនខ្ញុំចេញទៅធ្វើគម្រោងមួយទៀត ។

ប៉ុន្តែក្រោយមកទៀត បុរសម្នាក់នេះត្រូវបានចាត់តាំងឲ្យទៅពិនិត្យមើលការងារអេឡិចត្រូនិកនៅឯគម្រោងដែលកំពុងសាងសង់នៅតាមព្រំដែនអូម៉ង់ជាមួយនឹងប្រទេសយេម៉ែន ។ យើងបានរៀបចំពេលប្រហែលជាមួយម៉ោងដើម្បីជួបគ្នា ពីមុនគាត់ជិះយន្តហោះត្រឡប់ទៅទីស្នាក់ការកណ្ដាលវិញ ។

នៅពេលគាត់ទៅដល់ គាត់បានពិនិត្យមើលការងារ ហើយបានរកឃើញថាអ្វីៗគ្រប់យ៉ាង បំពេញតាមបំណងរបស់គាត់ ។ នៅពេលយើងជួបគ្នា ខ្ញុំបានផ្ដោតការសន្ទនារបស់យើងលើការងារ រួចហើយបានបើកឡានជូនគាត់ទៅកន្លែងចតយន្តហោះ ។

វាជារដូវមូសុង ហើយកន្លែងចតយន្តហោះនោះមានទីតាំងនៅលើភ្នំដែលមានកម្ពស់ 1,830 ម. នៅលើមហាសមុទ្រឥណ្ឌា ត្រូវបានពពកគ្របបាំងជុំជិត ។ ជើងយន្តហោះរបស់មិត្តរួមការងាររបស់ខ្ញុំត្រូវពន្យារពេល ។

បេះដូងខ្ញុំបានលោតខុសចង្វាក់ដោយសារខ្ញុំដឹងថាខ្ញុំត្រូវរង់ចាំនៅក្នុងឡានជាមួយនឹងបុរសម្នាក់នេះ ។ បន្ទាប់ពីខ្ញុំធ្វើការអធិស្ឋានដោយស្ងៀមស្ងាត់មក ខ្ញុំបានមានគំនិតមួយឲ្យសួរបុរសនោះពីគ្រួសារគាត់ ជាពិសេសភរិយារបស់គាត់ ។

ខ្ញុំបានធ្វើតាម ហើយរំពេចនោះវិស្វករម្នាក់នេះបានសម្រក់ទឹកភ្នែក ដោយសារពោលថា គាត់ទើបបានទទួលដំណឹងថាភរិយារបស់គាត់ចង់លែងលះនឹងគាត់ ។ រំពេចនោះពាក្យថា *សេចក្ដីស្រឡាញ់* បានផុសឡើងក្នុងគំនិតខ្ញុំ ហើយរយៈពេលពីរបីម៉ោងក្រោយមកទៀតយើងបាននិយាយពីសេចក្ដីស្រឡាញ់ដែលយើងគួរតែមានចំពោះគ្នា និងសេចក្ដីស្រឡាញ់ដែលព្រះអម្ចាស់ ព្រះយេស៊ូវគ្រីស្ទមានសម្រាប់យើងគ្រប់គ្នា ។ យើងបានក្លាយទៅជាមិត្ត ពីមុនខ្ញុំបានដឹងទៅទៀត ។ នៅពេលយើងបញ្ចប់ការសន្ទនារបស់យើង ផ្ទៃមេឃបានស្រឡះ ហើយវិស្វកររូបនេះបានឡើងជិះយន្តហោះចេញទៅ ។ មិនយូរប៉ុន្មានខ្ញុំបានឮថា គាត់បានសុំឈប់ពីការងារគាត់ ហើយបានត្រឡប់ទៅផ្ទះវិញ ។

ពីរបីឆ្នាំក្រោយមក កាលចេញទៅក្រៅនៅព្រឹមុតជាមួយនឹងយុវជនដែលជាបព្វជិតភាពអើរ៉ុន ជាទីក្រុងមួយនៅភាគខាងត្បូងប្រទេសអង់គ្លេស ខ្ញុំបានឃើញបុរសម្នាក់កំពុងដើរសំដៅមករកខ្ញុំ ។ នៅពេលគាត់បានដើរមកដល់ខ្ញុំហើយ គាត់បានពោលថា « នៀល ខ្ញុំបានគិតថា ពិតជាឯង » ។

បុរសម្នាក់នោះគឺជាវិស្វករអេឡិចត្រូនិកមកពីអូម៉ង់ ។ ពាក្យបន្ទាប់ដែលគាត់បាននិយាយបានស្ថិតនៅក្នុងចិត្តខ្ញុំជានិច្ច ៖ « អរគុណដែលបាននិយាយប្រាប់ខ្ញុំពីសេចក្ដីស្រឡាញ់កាលពីថ្ងៃនោះនៅលើភ្នំ ។ ឯងបានសង្គ្រោះអាពាហ៍ពិពាហ៍របស់ខ្ញុំ ហើយខ្ញុំនឹងមានអំណរគុណជានិច្ច » ។

យើងបានជជែកគ្នាមួយភ្លែត ហើយគាត់បានចេញទៅ ។ តាំងពីពេលនោះមក ខ្ញុំមិនបានឃើញគាត់ទៀតទេ ។

ខ្ញុំតែងមានអំណរគុណចំពោះការបំផុសគំនិតដែលខ្ញុំបានទទួលនៅអូម៉ង់ ។ វាបានប្រទានពរដល់វិស្វករម្នាក់នោះ ហើយបានផ្ដល់កម្លាំងដល់ខ្ញុំដើម្បីរក្សាជំនឿខ្ញុំលើសាសនាចក្រ នៅពេលខ្ញុំនៅតែម្នាក់ឯងឆ្ងាយពីផ្ទះ ។ ■

នៀល អេស រ៉យ រដ្ឋយ៉កស្សាយ ប្រទេសអង់គ្លេស

**បេះដូងខ្ញុំបានលោតខុសចង្វាក់ដោយសារខ្ញុំដឹងថាខ្ញុំត្រូវរង់ចាំនៅក្នុងឡានជាមួយនឹងបុរសម្នាក់ដែលមានគំនិតអវិជ្ជមានអំពីសាសនាចក្រ ។**






ដោយអែលឌើរ
ជែរិត ដ័ប្លុលយូ ហ្គង
នៃពួកចិតសិបនាក់


# ការប្រែក្លាយជាល្អឥតខ្ចោះនៅក្នុងព្រះគ្រីស្ទ

**ការយល់ដឹងពីសេចក្ដីស្រឡាញ់ដ៏ធួនដែលព្រះអង្គសង្គ្រោះបានប្រទានដោយសេរី អាចធ្វើឲ្យយើងរួចផុតពីការរំពឹងទុកមិនត្រឹមត្រូវ ហើយមិនពិតប្រាកដដែលបានដាក់ដោយខ្លួនឯង ស្ដីពីអត្ថន័យនៃពាក្យថាល្អឥតខ្ចោះ ។**

យើងច្រៀងជាមួយនឹងកូនចៅរបស់យើងថា « ខ្ញុំស្គាល់ក្ដីស្រឡាញ់ព្រះអង្គ ក្ដីស្នេហ៍ទ្រង់ប្រទានដល់ខ្ញុំ » ។[1]

សេចក្ដីស្រឡាញ់ដ៏ធួនរបស់ទ្រង់ដែលបានប្រទានឲ្យដោយសេរីគឺប្រៀបដូចជា « ទឹកដោះ និង ទឹកឃ្មុំដោយឥតបង់ប្រាក់ ហើយឥតថ្លៃផង » ( នីហ្វៃទី 2 26:25 ) ។ អនន្ត និង អស់កល្បជានិច្ច ( សូមមើល អាលម៉ា 34:10 ) ដង្វាយធួនអញ្ជើញយើងឲ្យ « មករកព្រះគ្រីស្ទ ហើយឲ្យបានល្អឥតខ្ចោះនៅក្នុងទ្រង់ » ( មរ៉ូណៃ 10:32 ) ។

ការយល់ដឹងពីសេចក្ដីស្រឡាញ់ដ៏ធួនដែលព្រះអង្គសង្គ្រោះបានប្រទានដោយសេរីអាច ធ្វើឲ្យយើងរួចផុតពីការរំពឹងទុកមិនត្រឹមត្រូវ ហើយមិនពិតប្រាកដដែលបានដាក់ដោយខ្លួនឯងស្ដីពីអត្ថន័យនៃពាក្យថាល្អឥតខ្ចោះ ។ ការយល់ដឹងបែបនេះជួយឲ្យយើងបំភ្លេចនូវការភ័យខ្លាចថាយើងមិនល្អឥតខ្ចោះ—ការភ័យខ្លាចថាយើងធ្វើខុស ការភ័យខ្លាចថាយើងមិនល្អគ្រប់គ្រាន់ ការភ័យខ្លាចថាយើងជាមនុស្សបរាជ័យបើប្រៀបធៀបនឹងមនុស្សដទៃទៀត ការភ័យខ្លាចថាយើងមិនបានធ្វើគ្រប់គ្រាន់ឲ្យសក្ដិសមនឹងសេចក្ដីស្រឡាញ់របស់ទ្រង់ ។

សេចក្ដីស្រឡាញ់ដ៏ធួនដែលព្រះអង្គសង្គ្រោះបានប្រទានឲ្យដោយសេរីជួយយើងឲ្យមានការអត់ទោសឲ្យច្រើន ហើយមិនសូវវិនិច្ឆ័យអ្នកដទៃ និង ខ្លួនយើង ។ សេចក្ដីស្រឡាញ់នេះព្យាបាលទំនាក់ទំនងយើង ហើយផ្ដល់ឱកាសឲ្យយើងស្រឡាញ់ យោគយល់ ហើយបម្រើដូចជាព្រះអង្គសង្គ្រោះបានធ្វើ ។

សេចក្ដីស្រឡាញ់ដ៏ធួនរបស់ទ្រង់បានផ្លាស់ប្ដូរគំនិតស្ដីពីភាពល្អឥតខ្ចោះរបស់យើង ។ យើងអាចទុកចិត្តលើទ្រង់ ខំប្រឹងគោរពតាមព្រះបញ្ញត្តិរបស់ទ្រង់ហើយបន្តនៅក្នុងសេចក្ដីជំនឿ ( សូមមើល ម៉ូសាយ 4:6 )—ទោះជាពេលយើងមានអារម្មណ៍ពីសេចក្ដីរាបសា អំណរគុណ និង ការពឹងផ្អែកលើព្រះគុណ សេចក្ដីមេត្តាករុណា និង ព្រះគុណរបស់ទ្រង់ក៏ដោយ ( សូមមើល នីហ្វៃទី 2 2:8 ) ។

នៅក្នុងន័យដ៏ទូលំទូលាយ ការមករកព្រះគ្រីស្ទ និង ការឲ្យបានល្អឥតខ្ចោះនៅក្នុងទ្រង់ដាក់ភាពល្អឥតខ្ចោះ នៅក្នុងដំណើរអស់កល្បជានិច្ចនៃវិញ្ញាណ និង រូបកាយរបស់យើង—ជាពិសេសដំណើរអស់កល្បជានិច្ចនៃព្រលឹងរបស់យើង ( សូមមើល គ. និង ស. 88:15 ) ។ ការប្រែក្លាយជាល្អឥតខ្ចោះកើតចេញពីដំណើររបស់យើងតាមរយៈជីវិតខាងរូបកាយ សេចក្ដីស្លាប់ និង ការរស់ឡើងវិញ នៅពេលរឿងទាំងអស់ត្រូវបានសាង « ជារូបរាងត្រឹមត្រូវ និង ល្អឥតខ្ចោះឡើងវិញ » ( អាលម៉ា 40:23 ) ។ វារួមបញ្ចូលនូវដំណើរការនៃកំណើតខាងវិញ្ញាណដែលនាំមកនូវ « ការផ្លាស់ប្ដូរយ៉ាងធំ » ដល់ដួងចិត្ត និង និស្ស័យរបស់យើង ( ម៉ូសាយ 5:2 ) ។ វាឆ្លុះបញ្ចាំងពីការផ្លាស់ប្ដូរអស់មួយជីវិតរបស់យើងតាមរយៈការបម្រើដូចជាព្រះគ្រីស្ទ និង ការគោរពប្រតិបត្តិចំពោះព្រះបញ្ញត្តិរបស់ព្រះអង្គសង្គ្រោះ និង សេចក្ដីសញ្ញារបស់យើង ។ ហើយវាស្គាល់ពីទំនាក់ទំនងយ៉ាងជិតស្និទ្ធរវាងអ្នករស់ និង អ្នកស្លាប់ ( សូមមើល គ. និង ស. 128:18 ) ។

ប៉ុន្តែពាក្យថា*ភាពល្អឥតខ្ចោះ*ពេលខ្លះត្រូវបានគេយល់ច្រឡំថាជាការគ្មានកំហុសទាល់តែសោះ ។ ប្រហែលជាអ្នក ឬមនុស្សម្នាក់ដែលអ្នកស្គាល់កំពុងខិតខំព្យាយាមយ៉ាងខ្លាំង ដើម្បីមានភាពល្អឥតខ្ចោះតាមរបៀបនេះ ។ ដោយភាពល្អឥតខ្ចោះបែបនេះទំនងដូចជាមិនអាចឈោងចាប់បាន ទោះជាយើងខិតខំអស់ពីលទ្ធភាពក្ដី ក៏វាអាចបន្សល់ទុកឲ្យយើងនូវការព្រួយបារម្ភ ការបាក់ទឹកចិត្ត ឬ ការនឿយហត់ជានិច្ចផងដែរ ។ យើងព្យាយាមគ្រប់គ្រង

*Light of the World* ដោយហោវួដ លីអូន ហាមចតចម្លង



កាលៈទេសៈរបស់យើង និងមនុស្សនៅជុំវិញ យើងតែមិនបានជោគជ័យឡើយ ។ យើង ព្រួយបារម្ភពីភាពទន់ខ្សោយ និង កំហុស ។ កាលណាយើងព្យាយាមកាន់តែខ្លាំង យើងមាន អារម្មណ៍ថាយើងកាន់តែនៅឆ្ងាយពីភាពល្អឥតខ្ចោះ ដែលយើងស្វែងរក ។

នៅក្នុងអ្វីដែលនឹងកើតឡើងតាមនោះ ខ្ញុំស្វែងរក ដើម្បីយើងមានអំណរគុណយ៉ាងជ្រាលជ្រៅសម្រាប់ គោលលទ្ធិនៃដង្វាយធួននៃព្រះយេស៊ូវគ្រីស្ទ និងសម្រាប់សេចក្តីស្រឡាញ់ និង សេចក្តីមេត្តា ករុណាដែលព្រះអង្គសង្គ្រោះបានប្រទានឲ្យ យើងដោយសេរី ។ ខ្ញុំសូមអញ្ជើញអ្នកឲ្យអនុវត្ត ការយល់ដឹងរបស់អ្នកស្តីពីគោលលទ្ធិនៃដង្វាយធួន ដើម្បីជួយខ្លួនអ្នកផ្ទាល់ និង អ្នកដទៃ រួមមាន អ្នកផ្សព្វផ្សាយសាសនា សិស្ស មជ្ឈិមវ័យវ័យ ក្មេងនៅលីវ ឪពុក ម្តាយ មេគ្រួសារទោល និង អ្នកផ្សេងទៀតដែលអាចទ្រនឹងសម្ពាធដើម្បីស្វែងរក ភាពល្អឥតខ្ចោះ ឬ ប្រែក្លាយជាល្អឥតខ្ចោះ ។



## ដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ

បានរៀបចំចាប់តាំងពីការបង្កបង្កើតលោកិយមក ( សូមមើល ម៉ូសាយ 4:6–7 ) ដង្វាយធួននៃព្រះអង្គ សង្គ្រោះរបស់យើងបានអនុញ្ញាតឲ្យយើងរៀន ប្រែចិត្ត ហើយរីកចម្រើនតាមរយៈបទពិសោធន៍ និង ការជ្រើសរើសរបស់យើង ។

ក្នុងការសាកល្បងនៅជីវិតរមែងស្លាប់ នេះ ទាំងការរីកចម្រើនខាងវិញ្ញាណ និង « ការផ្លាស់ប្តូរយ៉ាងធំ » នៃដួងចិត្ត ( អាលម៉ា 5:12, 13, ម៉ូសាយ 5:2 ) « មួយបន្ទាត់ម្តងៗ » យឺតៗ ( គ. និង ស. 98:12 ) បទពិសោធន៍ ខាងវិញ្ញាណជួយយើងឲ្យមករកព្រះគ្រីស្ទ ហើយឲ្យបានល្អឥតខ្ចោះនៅក្នុងទ្រង់ ។ ពាក្យ « កាន់ខ្ជាប់ដរាបដល់ចុងបំផុត » បាន រំឭកយើងថា ការរីកចម្រើនអស់កល្បជានិច្ច ជារឿយៗត្រូវការទាំងពេលវេលា និង ដំណើរការ ។

នៅក្នុងជំពូកចុងក្រោយនៃព្រះគម្ពីរមរមន ព្យាការីម៉ូរ៉ូណៃដ៏អស្ចារ្យបានបង្រៀន យើងអំពីរបៀបឲ្យចូលមក ហើយបានល្អ ឥតខ្ចោះនៅក្នុងព្រះគ្រីស្ទ ។ យើង « លះបង់ ចោលនូវអស់ទាំងអំពើដ៏ឥតអសុចរិត » ។ យើង « ស្រឡាញ់ព្រះឲ្យអស់ពីសមត្ថភាព អស់ពីគំនិត » ។ បន្ទាប់មកព្រះគុណរបស់ទ្រង់នឹង ល្មមគ្រប់គ្រាន់សម្រាប់យើង « ដោយសារព្រះគុណ នៃព្រះដែល [យើង] រាល់គ្នាបានល្អឥតខ្ចោះនៅ ក្នុងព្រះគ្រីស្ទ » ។ ប្រសិនបើយើង « ពុំបដិសេធ » ព្រះចេស្តានៃព្រះទេ នោះយើងអាចត្រូវបាន « ញែកចេញជាបរិសុទ្ធនៅក្នុងព្រះគ្រីស្ទដោយសារ ព្រះគុណនៃព្រះ » ដែល « មាននៅក្នុងសេចក្តីសញ្ញា នៃព្រះវរបិតាចំពោះការផ្តាច់បាប[របស់យើង] » ដើម្បីឲ្យយើងអាច « បានបរិសុទ្ធដោយគ្មាន ប្រឡាក់អ្វីសោះឡើយ » ( មរ៉ូណៃ 10:32, 33 ) ។

នៅទីបំផុត វាគឺជា « ការបូជាដ៏មហិមា និង ចុងក្រោយបង្អស់ » របស់ព្រះអង្គសង្គ្រោះដែល នាំឲ្យកើតមាននូវ « ចិត្តក្តួលមេត្តាដែលមាន អំណាចលើសេចក្តីយុត្តិធម៌ ដើម្បីនឹងនាំមកនូវ មធ្យោបាយទាំងឡាយដល់មនុស្ស ដើម្បីឲ្យគេ មានសេចក្តីជំនឿចំពោះការប្រែចិត្ត » ( អាលម៉ា 34:14, 15 ) ។ ពិតណាស់ « សេចក្តីជំនឿចំពោះ ការប្រែចិត្ត » របស់យើងគឺជាកត្តាដ៏ចាំបាច់សម្រាប់ យើងដើម្បីមករកព្រះគ្រីស្ទ ឲ្យបានល្អឥត ខ្ចោះនៅក្នុងទ្រង់ ហើយរីករាយនឹងពរជ័យ នៃ « សេចក្តីប្រោសលោះដ៏មហិមា និង អស់កល្បជានិច្ច » ( អាលម៉ា 34:16 ) ។

ការទទួលយកដង្វាយធួនរបស់ព្រះអង្គសង្គ្រោះ

**មានតែព្រះអង្គសង្គ្រោះរបស់យើង ប៉ុណ្ណោះដែលមានជីវិតល្អឥតខ្ចោះ ហើយសូម្បីតែទ្រង់ក៏បានរៀន ហើយរីកចម្រើន នៅក្នុងបទពិសោធន៍នៃជីវិតរមែងស្លាប់ដែរ ។**

នៃយើងដោយពេញលេញអាចបង្កើនសេចក្ដីជំនឿរបស់យើង ហើយវាផ្ដល់ភាពក្លាហានដល់យើង ឲ្យបំភ្លេចនូវការរំពឹងទុកដ៏បង្ខិតបង្ខំដែលយើងត្រូវបានតម្រូវឲ្យមាន ឬធ្វើរឿងដែលល្អឥតខ្ចោះ ។ ការគិតដ៏រឹងរូសបានលើកឡើងថា អ្វីៗគ្រប់យ៉ាងបើមិនមានភាពល្អឥតខ្ចោះទាំងស្រុងនោះទេ វានឹងទទួលបាននូវការខូចខាតដ៏ធ្ងន់ធ្ងរ ។ ប៉ុន្តែយើងអាចទទួលយកដោយអំណរគុណ ក្នុងនាមជាបុត្រាបុត្រីរបស់ព្រះថាយើង គឺជាការបង្កបង្កើតដ៏មហិមាបំផុតរបស់ទ្រង់ ( សូមមើល ទំនុកដំកើង 8:3–6, ហេព្រើរ 2:7 ) ទោះជាយើងនៅតែកំពុងអភិវឌ្ឍក្ដី ។

នៅពេលយើងយល់ពីសេចក្ដីស្រឡាញ់ដ៏ធំធេងដែលព្រះអង្គសង្គ្រោះនៃយើងបានប្រទានឲ្យដោយសេរី នោះយើងឈប់ភ័យខ្លាចថាទ្រង់អាចនឹងមានការកាត់សេចក្ដីរិះគន់ស្វែងរកកំហុស ។ ផ្ទុយទៅវិញ យើងទទួលអារម្មណ៍នូវការអះអាង « ពីព្រោះព្រះទ្រង់មិនបានចាត់ព្រះរាជបុត្រាទ្រង់ឲ្យមកក្នុងលោកីយ ដើម្បីនឹងជំនុំជំរះលោកីយនោះទេ គឺឲ្យលោកីយបានសង្គ្រោះដោយសារទ្រង់វិញ » ( យ៉ូហាន 3:17 ) ។ ហើយយើងយល់ថាពេលវេលា និង ដំណើរការគឺចាំបាច់សម្រាប់ការរីកចម្រើ ( សូមមើល ម៉ូសេ 7:21 ) ។

**គំរូដ៏ល្អឥតខ្ចោះរបស់យើង**

មានតែព្រះអង្គសង្គ្រោះរបស់យើងប៉ុណ្ណោះដែលមានជីវិតល្អឥតខ្ចោះ ហើយសូម្បីតែទ្រង់ក៏បានរៀន ហើយរីកចម្រើននៅក្នុងបទពិសោធន៍នៃជីវិតរមែងស្លាប់ដែរ ។ ពិតណាស់ « មុនដំបូងទ្រង់ពុំបានទទួលនូវភាពពោរពេញ ប៉ុន្តែបានព្រះគុណថែមពីលើព្រះគុណជាបន្តបន្ទាប់មករហូតដល់ទ្រង់បានទទួលនូវភាពពោរពេញ » ( គ. និង ស. 93:13 ) ។

ទ្រង់បានរៀនតាមរយៈបទពិសោធន៍នៃជីវិតរមែងស្លាប់ដើម្បី « ដាក់លើរូបអង្គទ្រង់នូវជំងឺឈឺចាប់របស់[យើង] . . . ដើម្បីទ្រង់អាចដឹងស្របតាមសាច់ឈាមថាតើទ្រង់ត្រូវជួយរាស្ត្រទ្រង់បែបណា » ( អាល់ម៉ា 7:12 ) ។ ទ្រង់មិនបានងាកទៅរកការល្បួង អំពើបាប ឬសម្ពាធប្រចាំថ្ងៃទេ ប៉ុន្តែទ្រង់បានលើកអង្គទ្រង់ឡើងនៅលើអស់ទាំងការសាកល្បង និង ឧបសគ្គនៃជីវិតរមែងស្លាប់ ( សូមមើល គ. និង ស. 122:8 ) ។

នៅក្នុងទេសនកថានៅលើភ្នំ ព្រះអង្គសង្គ្រោះបានបញ្ជាយើងថា ៖ « ចូរឲ្យអ្នករាល់គ្នាបានគ្រប់លក្ខណ៍ » ( ម៉ាថាយ 5:48 ) ។ ពាក្យ*ល្អឥតខ្ចោះ*ជាភាសាក្រិកអាចបកប្រែថា « បានអភិវឌ្ឍពេញលេញ ហើយចប់សព្វគ្រប់ទាំងស្រុង » ( នៅក្នុង ម៉ាថាយ 5:48 លេខយោង ខ ) ។ ព្រះអង្គសង្គ្រោះរបស់យើងសុំឲ្យយើងបានអភិវឌ្ឍពេញលេញ ហើយចប់សព្វគ្រប់ទាំងស្រុង—ដើម្បីឲ្យបានល្អឥតខ្ចោះនៅក្នុងគុណធម៌ និងលក្ខណៈដែលទ្រង់ និង ព្រះវរបិតាគង់នៅស្ថានសួគ៌បានបង្ហាញ ។[2]

ចូរយើងមើលឃើញពីរបៀបដែលការអនុវត្តគោលលទ្ធិនៃដង្វាយធួនអាចជួយជនដែលមានអារម្មណ៍ថា ពួកគេត្រូវការស្វែងរកភាពល្អឥតខ្ចោះ ឬឲ្យបានល្អឥតខ្ចោះ ។

**ភាពសុក្រឹតនិយម**

ការយល់ខុសពីអត្ថន័យនៃការឲ្យបានល្អឥតខ្ចោះបានផ្ដល់លទ្ធផលឲ្យជា*ភាពសុក្រឹតនិយម*—ជាឥរិយាបថ ឬអាកប្បកិរិយាមួយដែលយកបំណងប្រាថ្នាដ៏អស្ចារ្យមួយដើម្បីធ្វើល្អ ហើយបង្វែរវាទៅជាការរំពឹងទុកឲ្យបានល្អឥតខ្ចោះមិនពិតប្រាកដ*នៅពេលនេះ* ។ ពេលខ្លះភាពសុក្រឹតនិយមផុសចេញមកពីអារម្មណ៍ ដែលមានតែជនល្អឥតខ្ចោះប៉ុណ្ណោះដែលមានលទ្ធភាពនឹងទទួលបានសេចក្ដីស្រឡាញ់ ឬថាយើងមិនសមនឹងទទួលបានភាពរីករាយនោះទេ លុះត្រាយើងជាមនុស្សល្អឥតខ្ចោះ ។

ភាពសុក្រឹតនិយមអាចបង្កឲ្យមានការដេកមិនលក់ ការព្រួយបារម្ភ ការពន្យារពេល ការបាក់ទឹកចិត្ត ការមើលឃើញថាត្រូវតែខ្លួនឯង និង ការថប់បារម្ភ ។ អារម្មណ៍ទាំងនេះអាចរុញសេចក្ដីសុខសាន្ត សេចក្ដីអំណរ និង ការអះអាងដែលព្រះអង្គសង្គ្រោះសព្វព្រះទ័យឲ្យយើងមាន ។

ពួកអ្នកផ្សព្វផ្សាយសាសនាដែលចង់ឲ្យបានល្អឥតខ្ចោះ នៅពេលនេះប្រហែលជាព្រួយបារម្ភ ឬ បាក់ទឹកចិត្តប្រសិនបើការរៀនភាសាបេសកកម្មរបស់ពួកគេ ការមើលឃើញមនុស្សដែលបានជ្រមុជទឹក ឬការទទួលការចាត់តាំងជាអ្នកដឹកនាំក្នុងបេសកកម្ម មិនបានកើតឡើងភ្លាមៗនោះ ។ ចំពោះយុវវ័យមានសមត្ថភាពដែលបានសម្របខ្លួនទៅនឹងភាពជោគជ័យបេសកកម្មអាចក្លាយជាឧបសគ្គដ៏ធំដំបូងនៃជីវិត ។ ប៉ុន្តែពួកអ្នកផ្សព្វផ្សាយសាសនាអាចមានការគោរពប្រតិបត្តិទាំងស្រុងដោយពុំចាំបាច់មានភាពល្អឥតខ្ចោះ ។ ពួកគេអាចវាស់វែងជោគជ័យរបស់ពួកគេដោយការតាំងចិត្តរបស់ពួកគេ ដើម្បីជួយបុគ្គលម្នាក់ និងក្រុមគ្រួសារ « ឲ្យក្លាយជាសមាជិកសាសនាចក្រដ៏ស្មោះត្រង់ ដែលរីករាយនឹងវត្តមាននៃព្រះវិញ្ញាណបរិសុទ្ធ » ។[3]

និស្សិតទាំងឡាយចាប់ផ្ដើមឆ្នាំសិក្សាថ្មីជាពិសេសអ្នកដែលចាកចេញពីផ្ទះទៅរៀននៅមហាវិទ្យាល័យបានប្រឈមមុខទាំងសេចក្ដីរំភើប និង កង្វល់ ។ និស្សិត កីឡាករ និងសិល្បករជាដើមដោយចាប់ផ្ដើមប្រៀបដូចជា « ត្រីធំនៅក្នុងស្រះតូចមួយ » ទៅជាមានអារម្មណ៍ដូចជាត្រីតូចមួយនៅក្នុងមហាសមុទ្រមានចរន្តទឹកលឿនដែលមិនប្រាកដប្រជា ។ វាងាយស្រួយសម្រាប់និស្សិតដែលមាននិន្នាការជាអ្នកសុក្រិត្យនិយមមានអារម្មណ៍បែបនោះមិនថាពួកគេខិតខំប៉ុណ្ណានោះទេ ពួកគេនឹងបរាជ័យប្រសិនបើពួកគេមិនបានទទួលចំណាត់ថ្នាក់លេខមួយនៅក្នុងគ្រប់កិច្ចការទាំងអស់នោះ ។

ដោយគិតពិចារណាពីអ្វីដែលជីវិតត្រូវការនិស្សិតទាំងឡាយអាចរៀនថា ពេលខ្លះវាជាការជាការល្អណាស់ ដើម្បីធ្វើអ្វីៗដែលពួកគេអាចធ្វើបាន ហើយមិនអាចធ្វើបានថ្វីបើបានខំយ៉ាងអស់ពីលទ្ធភាពក្ដី ។

យើងក៏បានបង្ខំឲ្យមានការរំពឹងទុកនៃភាពល្អឥតខ្ចោះ នៅក្នុងផ្ទះរបស់យើងផ្ទាល់ផងដែរ ។ ឪពុក ឬម្ដាយម្នាក់អាចមានអារម្មណ៍បង្ខំឲ្យធ្វើជាស្វាមី ឬភរិយា ឪពុកម្ដាយ មេផ្ទះ និងជាអ្នករកស៊ីចិញ្ចឹមគ្រួសារដ៏ល្អឥតខ្ចោះ ឬជាផ្នែកនៃគ្រួសារពួកបរិសុទ្ធថ្ងៃចុងក្រោយមួយដ៏ល្អឥតខ្ចោះ—នៅពេលនេះ ។

តើអ្វីទៅអាចជួយដល់ជនដែលមាននិន្នាការជាអ្នកសុក្រិត្យនិយមបាន ? ការសួរសំណួរបើកចំហរ គាំទ្រ ជាទំនាក់ទំនងនៃការសុខចិត្តទទួល និងសេចក្ដីស្រឡាញ់ ។ វាធ្វើឲ្យអ្នកដទៃផ្ដោតទៅលើគំនិតវិជ្ជមាន ។ វា

*Jesus as a Youth in the Carpenter's Shop* ដោយដែល ឆាំស៊ុន

អនុញ្ញាតឲ្យយើងបញ្ជាក់ដល់អារម្មណ៍របស់យើង ថាមានដំណាក់ការល្អ ។ គ្រួសារ និង មិត្តភក្តិអាច ជៀសវាងពីការប្រៀបធៀបដែលមានលក្ខណៈជាការ ប្រកួតប្រជែង ប៉ុន្តែផ្ទុយទៅវិញផ្តល់ការលើកទឹកចិត្ត ដោយស្មោះស ។

កត្តាដ៏ធ្ងន់ធ្ងរមួយទៀតនៃអ្នកសុក្រិត្យនិយម គឺដើម្បីតម្រូវឲ្យអ្នកដទៃរស់នៅតាមបទដ្ឋានមិន ពិតប្រាកដ មានការរិះគន់ ឬមិនអាចលើកលែង បានរបស់យើង ។ ពិតណាស់ ឥរិយាបថ បែបនេះបានបដិសេធ ឬកំណត់ពរជ័យនៃដង្វាយ ធួនរបស់ព្រះអង្គសង្គ្រោះនៅក្នុងជីវិតរបស់យើង និង នៅក្នុងជីវិតអ្នកដទៃ ។ ឧទាហរណ៍ ពួក មជ្ឈិមវ័យវ័យក្មេងនៅលីវអាចបង្កើតជាបញ្ជី មួយស្តីពីគុណសម្បត្តិ ដែលខ្លួនចង់បាន សម្រាប់ស្វាមី ឬភរិយានាពេលអនាគត ប៉ុន្តែមិន អាចរៀបការបាន ដោយសារតែការរំពឹងទុកមិនពិត ប្រាកដចំពោះដៃគូដ៏ឥតខ្ចោះនោះ ។

ដូច្នេះ បងប្អូនស្រីម្នាក់អាចមិនព្រមគិតពី ការដើរលេងជាគូនឹងបងប្អូនប្រុសដ៏សក្តិសម ម្នាក់ដែលមិនគ្រប់លក្ខណៈសម្បត្តិចំពោះកម្រិត នៃភាពសុក្រិត្យនិយមរបស់នាង—ដូចជាគាត់ រាំមិនបានល្អ គាត់គ្មានផែនការនឹងក្លាយជាអ្នក មានស្តុកស្តម គាត់មិនបានបម្រើបេសកកម្ម ឬបានសារភាពនូវបញ្ហាពីអតីតជាមួយ នឹង រូបភាពអាសគ្រាមដែលបានដោះស្រាយ រួចរាល់ហើយតាមរយៈការប្រែចិត្ត និង ការ ប្រឹក្សានោះ ។

ស្រដៀងគ្នានេះដែរ បងប្អូនប្រុសម្នាក់មិន បានគិតពីការដើរលេងជាគូនឹងបងប្អូនស្រីសក្តិ សមម្នាក់ដែលមិនសក្តិសមនឹងបទដ្ឋានដែលមិន ពិតប្រាកដរបស់ខ្លួន—ដូចជានាងមិនចូលចិត្ត កីឡា នាងពុំមែនជាប្រធានសមាគមសង្គ្រោះ នាង ពុំមែនជាស្ត្រីដ៏ស្រស់ស្អាត នាងពុំមានជំនាញ ជាអ្នកគ្រប់គ្រងថវិកា ឬនាងបានសារភាពពីបញ្ហា កាលពីមុនជាមួយនឹងពាក្យសម្តីនៃប្រាជ្ញារាងវៃ ដែលឥឡូវបានដោះស្រាយរួចហើយ ។

ពិតណាស់ យើងគួរគិតពីគុណសម្បត្តិដែល យើងចង់បាននៅក្នុងខ្លួនយើង និង នៅក្នុង ស្វាមី ឬភរិយានាពេលអនាគត ។ យើងគួររក្សា សេចក្តីសង្ឃឹម និង បទដ្ឋានដ៏ខ្ពស់បំផុតរបស់ យើង ។ ប៉ុន្តែ ប្រសិនបើយើងមានចិត្តរាបសា យើង នឹងភ្ញាក់ផ្អើលចំពោះសេចក្តីល្អ នៅក្នុងទីកន្លែងដែល មិនរំពឹងទុក ហើយយើងអាចបង្កើតឱកាស ដើម្បី ខិតទៅជិតមនុស្សម្នាក់ទៀតដែលជាមនុស្សមិន ល្អឥតខ្ចោះដូចជាយើងដែរ ។

សេចក្តីជំនឿទទួលស្គាល់ថា តាមរយៈ ការប្រែចិត្ត និងអំណាចនៃដង្វាយធួន ភាពទន់ ខ្សោយបានធ្វើឲ្យរឹងមាំ ហើយអំពើបាបដែលបាន ប្រែចិត្តអាចទទួលបានការអត់ទោសឲ្យយ៉ាងពិត ។

អាពាហ៍ពិពាហ៍ដ៏រីករាយពុំមែនកើតឡើង ចេញពីមនុស្សល្អឥតខ្ចោះពីរនាក់និយាយពាក្យ សច្ចានោះទេ ។ ផ្ទុយទៅវិញ ការលះបង់ និង សេចក្តីស្រឡាញ់កាន់តែរីកធំឡើង នៅពេលមនុស្ស មិនល្អឥតខ្ចោះពីរនាក់គាំទ្រគ្នា ប្រទានពរឲ្យគ្នា ជួយគ្នា និងអត់ទោសឲ្យគ្នាជានិច្ច ។ មាន ភរិយានៃព្យាការីសម័យទំនើបម្នាក់ នាគ្រាមួយ ត្រូវបានគេសួរថាតើការរៀបការជាមួយនឹង ព្យាការីមានអារម្មណ៍បែបណាដែរ ។ គាត់បាន តបដោយឈ្លាសវៃថា គាត់មិនបានរៀបការនឹង ព្យាការីទេ គាត់គ្រាន់តែរៀបការនឹងបុរសម្នាក់ដែល មានការលះបង់ទាំងស្រុងចំពោះសាសនាចក្រ មិន ថាគាត់ទទួលបានការហៅអ្វីនោះទេ ។[4] និយាយ ម្យ៉ាងទៀត ស្វាមី និងភរិយារីកចម្រើនរួមគ្នា— ទាំងខ្លួនឯង និងជាគូស្វាមីភរិយា ។

ការរង់ចាំស្វាមី ឬភរិយា ការអប់រំ ការងារ ឬផ្ទះដ៏ល្អឥតខ្ចោះនឹងមានរយៈពេលវែង ហើយ ឯកោ ។ យើងឈ្លាសវៃដើម្បីធ្វើតាម ព្រះវិញ្ញាណនៅក្នុងការសម្រេចចិត្តដ៏សំខាន់នៃ ជីវិត ហើយមិនត្រូវឲ្យការសង្ស័យដែលកើតចេញ ពីតម្រូវការនៃភាពល្អឥតខ្ចោះរារាំងការរីកចម្រើន របស់យើងឡើយ ។

ចំពោះជនដែលអាចមានអារម្មណ៍ថាមានបន្ទុក ឬការព្រួយបារម្ភ រ៉ៃ សូមសួរខ្លួនអ្នកដោយស្មោះថា « តើខ្ញុំបានកំណត់ន័យ*ភាពល្អឥតខ្ចោះ* និង *ភាពជោគជ័យ* តាមគោលលទ្ធិនៃ សេចក្តីស្រឡាញ់ដ៏ធួនរបស់ព្រះអង្គសង្គ្រោះ ឬ តាមបទដ្ឋានរបស់ពិភពលោកដែរឬទេ ? តើខ្ញុំបាន វាស់វែង*ភាពជោគជ័យ* ឬ *ភាពបរាជ័យ* ដោយ ព្រះវិញ្ញាណបរិសុទ្ធដែលបញ្ជាក់បំណងប្រាថ្នា ដ៏សុចរិតរបស់ខ្ញុំ ឬតាមបទដ្ឋានមួយចំនួនរបស់ លោកិយ ? »

ចំពោះជនដែលមាន អារម្មណ៍នឿយហត់ខាងរូបកាយ ឬខាង ផ្លូវចិត្ត សូមចាប់ផ្តើមទទួលទានដំណេក សម្រាកតាមធម្មតា ហើយមានពេលដើម្បី ទទួលទានអាហារ និងសម្រាក ។ សូមដឹងថា ការមានភាពមមាញឹកមិនដូចគ្នានឹងការមាន ភាពសក្តិសម ហើយការមានភាពសក្តិសមមិន តម្រូវឲ្យមានភាពល្អឥតខ្ចោះនោះទេ ។[5]

ចំពោះជនដែលឆាប់មើលឃើញពី ភាពទន់ខ្សោយ ឬកំហុសផ្ទាល់ខ្លួន សូម រីករាយដោយអំណរគុណ ចំពោះកិច្ចការទាំងឡាយ ដែលអ្នកធ្វើបានល្អ ទាំងតូច ឬធំ ។

ចំពោះជនដែលភ័យខ្លាចនឹងភាពបរាជ័យ និងអ្នកដែលពន្យារពេល ពេលខ្លះដោយការ រៀបចំខ្លួនច្រើនពេក សូមធ្វើឲ្យប្រាកដ ហើយ លើកទឹកចិត្តថា ពុំចាំបាច់ត្រូវដកខ្លួនចេញពី សកម្មភាពលំបាកៗដែលអាចនាំមកនូវការ រីកចម្រើនដ៏អស្ចារ្យនោះទេ !

បើចាំបាច់ ហើយសមរម្យ សូមស្វែងរកការប្រឹក្សា ខាងវិញ្ញា ឬទទួលការមើលថែលខាងវេជ្ជសាស្ត្រ ដើម្បីជួយអ្នកឲ្យសម្រាក អភិវឌ្ឍគំនិតវិជ្ជមាន ហើយ រៀបចំជីវិតរបស់អ្នក កាត់បន្ថយឥរិយាបថការពារ ខ្លួនឯង ហើយទទួលបទពិសោធន៍ ព្រមទាំងសម្តែង អំណរគុណបន្ថែមទៀត ។[6]

ការខ្វះភាពអត់ធ្មត់រារាំងនូវសេចក្តីជំនឿ ។ សេចក្តីជំនឿ និង ការអត់ធ្មត់នឹងជួយពួក អ្នកផ្សព្វផ្សាយសាសនាឲ្យយល់នូវភាសា ឬ វប្បធម៌ថ្មីមួយ ជួយនិស្សិតឲ្យរៀនប្រធានបទ ថ្មីៗ ហើយជួយមជ្ឈិមវ័យវ័យក្មេងនៅលីវឲ្យ ចាប់ផ្តើមស្ថាបនាទំនាក់ទំនងនានាជាជាងរង់ចាំឲ្យ អ្វីៗគ្រប់យ៉ាងបានល្អឥតខ្ចោះ ។ សេចក្តីជំនឿ និង ការអត់ធ្មត់ក៏ជួយជនដែលកំពុងរង់ចាំសម្រាប់សិទ្ធិ អនុញ្ញាតឲ្យផ្សារភ្ជាប់ក្នុងព្រះវិហារបរិសុទ្ធ ឬ ការស្តារឡើងវិញនៃពរជ័យនៃបព្វជិតភាពផងដែរ ។

ពេលយើងធ្វើសកម្មភាព ដោយមិនបណ្តោយ ឲ្យសកម្មភាពកើតឡើងចំពោះយើង ( សូមមើល នីហ្វៃទី 2 2:14 ) យើងអាចរស់នៅក្នុងជីវិតមួយ នៃគុណធម៌ដែលមានតុល្យភាព ហើយសម្រេច បាននូវការរីកចម្រើនយ៉ាងច្រើននៅក្នុង



**ចំពោះជនដែលធាប់មើលឃើញភាពទន់ខ្សោយ ឬកំហុសផ្ទាល់ខ្លួន សូមរីករាយជាមួយនឹងអំណរគុណចំពោះកិច្ចការទាំងឡាយដែលអ្នកធ្វើបានល្អទាំងតូច ឬធំ ។**

ជីវិត ។ ការណ៍ទាំងនេះអាចលេចឡើងជា « ការផ្ទុយ » ដោយក្លាយជា « រូបកាយតែមួយ » ( នីហ្វៃទី 2 2:11 ) ។

ឧទាហរណ៍ យើងអាចឈប់មានចិត្តខ្ជិលច្រអូស ( សូមមើល គ. និង ស. 88:124 ) ដោយមិនរត់លឿនជាងកម្លាំងដែលយើងមាន ( សូមមើល ម៉ូសាយ 4:27 ) ។

យើងអាច « ឧស្សាហ៍ចូលរួមកម្មប្រយោជន៍ល្អ » ( គ. និង ស. 58:27 ) ខណៈដែលត្រូវឈប់ម្តងម្កាលផងដែរដើម្បី « បង្អង់សិន ដោយបានដឹងថាយើងជាព្រះ » ( ទំនុកដំកើង 46:10, សូមមើលផងដែរ គ. និង ស. 101:16 ) ។

យើងអាចរកឃើញជីវិតរបស់យើងដោយការលះបង់ជីវិតយើង សម្រាប់បុព្វហេតុរបស់ព្រះអង្គសង្គ្រោះ ( សូមមើល ម៉ាថាយ 10:39, 16:25 ) ។

យើងមិនអាច « ណាយចិត្តនឹងធ្វើការល្អឡើយ » ( គ. និង ស. 64:33 សូមមើលផងដែរ កាឡាទី 6:9 ) ខណៈដែលចំណាយពេលដ៏សមរម្យដើម្បីធ្វើឲ្យជីវិតខាងវិញ្ញាណ និង ខាងរូបកាយបានស្រស់ស្រាយឡើងវិញ ។

យើងអាចមានចិត្តរីករាយដោយគ្មានការទ្រគោះបោះបោក ។

យើងអាចសើចសប្បាយជាមួយមនុស្សម្នាក់ ប៉ុន្តែពុំមែនសើចដោយអំនួតឡើយ ។

ព្រះអង្គសង្គ្រោះរបស់យើង និង ដង្វាយធួនរបស់ទ្រង់បានអញ្ជើញយើងឲ្យ « មករកព្រះគ្រីស្ទ » ហើយឲ្យបានល្អឥតខ្ចោះនៅក្នុងទ្រង់ » ។ នៅពេលយើងធ្វើដូច្នោះ ទ្រង់សន្យាថាព្រះគុណរបស់ទ្រង់ « ល្មមដល់អ្នកហើយ ដោយសារព្រះគុណនៃព្រះ នោះអ្នករាល់គ្នាអាចបានល្អឥតខ្ចោះ » ( មរ៉ូណៃ 10:32 ) ។

ចំពោះជនដែលមានបន្ទុកធ្ងន់ដោយសារកង្វល់ស្វែងរកភាពល្អឥតខ្ចោះ ឬឲ្យបានល្អឥតខ្ចោះនៅពេលនេះ សេចក្តីស្រឡាញ់ដ៏ធួនដែលព្រះអង្គសង្គ្រោះរបស់យើងបានប្រទានឲ្យដោយសេរីជានាដល់យើងថា ៖

« អស់អ្នកដែលនឿយព្រួយ ហើយផ្ទុកធ្ងន់អើយ ចូរមកឯខ្ញុំ ខ្ញុំនឹងឲ្យអ្នករាល់គ្នាឈប់សម្រាក ។

«. . . ពីព្រោះនឹមខ្ញុំងាយទេ ហើយបន្ទុកខ្ញុំក៏ស្រាល » ( ម៉ាថាយ 11: 28–30 ) ។[7] ■

**កំណត់ចំណាំ**

1. « I Feel My Savior's Love » *Children's Songbook* ទំព័រ 75 ។
2. សូមមើលផងដែរ រ័សុល អិម ណិលសុន « Perfection Pending » *Ensign* ខែ វិច្ឆិកា ឆ្នាំ 1995 ទំព័រ 86–88 ។
3. *ប្រកាសដំណឹងល្អរបស់យើង ៖ មគ្គុទេសន៍ចំពោះការបម្រើជាអ្នកផ្សព្វផ្សាយសាសនា* ( ឆ្នាំ 2004 )ទំព័រ 10 ។
4. សូមមើល Lavina Fielding « Camilla Kimball: Lady of Constant Learning » *Ensign* ខែ តុលា ឆ្នាំ 1975 ទំព័រ 62 ។
5. ឧទាហរណ៍ សូមមើល ឌៀថើរ អេហ្វ អុជដូហ្វ « Four Titles » *Liahona* ខែ ឧសភា ឆ្នាំ 2013 ទំព័រ 58–61 ។ ប្រធានអុជដូហ្វក៏បានព្រមានផងដែរថា « មានមនុស្សមួយចំនួនអាចគិតផងដែរថា តម្លៃផ្ទាល់ខ្លួនរបស់ពួកគេអាស្រ័យទៅលើប្រវែងនៃបញ្ជីការងារដែលពួកគេបានធ្វើ » « Of Things That Matter Most »*Liahona* ខែវិច្ឆិកា ឆ្នាំ 2010 ទំព័រ 20 ។
6. គំនិតនេះបានមកពី ខាឡុស អេហ្វ និង អាទ្បែន ខែ វ៉តខីនស៍ អ្នកប្រឹក្សាខាងសុខភាពផ្លូវចិត្តនៅតំបន់អាស៊ី បានចាត់តាំងនៅហុងកុង ។ គំនិតផ្សេងទៀតសម្រាប់អត្ថបទនេះបានមកពី ស៊ូសាន ហ្គុង ឡារី វ៉ាយ និង លីដាន វិលសិន រេនឌី ឌី និង អាន់ឌ្រា ហ្វាំង ជេនិត អេសហ្សាមិន និងពួកអ្នកផ្សព្វផ្សាយសាសនានៅបេសកកម្មចាកាតាឥណ្ឌូណេស៊ី ។
7. សូមមើលផងដែរ សេស៊ីល អូ សាំយ៉ូអែលសុន « What Does It Mean to Be Perfect? » *New Era* ខែ មករា ឆ្នាំ 2006 ទំព័រ 10–13, ជេនិត អេស ស្កាមិន « Seeking Perfection without Being a Perfectionist » នៅក្នុង *Virtue and the Abundant Life ៖ Talks from the BYU Religious Education and Wheatley Institution Symposium,* រៀបរៀងដោយ ឡយដ៏ ឌី ញ៉ូវែល និង អ្នកផ្សេងទៀត (ឆ្នាំ 2012) ទំព័រ 280–302 ។

# សេចក្ដីសញ្ញាដ៏ទេវភាព

## ធ្វើឲ្យមានពួកគ្រីស្ទានដ៏រឹងមាំ

*តើអ្វីទៅដែលជាការធ្វើ និង ការរក្សាសេចក្ដីសញ្ញាជាមួយព្រះដែលផ្ដល់អំណាចឲ្យយើងនោះ ?*



**ដោយអែលឌើរ ឌី ថត គ្រីស្ដូហ្វឺសិន**
នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់

នៅថ្ងៃទី 15 ខែ សីហា ឆ្នាំ 2007 ប្រទេសប៉េរូ បានទទួលរងនូវការរញ្ជួយដីមួយដ៏ធំ ដែលបានបំផ្លាញទីក្រុងនៅលើឆ្នេរសមុទ្រឈ្មោះពីស្កូ និង ឈីនឆា ។ ដូចជាថ្នាក់ដឹកនាំ និង សមាជិកសាសនាចក្រដទៃទៀតជាច្រើនផងដែរ ក្រុងវ៉ែនសេសឡោ ខុនដេ ជាប្រធានសាខាបាលកុនស៊ីតូ របស់សាសនាចក្រនៅទីក្រុងឈីនឆា បានជួយភ្លាមៗដល់អស់អ្នកដែលផ្ទះសម្បែងរបស់ពួកគេត្រូវបានបំផ្លាញ ។

បួនថ្ងៃក្រោយពីការរញ្ជួយដីនោះ អែលឌើរម៉ាកុស ប៊ី ណាស្ស នៃពួកចិតសិបនាក់បាននៅក្នុងទីក្រុងឈីនឆា ដើម្បីជួយរៀបចំសមត្ថភាពជួយសង្គ្រោះរបស់សាសនាចក្រនៅទីនោះ ហើយបានជួបនឹងប្រធាន ខុនដេ ។ នៅពេលពួកគាត់បានពិភាក្សាពីការបំផ្លិចបំផ្លាញដែលបានកើតឡើង និង អ្វីដែលបានធ្វើដើម្បីជួយដល់ជនរងគ្រោះ ភរិយារបស់ប្រធាន ខុនដេ ឈ្មោះ ប៉ាមេឡា បានមកដល់ដោយមានបីកូនតូចរបស់នាងម្នាក់នៅក្នុងដៃ ។ អែលឌើរ ណាស្ស បានសួរបងស្រី ខុនដេ ថា តើកូនរបស់នាងយ៉ាងម៉េចដែរ ។ នាងបានតបទាំងញញឹមថា តាមរយៈព្រះគុណនៃព្រះពួកគេទាំងអស់មានសុវត្ថិភាព ។ គាត់បានសួរពីផ្ទះរបស់គ្រួសារខុនដេ ។

នាងបានតបដោយសាមញ្ញថា « វាខ្ទេចខ្ទីអស់ហើយ » ។

« ចុះទ្រព្យសម្បត្តិរបស់បងស្រីវិញ? » គាត់បានសួរ ។

បងស្រីខុនដេបានតបថា « អ្វីៗគ្រប់យ៉ាងបានកប់នៅក្រោមគំនរផ្ទះយើង » ។

អែលឌើរនែសហ៍ បានពោលថា « ប៉ុណ្ណឹងហើយ បងស្រីនៅនិយាយទាំងញញឹមទៀត » ។

នាងតបថា « មែនហើយ ខ្ញុំបានអធិស្ឋាន ហើយខ្ញុំមានសេចក្ដីសុខសាន្ត ។ យើងមានអ្វីដែលយើងត្រូវការ ។ យើងមានភាពជិតស្និទ្ធនឹងគ្នា យើងមានកូនចៅយើង យើងបានផ្សារភ្ជាប់នៅក្នុងព្រះវិហារបរិសុទ្ធ យើងមានសាសនាចក្រដ៏អស្ចារ្យ ហើយយើងមានព្រះអម្ចាស់ ។ យើងអាចសង់វាម្ដងទៀតបានដោយមានជំនួយពីព្រះអម្ចាស់ » ។

### អំណាចនៃសេចក្ដីសញ្ញា

តើអ្វីទៅជាប្រភពនៃអំណាចខាងសីលធម៌ និង ខាងវិញ្ញាណបែបនេះ ហើយតើយើងទទួលបានវាតាមរបៀបណា ? ប្រភពនោះគឺជាព្រះ ។ សិទ្ធិរបស់យើងដើម្បីទទួលបានអំណាចនោះគឺតាមរយៈសេចក្ដីសញ្ញារបស់យើងនឹងទ្រង់ ។ ធ្វើសេចក្ដីសញ្ញាគឺជាកិច្ចព្រមព្រៀងមួយរវាងព្រះ និង មនុស្ស។ វាជាកិច្ចព្រមព្រៀងមួយដែលព្រះជាអ្នកកំណត់នូវលក្ខខណ្ឌ ។[1] នៅក្នុងកិច្ចព្រមព្រៀងដ៏ទេវភាពទាំងនេះ ព្រះបានសន្យាដើម្បីគាំទ្រ ញែកឲ្យបរិសុទ្ធ ហើយលើកតម្កើងយើង ក្នុងការត្រឡប់ទៅកាន់ការតាំងចិត្តដើម្បីបម្រើទ្រង់ ហើយរក្សាព្រះបញ្ញត្តិរបស់ទ្រង់ ។

តើអ្វីទៅជាការធ្វើ និង ការរក្សាសេចក្ដីសញ្ញាជាមួយនឹងព្រះ ដែលផ្ដល់អំណាចឲ្យយើងញញឹមនៅក្នុងគ្រាដ៏លំបាក ដើម្បីកែប្រែទុក្ខព្រួយទៅជាជ័យជំនះ ដើម្បី « ឧស្សាហ៍ចូលរួមក្នុងប្រយោជន៍ល្អ . . . ហើយនាំមកនូវសេចក្ដីសុចរិតដ៏ច្រើន » ( គ. និង ស. 58:27 ) ?

## បានពង្រឹងដោយអំណោយទាន និង ពរជ័យ

ដំបូង នៅពេលដើរនៅក្នុងការគោរពប្រតិបត្តិទៅនឹងគោលការណ៍ និង ព្រះបញ្ញត្តិនៃដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ យើងរីករាយចំពោះព្រះពរដែលមានបង្ហូរមកជាបន្តបន្ទាប់ ដែលព្រះបានសន្យានៅក្នុងសេចក្ដីសញ្ញារបស់ទ្រង់ជាមួយនឹងយើង ។ ពរជ័យទាំងនោះបានផ្ដល់ជាធនធានដែលយើងត្រូវការដើម្បីធ្វើសកម្មភាពជាជាងទទួលសកម្មភាពនៅពេលយើងបន្ដដំណើរនៅក្នុងជីវិតនេះ ។ ឧទាហរណ៍ ព្រះបញ្ញត្តិរបស់ព្រះអម្ចាស់នៅក្នុងពាក្យសម្ដីនៃប្រាជ្ញាវាងវៃទាក់ទងនឹងការមើលថែរូបកាយរបស់យើងបានប្រទានដល់យើងដែលជារឿងដំបូងហើយសំខាន់បំផុតគឺ « ប្រាជ្ញា និង ផលថ្លៃវិសេសនៃចំណេះវិជ្ជា គឺជាសម្បត្តិដែលលាក់ទុក » ( គ. និង ស. 89:19 ) ។ លើសពីនេះទៀត ជាទូទៅវាដឹកនាំទៅរកជីវិតដែលមានសុខភាពល្អ និង សេរីភាពពីការញៀនដ៏បំផ្លិចបំផ្លាញ ។ ការគោរពប្រតិបត្តិផ្ដល់ឲ្យយើងនូវការគ្រប់គ្រង កាន់តែតែច្រើនលើជីវិតយើង មានសមត្ថភាពកាន់តែច្រើនដើម្បីផ្លាស់ប្ដូរ ដើម្បីធ្វើការ និង បង្កើត ។ ពិតណាស់ អាយុ គ្រោះថ្នាក់ និង ជំងឺតែងជ្រៀតជ្រែកចូលមកក្នុងជីវិតរបស់យើង ប៉ុន្តែទោះជាយ៉ាងនោះក្ដី ការគោរពប្រតិបត្តិរបស់យើងចំពោះក្រិត្យវិន័យនៃដំណឹងល្អ បង្កើនសមត្ថភាពរបស់យើងដើម្បីប្រឈមមុខនឹងឧបសគ្គទាំងនេះ ។

នៅលើផ្លូវនៃសេចក្ដីសញ្ញានោះ យើងបានរកឃើញនូវប្រភពដ៏រឹងមាំមួយនៃអំណោយទាន និង ជំនួយ ។ « សេចក្ដីសប្បុរសពុំបាត់បង់ទៅឡើយ » ( កូរិនថូសទី 1 13:8, មរ៉ូណៃ 7:46 ) សេចក្ដីស្រឡាញ់នាំមកនូវសេចក្ដីស្រឡាញ់ សេចក្ដីមេត្តានាំមកនូវសេចក្ដីមេត្តា គុណធម៌នាំមកនូវគុណធម៌ ការតាំងចិត្តនាំមកនូវភាពស្មោះត្រង់ ហើយការបម្រើនាំមកនូវសេចក្ដីអំណរ ។ យើងជាផ្នែកមួយក្នុងរាស្ត្រនៃសេចក្ដីសញ្ញា ជាសហគមន៍មួយនៃពួកបរិសុទ្ធដែលលើកទឹកចិត្ត គាំទ្រ ហើយបម្រើគ្នាទៅវិញទៅមក ។ ដូចជានីហ្វៃបានពន្យល់ថា « ហើយបើសិនជាកូនចៅមនុស្សកាន់តាមព្រះបញ្ញត្តិទាំងឡាយនៃព្រះ នោះទ្រង់នឹងចិញ្ចឹមគេ ហើយផ្ដល់កម្លាំងដល់គេ » ( នីហ្វៃទី 1 17:3 ) ។



## បានពង្រឹងដោយសេចក្ដីជំនឿដែលកើនឡើង

ការណ៍នេះនាំយើងទៅរកវិធីទីពីរដែលសេចក្ដីសញ្ញារបស់យើងផ្ដល់កម្លាំង—វាបង្កើតនូវសេចក្ដីជំនឿដ៏ចាំបាច់ដើម្បីបន្ត ហើយធ្វើនូវរឿងគ្រប់យ៉ាងដែលចាំបាច់ចំពោះព្រះអម្ចាស់ ។ ឆន្ទៈរបស់យើងដើម្បីលើកមកដាក់លើខ្លួនយើងនូវព្រះនាមនៃព្រះគ្រីស្ទ ហើយគោរពព្រះបញ្ញត្តិរបស់ទ្រង់តម្រូវឲ្យមានជំហាននៃសេចក្ដីជំនឿ ប៉ុន្តែនៅពេលយើងគោរពសេចក្ដីសញ្ញារបស់យើង នោះសេចក្ដីជំនឿនឹងកើនឡើង ។ ទីមួយ ផលផ្លែនៃការគោរពប្រតិបត្តិដែលបានសន្យា ក្លាយទៅជាភស្តុតាងពិត បញ្ជាក់ពីសេចក្ដីជំនឿរបស់យើង ។ ទីពីរ ព្រះវិញ្ញាណផ្ដល់ជាទំនាក់ទំនងនូវសេចក្ដីរីករាយរបស់ព្រះ ហើយយើងមានអារម្មណ៍ថា មានសុវត្ថិភាពនៅក្នុងពរជ័យ និង ជំនួយជាបន្តបន្ទាប់របស់ទ្រង់ ។ ទីបី ទោះជាមានអ្វីកើតឡើងក៏ដោយ យើងអាចប្រឈមមុខនឹងជីវិតដោយមានសេចក្ដីសង្ឃឹម និង ភាពនឹងនរ ដោយដឹងថា នៅចុងបញ្ចប់ យើងនឹងបានជោគជ័យ ដោយសារយើងមានការសន្យាដែលព្រះបានប្រទានឲ្យយើងម្នាក់ៗ ហើយយើងដឹងថាទ្រង់មិនកុហកនោះឡើយ ( សូមមើល អេណុស 1:6, នាងអេសធើរ 3:12 ) ។

ថ្នាក់ដឹកនាំសាសនាចក្រនៅក្នុងការកាន់កាប់ត្រួតត្រានេះកាលពីមុនបានបញ្ជាក់ថា ការដើរតាមផ្លូវនៃសេចក្ដីសញ្ញាផ្ដល់នូវការធានាដែលយើងត្រូវការនៅក្នុងគ្រាសាកល្បង ៖ « វាគឺជា [ចំណេះដំណឹងថា ផ្លូវជីវិតរបស់ពួកគេត្រូវធ្វើតាមព្រះទ័យរបស់ព្រះ] នោះហើយដែលជួយពួកបរិសុទ្ធកាលពីបុរាណឲ្យស៊ូទ្រាំរាល់ទុក្ខលំបាក និង ការបៀតបៀនរបស់ពួកគេ មិនមែនគ្រាន់តែ . . . បំផ្លាញទ្រព្យសម្បត្តិពួកគេ ហើយខាត់បង់ស្បៀងអាហាររបស់ខ្លួនប៉ុណ្ណោះទេ ប៉ុន្តែក៏រងនូវសេចក្ដីស្លាប់នៅក្នុងទម្រង់យ៉ាង ព្រៃផ្សៃបំផុតផងដែរ ដោយដឹង ( ពុំមែនគ្រាន់តែជឿនោះទេ ) ថា នៅពេលទីលំនៅរបស់ពួកគេនៅលើផែនដីនេះត្រូវបំផ្លាញ នោះពួកគេមានវិមានលោកីយនៃរូបកាយនេះត្រូវបានរលាយអស់ទៅ ថាពួកគេមានដំណាក់នៃព្រះដែលមិនបានសាងឡើងដោយមនុស្ស លោកដ៏នៅអស់កល្បជានិច្ច នៅក្នុងស្ថានសួគ៌ ។ ( 2 កូរិន. 5:1 ) » ។[2]

ពួកគេបានចង្អុលបង្ហាញទៀតថា នៅក្នុងការលះបង់អ្វីក៏ដោយដែលព្រះបានបញ្ជាដល់យើង យើងទទួលសាក្សីនៃព្រះវិញ្ញាណថា យើងបានធ្វើត្រឹមត្រូវ ហើយបានធ្វើឲ្យព្រះសព្វព្រះហឫទ័យ ។[3] ដោយមានចំណេះដឹងនោះ សេចក្ដីជំនឿរបស់យើងនឹងរីកចម្រើនដោយឥតព្រំដែន ដោយមានការអះអាងថាព្រះនឹងបង្វែររាល់ទុក្ខលំបាកទៅជាប្រយោជន៍របស់អ្នកវិញនៅពេលកំណត់មួយ ។ ( សូមមើល គ. និង ស. 97:8–9 ) ។



## បានពង្រឹងតាមរយៈ « ព្រះចេស្ដានៃព្រះ »

យើងបានពិភាក្សា ទីមួយ ពរជ័យដែលប្រទានឲ្យ និងទីពីរ អំណោយទាននៃសេចក្ដីជំនឿដែលព្រះប្រទានឲ្យជនដែលរក្សាសេចក្ដីសញ្ញារបស់ពួកគេជាមួយនឹងទ្រង់ ។ កត្តាចុងក្រោយនៃកម្លាំងតាមរយៈសេចក្ដីសញ្ញាដែលខ្ញុំនឹងលើកឡើងគឺការប្រទានឲ្យនូវអំណាចដ៏ទេវភាព ។ ការតាំងចិត្តរបស់យើងចំពោះទ្រង់នៅក្នុងសេចក្ដីសញ្ញា អនុញ្ញាតឲ្យព្រះវរបិតាសួគ៌យើងអនុវត្តនូវព្រះចេស្ដាដ៏ទេវភាពរបស់ទ្រង់ « អំណាចនៃព្រះ » ( គ. និង ស. 84:20 ) កើតមាននៅក្នុងជីវិតរបស់យើង ។ ទ្រង់អាចធ្វើការណ៍នោះបានដោយសារការចូលរួមរបស់យើង នៅក្នុងពិធីបរិសុទ្ធនៃបព្វជិតភាព យើងអនុវត្តសិទ្ធិជ្រើសរើសរបស់យើង ហើយបានរើសតាំងដើម្បីទទួលវា ។ ការចូលរួមរបស់យើងនៅក្នុងពិធីបរិសុទ្ធទាំងនោះក៏បង្ហាញថា យើងបានរៀបចំខ្លួនដើម្បីទទួលយកទំនួលខុសត្រូវបន្ថែមទៀតដែលកើតមានជាមួយនឹងពន្លឺបន្ថែមទៀត និង អំណាចខាងវិញ្ញាណផងដែរ ។

នៅរាល់ពិធីបរិសុទ្ធ ជាពិសេសនៅក្នុងព្រះវិហារបរិសុទ្ធ យើងត្រូវបានប្រទានឲ្យជាមួយនឹងអំណាចពីស្ថានសួគ៌ ( សូមមើល គ. និង ស. 109:22 ) ។ « អំណាចនៃព្រះ » នេះកើតមាននៅក្នុងមនុស្ស ហើយដោយព្រះចេស្ដានៃព្រះវិញ្ញាណបរិសុទ្ធ ។ អំណោយទានព្រះវិញ្ញាណបរិសុទ្ធគឺជាផ្នែកនៃសេចក្ដីសញ្ញាថ្មី ហើយអស់កល្បអស់កាលជានិច្ច ។ វាគឺជាផ្នែកមួយដ៏ចាំបាច់នៃបុណ្យជ្រមុជទឹករបស់យើង ជាបុណ្យជ្រមុជទឹកនៃព្រះវិញ្ញាណ ។ វាគឺជាសារទូតនៃព្រះគុណដែលលោហិតនៃព្រះគ្រីស្ទត្រូវបានអនុវត្តដើម្បីយកអំពើបាបចេញពីយើង ហើយញែកយើងឲ្យបរិសុទ្ធ ( សូមមើល នីហ្វៃទី 2 31:17 ) ។ វាគឺជាអំណោយទានដែលអ័ដាមត្រូវបាន « ក្លាយទៅជាមនុស្សដែលបានប្រោសខាងក្នុង » ( ម៉ូសេ 6:65 ) ។ ដោយសារតែព្រះវិញ្ញាណបរិសុទ្ធទើបពួកព្យាការីពីបុរាណបានស៊ូទ្រាំនឹងរឿងគ្រប់យ៉ាងដែលពួកគាត់បានស៊ូទ្រាំ និងដោយសារកូនសោនៃបព្វជិតភាពរបស់ពួកគាត់បាននាំដំណឹងល្អទៅកាន់ពិភពលោកនៃជំនាន់ពួកគាត់ ។

នៅពេលយើងបានចូលទៅក្នុងសេចក្ដីសញ្ញាពិសិដ្ឋ ព្រះវិញ្ញាណបរិសុទ្ធគឺជាព្រះដ៏ជាជំនួយរបស់យើង ជាអង្គដឹកនាំយើង និងជាដៃគូយើង ។ ផលផ្លែនៃព្រះវិញ្ញាណបរិសុទ្ធគឺជា « ការណ៍ទាំងឡាយដ៏ប្រកបដោយសេចក្ដីសុខសាន្តអំពីសិរីល្អដ៏នៅអមតៈ ជាសេចក្ដីពិតអំពីគ្រប់ការណ៍ទាំងអស់ ដែលប្រោសគ្រប់អ្វីទាំងអស់ដែលធ្វើឲ្យគ្រប់អ្វីទាំងអស់មានជីវិត ដែលជ្រាបគ្រប់ការណ៍ទាំងអស់ ហើយមានព្រះចេស្ដាគ្រប់យ៉ាងស្របតាមប្រាជ្ញា សេចក្ដីមេត្រាករុណា សេចក្ដីពិត សេចក្ដីយុត្តិធម៌ និង សេចក្ដីជំនុំជំរះ » ( ម៉ូសេ 6:61 ) ។ អំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធគឺជាទីបន្ទាល់ សេចក្ដីជំនឿ ចំណេះដឹង ប្រាជ្ញា វិវរណៈ អព្ភូតហេតុ ការព្យាបាល និង សេចក្ដីសប្បុរស



ហើយមានច្រើនជាងនេះ ( សូមមើល គ. និង ស. 46:13–26 ) ។

ព្រះវិញ្ញាណបរិសុទ្ធគឺជាអង្គដែលថ្លែងសាក្សីដល់ពាក្យសម្ដីរបស់អ្នកនៅពេលអ្នកបង្រៀន ហើយថ្លែងទីបន្ទាល់ ។ ព្រះវិញ្ញាណបរិសុទ្ធនេះ ហើយគឺជាអង្គដែលដាក់នៅក្នុងចិត្តអ្នកនូវអ្វីដែលអ្នកគួរនិយាយ ហើយបំពេញការសន្យារបស់ព្រះអម្ចាស់ថា « អ្នកនឹងមិនត្រូវបានធ្វើឲ្យខ្មាស់នៅចំពោះមនុស្សលោកឡើយ » ( គ. និង ស. 100:5 ) នៅពេលអ្នកនិយាយទៅកាន់មនុស្សដែលមានគំនិតខុសឆ្គងចំពោះសាសនាចក្រ ។ ព្រះវិញ្ញាណបរិសុទ្ធជាអង្គដែលបើកសម្ដែងពីរបៀបដែលអ្នកអាចយកឈ្នះលើការសាកល្បងបន្ទាប់ទៀតដែលទំនងដូចជាធំហួសពីសមត្ថភាពរបស់អ្នក ។ ដោយសារតែមានព្រះវិញ្ញាណបរិសុទ្ធនៅក្នុងខ្លួនអ្នក ទើបអ្នកដទៃអាចមានអារម្មណ៍ពីសេចក្ដីស្រឡាញ់ដ៏បរិសុទ្ធនៃព្រះគ្រីស្ទ ហើយទទួលកម្លាំងដើម្បីដើរឆ្ពោះទៅមុខ ។ នៅក្នុងតួនាទីទ្រង់ជាព្រះវិញ្ញាណបរិសុទ្ធនៃសេចក្ដីសញ្ញា ព្រះវិញ្ញាណបរិសុទ្ធក៏ជាអង្គដែលបញ្ជាក់ពីសុពលភាព និង តម្លៃនៃសេចក្ដីសញ្ញារបស់អ្នក ហើយទ្រង់បានផ្សារភ្ជាប់ការសន្យារបស់យើងមកលើអ្នកផងដែរ ( សូមមើល គ. និង ស. 88:4–5, 109:14–15 ) ។

## ព្រះវរបិតាសួគ៌នឹងគង់ជាមួយអ្នក

សេចក្ដីសញ្ញាដ៏ទេវភាពធ្វើឲ្យមានពួកគ្រីស្ទានដ៏រឹងមាំ ។ « ខ្ញុំសូមអញ្ជើញអ្នកគ្រប់គ្នាឲ្យមានភាពសក្ដិសម ហើយទទួលពិធីបរិសុទ្ធនៃបព្វជិតភាពទាំងអស់ដែលអ្នកអាចទទួល រួចហើយរក្សាការសន្យាដែលអ្នកបានធ្វើនោះដោយស្មោះត្រង់ ។ ក្នុងគ្រាមានទុក្ខព្រួយ ចូរឲ្យសេចក្ដីសញ្ញារបស់អ្នកក្លាយជាអ្វីដែលសំខាន់បំផុត ហើយចូរឲ្យការគោរពរបស់អ្នកបានឥតល្អៀង ។ បន្ទាប់មកអ្នកអាចសុំដោយសេចក្ដីជំនឿ ដោយឥតប្រែប្រួល ទៅតាមអ្វីដែលអ្នកត្រូវការ ហើយព្រះនឹងឆ្លើយតប ។ ទ្រង់នឹងគាំទ្រអ្នកនៅពេលអ្នកធ្វើការ ហើយឃ្លាំមើល ។ តាមពេលវេលា និង របៀបរបស់ទ្រង់ ទ្រង់នឹងលូកព្រះហស្តទ្រង់ទៅរកអ្នកដោយមានបន្ទូលថា « យើងនៅទីនេះ » ។ ■

*ដកស្រង់ចេញពីសុន្ទរកថានៅសន្និសីទទូទៅខែ មេសា ឆ្នាំ 2009 « The Power of Covenants » ។*

**កំណត់ចំណាំ**

1. សូមមើល សេចក្ដីណែនាំដល់បទគម្ពីរទាំងឡាយ « បេថ្លេហិម » scriptures.lds.org ។
2. *Lectures on Faith* ( ឆ្នាំ 1985 ) ទំព័រ 67 ។
3. សូមមើល*Lectures on Faith* ទំព័រ 69–71 ។




# តើអ្នកមើលឃើញអ្វីខ្លះ ?

*នៅពេលយើងសិក្សា ហើយសញ្ជឹងគិតនូវនិមិត្តរូបនៅក្នុងពិធីបរិសុទ្ធនៃដំណឹងល្អ នោះគំនិតរបស់យើងផ្ដោតទៅលើព្រះយេស៊ូវគ្រីស្ទ ។*

**ដោយ ដេវីឌ អេ អេដវួដ**
ទស្សនាវដ្ដីសាសនាចក្រ

ដោយនិមិត្តរូបទាំងឡាយមាននៅជុំវិញខ្លួនយើង ជារឿយៗយើងមិនបានគិតពីវាច្រើននោះទេ ។ ប៉ុន្តែការយកចិត្តទុកដាក់កាន់តែជិតដល់ចំពោះនិមិត្តរូបនៃដំណឹងល្អ អាចជាគន្លឹះមួយចំពោះការយល់ដឹងកាន់តែច្រើន ។

ព្រះគម្ពីរប្រើពាក្យដូចជា*ប្រភេទ ស្រមោល និមិត្តរូប រូបតំណាង សញ្ញារឿង ប្រៀបប្រដូច ការចងចាំ សាក្សី* ឬ *ទីបន្ទាល់*ដើម្បីរៀបរាប់ពីអ្វីមួយដែលមានន័យចង់ចង្អុលបង្ហាញគំនិតរបស់យើងឆ្ពោះទៅអ្វីមួយផ្សេងទៀត ( សូមមើល ម៉ូសេ 6:63 ) ។ ឧទាហរណ៍ នៅពេលព្រះយេស៊ូវបានរៀបចំសាក្រាម៉ង់ដំបូងនៅអាហារយប់ថ្ងៃចុងក្រោយ នោះទ្រង់បានហុចបំបែកនំប៉័ងទៅពួកសាវកទ្រង់ហូប ហើយបន្ទូលថា « នេះហើយជារូបកាយខ្ញុំដែលបានប្រទានមកសម្រាប់អ្នករាល់គ្នា ចូរធ្វើបុណ្យនេះដើម្បីរំឭកពីខ្ញុំចុះ » ( លូកា 22:19 ) ។ ឥឡូវនេះពិតណាស់នំប៉័ងពុំមែនរូបកាយពិតរបស់ទ្រង់ទេ ដូចដែលទ្រង់បានមានបន្ទូល វាមានន័យថាដើម្បី*រំឭក*យើងពីរូបកាយរបស់ទ្រង់—*និងអ្វីច្រើនទៀត* ។ នោះគឺជាអ្វីដែលធ្វើឲ្យនិមិត្តរូបមានឥទ្ធិពលយ៉ាងខ្លាំង—វាទំនាក់ទំនងដោយគ្មានប្រើភាសា ហើយបំផុសឲ្យមានគំនិតជាច្រើនក្នុងពេលតែមួយ ដោយបន្ថែមនូវភាពសឹជម្រៅ និង អត្ថន័យ ។

ពិតណាស់ ពិធីបរិសុទ្ធទាំងឡាយមិនគ្រាន់តែជាការបង្ហាញជាតំណាងនោះទេ វាមាននូវអំណាចដ៏ពិតដើម្បីប្រទានដល់យើងតាមរយៈសិទ្ធិអំណាចនៃបព្វជិតភាព ។ ប៉ុន្តែវាក៏មាននិមិត្តរូបដែលបង្រៀនយើងពីព្រះអង្គសង្គ្រោះ និងពីសេចក្ដីសញ្ញារបស់យើងដែរ ។ សូម្បីតែសកម្មភាពនៃការដាក់ស្នើ និង ការទទួលពិធីបរិសុទ្ធនៃបព្វជិតភាពក៏ជាសញ្ញាបង្ហាញពីខាងក្រៅស្ដីពីសេចក្ដីជំនឿ និង សេចក្ដីរាបសារបស់មនុស្សម្នាក់ដែរ ។ នេះជានិមិត្តរូបជាច្រើនដែលទាក់ទងនឹងពិធីបរិសុទ្ធនៃបុណ្យជ្រមុជទឹក ពីធីបញ្ជាក់ និង សាក្រាម៉ង់ រួមទាំងគំនិតមួយចំនួនដែលពាក់ព័ន្ធនឹងវាផងដែរ ។ ■



## ពិធីបុណ្យជ្រមុជទឹក

***ទឹក ៖*** *ការលាង ការសម្អាត ការធ្វើឲ្យបរិសុទ្ធជ្រះពីបាប ។*

***សំលៀកបំពាក់ពណ៌ស ៖*** *ភាពបរិសុទ្ធ ( « គ្មានអ្នកណាអាចបានសង្គ្រោះឡើយ លើកលែងតែសំលៀកបំពាក់របស់អ្នកនោះត្រូវបានជំរះឲ្យស . . . [ហើយ] ធ្វើឲ្យបរិសុទ្ធ . . . តាមរយៈព្រះលោហិតនៃ [ព្រះគ្រីស្ទ] » [អាលម៉ា 5:21] ) ។ ភាពស្មើគ្នា ( មិនថាមាន ឬ ក្រនោះទេ មនុស្សទាំងអស់ស្លៀកសំលៀកបំពាក់ដូចគ្នាពេលបុណ្យជ្រមុជទឹក ពីព្រោះមនុស្សទាំងអស់ « ដូចគ្នានៅចំពោះព្រះ » [នីហ្វៃទី 2 26:33] )*

***ការលើកដៃស្ដាំឡើង ៖*** *គឺជាការលើកដៃឡើងឆ្ពោះទៅស្ថានសួគ៌ ការធ្វើសេចក្ដីសញ្ញាមួយនឹងស្ថានសួគ៌ និង ជាសញ្ញាខាងក្រៅនៃសេចក្ដីសម្បថមួយផងដែរ ( សូមមើល លោកុប្បត្តិ 14:22, ដានីយ៉ែល 12:7 )*

***ការពន្លិចទៅក្នុងទឹក ៖*** *គឺជាសេចក្ដីស្លាប់ ការកប់ និង ការរស់ឡើងនៃព្រះគ្រីស្ទ ( សូមមើល រ៉ូម 6:3–4 ) ការកើតជាថ្មីខាងវិញ្ញាណរបស់យើងនៅក្នុងព្រះគ្រីស្ទ ( «កើតពីទឹក » [យ៉ូហាន 3:5] ) ។*

## ពិធីបញ្ជាក់



***ការដាក់ដៃលើ ៖*** *គឺជាការប៉ះខាងរូបកាយដោយពួកអ្នកដែលតំណាងឲ្យព្រះ ដោយបញ្ជូនពរជ័យពីព្រះទៅអ្នកដទៃទៀត*

***ការទទួលអំណោយទានព្រះវិញ្ញាណបរិសុទ្ធ ៖*** *ត្រូវបានហៅថា « បុណ្យជ្រមុជទឹកដោយភ្លើង » ( សូមមើលនីហ្វៃទី 2 31:13 ) ។ ការលាងជម្រះ និង ការកើតជាថ្មីខាងវិញ្ញាណនៅក្នុងព្រះគ្រីស្ទ ។*

## ពិធីសាក្រាម៉ង់



***ការទទួលទាននំបុ័ង ៖*** *ការចងចាំដល់ព្រះកាយនៃព្រះយេស៊ូវគ្រីស្ទ ( សូមមើលម៉ាថាយ 26:26–29 ) នំបុ័ងនៃជីវិត ( « អ្នកណាដែលមកឯខ្ញុំ នោះនឹងមិនឃ្លានទៀតឡើយ » [យ៉ូហាន 6:35] «អ្នកណាដែលបរិភោគនំបុ័ងនេះនឹងរស់នៅអស់កល្បជានិច្ច » [យ៉ូហាន 6:58] )*

***ការលុតជង្គង់អធិស្ឋាន ៖*** *សេចក្ដីរាបសា ការធ្វើតាមព្រះទ័យរបស់ព្រះ សញ្ញានៃសេចក្ដីសញ្ញាដ៏អស់កល្បជានិច្ច ( សូមមើល គ. និង ស. 88:131 )*

***ការហែកនំបុ័ង ៖*** *ការរងទុក្ខខាងរូបកាយរបស់ព្រះគ្រីស្ទដើម្បីប្រយោជន៍យើង ការសុគតខាងសាច់ឈាមរបស់ទ្រង់ ការរស់ឡើងវិញរបស់ទ្រង់ដើម្បីឲ្យយើងអាចមានជីវិតម្ដងទៀត ។*

***ការដាក់នំបុ័ង និង ទឹកនៅមុខក្រុមជំនុំ ៖*** *តំណាងឲ្យការលះបង់របស់ព្រះគ្រីស្ទដែលបានបញ្ចប់ការលះបង់នេះដោយការបង្ហូរព្រះលោហិត ( សូមមើលអាលម៉ា 34:13–14 ) ឥឡូវនេះយើងថ្វាយ « ការបូជាដល់ព្រះអម្ចាស់ . . . ដោយចិត្តសង្រេង និង វិញ្ញាណទន់ទាប » ( គ. និង ស. 59:8 ) ។*

***ការទទួលទឹក (ពីដើមគឺជាស្រា) ៖*** *ព្រះលោហិតព្រះគ្រីស្ទ ( បានបង្ហូរនៅសួនច្បារគែតសេម៉ានី អំឡុងការរងទុក្ខរបស់ទ្រង់នៅក្នុងកណ្ដាប់ដៃនៃពួកទាហាន និងលើឈើឆ្កាង ) ដែល « សម្អាតយើងរាល់គ្នាពីគ្រប់អំពើបាបទាំងអស់ » ( យ៉ូហាន 1 1:7 ) ហើយ « ដែលមាននៅក្នុងសេចក្ដីសញ្ញានៃព្រះវរបិតាចំពោះការផ្ដាច់បាប [របស់យើង] » ( ម៉ូរ៉ូណៃ 10:33 ) លោហិតជា « គោលជីវិត ឬជាថាមពលដ៏សំខាន់នៃសាច់ឈាមទាំងអស់ » ( សេចក្ដីណែនាំដល់បទគម្ពីរទាំងឡាយ « លោហិត », scriptures.lds.org ) ហើយដែលបានធ្វើឲ្យធួនចំពោះអំពើបាបតាមរយៈការបូជា ( សូមមើលលេវីវិន័យ 17:11 ), ទឹករស់ ( សូមមើល យ៉ូហាន 4:14 )*



**ផ្ដោតលើដង្វាយធួន**

« រាល់ពិធីបរិសុទ្ធនៃដំណឹងល្អផ្ដោតទៅលើដង្វាយធួននៃព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទ ហើយពិតណាស់ថា នោះជាហេតុផលដែលពិធីបរិសុទ្ធដ៏ជាក់លាក់នេះ [នៃសាក្រាម៉ង់] ដែលមាននូវរាល់និមិត្តសញ្ញា និង រូបភាពរបស់ខ្លួនបានកើតមានចំពោះយើងយ៉ាងរីករាយ ហើយធ្វើម្ដងហើយម្ដងទៀតលើសពីពិធីបរិសុទ្ធផ្សេងទៀតនៅក្នុងជីវិតរបស់យើង » ។

អែលឌើរ ជែហ្វ្រី អ័រ ហូឡិន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ « This Do in Remembrance of Me » *Ensign* ខែ វិច្ឆិកា ឆ្នាំ 1995 ទំព័រ 67 ។

## ចូលរួមក្នុងការសន្ទនា

### រឿងដើម្បីពិចារណាសម្រាប់ថ្ងៃអាទិត្យ

- តើនិមិត្តសញ្ញានៅក្នុងពិធីបរិសុទ្ធនៃបុណ្យជ្រមុជទឹក ពិធីបញ្ជាក់ និង សាក្រាម៉ង់ជួយអ្នកឲ្យចងចាំពីព្រះអង្គសង្គ្រោះ និងសេចក្ដីសញ្ញារបស់អ្នកតាមរបៀបណា ?
- តើអ្នកបានគិតពីអ្វីខ្លះនៅក្នុងពិធីសាក្រាម៉ង់រាល់សប្ដាហ៍ ?

### រឿងទាំងឡាយដែលអ្នកអាចធ្វើ

- សូមសរសេរនៅក្នុងទិនានុប្បវត្តិរបស់អ្នកស្ដីពីអ្វីមួយដែលអ្នកបានគិត ឬ មានអារម្មណ៍នៅក្នុងពិធីសាក្រាម៉ង់ ។
- នៅឯព្រះវិហារ សូមនិយាយពីនិមិត្តសញ្ញាមួយនៅក្នុងពិធីសាក្រាម៉ង់ និងរបៀបដែលពិធីបរិសុទ្ធនេះជួយអ្នកឲ្យចងចាំព្រះអង្គសង្គ្រោះ ។

# ទីកន្លែងរបស់យើង



## បុណ្យជ្រមុជទឹកសម្រាប់លោកតារបស់ខ្ញុំ

ខ្ញុំមានអំណរគុណដែលថ្នាក់ដឹកនាំនៃយុវវ័យយើងបានដាក់ផែនការទៅលេងនៅព្រះវិហារបរិសុទ្ធ ។ នៅពេលយើងរៀបចំការធ្វើដំណើរនេះទៅទីក្រុង អាប្យា ប្រទេសសាម័រ យើងមានចិត្តរីករាយចំពោះឱកាសដ៏កម្រនេះ ។ យើងបានចូលទៅក្នុងព្រះវិហារបរិសុទ្ធដោយក្ដីអំណរយ៉ាងខ្លាំង ដើម្បីបុណ្យជ្រមុជទឹកសម្រាប់បុព្វការីជន—ពីព្រោះអ្នកដែលនៅពិភពវិញ្ញាណកំពុងរង់ចាំយើងស្វែងរកពង្សប្រវត្តិរបស់យើង ហើយធ្វើកិច្ចការសម្រាប់ពួកគាត់ ។

នៅក្នុងពិធីបុណ្យជ្រមុជទឹក ខ្ញុំបានឃើញយុវជនម្នាក់នៅក្នុងក្រុមយើងបានជ្រមុជទឹកឲ្យហ្វាអាតាហ្គា អាហ្គាវ៉ាឡេ ជាជីតារបស់ខ្ញុំ ។ ខ្ញុំបានស្រក់ទឹកភ្នែកដោយក្ដីអំណរ ហើយខ្ញុំបានដឹងថាវិញ្ញាណរបស់គាត់បាននៅទីនោះ ។ ខ្ញុំរីករាយណាស់ដែលយើងអាចធ្វើកិច្ចការសម្រាប់គាត់នៅក្នុងព្រះវិហារបរិសុទ្ធ ។

សែនី អាហ្គាវ៉ាឡេ ប្រទេស សាម័រ





## ព័ត៌មានដ៏សំខាន់ពីមិត្តម្នាក់

កាលពីក្មេង ខ្ញុំមិនចូលចិត្តទៅព្រះវិហារទេ ដូច្នេះខ្ញុំមិនបានដឹងច្រើនពីព្រះគម្ពីរប៊ីប ឬ ពីព្រះ ឬពីអ្វីដែលខ្ញុំចង់បាននោះទេ ។ នៅពេលខ្ញុំមានអាយុ 17 ឆ្នាំ មានមិត្តខ្ញុំម្នាក់បានប្រាប់ខ្ញុំថា នាងជាមរមន ។ ខ្ញុំមិនដឹងថា មរមនជាអ្វីនោះទេ ។ ខ្ញុំបានប្រាប់មិត្តខ្ញុំថា « បើខ្ញុំចង់ដឹងអ្វីទៀតពីព្រះវិហារនោះ ខ្ញុំនឹងស្វែងរកវាដោយខ្លួនឯង » ។

ដោយឃើញថា ខ្ញុំមិនសូវចាប់អារម្មណ៍ពីសាសនា នាងបានឲ្យព្រះគម្ពីរមរមនមកខ្ញុំ ហើយសុំឲ្យខ្ញុំអាន ហើយអធិស្ឋានពីព្រះគម្ពីរនោះ ។ នាងមិនបានបង្ខំខ្ញុំនោះទេ ។ ក្រោយមកទៀតនៅយប់នោះ ពេលខ្ញុំបើកព្រះគម្ពីរនោះ ខ្ញុំបានឃើញនាងសរសេរទីបន្ទាល់របស់នាងទំព័រខាងមុខ ។ នៅពេលខ្ញុំបានអានវា ខ្ញុំមានអារម្មណ៍ថាខ្ញុំគួររៀនពីព្រះគម្ពីរមរមនបន្ថែមទៀត ។ ដូច្នេះខ្ញុំបានចាប់ផ្ដើមអាននីហ្វៃទី 1 ។ ខ្ញុំជក់អានរហូតដល់មិនចង់ដាក់ព្រះគម្ពីរនោះចុះ ។ ខ្ញុំចង់ដឹងបន្ថែមទៀត ។

នៅក្នុងរាត្រីជួបជុំក្រុមគ្រួសារ គ្រួសារនាងបានបង្រៀនខ្ញុំពីដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ។ អ្វីគ្រប់យ៉ាងទំនងដូចជាត្រឹមត្រូវ ។ មិនយូរប៉ុន្មានពួកអ្នកផ្សព្វផ្សាយសាសនាបានបង្រៀនខ្ញុំ ហើយខ្ញុំបានជ្រមុជទឹក ព្រមទាំងបញ្ជាក់ជាសមាជិកនៃសាសនាចក្រពិតរបស់ព្រះអម្ចាស់ ។ ដំណឹងល្អបានជួយខ្ញុំឲ្យដឹងថាខ្ញុំជានរណា ខ្ញុំមកពីណា និងពីកន្លែងដែលខ្ញុំអាចទៅ ប្រសិនបើខ្ញុំស្មោះត្រង់ ។

នៅពេលខ្ញុំក្រឡេកមើលទៅក្រោយវិញ ខ្ញុំអាចឃើញពីរបៀបដែលព្រះវិញ្ញាណបរិសុទ្ធបានជួយខ្ញុំឲ្យចង់រៀនបន្ថែមទៀត ។ នៅពេលខ្ញុំបានរៀនបន្ថែមទៀត ឥរិយាបថខ្ញុំចំពោះព្រះវិហារ និង ព្រះបានផ្លាស់ប្ដូរ ។ ជាគ្រាដំបូងនៅក្នុងជីវិតខ្ញុំ ដែលខ្ញុំចង់ធ្វើនូវអ្វីដែលទ្រង់សព្វព្រះហឫទ័យឲ្យខ្ញុំធ្វើ ។

ព្រះគម្ពីរមរមនបានផ្លាស់ប្ដូរជីវិតខ្ញុំ ហើយខ្ញុំមានអំណរគុណចំពោះមិត្តខ្ញុំដែលបានចែកចាយវាដល់ខ្ញុំ ។ មិត្តពិតចែកចាយនូវព័ត៌មានដ៏សំខាន់ដូចនេះឯង ។

ម៉ែខល ភី រដ្ឋអូហៃអូ ស.រ.អា.



**ដោយ វ៉ាំនឌល អិល រីឌ**
ទីប្រឹក្សាទីពីរ គណៈប្រធាន
យុវជនទូទៅ

# ការងារ
## តើនរណាត្រូវការវា ?

*ការងារប្រហែលជាមិនសប្បាយជានិច្ចឡើយ ប៉ុន្តែអ្នកប្រហែលជាភ្ញាក់ផ្អើលពីអារម្មណ៍ល្អដែលអ្នកមានចំពោះវា ។*

កាលពីក្មេង ខ្ញុំចូលចិត្តលេងសប្បាយដូចជាក្មេងដទៃទៀតដែរ ។ ហើយពេលខ្ញុំមានអាយុ 16 ឆ្នាំ ខ្ញុំចូលចិត្តចេញទៅដើរលេងជាគូ និងការចេញទៅដើរលេងនឹងមិត្តខ្ញុំ ។ ខ្ញុំចូលចិត្តសកម្មភាពទាំងនេះច្រើនជាងធ្វើការងារ ។

ប៉ុន្តែដូចជាអ្នករាល់គ្នាភាគច្រើនដែរ ខ្ញុំមានការងារមួយ ។ ឪពុកខ្ញុំធ្វើការនៅក្រុមហ៊ុនសំណង់ ហើយជារឿយៗគាត់បានចុះឈ្មោះបងប្អូនប្រុសខ្ញុំទាំងបី ហើយនិងខ្ញុំដើម្បីទៅជួយគាត់ ។ ការងារត្រូវនៅហាលក្ដៅ ហើយនឿយហត់ណាស់ មានពេលខ្លះខ្ញុំពិតជាមិនចង់ធ្វើការទាល់តែសោះ ។ ប៉ុន្តែយើងត្រូវធ្វើតាមកាលវិភាគ ដើម្បីគម្រោងបានបញ្ចប់ទាន់ពេល ដូច្នេះយើងបានខិតខំធ្វើការរាល់ថ្ងៃរហូតដល់ការងារនោះបានរួចរាល់ ។ ទោះជានៅពេលនោះខ្ញុំមិនបានដឹងថា ការធ្វើការជាមួយនឹងគ្រួសារខ្ញុំបង្រៀនខ្ញុំនូវមេរៀនជាច្រើនក្ដី ។ ភាពរីករាយកើតចេញពីការងារមួយដែលបញ្ចប់ទៅបានយ៉ាងល្អ ។

ការសង់ផ្ទះតម្រូវការពេលវេលា កិច្ចខិតខំ និងការយកចិត្តទុកដាក់ជាច្រើន ។ នៅផ្នែកមួយដែលខ្ញុំបានគិតថា យើងមិនចាំបាច់ត្រូវជីកដីសម្រាប់គ្រឹះផ្ទះឲ្យបានត្រឹមត្រូវនោះទេ ។ ឪពុកខ្ញុំបានគិតឃើញផ្សេងទៅវិញ ។

ដើម្បីចាក់គ្រឹះផ្ទះមួយ ដំបូងអ្នកត្រូវជីកដី ហើយចាក់ស៊ីម៉ង់ចូល ។ ជើងទ្រគឺជាបន្ទះស៊ីម៉ង់ក្រាស់ដែលមានទំហំធំជាងគ្រឹះ ។ នៅពេលជើងទ្រនោះត្រូវបានចាក់ឲ្យរឹងហើយ អ្នកចាក់គ្រឹះនៅពីលើជើងទ្រនោះ ។ បន្ទាប់មកអ្នកចាក់ដីលុបវាវិញ ។

ជារឿយៗខ្ញុំឆ្ងល់ថា តើវាមានបញ្ហាទេប្រសិនបើជើងសរសរនោះមិនមានរាងបួនជ្រុងស្មើនោះ ។ ក្រោយពីលុបដីវាមក គ្មាននរណាម្នាក់ឃើញវាទេ ហើយវានៅតែទ្រផ្ទះបានមាំដដែល ។ ប៉ុន្តែឪពុកខ្ញុំនៅតែចង់ឲ្យជើងសរសរនោះមានរាងបួនជ្រុង ហើយសំប៉ែត ដោយវាស់វែងដោយត្រឹមត្រូវ ហើយប្រុងប្រយ័ត្ន ហើយគាត់បានធ្វើដូច្នេះគ្រប់ផ្ទះដែលគាត់សង់ ។

ដោយក្រឡេកមើលទៅក្រោយវិញ ខ្ញុំបានដឹងថា ឪពុកខ្ញុំបានធ្វើរាល់កិច្ចការរបស់គាត់ដោយការយកចិត្តទុកដាក់ដូចគ្នា សូម្បីតែកិច្ចការដែលម្ចាស់ផ្ទះមិនដែលឃើញក្ដី ។ ការយកចិត្តទុកដាក់របស់គាត់ចំពោះភាពលម្អិតមានន័យថាមនុស្សគ្រប់គ្នាអាចទុកចិត្តថាគាត់ធ្វើកិច្ចការបានល្អ ហើយគាត់រីករាយដោយដឹងថាកិច្ចការរបស់គាត់មានគុណភាពល្អ ហើយថាម្ចាស់ផ្ទះនឹងមានអំណរគុណចំពោះកិច្ចការនោះ ។

មានពេលខ្លះគ្មាននរណាម្នាក់អាចដឹងថាតើអ្នកធ្វើកិច្ចការដែលអ្នកត្រូវធ្វើបានល្អប៉ុណ្ណាទេ មានតែអ្នក និង ព្រះអម្ចាស់ប៉ុណ្ណោះដែលដឹង ។ អ្នកអាចមានទំនុកចិត្តថាព្រះអម្ចាស់*ពិតជា*ជ្រាបពីកិច្ចការខិតខំរបស់អ្នក ។ នៅពេលអ្នកធ្វើអស់ពីលទ្ធភាព អ្នកនឹងមានអារម្មណ៍ល្អពីខ្លួនឯង ដោយដឹងថាអ្នកបានអភិវឌ្ឍនូវភាពសុចរិត ភាពស្មោះត្រង់ និងជំនាញដ៏មានប្រយោជន៍ ។



អ្នកនឹងរៀនតាមរយៈបទពិសោធន៍របស់អ្នកនូវគុណតម្លៃនៃច្បាប់ច្រូតកាត់របស់ព្រះអម្ចាស់ ៖ « ពូជណាដែលមនុស្សព្រោះចុះ នោះនឹងច្រូតបានពូជនោះឯងវិញ » ( កាឡាទី 6:7សូមមើលផងដែរ គ. និង ស. 130:20–21 ) ។

## ឥរិយាបថជះឥទ្ធិពលអ្វីៗគ្រប់យ៉ាង

ការជីកដាក់ជើងទ្រសរសរតម្រូវពេលច្រើននៅហាលក្ដៅ ហើយខ្ញុំសារភាពថា ខ្ញុំមានឥរិយាបថមិនល្អចំពោះការងារនេះឡើយ ។ នៅពេលណាម្ដាយខ្ញុំឃើញខ្ញុំត្អូញត្អែរពីការងារ គាត់បានពោលថា « ចេះប្រយ័ត្នប្រយែង ។ កូននឹងបាត់បង់ពររបស់កូន ហើយកូនត្រូវធ្វើដោយខានមិនបាន ! » ( សូមមើល គ. និង ស. 58:28–29 ) ។ គាត់មានប្រសាសន៍ត្រូវ ។ ការត្អូញត្អែរមិនបានដកយកការងារនោះចេញទេ វានឹងដកយកភាពរីករាយ និងពរជាច្រើននៅក្នុងការធ្វើកិច្ចការនោះទៅវិញ ។

ខ្ញុំបានរកឃើញថា នៅពេលខ្ញុំបានជ្រើសរើសស្ដាប់តាមម្ដាយខ្ញុំ ហើយធ្វើកិច្ចការដោយចិត្តរីករាយ ពេលវេលាបានកន្លងផុតទៅយ៉ាងលឿន កិច្ចការនោះបញ្ចប់ទៅយ៉ាងប្រសើរ ហើយខ្ញុំសប្បាយចិត្តជាងពេលដែលខ្ញុំត្អូញត្អែរ ។ ឥរិយាបថជះឥទ្ធិពលអ្វីៗគ្រប់យ៉ាង ។

## កិច្ចការដ៏សំខាន់បំផុតគឺជាកិច្ចការរបស់ព្រះ

ការបម្រើបេសកកម្មគឺជាបទពិសោធន៍ដ៏សំខាន់មួយចំពោះខ្ញុំ ។ ខ្ញុំបានដឹងថា គ្មានកិច្ចការណាផ្សេងទៀតសំខាន់ជាងកិច្ចការរបស់ព្រះវរបិតាសួគ៌យើងឡើយ ដែលវានឹងផ្ដល់ជាពរដល់យើង ដែលជាកូនចៅរបស់ទ្រង់ ៖ « ត្បិតមើលចុះ នេះហើយជាកិច្ចការរបស់យើង និងសិរីល្អរបស់យើង—គឺដើម្បីនាំឲ្យមានអមតភាព និង ជីវិតដ៏នៅអស់កល្បជានិច្ចដល់មនុស្ស » ( ម៉ូសេ 1:39 ) ។

នៅពេលអ្នកចូលរួមនៅក្នុងកិច្ចការរបស់ព្រះវរបិតាសួគ៌ ដើម្បីបម្រើដល់កូនចៅទ្រង់ អ្នកនឹងរកឃើញនូវសេចក្ដីអំណរដ៏មហិមាដូចជាអាលម៉ាដែរ នៅក្នុងការធ្វើជា « ឧបករណ៍មួយនៅក្នុងព្រះហស្តនៃព្រះ ដើម្បីនាំមនុស្សខ្លះទៅកាន់ការប្រែចិត្ត ហើយនេះគឺសេចក្ដីអំណរ [របស់អ្នក] » ( អាលម៉ា 29:9 ) ។

## ការអញ្ជើញមួយ

ដូច្នេះតើនរណាខ្លះត្រូវធ្វើការ ? គឺយើងទាំងអស់គ្នា ! វាជាកត្តាដ៏សំខាន់នៃភាពខ្លួនទីពឹងខ្លួន ភាពជោគជ័យ និងសេចក្ដីអំណរនៅក្នុងជីវិតនេះ ។ នៅពេលអ្នកចូលប្រទូ្បកក្នុងការងារដោយរីករាយ នោះមនុស្សនៅជុំវិញខ្លួនអ្នកនឹងទទួលបានផលផ្លែយ៉ាងច្រើន ដោយសារតែគ្រាប់ពូជដែលអ្នកបានព្រួស ។

នៅពេលអ្នកធ្វើការនៅរាល់សប្ដាហ៍ ខ្ញុំអញ្ជើញអ្នកឲ្យគិតពីមេរៀនដែលខ្ញុំបានរៀនរួចហើយធ្វើការសាកល្បងធ្វើវា ៖ ពេលអ្នកផ្ដល់ការងារឲ្យធ្វើនៅពេលក្រោយទៀត សូមធ្វើវាឲ្យអស់ពីលទ្ធភាព មានឥរិយាបថរីករាយ ហើយរង់ចាំមើលពីអ្វីដែលនឹងកើតឡើង ។ អ្នកអាចនឹងមានការភ្ញាក់ផ្អើលពីអារម្មណ៍ល្អដែលអ្នកមានចំពោះការងារនោះ ។ ■

# ការប្ដូរបំពង់ទឹក ទាំងស្បែកជើងសុទ្ធតែភក់

ដោយ បម៉ឺន អិម អល់តុន

« អរគុណ ប៊ីស្សពរវលី។ យើងរីករាយនឹងជួយ » ។ បងប្រុសហ៊ូទ្បេត ជាអ្នកប្រឹក្សាក្វ៉ុមឌីកុនរបស់យើង បានយកក្ដារតម្បៀតខ្ទាស់ពីដៃរបស់ប៊ីស្សព ហើយប្រកាសថា « ខ្ញុំមានបញ្ជីឈ្មោះពួកអ្នកស្ម័គ្រចិត្តសម្រាប់កសិដ្ឋានសាសនាចក្រ ។ ខ្ញុំជឿជាក់ថាព្រះអម្ចាស់នឹងសព្វព្រះហឫទ័យប្រសិនបើយើងរាល់គ្នាជួយកិច្ចការនេះនៅសប្ដាហ៍ក្រោយ » ។

« តើការជួយប្រភេទណា ? » ខ្ញុំបានសួរដោយបារម្ភ ។ គំនិតសម្រាប់កសិដ្ឋានសាសនាចក្រនេះទំនងដូចជាមិនសប្បាយសោះ ។

« កិច្ចការតែមួយគត់របស់យើងនៅសប្ដាហ៍នេះគឺការលើករើបំពង់ទឹក » ។

ការរើបំពង់ទឹក ! ពាក្យនោះបានធ្វើឲ្យខ្ញុំភ័យខ្លាច ។ គំនិតរបស់ខ្ញុំបានគិតពីរឿងបីខែមុនកាលម្ដាយរបស់ខ្ញុំបានជម្រុញឲ្យខ្ញុំរកការងារធ្វើសម្រាប់

*ខ្ញុំមិនចង់ប្ដូរបំពង់ទឹកមួយទៀតឡើយ ។*



រដូវក្តៅ ។ នៅក្នុងក្រុងតូចរបស់យើង ការងារដ៏ល្អបំផុតមួយ—ការប្តូរបំពង់ទឹក ។ ដូច្នេះពេញមួយរដូវក្តៅ បងប្អូនជីដូនមួយខ្ញុំឈ្មោះស្កុត ហើយនិងខ្ញុំបានរើបំពង់ទឹក ។

នៅថ្ងៃទីមួយនៃការងារក្នុងរដូវក្តៅរបស់យើង យើងបានឈរមើលវាលដ៏ធំនៃរុក្ខជាតិអាល់ហ្វាល់ហ្វា ។ មានបំពង់ទឹកប្រវែង 12 ម. ត្រូវបានដាក់ភ្ជាប់គ្នាជាបន្ទាត់ត្រង់មួយដែលមើលទៅហាក់ដូចជាត្រូវបានដាក់តគ្នាពីរបីគីឡូម៉ែត្រទៀត ។ បន្ទាប់ពីការបំពាក់បំប៉ន ខ្លីមួយមក ស្កុត និង ខ្ញុំបានដោះផ្តាច់បំពង់ទឹកទីមួយរបស់យើងចេញ ។ ស្កុតបានលើកនៅចុងម្ខាង ហើយបានធ្វើឲ្យទឹកខ្ទាតមកលើស្បែកជើងកីឡារបស់ខ្ញុំ ។ យើងបានលើកបំពង់ទឹកនោះដើរកាត់ភក់ដ៏ជ្រៅ ហើយតវាឡើងវិញជាមួយនឹងបំពង់ទឹកបញ្ឈរក្បែរនោះ ។ នៅពេលយើងដើរត្រឡប់មកយកបំពង់ទឹកបន្ទាប់ទៀត ជើងរបស់យើងខ្ញុំចាប់ផ្តើមធ្ងន់ទៅៗដោយសារមានភក់ស្អិតជាប់វាយ៉ាងក្រាស់ ។ នៅទីបំផុត ភក់ ទឹក និង ខោអាវសុទ្ធតែញើសបានធ្វើឲ្យយើងមានអារម្មណ៍សោកសៅ ។

គំនិតរបស់ខ្ញុំបានត្រឡប់ទៅរកការស្ម័គ្រចិត្តនៅឯកសិដ្ឋានសាសនាចក្រវិញ ។ ខ្ញុំបាននិយាយថា « ខ្ញុំ—ខ្ញុំគិតថាខ្ញុំមិនអាចមកបានទេ » ។ « ខ្ញុំត្រូវទៅធ្វើការងាររបស់ខ្ញុំរាល់ព្រឹក » ។

បងប្រុសហ៊្វូទ្បេតបានបញ្ជាក់ថា « គ្មានបញ្ហាទេ »។ « យើងតែងទៅកសិដ្ឋានសាសនាចក្រនៅពេលរសៀល » ។ បងប្រុសហ៊្វូទ្បេតបានហុចបញ្ជីចុះឈ្មោះឲ្យពួកយើង ។ « នៅពេលអ្នករាល់គ្នាម្នាក់ៗត្រូវបានតែងតាំងជាបព្វជិតភាព អ្នកត្រូវបានប្រទានឲ្យនូវអំណាចដើម្បីធ្វើកិច្ចការនៅក្នុងព្រះនាមព្រះ ។ ហើយនៅពេលយើងបម្រើទ្រង់ដោយការបម្រើដល់អ្នកដទៃ យើងកំពុងធ្វើនៅក្នុងព្រះនាមទ្រង់ ។ ជាងនេះទៀត ដោយមានជំនួយពីយើងរាល់គ្នា ការងារនោះនឹងមានភាពងាយស្រួល » ។

បញ្ជីនោះបានហុចមកឲ្យខ្ញុំ ។ ខ្ញុំមិនចង់ជឿសោះថាមកដល់នោះ មនុស្សគ្រប់គ្នាបានចុះឈ្មោះទៅរាល់ថ្ងៃសម្រាប់សប្តាហ៍នេះ រួចទៅហើយ ។ តើពួកគេមិនដឹងថាការងារនេះ វាលំបាកយ៉ាងណាទេឬអី ? ខ្ញុំបានទទួលអារម្មណ៍នូវសម្ពាធដ៏សុចរិតពីក្រុមអ្នកមានអាយុប្រហាក់ប្រហែលនឹងខ្ញុំ ដ៏ធ្ងន់បានសង្កត់មកលើខ្ញុំ ។ ខ្ញុំបានចុះឈ្មោះ ហើយហុចវាបន្តទៀតទាំងមានចិត្តចង្អៀតចង្អល់ ។

នៅរសៀលថ្ងៃចន្ទ កាលខ្ញុំអង្គុយនៅក្នុងបន្ទប់ខ្ញុំដើម្បីសម្រាកឲ្យបាត់ហត់ពីការងារនៅពេលព្រឹក ស្រាប់តែខ្ញុំឮបងប្រុសហ៊្វូទ្បេតចុចសីផ្លេហៅនៅខាងក្រៅ ។ ខ្ញុំបានស្ទាក់ស្ទើរមួយភ្លែតពីមុនពាក់ខោអាវប្រឡាក់កាលពីព្រឹកមិញឡើងវិញ ។

មិនយូរប៉ុន្មានយើងបានទៅដល់កសិដ្ឋានសាសនាចក្រ ។ មនុស្សគ្រប់គ្នាលើកលែងតែខ្ញុំបានរត់ប្រណាំងគ្នាទៅកាន់ទីវាលនោះ ។ ខ្ញុំបានដើរឈ្ងោកមុខចុះទាត់ដុំថ្មតាមក្រោយ ស្រាប់តែមានដៃមួយដាក់លើស្មារខ្ញុំ ដែលធ្វើឲ្យខ្ញុំភ្ញាក់ផ្អើល ។ បងប្រុសហ៊្វូទ្បេតបានលើកទឹកចិត្តថា « អរគុណដែលបានមកជាមួយពួកយើង » ។ « ខ្ញុំដឹងថាឯងធ្វើការហត់កាលពីព្រឹកមិញ »។ យើងបានដើរជាមួយគ្នាដោយស្ងៀមស្ងាត់ពីរបីនាទី ។ បន្ទាប់មកគាត់រត់ទៅមុនដើម្បីរៀបចំក្រុម ។

ខ្ញុំបានសម្លឹងមើលគាត់ ហើយគិតពីអ្វីដែលបានពោលមកកាន់ខ្ញុំ ។ ខ្ញុំបានធ្វើការច្រើនកាលពីព្រឹកមិញ ។ ខ្ញុំនឿយហត់ ហើយធុំក្លិនខ្លួន ហើយខ្ញុំចង់ទៅផ្ទះវិញ ។ ចុះបងប្រុសហ៊្វូទ្បេតវិញ ? គាត់ក៏បានខំធ្វើការពីព្រឹកមិញដែរ ។ រីឯងក្មេងប្រុសទាំងនោះក៏ដូច្នោះដែរ ។ ហេតុអ្វីបានជាពួកគេរីករាយមកទីនេះម្ល៉េះ ?

ខ្ញុំទៅចូលរួមនឹងអ្នកផ្សេងទៀត ហើយយើងចាប់ផ្តើមកិច្ចការយើង ។ ដំបូង ខ្ញុំព្យាយាមធ្វើឲ្យខ្លួនឯងរីករាយដោយគិតពីការលះបង់ដ៏អង់អាចដែលខ្ញុំកំពុងធ្វើ ។ ប៉ុន្តែមិនយូរប៉ុន្មានគំនិតអាត្មានិយមរបស់ខ្ញុំបានរសាយបាត់ទៅ ហើយខ្ញុំបានសម្គាល់ឃើញយើងធ្វើការបានយ៉ាងលឿនដោយមានជំនួយពីមនុស្សគ្រប់គ្នា ។ យើងបានសើច ហើយនិយាយគ្នា ហើយរំពេចនោះខ្ញុំបានដឹងថា ខ្ញុំពិតជារីករាយណាស់ ! រយៈពេលតែពីរបីម៉ោង យើងបានបញ្ចប់ការងាររបស់យើង ។

នៅពេលយើងជិះឡានមកផ្ទះវិញ ខ្ញុំបានដឹងថាអ្វីដែលខ្ញុំបានគិតថាជាការលះបង់មួយដ៏លំបាកបែរទៅជារឿងតូចតាចមួយទៅវិញ ។ ពិតណាស់ ដោយមានជំនួយពីមនុស្សគ្រប់គ្នា វាហាក់ដូចជាពុំមែនជាការលះបង់សោះឡើយ ។

បងប្រុសហ៊្វូទ្បេតបានឈប់ឡានគាត់នៅមុខផ្ទះខ្ញុំ ហើយបានក្រឡេកមើលមុខខ្ញុំ ។ « អរគុណដែលឯងបានជួយនៅថ្ងៃនេះ ។ ការខំធ្វើការរបស់ឯងបានជួយសម្រាលការងាររបស់យើងរាល់គ្នា » ។ គាត់បានញញឹម ហើយមិចភ្នែកជាសញ្ញា ។

ខ្ញុំបានញញឹមដាក់គាត់វិញ ។ « អរគុណ ប៉ុន្តែការដែលយើងធ្វើរួមគ្នាទៅវិញទេដែលធ្វើឲ្យវាមានភាពងាយស្រួល » ។ ខ្ញុំបានចេញពីឡាន ហើយបិទទ្វារ ។

បងប្រុសហ៊្វូទ្បេតបានចាប់ផ្តើមបើកឡានចេញទៅ ។ « ចាំជួបគ្នាស្អែកទៀត ? » គាត់បានស្រែកតាមកញ្ចក់ទ្វារឡាន ។

« ពិតជាបាន។ ជួបគ្នាថ្ងៃស្អែក » ខ្ញុំបានតប ។ ■

*អ្នកនិពន្ធរស់នៅក្នុងរដ្ឋ យូថាហ៍ ស.រ.អា.*



# ទៅកាន់គោលដៅ



## នៅពេលខ្ញុំនិយាយប្រាប់មិត្តខ្ញុំពីសាសនាចក្រ ពួកគេនិយាយថា ពួកគេមិនចាប់អារម្មណ៍ដោយសារមានច្បាប់ច្រើនពេក ។ តើខ្ញុំអាចប្រាប់ពួកគេអ្វីខ្លះ ?

ឥរិយាបថរបស់យើងចំពោះ « ច្បាប់ » នានាពាក់ព័ន្ធនឹងអ្វីដែលយើងធ្លាប់ធ្វើ ។ ប្រសិនបើមិត្តអ្នកមិនធ្លាប់ជុសធ្មេញ ហើយអ្នកប្រាប់ពួកគេថាអ្នកដុសធ្មេងរាល់ថ្ងៃ ដោយសារអ្នកបានបង្រៀនឲ្យធ្វើដូច្នោះ នោះពួកគេអាចគិតថាការណ៍ជាការគាបសង្កត់ឡើយ ។ ប៉ុន្តែអ្នកមិនបានគិតថាវាជាច្បាប់មួយនោះទេ ដោយសារវាបានក្លាយជាទម្លាប់មួយទៅហើយ ជារបៀបមួយនៃជីវិត ។ កាលពួកគេអាចគិតថា ការមិនដុសធ្មេញពួកគេជាសេរីភាពមួយប្រភេទក្តី អ្នកដឹងពីបញ្ហាដែលវានាំឲ្យកើតឡើង ហើយថាតើវាមានអារម្មណ៍ល្អបែបណាដែលមានធ្មេញស្អាតរឹងមាំនោះ ។

ដូច្នេះវាដូចគ្នានឹង « ច្បាប់ » របស់សាសនាចក្រផងដែរ ។ មិត្តអ្នកអាចគិតថា បទដ្ឋានដែលយើងធ្វើតាមមានភាពរឹតបណ្តឹង ប៉ុន្តែអ្នកដឹងថា ព្រះអម្ចាស់ និង ពួកអ្នកបម្រើទ្រង់បានប្រទានច្បាប់ទាំងនោះមកឲ្យយើង ដើម្បីជួយយើងឲ្យមានជីវិតល្អប្រសើរ ហើយត្រឡប់ទៅព្រះវរបិតាសួគ៌វិញ ។ ដូចគ្នានេះដែរ ការគោរពប្រតិបត្តិចំពោះព្រះបញ្ញត្តិរបស់ព្រះតែងនាំមកនូវពរជ័យ អ្វីដែលសំខាន់បំផុតគឺភាពជាដៃគូនៃព្រះវិញ្ញាណបរិសុទ្ធ ។ អ្នកអាចសាកល្បងរៀបរាប់ពីអត្ថប្រយោជន៍ និង ពរជ័យទាំងនេះដល់មិត្តអ្នក ហើយអ្នកអាចប្រាប់ពួកគេថា មានវិធីតែមួយគត់ដែលអាចដឹងថា « ច្បាប់ » ទាំងនោះមកពីព្រះ គឺការសាកល្បងវា ( សូមមើល យ៉ូហាន 7:17 ) ។ ■

## ហេតុអ្វីបានជាព្រះបង្កើតយើង ?

វាជាការសំខាន់ដើម្បីយល់ថា ព្រះមិនបាន « បង្កើត » យើងមកដោយបណ្តាលឲ្យយើងកើតជាមនុស្សដែលគ្មានអ្វីសោះ ។ ផ្នែកដ៏សំខាន់មួយចំនួននៃយើងបានកើតមានពីមុនកំណើតខាងវិញ្ញាណរបស់យើងមកម្ល៉េះ ៖ « កាលដើមឡើយមនុស្សក៏បាននៅជាមួយនឹងព្រះដែរ ។ បញ្ញា ឬពន្លឺនៃសេចក្តីពិតក៏ពុំបានបង្កើត ឬធ្វើឡើង ឬអាចបង្កើត ឬធ្វើឡើងឡើយ » ( គ. និង ស. 93:29 ) ។ ដោយសារយើងដឹងពីការណ៍នេះ យើងក៏ដឹងផងដែរថា ការលើកទឹកចិត្តរបស់ព្រះវរបិតាសួគ៌នៅក្នុងការបង្កើតយើង ពុំមែនជារឿងចៃដន្យ ឬ តាមតែព្រះទ័យទ្រង់នោះទេ ប៉ុន្តែដោយមានគោលបំណងជាក់លាក់ ។ ព្យាការីយ៉ូសែបស្ម៊ីធបានបង្រៀនថា « ដោយឃើញថាទ្រង់ស្ថិតនៅក្នុងចំណោមពួកវិញ្ញាណ និង សិរីល្អ ដោយសារទ្រង់មានបញ្ញាច្រើនជាងពួកគេ ព្រះអង្គទ្រង់ផ្ទាល់បានទតឃើញយ៉ាងត្រឹមត្រូវដើម្បីបង្កើតច្បាប់ ដែលកូនចៅវិញ្ញាណផ្សេងទៀតអាចមានឱកាសបានក្លាយដូចជាទ្រង់ដែរ » ( *Teachings of Presidents of the Church: Joseph Smith* [ឆ្នាំ 2007] ទំព័រ 210 សូមមើលផងដែរ ម៉ូសេ 1:39 ) ។ ដោយសារព្រះវរបិតាសួគ៌សព្វព្រះហឫទ័យឲ្យយើងមានឱកាសរីកចម្រើន ហើយក្លាយដូចជាទ្រង់ ទើបទ្រង់បង្កើតវិញ្ញាណយើងឡើង ហើយទ្រង់បានប្រទានផែនការនៃសេចក្តីសង្គ្រោះ និង សុភមង្គលមួយដែលចាំបាច់ត្រូវមានបទពិសោធន៍ខាងលោកិយនេះ ។ បន្ទាប់មកប្រហែលជាចម្លើយដ៏សាមញ្ញ ហើយល្អបំផុតចំពោះសំណួរនេះក៏ជាចម្លើយចំពោះហេតុផលដែលព្រះទ្រង់បានធ្វើចំពោះអ្វីៗផ្សេងទៀតដែរ ៖ ដោយសារទ្រង់ស្រឡាញ់យើង ។ ■

# រឿងទាំងឡាយទំនងមិនដូចជាអ្វីដែលបានគិតជានិច្ចឡើយ

សូមធ្វើឲ្យប្រាកដថាការសប្បាយ និង ការលេងកំសាន្តរបស់អ្នកពុំបាននាំអ្នកឲ្យធ្លាក់ចូលផ្លូវដ៏គ្រោះថ្នាក់ ។

*( សូមមើល ហេលេមិន 3:29 ) ។*





# ការបម្រើសម្រាប់

**រ៉ាសេម ម៉ាឡូហ្វ**

នៅឆ្នាំ 2011 ខ្ញុំបានធ្វើការសម្រេចចិត្តដ៏សំខាន់មួយនៅក្នុងជីវិតខ្ញុំ ។ វាបាននាំមកឲ្យខ្ញុំនូវទ្រព្យដ៏អស្ចារ្យបំផុតដែលខ្ញុំពុំធ្លាប់មានពីមុនមក ។ ខ្ញុំបានសម្រេចចិត្តទៅបម្រើបេសកកម្ម ប៉ុន្តែវាពុំមែនជាការសម្រេចចិត្តដ៏ងាយស្រួលនោះទេ ។

ព្រះអម្ចាស់បានប្រទានឱកាសឲ្យខ្ញុំរីករាយនឹងកីឡាបាល់ទាត់កាលខ្ញុំនៅក្មេង និងជាយុវវ័យ ។ ខ្ញុំបានតំណាងឲ្យប្រទេសប៉ារ៉ាហ្គាយនៅក្នុងការប្រកួតអន្តរជាតិ ដោយធ្វើដំណើរជាមួយនឹងក្រុមបាល់ទាត់យុវជនជម្រើសជាតិរបស់ប្រទេសខ្ញុំឈ្មោះថា លីប៊ើរថាត ទៅកាន់ប្រទេសជាច្រើននៅក្នុងតំបន់អឺរ៉ុប អាស៊ី និង អាមេរិកខាងត្បូង ។

សំណាងល្អឪពុកម្ដាយខ្ញុំតែងភ្ជាប់សកម្មភាពកីឡារបស់ខ្ញុំនឹងការអប់រំមួយត្រឹមត្រូវ ព្រមទាំងចំណេះដឹងខាងវិញ្ញាណមួយផងដែរ ។ សេចក្ដីជំនឿ និង ទីបន្ទាល់របស់ម្ដាយខ្ញុំពិតជាគ្រាប់ពូជដែលបានធ្វើឲ្យសេចក្ដីជំនឿ និង ទីបន្ទាល់ខ្ញុំរីកចម្រើនយ៉ាងពិតប្រាកដ ។ ដោយសារភាពស្មោះត្រង់របស់គាត់ ខ្ញុំបានចូលរួមក្នុងថ្នាក់សិក្ខាសាលា ទោះជាកាលវិភាគកីឡាខ្ញុំមានភាពមមាញឹកយ៉ាងណាក្ដី ។

ទោះជាខ្ញុំធ្លាប់ឮពីបេសកកម្មពេញម៉ោងតាំងពីខ្ញុំនៅក្មេងក្ដី ក៏ខ្ញុំមិនសម្រេចចិត្តចំពោះការបម្រើបេសកកម្មដែរ ។ ការណ៍នោះបានផ្លាស់ប្ដូរនៅពេលឪពុកខ្ញុំបានទទួលការហៅមួយឲ្យបម្រើនៅក្នុងគណៈប៊ីស្សពនៃវួដរបស់យើង ។ នេះជាការសម្រេចចិត្តដ៏លំបាកមួយសម្រាប់ឪពុកខ្ញុំ ដោយសារគាត់ចូលប្រឡូកយ៉ាងសកម្មនៅក្នុងអាជីពកីឡារបស់ខ្ញុំ ។ គាត់តែងចូលរួមការហាត់ និង ការប្រកួតបាល់ទាត់របស់ខ្ញុំ ហើយយើងបានចំណាយពេលជាច្រើនរួមគ្នា ។ សម្រាប់រដូវកាលនេះ ការទទួលយកការហៅបម្រើនៅក្នុងគណៈប៊ីស្សពនឹងបង្ហាញពីការលះបង់ពេលវេលាគាំទ្រដល់អាជីពរបស់ខ្ញុំ ។

នៅក្នុងការប្រជុំសាក្រាម៉ង់ ពេលឪពុកខ្ញុំត្រូវបានគេគាំទ្រ មានគំនិតមួយដ៏អស្ចារ្យបានផុសឡើង ដោយប្រាប់ខ្ញុំថា ការលះបង់របស់អ្នកដទៃនឹងក្លាយជាអសារឥតការ ប្រសិនបើខ្ញុំមិនព្រមលះបង់រឿងដ៏សំខាន់សម្រាប់រដូវកាលដ៏ត្រឹមត្រូវនោះទេ ។ នៅពេលថ្លែងទីបន្ទាល់ មានសមាជិកម្នាក់បាននិយាយពីគំនិតមួយថា ប្រសិនបើយើងមានការគោរពប្រតិបត្តិ នោះក្រុមគ្រួសារយើងអាចរួមរស់ដ៏អស់កល្បជានិច្ច ។ គំនិតនោះបានប៉ះដល់ដួងចិត្តខ្ញុំហើយខ្ញុំបានសម្រេចចិត្តថា ខ្ញុំនឹងធ្វើគ្រប់បែបយ៉ាង ដែលខ្ញុំអាចធ្វើបានដើម្បីបានរួមរស់នឹងគ្រួសារខ្ញុំជារៀងរហូត ។ នៅក្នុងថ្នាក់រៀននាថ្ងៃអាទិត្យនោះ សារៈសំខាន់នៃការគោរពតាមព្រះបញ្ញត្តិត្រូវបានលើកឡើងជាច្រើនដង ។ ខ្ញុំបានមានអារម្មណ៍នូវការបំផុសគំនិតយ៉ាងខ្លាំងពី

*គ្មានអ្វីផ្សេងបានផ្ដល់ឲ្យខ្ញុំនូវសេចក្ដីអំណរ និង សេចក្ដីសុខសាន្តបែបនេះ ឬនាំអព្ភូតហេតុជាច្រើនមកឲ្យខ្ញុំ ដូចជាការបម្រើបេសកកម្មខ្ញុំឡើយ ។*

រចនារូបភាពដោយ អាឡិច ផេសហ្គេត



*ពេលវេលារបស់អ្នកសម្រាប់បេសកកម្ម*

*ដើម្បីមើលវីដេអូមួយ (ជាភាសាអង់គ្លេស) ពីអ្នកលេងបាល់ឱបនូវែលសេឡង់ ស៊ីដនី ហ្គោអ៊ីង សូមមើលចូលទៅ lds.org/go/sid-going ។*

# មូលហេតុត្រឹមត្រូវ

ព្រះវិញ្ញាណ ឲ្យបម្រើដល់ព្រះអម្ចាស់រហូតធ្វើឲ្យខ្ញុំប្រាប់គ្រួសារខ្ញុំពីការសម្រេចចិត្តខ្ញុំទៅបម្រើបេសកកម្មនៅក្នុងរាត្រីជួបជុំក្រុមគ្រួសារ ។

ការសម្រេចខ្ញុំមានន័យថាខ្ញុំត្រូវផ្អាកការសិក្សារបស់ខ្ញុំនៅមហាវិទ្យាល័យ ព្រមទាំងកិច្ចសន្យាចំនួនប្រាំ ឆ្នាំដែលខ្ញុំបានធ្វើនឹងក្លឹបបាល់ទាត់របស់ខ្ញុំផងដែរ ។ តាំងពីដំបូងមក ព្រះអម្ចាស់បានបើកទ្វារ ហើយប៉ះដួងចិត្ត ដើម្បីកិច្ចសន្យានោះអាចត្រូវបានដោះស្រាយ ។

បន្ទាប់ពីខ្ញុំបានដាក់បែបបទបេសកកម្មរបស់ខ្ញុំ ខ្ញុំបានស្ដាប់សន្និសីទទូទៅខែ មេសា 2011 ដែលអែលឌើរ នែល អិល អាន់ឌើរសិន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានចែកចាយពីបទពិសោធន៍អ្នកផ្សព្វផ្សាយសាសនាឈ្មោះ ស៊ីដនី ហ្គោអ៊ីង ដែលជាអ្នកលេងបាល់ឱបអាជីព និង ជាសមាជិកក្រុមជម្រើសជាតិនូវែលសេឡង់ ។ កាលដែលបងប្រុសហ្គោអ៊ីងបានបម្រើបេសកកម្ម ហើយក្រោយមកបានត្រឡប់មកវិញ ហើយបានបន្តអាជីពរបស់គាត់បានបង្រៀនមេរៀនមួយដល់ខ្ញុំ ។ នៅក្នុងបេសកកម្មខ្ញុំ និងរហូតមកដល់សព្វថ្ងៃនេះ ការស្ដាប់សុន្ទរកថានោះម្ដងហើយម្ដងទៀតបានប្រទានពរខ្ញុំ ហើយបាននាំសេចក្ដីសុខសាន្តនៅក្នុងចិត្តខ្ញុំ ។ ទីបន្ទាល់រាប់មិនអស់ដែលសមាជិកគ្រួសារ វ៉ូដ និង ស្ដេកបានចែកចាយនឹងខ្ញុំនៅពេលខុសគ្នា វាមិនគ្រាន់តែពង្រឹងដល់ការសម្រេចចិត្តខ្ញុំឲ្យបម្រើប៉ុណ្ណោះទេ ប៉ុន្តែវាក៏គាំទ្រខ្ញុំនៅគ្រាដ៏លំបាកក្នុងបេសកកម្មខ្ញុំផងដែរ ។

ប្រភពនៃភាពរីករាយមួយទៀតក្នុងជីវិតខ្ញុំចំពោះការសម្រេចចិត្តរបស់ខ្ញុំទៅបេសកកម្មបានជួយមិត្តសម្លាញ់ខ្ញុំបីនាក់ឲ្យសម្រេចចិត្តបម្រើបេសកកម្មផងដែរ ។ ក្រោយមកពួកគេបានបម្រើជាពួកអ្នកដឹកនាំតំបន់ ជាជំនួយការប្រធានបេសកកម្ម និងជាប្រធានសាខាទៀតផង ។ ឥឡូវនេះយើងបានសម្លឹងមើលទៅផ្លូវដែលនឹងអនុញ្ញាតឲ្យយើងត្រឡប់ទៅវត្តមានរបស់ព្រះវរបិតាសួគ៌ ។

ខ្ញុំជាមនុស្សថ្មីខុសពីខ្ញុំកាលពីបីឆ្នាំមុន ។ បំណងប្រាថ្នាដ៏ធំបំផុសរបស់ខ្ញុំគឺការធ្វើតាមព្រះហឫទ័យរបស់ព្រះអម្ចាស់ ។ ព្រះអម្ចាស់បានប្រទានពរខ្ញុំ « មួយរយភាគរយ » ( ម៉ាថាយ 19:29 ) ។ ខ្ញុំមានទីបន្ទាល់ពិតដ៏រស់រវើកមួយស្ដីពីទេវភាពនៃព្រះវរបិតាសួគ៌ បុត្រាដ៏ជាទីស្រលាញ់របស់ទ្រង់ និង ដង្វាយធួនទ្រង់ អំណាចដ៏បរិសុទ្ធនៃព្រះវិញ្ញាណបរិសុទ្ធនៃព្រះ និងកិច្ចការធំ ហើយអស្ចារ្យនៅថ្ងៃចុងក្រោយនេះ នៅពេលដំណឹងល្អត្រូវបានស្ដារឡើងវិញលើនៅផែនដីនេះតាមរយៈព្យាការី យ៉ូសែបស្ម៊ីធ ( សូមមើល អេសាយ 29:14 ) ។

ដួងចិត្តរបស់ខ្ញុំពោរពេញដោយសេចក្ដីស្រឡាញ់ និងអំណរគុណចំពោះពេលវេលាដ៏ពិសិដ្ឋនេះ និងចំពោះការស្គាល់ និងការស្រឡាញ់ដល់បងប្អូនប្រុសស្រីជាច្រើននៅក្នុងបេសកកម្មមុនតេវីដេអូអ៊ុយរូហ្គាយ ។ ខ្ញុំមានពរណាស់ដោយបម្រើនៅក្នុងចំណោមពួកគេ ។ គ្មានអ្វីផ្សេងបានផ្ដល់ឲ្យខ្ញុំនូវសេចកក្ដីអំណរ និង សេចក្ដីសុខសាន្តបែបនេះ ឬនាំអព្ភូតហេតុជាច្រើនមកឲ្យខ្ញុំ ដូចជាការបម្រើបេសកកម្មខ្ញុំឡើយ ។ ■

*អ្នកនិពន្ធរស់នៅប្រទេសប៉ារ៉ាហ្គាយ ។*



# ពួកមរមនពិតជាជឿលើព្រះ

*នៅឯអាកាសយានដ្ឋានមួយឆ្ងាយពីផ្ទះ ខ្ញុំបានមានឱកាសមួយដើម្បីចែកចាយដំណឹងល្អជាមួយនឹងមនុស្សដែលមិនស្គាល់ ។*

ប្រេនដា ហ៊ើណាន់ឌេស្ស រីស្ស

ខ្ញុំបានធ្វើដំណើរពីម៉ិកស៊ិក ទៅ ម៉ុនតាណា ស.រ.អា. ហើយបានឈប់នៅឌេនវើរ រដ្ឋកូឡូរ៉ាដូ ។ ខ្ញុំបានដើរជុំវិញអាកាសយានដ្ឋាននោះ ដោយមើលចេញទៅតាមបង្អួចធំៗ នូវយន្តហោះចុះចត និង ហោះចេញ ។ ខ្ញុំមានការព្រួយបារម្ភដោយសារខ្ញុំមិនធ្លាប់ធ្វើដំណើរតាមយន្តហោះពីមុនមក ។ អាកាសយានដ្ឋាននោះទំនងដូចជាធំណាស់ ។

ខ្ញុំបានមើលសំបុត្រយន្តហោះខ្ញុំ ហើយដឹងថាខ្ញុំមានពេលពីរម៉ោងទៀតពីមុនជើងហោះហើររបស់ខ្ញុំនឹងធ្វើដំណើរ ។ ខ្ញុំបានសម្រេចចិត្តរកកន្លែងអង្គុយអានរហូតដល់ខ្ញុំចូលទៅក្នុងយន្តហោះ ។ ខ្ញុំមានអារម្មណ៍ភ័យខ្លាចនៅពេលខ្ញុំស្វែងរកកន្លែងអង្គុយ ។ កៅអីមានមនុស្សអង្គុយស្ទើរតែទាំងអស់ ។ ខ្ញុំបានសម្រេចចិត្តអង្គុយនៅក្បែរស្ត្រីចំណាស់ម្នាក់ដែលទំនងជាឯកោ។ គាត់ជាមនុស្សតែម្នាក់គត់ដែលមិនធ្វើឲ្យខ្ញុំខ្លាច ។

រយៈពេលមួយម៉ោងជាងបានកន្លងផុតទៅ ខ្ញុំបានសម្រេចចិត្តនិយាយរកគាត់ ។ ខ្ញុំបានណែនាំខ្លួនខ្ញុំ គាត់ទំនងជាមនុស្សល្អ ហើយចង់និយាយនឹងខ្ញុំពីជោគជ័យរបស់ចៅគាត់ ។ គាត់បានសួរបន្តិចបន្តួចពីខ្លួនខ្ញុំ ហើយខ្ញុំបានប្រាប់គាត់ពីជីវិតខ្ញុំនៅប្រទេសម៉ិកស៊ិក ។ បន្ទាប់មក ខ្ញុំមានការជម្រុញចិត្តភ្លាមៗមួយឲ្យចែកចាយដំណឹងល្អនឹងគាត់ ។ គាត់បានសួរពីសាសនាខ្ញុំ ហើយខ្ញុំបានប្រាប់គាត់ថា ខ្ញុំជាសមាជិកសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ។

គាត់បានពោលថាគាត់ពុំធ្លាប់ឮពីមុនមកទេ ។

ខ្ញុំញញឹម ហើយតបថា « យើងក៏ត្រូវបានគេរាប់ទុកថាជាពួកមរមនផងដែរ » ។

រំពេចនោះគាត់បានផ្លាស់ប្ដូរឥរិយាបថភ្លាម ។ ទឹកមុខគាត់ និង ការនិយាយរបស់គាត់បានផ្លាស់ប្ដូរ ។ គាត់ទំនងដូចជាមិនដឹងថាត្រូវនិយាយពីអ្វីទេ ។ ខ្ញុំមានអារម្មណ៍ថា ការសន្ទនារបស់យើងបានបញ្ចប់ហើយ ប៉ុន្តែខ្ញុំបានព្យាយាមបន្តនិយាយរកគាត់ ។ ខ្ញុំបានសួរគាត់ពីសាសនារបស់គាត់ ។ គាត់បានតបដោយគ្មានការស្ទាក់ស្ទើរថា « ខ្ញុំជាកាតូលីក » ។

រចនារូបភាពដោយ ស្ទីវ ឃីល



បន្ទាប់មកគាត់ពោលថា « ខ្ញុំមិនយល់ទេ ។ អ្នកជាក្មេងស្រីម្នាក់ដ៏ល្អ ។ អ្នកហាក់ដូចជានារីដ៏សមរម្យម្នាក់ ។ ហេតុអ្វីបានជាអ្នកចង់ក្លាយជាពួកមរមន ? »

ខ្ញុំមានការភ្ញាក់ផ្អើលចំពោះពាក្យសម្ដីនេះ ហើយខ្ញុំមិនដឹងត្រូវតបបែបណាទេ ។ ខ្ញុំបានធ្វើការអធិស្ឋានដោយស្ងៀមស្ងាត់ ដោយទូលសុំព្រះវរបិតាសួគ៌ឲ្យជួយខ្ញុំពន្យល់ថាតើការធ្វើជាពួកបរិសុទ្ធថ្ងៃចុងក្រោយមានន័យយ៉ាងណាចំពោះខ្ញុំនោះ ។ ខ្ញុំបានប្រាប់គាត់ថា មានចិត្តសោមនស្សនឹងធ្វើជាសមាជិកសាសនាចក្រណាស់ ហើយដោយសារការបង្រៀននៃដំណឹងល្អ ខ្ញុំអាចធ្វើជាមនុស្សម្នាក់ដ៏ប្រពៃ ហើយមើលរឿងទាំងឡាយដោយមានការយល់ដឹងច្បាស់ ។

គាត់ទំនងជាភ្ញាក់ផ្អើល ហើយបានតបថា « ពួកមរមនមិនជឿលើព្រះទេ » ។

ខ្ញុំខំទប់សំណើចចំពោះពាក្យសម្ដីនោះ ផ្ទុយទៅវិញខ្ញុំបានញញឹម ហើយដឹងថានេះជាឱកាសខ្ញុំដើម្បីចែកចាយសេចក្ដីពិតជាមួយនឹងគាត់ ។ ខ្ញុំបានពន្យល់ពីជំនឿសំខាន់ៗរបស់យើងមួយចំនួន ។ ខ្ញុំបានបង្រៀនគាត់ពីផែនការសង្គ្រោះ និង ពីសារៈសំខាន់នៃក្រុមគ្រួសារ ។ គាត់ហាក់ដូចនៅតែមិនជឿ ដូច្នេះខ្ញុំបានសម្រេចចិត្តថ្លែងទីបន្ទាល់របស់ខ្ញុំទៅគាត់ ។ នៅក្នុងអាកាសយានដ្ឋានដ៏ធំនោះ ខ្ញុំត្រូវបានប្រទានពរឲ្យនូវភាពក្លាហាន ដើម្បីចែកចាយទីបន្ទាល់របស់ខ្ញុំស្ដីពីយ៉ូសែប ស្ម៊ីធ ស្ដីពីព្យាការី និង ពួកសាវកដែលនៅរស់ និងពីសេចក្ដីស្រឡាញ់ដែលខ្ញុំមានចំពោះដំណឹងល្អ និង ព្រះគម្ពីរមរមន ។

ខ្ញុំមើលនាឡិការបស់ខ្ញុំ ។ វាដល់ពេលដែលខ្ញុំត្រូវឡើងយន្ដហោះ ។

នៅថ្ងៃរសៀលនោះបានពង្រឹងទីបន្ទាល់ខ្ញុំតាមរបៀបមួយដែលខ្ញុំពុំធ្លាប់មានពីមុនមកឡើយ ។ ខ្ញុំមានចិត្តរីករាយដែលខ្ញុំបានចែកចាយទីបន្ទាល់ខ្ញុំនឹងគាត់ ហើយមានអំណរគុណដែលខ្ញុំអាចជួយផ្លាស់គំនិតគាត់អំពីសមាជិកសាសនាចក្រ ។ ឥឡូវនេះខ្ញុំកាន់តែមានចិត្តក្លាហាន នៅពេលមនុស្សម្នាក់សួរខ្ញុំពីសាសនាចក្រ ។ ■

*អ្នកនិពន្ធរស់នៅរដ្ឋ ឈីវ៉ាវ៉ា ប្រទេសម៉ិកស៊ិក ។*



# តើយើងអាចធ្វើអ្វីខ្លះដើម្បីមានភាពសក្ដិសមនឹងព្រះវិញ្ញាណ ?

**ដោយប្រធាន**
**ប៊យដ៏ កេ ផាកកឺ**
ប្រធានកូរ៉ុមនៃពួកសាវកដប់ពីរនាក់

*សមាជិកកូរ៉ុមនៃពួកដប់ពីរនាក់ គឺជាសាក្សីពិសេសរបស់ព្រះយេស៊ូវគ្រីស្ទ ។*



ស្ដាប់តន្ត្រីដែលលើកតម្កើង ។



និយាយឲ្យមានគារវភាព ។



ប្រែចិត្តពេលអ្នកធ្វើខុស ។



ស្លៀកពាក់ឲ្យថ្លៃថ្នូរ ។

ប្រសិនបើអ្នកធ្វើរឿងទាំងនេះ
អ្នកនឹងត្រូវបានថែរក្សា ហើយ
ព្រះវិញ្ញាណបរិសុទ្ធនឹងដឹកនាំអ្នក ។

គំនូរព្រាងដោយ ម៉ាត ស្មីធ

ដកស្រង់ពី « **Counsel to Youth** » ***Liahona*** ខែ វិច្ឆិកា ឆ្នាំ 2011 ទំព័រ 16–19 ។

# មេរៀនរបស់ខ្ញុំស្តីពីសេចក្តីជំនឿ



**អិមម៉ា អ័រ** អាយុ 11 ឆ្នាំ រដ្ឋតិចសាស ស.រ.អា.

ពីរបីឆ្នាំមុន ខ្ញុំបានបង្រៀនមេរៀនមួយស្តីពីសេចក្តីជំនឿនៅក្នុងរាត្រីជួបជុំក្រុមគ្រួសារ ។ គ្រួសារខ្ញុំបានចំណាយពេលយ៉ាងច្រើនពិភាក្សាគ្នាពីសេចក្តីជំនឿ ដោយសារបងប្រុសខ្ញុំបានឆ្ងល់ថាហេតុអ្វីបានជាយើងត្រូវការសេចក្តីជំនឿ ។ ខ្ញុំបានដាំគ្រាប់ផ្លែឪឡឹកមួយនៅក្នុងពែងតូចមួយ ។ ខ្ញុំបានប្រាប់គ្រួសារខ្ញុំថា សេចក្តីជំនឿដូចជាគ្រាប់ពូជមួយដែរ ។ ប្រសិនបើអ្នកមើលថែវាឲ្យល្អ គ្រាប់ពូជនោះនឹងលូតលាស់ ។

យើងពុំធ្លាប់មានជោគជ័យច្រើននៅក្នុងការដាំបន្លែនោះទេ ។ ប៉ុន្តែខ្ញុំសង្ឃឹមថា ខ្ញុំអាចធ្វើឲ្យរុក្ខជាតិនេះលូតលាស់ ហើយថាខ្ញុំអាចធ្វើជាគំរូល្អនៃសេចក្តីជំនឿ ។ ខ្ញុំបានដាក់ពែងនោះនៅមាត់បង្អួច ហើយមើលថែវា ។ ខ្ញុំបានរង់ចាំ ហើយបានអធិស្ឋានឲ្យគ្រាប់ពូជខ្ញុំលូតលាស់ ។

ខ្ញុំស្ទើរតែបោះបង់ចោលទៅហើយ ប៉ុន្តែមួយសប្តាហ៍ក្រោយមកនៅទីបំផុតខ្ញុំបានឃើញពន្លកពណ៌ខៀវបានដុះឡើង ។ វាដុះនៅត្រង់មាត់បង្អួចអស់មួយសប្តាហ៍ទៀត ។ បន្ទាប់មកឪពុកម្តាយខ្ញុំបានជួយខ្ញុំរកកន្លែងមួយដើម្បីដាំវានៅសួនផ្កាខាងក្រោយផ្ទះយើង ។

ខ្ញុំមើលថែរុក្ខជាតិខ្ញុំបានយ៉ាងល្អ ។ ខ្ញុំបានស្រោចទឹកវា ហើយធ្វើឲ្យវាមានសំណើមជានិច្ច ។ វាបន្តលូតលាស់កាន់តែធំទៅៗ ។ ខ្ញុំរីករាយខ្លាំងណាស់ !

បន្ទាប់ពីពេលវេលាបានកន្លងផុតទៅជាច្រើនសប្តាហ៍ ខ្ញុំបានឃើញមានផ្កា រួចហើយមានផ្លែតូចបានចាប់ផ្តើមចេញពន្លក ។ យើងបានមើលផ្លែឪឡឹកប្រាំពីរបានដុះចេញជាវល្លិចេញពីពីគ្រាប់ពូជដ៏តូចមួយរបស់ខ្ញុំ ។ ចំពោះខ្ញុំវាជាអព្ភូតហេតុ និង ជាចម្លើយចំពោះការអធិស្ឋានខ្ញុំ ។ ផ្លែនោះផ្អែមដូចជាបានចែងនៅក្នុង អាលម៉ា 32:42 ថា ៖ « ហើយដោយសារសេចក្តីព្យាយាមរបស់អ្នក និង សេចក្តីជំនឿរបស់អ្នក និង សេចក្តីអត់ធន់របស់អ្នកទៅលើព្រះបន្ទូល ដោយថែទាំព្រះបន្ទូលនោះដើម្បីឲ្យវាចាក់ឫសនៅក្នុងខ្លួនអ្នក មើលចុះ នៅមិនយូរមិនឆាប់ អ្នករាល់គ្នានឹងបេះបានផ្លែឈើនោះដែលពិសេសបំផុត ដែលផ្អែមជាងអ្វីៗដែលផ្អែមទាំងអស់ » ។

បទពិសោធន៍នេះបានធ្វើឲ្យខ្ញុំរីករាយណាស់ ហើយបានបង្រៀនខ្ញុំ និង គ្រួសារខ្ញុំថា សេចក្តីជំនឿគឺជាគោលការណ៍ពិតនៃដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ។ ■

រចនារូបភាពដោយ ខាធី ម៉ាកឌី

## វេនរបស់អ្នក

យើងចង់ដាំគ្រាប់ពូជមួយជាមួយនឹងអ្នក ៖ តើអ្នកធ្លាប់គិតពីការចែកចាយបទពិសោធន៍របស់អ្នកជាមួយនឹង*លីអាហូណា*ដែរទេ ? យើងសូមស្វាគមន៍ចំពោះដំណើររឿងពិតស្តីពីរបៀបដែលអ្នករស់នៅតាមដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ ។ ឧទាហរណ៍ អ្នកអាចសរសេរពីគ្រាមួយដែលអ្នកបានទទួលចម្លើយពីការអធិស្ឋាន ឬពេលអ្នកបានអញ្ជើញមិត្តម្នាក់ទៅព្រះវិហារ ។

ឪពុកម្តាយអ្នកអាចជួយអ្នកផ្ញើវា ៖ តាមអ៊ិនធើរណែតនៅ liahona.lds.org តាមអ៊ីម៉ែលទៅកាន់ liahona@ldschurch.org ឬតាមសំបុត្រទៅកាន់អាសយដ្ឋាននៅលើទំព័រទី 3 ។ សូមភ្ជាប់ឈ្មោះវួដ ឬសាខារបស់អ្នក និងមានការអនុញ្ញាតរបស់ឪពុកម្តាយអ្នកមកជាមួយ ។



### តើការមានរូបកាយមានអ្វីអស្ចារ្យទៅ ?

រូបកាយយើងមានសារៈសំខាន់ណាស់ ហើយបរិសុទ្ធ រហូតដល់ព្រះអម្ចាស់ឲ្យឈ្មោះថាជាព្រះវិហារបរិសុទ្ធ ( សូមមើលកូរិនថូសទី 1 3:16–17 ) ។ ហើយការមានរូបកាយក៏សប្បាយផងដែរ ! រូបកាយអាចរត់ ច្រៀង ឡើងភ្នំ សើច គូររូប ហែលទឹក រាំ ហើយធ្វើសកម្មភាពសប្បាយផ្សេងទៀត ។ យើងក៏អាចប្រើរូបកាយយើងដើម្បីរៀន ជួយមនុស្ស បង្កើតក្រុមគ្រួសារ ហើយធ្វើឲ្យពិភពលោកនេះក្លាយជាកន្លែងមួយដ៏ប្រពៃផងដែរ ។



### ហេតុអ្វីយើងមានរូបកាយ ?

ពីមុនយើងចាប់កំណើត យើងជាវិញ្ញាណដែលគ្មានរូបកាយ ។ មានរឿងជាច្រើនដែលយើងមិនអាចធ្វើលុះត្រាយើងមានរូបកាយ ។ ព្រះបានចាត់យើងឲ្យមកផែនដីនេះដើម្បីទទួលរូបកាយ ។ យើងត្រូវការទាំងវិញ្ញាណ និង រូបកាយដើម្បីប្រែក្លាយដូចជាព្រះវរបិតាសួគ៌ ។ ( សូមមើលគ. និង ស. 88:15 ) ។

# រូបកាយរបស់ខ្ញុំ គឺជា

## ចុះបើខ្ញុំមិនចូលចិត្តរូបកាយខ្ញុំត្រង់ផ្នែកណាមួយវិញ ?

ពេលខ្លះរូបកាយយើងមើលទៅ ឬធ្វើចលនាមិនដូចជាអ្វីដែលយើងចង់បាននោះទេ ។ ប៉ុន្តែ មិនថារូបកាយយើងមានភិនភាគបែបណានោះទេនាពេលនេះ យើងក៏អាចជ្រើសមានអំណរគុណចំពោះវា ហើយប្រើវាធ្វើរឿងល្អៗនៅលើផែនដីនេះបានដែរ ។ នៅថ្ងៃមួយ យើងម្នាក់ៗនឹងត្រូវបានរស់ឡើងវិញ ហើយមានរូបកាយដែលល្អឥតខ្ចោះ (សូមមើល អាលម៉ា 40:23) ។ ព្រះស្រឡាញ់យើង មិនថាយើងមានរូបកាយបែបណាទេ ហើយយើងអាចស្រឡាញ់ខ្លួនយើងផងដែរ ។

## ហេតុអ្វីបានជាមនុស្សទូទៅមិនដូចគ្នា ?

រូបកាយកើតមកជារាង ពណ៌សម្បុរ និងទំហំគ្រប់ប្រភេទ ហើយនេះជាផ្នែកមួយនៃផែនការនៃព្រះវរបិតាសួគ៌ ។ ទោះជារូបកាយនីមួយខុសគ្នាក្តី ក៏យើងរាល់គ្នាត្រូវបានបង្កើតឡើងតាមរូបភាពនៃព្រះដែរ ( សូមមើលលោកុប្បត្តិ 1:26 ) ។ នោះមានន័យថា រូបកាយយើងយកលំនាំតាមព្រះកាយដ៏ល្អឥតខ្ចោះរបស់ទ្រង់ ។ រូបកាយមនុស្សគ្រប់គ្នាមានភាពស្រស់ស្អាត ដោយសាររូបកាយនីមួយៗគឺជាអំណោយទានពីព្រះវរបិតាសួគ៌ជាទីស្រឡាញ់នៃយើង ។



## តើខ្ញុំគួរធ្វើដាក់រូបកាយខ្ញុំបែបណា ?

យើងគួរធ្វើដាក់រូបកាយយើងតាមរបៀប ដែលយើងនឹងមើលថែទ្រព្យដ៏មានតម្លៃបំផុតដែរ—ដោយសេចក្តីស្រឡាញ់ និង សេចក្តីគោរព ។ តាមរយៈពួកព្យាការី និង ពាក្យសំម្តីនៃប្រាជ្ញាវាងវៃ ព្រះវរបិតាសួគ៌បានមានបន្ទូលប្រាប់យើងពីអ្វីដែលល្អ និង មិនល្អសម្រាប់រូបកាយយើង ។ មានរឿងជាច្រើនដែលយើងអាចធ្វើដើម្បីមើលថែរូបកាយយើង ៖

- ហូបអាហារល្អៗ ហើយធ្វើលំហាត់ប្រាណ ។
- ស្លៀកពាក់ថ្លៃថ្នូរ ហើយរក្សារូបកាយយើងឲ្យស្អាតស្អំ ។
- គោរពចំពោះរូបកាយរបស់មនុស្សដទៃទៀត ។
- កុំសាក់ ឬចោះលើរូបកាយយើង ។
- កុំប្រើថ្នាំញៀន សុរា បារី កាហ្វេ ឬតែ ។
- លេងល្បែងដែលមានសុវត្ថិភាព ហើយរីករាយ ហើយនៅឲ្យឆ្ងាយពីសកម្មភាពដែលគ្រោះថ្នាក់ ។

នៅពេលយើងមើលថែរូបកាយយើង យើងអាចទទួលអារម្មណ៍ពីព្រះវិញ្ញាណបរិសុទ្ធកាន់តែច្រើន ។



**នៅពេលយើងមើលថែរូបកាយយើងតាមរបៀបដែលព្រះបានបញ្ជា យើងនឹងមានពរ ! ( សូមមើល ម៉ូសាយ 2:41,គ. និង ស. 89:18–21 ) ។**

# ព្រះវិហារបរិសុទ្ធ

ដោយ ម៉ារីស្សា វីដឌីសុន
ទស្សនាវដ្តីសាសនាចក្រ



គំនូរព្រាង ដោយ ស្ទីវ ក្រិប

# យើងក្លាយជាសមាជិកនៃសាសនាចក្រតាមរយៈពិធី បុណ្យជ្រមុជទឹក និងពិធីបញ្ជាក់

ដោយ ជែននីហ្វើ ម៉ាឌី

ម៉ារីអេឡាបានមកដល់ផ្ទះពីសាលារៀនវិញដោយមានទឹកមុខជូរចត់ ។ « មានរឿងអី ? » ម្ដាយបានសួរនៅពេលគាត់ដាំផ្កានៅក្នុងសួន ។

ម៉ារីអេឡាបានតបថា « សូនីយ៉ាបានសន្យាថានាងនឹងលេងជាមួយកូន តែនាងមិនបានធ្វើទេ » ។ នាងបានលុតជង្គង់ចុះទៅនឹងដីជិតម្ដាយ ។

ម្ដាយពោលថា « ម៉ាក់សុំទោស » ។ « ការរក្សាការសន្យាជារឿងដ៏សំខាន់ ។ សប្ដាហ៍ក្រោយពេលកូនជ្រមុជទឹក និង ទទួលការបញ្ជាក់ កូននឹងធ្វើការសន្យាដ៏សំខាន់មួយចំនួន ដែលហៅថាសេចក្ដីសញ្ញា » ។

« ពិតមែនឬ ? » ម៉ារីអេឡាបានសួរ ។ នាងមានចិត្តរីករាយដោយបានទទួលបុណ្យជ្រមុជទឹក ។

ម្ដាយបានដាក់ផ្កាពណ៌លឿងមួយចំនួនទៅក្នុងដី ។ « កូនសន្យាដើម្បីគោរពប្រតិបត្តិព្រះបញ្ញត្តិ ។ កូនក៏សន្យាផងដែរដើម្បីយកព្រះនាមនៃព្រះយេស៊ូវគ្រីស្ទមកដាក់លើខ្លួនកូន ។ តើព្រះវរបិតាសួគ៌បានសន្យាអ្វីខ្លះ ប្រសិនបើកូនធ្វើកិច្ចការទាំងនោះ ? »

ម៉ារីអេឡាបានគិតពីអ្វីដែលនាងបានរៀននៅក្នុងថ្នាក់កុមារ ។ « ថាកូននឹងមានព្រះវិញ្ញាណបរិសុទ្ធគង់នៅជាមួយនឹងកូន » ។

ម្ដាយបានតបថា « ត្រឹមត្រូវហើយ »។ « កូនក៏នឹងក្លាយជាសមាជិកសាសនាចក្ររបស់ព្រះយេស៊ូវផងដែរ ។ « តើកូនអាចរក្សាការសន្យារបស់កូនដើម្បីគោរពប្រតិបត្តិព្រះបញ្ញត្តិបានដោយរបៀបណា ? »

ម៉ារីអេឡាតបថា « ខ្ញុំត្រូវមានចិត្តល្អ ហើយខ្ញុំអាចប្រាប់ពីសេចក្ដីពិត » ។ « តើការយកព្រះនាមព្រះយេស៊ូវមកដាក់លើខ្លួនកូនមានន័យយ៉ាងដូចម្ដេច ? »

ម្ដាយតបថា « វាមានន័យថា កូនព្យាយាមប្រែក្លាយដូចជាទ្រង់ ហើយធ្វើអ្វីដែលទ្រង់សព្វព្រះហឫទ័យចង់ឲ្យកូនធ្វើ » ។ « តើកូនអាចធ្វើអ្វីខ្លះដើម្បីប្រែក្លាយដូចជាព្រះយេស៊ូវ ? »

ម៉ារីអេឡាបានបង្វិលផ្កាពណ៌ស្វាយមួយនៅចន្លោះម្រាមដៃនាង ។ « កូនអាចអង្គុយជិតក្មេងស្រីថ្មីនៅឯសាលា ។ ហើយកូនអាចព្យាយាមធ្វើល្អដល់សូនីយ៉ា » នាងបានតប ។

ម្ដាយតបវិញថា « នោះជាគំនិតល្អណាស់ » ។ « ហើយនៅពេលកូនទទួលទានសាក្រាម៉ង់ កូនអាចចងចាំពីការសន្យារបស់កូន » ។

ម៉ារីអេឡាបានញញឹម ។ « កូនដឹងពីការសន្យាមួយទៀត—គឺការស្រោចទឹកផ្កាដើម្បីយើងអាចមានសួនផ្កាដ៏ស្រស់ស្អាត ! » ■

*អ្នកនិពន្ធរស់នៅក្នុងរដ្ឋ យូថាហ៍ ស.រ.អា. ។*



## ចម្រៀង និង ព្រះគម្ពីរ

- « Baptism » *Children's Songbook* ទំព័រ 100 ( វគ្គទី 1 និងទី 3 )
- យ៉ូហាន 3:5

## គំនិតយោបល់សម្រាប់ការនិយាយក្នុងគ្រួសារ

ម៉ារីអេឡាបានគិតពីរបៀបដែលនាងអាចរក្សាសេចក្ដីសញ្ញានៃពិធីបុណ្យជ្រមុជទឹករបស់នាងដោយការធ្វើតាមព្រះយេស៊ូវគ្រីស្ទ ។ គ្រួសារអ្នកអាចគិតពីរបៀបដើម្បីប្រែក្លាយ ឲ្យកាន់តែដូចជាព្រះគ្រីស្ទនៅក្នុងផ្ទះ នៅសាលារៀន និង ទីកន្លែងផ្សេងទៀត ។ សូមដាក់គោលដៅមួយសម្រាប់គ្រួសារ ដើម្បីគិតពីសេចក្ដីសញ្ញានៃពិធីបុណ្យជ្រមុជទឹកនៅពេលអ្នកទទួលទានសាក្រាម៉ង់ ។

# ខ្ញុំអាចរក្សាសេចក្ដីសញ្ញានៃពិធីបុណ្យជ្រមុជទឹករបស់ខ្ញុំបាន

ដើម្បីធ្វើជាខ្សែភាពយន្តមួយស្ដីពីសេចក្ដីសញ្ញានៃពិធីបុណ្យជ្រមុជទឹករបស់អ្នក សូមកាត់ស៊ុម និង បន្ទះរូបភាពនោះចេញ ។ សូមបិទបន្ទះរូបភាពពីររួមគ្នាទៅជាបន្ទះមួយវែង ( ដាក់តម្រួត ក និង ខ ) ។ សូមបិទស៊ុម និង បន្ទះរូបភាពទៅនឹងក្រដាសរឹង ។ សូមកាត់លើបន្ទាត់ដាច់ៗនៅលើស៊ុមនោះដើម្បីបានជារន្ធពីរ ។ អូសបន្ទះរូបភាពកាត់រន្ធទាំងពីរនោះ ដើម្បីឲ្យរូបភាពបង្ហាញនៅពីមុខស៊ុម ។







A










B






រចនារូបភាព ដោយ វ៉ាំដែល ហូមិន បេស។ ខាងស្ដាំ ៖ វាយនភាពក្រដាសដោយ អេនរីក ផ្លូវរ៉េត

# ទំព័ររបស់យើង



ឡេស្លី យូ អាយុ 6 ឆ្នាំ ប្រទេសអេក្វាទ័រ



ឡេឌី យូ អាយុ 9 ឆ្នាំ ប្រទេសអេក្វាទ័រ



សាទីយ៉ា អេស អាយុ 11 ឆ្នាំ ប្រទេសឥណ្ឌូណេស៊ី

អ្នកអាចដាក់ស្នើរូបគំនូរ រូបថត ឬបទពិសោធន៍របស់អ្នកតាមអ៊ិនធើរណែត នៅ liahona.lds.org ដោយអ៊ីម៉ែលទៅកាន់ liahona@ldschurch.org ដោយដាក់ « Our Page » ក្នុងប្រអប់ប្រធានបទ ឬដោយផ្ញើសំបុត្រទៅអាសយដ្ឋាននៅលើទំព័រ 3 ។

រាល់ការផ្ញើមកត្រូវតែមានឈ្មោះពេញរបស់កុមារ ភេទ និងអាយុ ( អាយុចាប់ពី 3 ឆ្នាំ ដល់ 11 ឆ្នាំ ) រួមទាំងឈ្មោះពេញរបស់ឪពុកម្ដាយ វួដ ឬ សាខា ស្តេក ឬ មណ្ឌល និង សំបុត្រអនុញ្ញាតជាលាយលក្ខណ៍អក្សរពីឪពុកម្ដាយផងដែរ ដើម្បីប្រើប្រាស់រូបថត និងឯកសាររបស់កុមារដែលបានបញ្ជូនមក ( អ៊ីម៉ែលក៏អាចទទួលយកបានដែរ ) ។ សូមកុំផ្ញើរូបគំនូររបស់ព្រះអង្គសង្គ្រោះ ។ ការដាក់ស្នើអាចនឹងត្រូវធ្វើការកែសម្រួលដើម្បីឲ្យត្រូវនឹងទំហំ ឬ ភាពច្បាស់លាស់ ។



នៅក្នុងបទបង្ហាញនៃអង្គការបឋមសិក្សាយើងនៅឆ្នាំមួយ ខ្ញុំបានលេងព្យាណូបទ « ខ្ញុំបានរស់នៅស្ថានសួគ៌ » ។ ឆ្នាំក្រោយមកទៀតខ្ញុំបានដឹកនាំចម្រៀងជាភាសាមនុស្ស-គ គឺបទ « ខ្ញុំចូលចិត្តមើលព្រះវិហារបរិសុទ្ធ » ។ ឆ្នាំបន្ទាប់ទៀត ខ្ញុំមានគោលដៅដើម្បីរៀនបទ « បើខ្ញុំស្ដាប់ដោយដួងចិត្តខ្ញុំ » ។ ខ្ញុំដឹងថាព្រះអម្ចាស់ប្រទានទេពកោសល្យដល់ខ្ញុំ ហើយខ្ញុំគួរអភិវឌ្ឍវា ហើយប្រើវាដើម្បីប្រទានពរដល់មនុស្សដទៃទៀត—នោះទេពកោសល្យរបស់ខ្ញុំនឹងរីកចម្រើន ។ ខ្ញុំដឹងថា ខ្ញុំជាបុត្រីម្នាក់របស់ព្រះ ហើយថាព្រះយេស៊ូវគ្រីស្ទបានលះបង់ព្រះជន្មទ្រង់សម្រាប់ខ្ញុំ ។

**លូណា ម៉ារីសុល អ៊ី អាយុ 8 ឆ្នាំ ប្រទេសអាហ្សង់ទីន**





« ព្រះគម្ពីរមរមន » វិល្លាម អិម អាយុ 10 ឆ្នាំ ប្រទេសប្រេស៊ីល

# បានរៀបចំខ្លួនដើម្បីបម្រើ



**ដោយអែលឌើរ អេក្វាដូ ហ្គាវ៉ារ៉េត**
នៃពួកចិតសិបនាក់

« *ចូររៀននៅក្នុងយុវវ័យរបស់កូនឲ្យចេះកាន់តាមព្រះបញ្ញត្តិទាំងឡាយនៃព្រះ* » ( *អាលម៉ា 37:35* ) ។

ខ្ញុំបានធំដឹងក្តីឡើងនៅទីក្រុងមីណាស់ ប្រទេសអ៊ុយរូហ្គាយ ។ ពេលខ្ញុំអាយុប្រាំមួយឆ្នាំ ម្តាយខ្ញុំ និង បងស្រីខ្ញុំបានជ្រមុជទឹកចូលទៅក្នុងសាសនាចក្រ ។ ឪពុកខ្ញុំមិនបានចូលរួមនឹងសាសនាចក្រទេ ប៉ុន្តែគាត់តែងរីករាយដែលយើងបានទៅព្រះវិហារ ។ គាត់ថែមទាំងបានរក្សាពាក្យសម្តីនៃប្រាជ្ញាវាងវៃ ហើយបង់ដង្វាយមួយភាគក្នុងដប់ទៀតផង ។

សាខាយើងតូចណាស់ ហើយយើងគ្មានអគារព្រះវិហារទេ ។ យើងជួបជុំគ្នានៅផ្ទះជួលមួយ ។ ផ្ទះមានអាងទឹកតូចមួយនៅខាងក្រៅ ដើម្បីយើងប្រើសម្រាប់បុណ្យជ្រមុជទឹក ។

នៅពេលខ្ញុំមានអាយុជិតប្រាំបីឆ្នាំ ខ្ញុំរីករាយចង់ទទួលបុណ្យជ្រមុជទឹក ។ ប៉ុន្តែនៅថ្ងៃបុណ្យជ្រមុជទឹក មានភ្លៀងធ្លាក់ ហើយអាកាសធាតុត្រជាក់យ៉ាងខ្លាំង ។ ម្តាយខ្ញុំបានពោលថា ប្រហែលជាខ្ញុំមិនគួរធ្វើបុណ្យជ្រមុជទឹកនៅថ្ងៃនោះទេ ដោយសារតែអាកាសធាតុត្រជាក់ ។ ប៉ុន្តែវាជាថ្ងៃខួបកំណើតខ្ញុំ ហើយខ្ញុំចង់ធ្វើបុណ្យជ្រមុជទឹកនៅថ្ងៃនោះ ។

ខ្ញុំចាំពីការស្លៀកពាក់ខោអាវសររបស់ខ្ញុំ ហើយដើរចូលទៅក្នុងអាងនោះដើម្បីទទួលបុណ្យជ្រមុជទឹក ។ ខ្ញុំបានដឹងថា ទឹកនោះនឹងត្រជាក់ខ្លាំង ប៉ុន្តែខ្ញុំមិនត្រជាក់នោះទេ ។ ខ្ញុំបានដឹងថា ខ្ញុំកំពុងធ្វើរឿងត្រឹមត្រូវ ហើយខ្ញុំមានអារម្មណ៍កក់ក្តៅ ។

ក្រោយមកទៀតមិនយូរប៉ុន្មាន រោងថ្វាយបង្គំមួយត្រូវបានសង់ឡើងសម្រាប់សាខាយើង ។ នៅពេលនោះ សមាជិកសាសនាចក្រអាចជួយសង់សាលាប្រជុំបាន ។ ការងាររបស់ខ្ញុំគឺរើសដែកគោល និង ខ្ទៅដែលធ្លាក់មកលើដី ដើម្បីយើងអាចប្រើវាម្តងទៀតបាន ។ វាជាការងារដ៏ងាយស្រួលមួយ ប៉ុន្តែវាសំខាន់ចំពោះខ្ញុំណាស់ ។ វាបានបង្រៀនខ្ញុំពីរបៀបបម្រើ ហើយវាបានជួយរៀបចំខ្លួនខ្ញុំសម្រាប់ការបម្រើនាពេលអនាគតក្នុងសាសនាចក្រ ។ សូមចងចាំថា ទោះជាអ្នកក្មេងក្តី រឿងទាំងឡាយដែលអ្នកធ្វើនៅពេលនេះគឺសំខាន់ខ្លាំងណាស់ ។ ■



# ខ្ញុំឈ្មោះ ផេដ្រូមកពីប្រទេសប្រេស៊ីល

ដកស្រង់ពីការសម្ភាសមួយ ដោយអាមី
ជេន លីវិត




ផេដ្រូរស់នៅក្នុងប្រទេសដ៏ធំបំផុតមួយនៃអាមេរិកខាងត្បូង—ប្រទេសប្រេស៊ីល ។ គាត់រស់នៅក្នុងទីក្រុង ខើរីទីបា ជារាជធានីនៃរដ្ឋប៉ារ៉ាណារបស់ប្រជាជនប្រេស៊ីល ។ ផេដ្រូចូលចិត្តចំណាយពេលជាមួយនឹងឪពុកម្ដាយ និង បងប្រុសគាត់ព្រមទាំងប្អូនស្រីគាត់ផងដែរ ។ ពួកគេចូលទៅលេងព្រះវិហារបរិសុទ្ធ និងទៅឆ្នេរសមុទ្រជាមួយគ្នា ។ ផេដ្រូទន្ទឹងរង់ចាំដើម្បីក្លាយជាអ្នកផ្សព្វផ្សាយសាសនានៅថ្ងៃណាមួយ ! ■

*« សួស្ដី មិត្តភក្ដិទាំងឡាយ ! » ជាភាសាព័រទុយហ្គាល់ ។

*រាល់ព្រឹកខ្ញុំអានព្រះគម្ពីរ ហើយអធិស្ឋាននឹងគ្រួសារខ្ញុំពីមុនខ្ញុំទៅសាលារៀន ។ មុខវិជ្ជាដែលខ្ញុំចូលចិត្តគឺផ្នែកសិល្បៈ និង ប្រវត្តិសាស្ត្រនៃប្រជាជនជាតិដើមប្រេស៊ីល ។ មិត្តខ្ញុំភាគច្រើនពុំមែនជាសមាជិកសាសនាចក្រទេ ។ ខ្ញុំនិយាយនឹងពួកគេពីអ្វីដែលខ្ញុំជឿ ហើយអញ្ជើញពួកគេឲ្យមកព្រះវិហារជាមួយខ្ញុំ ។*








ដំណើររឿងក្នុងព្រះគម្ពីរដែលខ្ញុំចូលចិត្ត គឺនៅពេលនីហ្វៃត្រឡប់ទៅយេរូសាឡិមវិញដើម្បីយកផ្ទាំងចំណារស្ពាន់ ។ ខ្ញុំចូលដាក់គោលដៅហើយសម្រេចវា ។ ខ្ញុំមានផែនការដើម្បីបានរង្វាន់របស់ខ្ញុំស្ដីពីសេចក្ដីជំនឿជឿដល់ព្រះពីមុនខ្ញុំមានអាយុ 12 ឆ្នាំ ។





តើអ្នកបានសម្គាល់ឃើញថាត្រាលិខិតឆ្លងដែលបាត់ពីខែមកវាដែរឬទេ ? អ្នកអាចកាត់វាចេញ ហើយដាក់វាតឡូវនេះ !




ខ្ញុំចូលចិត្តគូររូប ។ ខ្ញុំចំណាយពេលច្រើនម៉ោងរាល់សប្ដាហ៍លើកិច្ចការគូររូបរបស់ខ្ញុំ ។ ខ្ញុំក៏ចូលចិត្តទៅបណ្ណាល័យ ហើយមើលសៀវភៅសិល្បៈផងដែរ ។



ខ្ញុំចូលចិត្តលេងបាល់ទាត់ ។ កីឡាមួយទៀតដែលខ្ញុំចិត្តគឺកីឡាហាប់គីដូ ជាក្បាច់គុនមួយប្រភេទមកពីប្រទេសកូរ៉េ ។



## ខ្ញុំចូលចិត្តមើលព្រះវិហារបរិសុទ្ធ

គ្រួសារខ្ញុំចូលចិត្តទៅព្រះវិហារបរិសុទ្ធនៅខើរីប៉ាទី ហើយដើរមើលសួនផ្កាជាមួយគ្នា ។ ខ្ញុំមានអាយុទើបតែប្អូនឆ្នាំប៉ុណ្ណោះពេលព្រះវិហារបរិសុទ្ធនោះបានសាងសង់ឡើង ប៉ុន្តែខ្ញុំចាំពីការទៅដើរមើលនៅថ្ងៃបើកសម្ពោធឲ្យប្រើប្រាស់ ។ វាជាការចងចាំមួយដ៏ពិសេសសម្រាប់ខ្ញុំ ។

## ត្រៀមខ្លួនហើយឬនៅ!

វ៉ាលីរបស់ធេជ្រួមាននូវរបស់មួយចំនួនដែលគាត់ចូលចិត្ត ។ តើរបស់ណាខ្លះដែលអ្នកចង់ដាក់ក្នុងកាបូបរបស់អ្នក ?



ពេលខ្ញុំធំដឹងក្ដីឡើង ខ្ញុំចង់ធ្វើជាអ្នកផ្សព្វផ្សាយសាសនា ។ ខ្ញុំចង់បម្រើនៅម៉ាណោសដោយសារវាជាកន្លែងដែលព្រៃអាម៉ាហ្សូនស្ថិតនៅ ។ បន្ទាប់មកខ្ញុំចង់ធ្វើការជាអ្នករចនាម៉ូតផ្នែកសិល្បៈ ។



ខាងស្ដាំ ៖ រចនារូបភាពដោយថូម៉ាស អេស ឆាល

# សារ៉ាបានដើរហើយដើរទៀត

ដោយ ហៃឌី ផូលម៉ែន

ផ្អែកទៅលើដំណើររឿងពិតមួយ



សារ៉ាបានលេងលោតអន្ទាក់ ។ នាងបានត្រៀមខ្លួនឡើងភ្នំនៅជុំវិញបឹងឈ្មោះ ស៊ីលវើរ ឡេកជាមួយនឹងគ្រួសារនាង ។ ប្អូនប្រុសនាងឈ្មោះ ចស្ស បានរត់ទៅមុន ។



រំពេចនោះព្រះអាទិត្យបានចាប់ផ្តើមធ្វើឲ្យដៃរបស់សារ៉ាក្តៅ ។ ជើងនាងបានចាប់ផ្តើមរ៉ាយ ។

ម្តាយបានពោលថា « កុំបារម្ភអី » ។ « យើងជិតដល់ឡានយើងហើយ » ។

គំនូរដោយ ស្ទីវ ក្រុប

បន្ទាប់មកសារ៉ាបានឃើញខ្សែធំពណ៌ពណ៌ទឹកក្រូចបានដាក់ឃាំងផ្លូវ ។ ឪពុកបានពោលថា « ស្ពានខូចហើយ » ។ « យើងត្រូវដើរត្រឡប់ទៅជុំវិញបឹងវិញ » ។

« ប៉ុន្តែកូនហត់ណាស់ ! » សារ៉ាបានពោលឡើង ។ ចស្ស បានអង្គុយនឹងដី ហើយធ្វើមុខសោកសៅ ។






« តើកូនចាំពីដំណើររឿងរបស់ពួកអ្នកត្រួសត្រាយផ្លូវទេ ? » ម្ដាយបានសួរ ។

សារ៉ាបានងក់ក្បាល ។ នាងចូលចិត្តពួកអ្នកត្រួសត្រាយផ្លូវ ។

ម្ដាយបានពោលថា « ពួកគេត្រូវដើរលើផ្លូវយ៉ាងឆ្ងាយ » ។ « ពេលខ្លះ វាក្ដៅខ្លាំងណាស់ ហើយពេលខ្លះទៀតវាត្រជាក់ណាស់ ។ ប៉ុន្តែពួកគេនៅតែបន្តដើរទៅមុខ ។ ពេលពួកគេទៅដល់ផ្ទះថ្មីរបស់ពួកគេ ពួកគេបានសង់ផ្ទះ និង ព្រះវិហារបរិសុទ្ធ » ។

សារ៉ាមានចិត្តរីករាយដែលពួកអ្នកត្រួសត្រាយផ្លូវបន្តដើរទៅមុខទៀត ។ នាងនឹងបន្តដើរផងដែរ ។ នាងបានហុចដៃនាងទៅចស្ស ។ នាងពោលថា « តោះ » ។ « យើងត្រូវដើរឆ្ងាយទៀត » ។ ■

*អ្នកនិពន្ធរស់នៅក្នុងរដ្ឋ យូថាហ៍ ស.រ.អា. ។*





តើជីវិតអ្នកខុសពីជីវិតរបស់ពួកអ្នកត្រួសត្រាយផ្លូវពីសម័យមុនបែបណាខ្លះ ?
តើវាដូចគ្នាបែបណាខ្លះ ?

# ការសម្លឹងមើលទៅច្រាំងទន្លេ

**ដោយ រីឆាត អិម រ៉ូមនី**
ទស្សនាវដ្ដីសាសនាចក្រ

ការធ្វើដំណើរតាមទូកតូចមួយទៅកាន់កោះនៅជិតនឹងសួនធម្មជាតិហាក់ដូចជាឱកាសដ៏ល្អបំផុតដើម្បីនៅជិតនឹងកូនប្រុសខ្ញុំ ។ ថ្នាក់ដឹកនាំបព្វជិតភាពអើរ៉ុន និង ក្រុមយុវជននៅក្នុងវួដយើងបានមានគម្រោងធ្វើដំណើរជាច្រើនខែ ហើយខ្ញុំបានរួមដំណើរនឹងពួកគេ ។

កូនប្រុសខ្ញុំឈ្មោះ ម៉ាកឃេ មានរូបរាងមាំមួន ដោយបានចូលរួមក្រុមកីឡាចំនួនបីកាលនៅវិទ្យាល័យ ។ នោះប្រហែលជាហេតុផលមួយដែលថ្នាក់ដឹកនាំដាក់យើងនៅក្នុងទូកតែមួយ— ពួកគាត់ដឹងថា គាត់អាចអុំទូកបានប្រសិនបើចាំបាច់ ។ ខ្ញុំមានបទពិសោធន៍មួយចំនួនក្នុងការដឹកនាំទូក ដូច្នេះយើងទំនងជាក្រុមមួយដ៏ល្អ ។

ខ្ញុំក៏ចង់មានពេលអង្គុយនៅមាត់បឹងនិយាយគ្នាដែរ ។ ម៉ាកឃេបានឆ្លងកាត់នូវការលំបាកជាច្រើនចាប់តាំងពីម្ដាយគាត់បានចែកឋានទៅ ហើយខ្ញុំមិនទទួលបានអ្វីតាមរបៀបមួយដ៏ល្អបំផុតដើម្បីបំពេញសេចក្ដីត្រូវការ និង ចំណាប់អារម្មណ៍របស់គាត់បានជានិច្ចនោះទេ ។

យើងមានការបំពាក់បំប៉ន យើងមានអាវសុវត្ថិភាព យើងចេះហែលទឹក ហើយយើងមានថ្នាក់ដឹកនាំដ៏មានបទពិសោធន៍ដឹកនាំយើង ។

អ្វីដែលយើងមិនបានរំពឹងគិតនោះគឺខ្យល់ ។ យើងបានអុំទូកបានចម្ងាយពីរបីគីឡូម៉ែត្រ បន្ទាប់មកបានទៅដល់ពាក់កណ្ដាលបឹង ហើយទៅជិតដល់មាត់បឹង ស្រាប់តែមានខ្យល់ដ៏ខ្លាំងខុសពីធម្មតាបានបក់មក ។

ទូកផ្សេងទៀតបានទៅដល់ច្រាំងអស់ហើយ ប៉ុន្តែម៉ាកឃេ និង ខ្ញុំនៅលើទូកចុងក្រោយគេ ។ ទឹករលកចាប់ផ្ដើមធំទៅៗ ហើយយើងខំប្រឹងអុំហើយអុំទៀត ប៉ុន្តែហាក់ដូចជាមិនទៅមុខសោះ ។ ខ្ញុំបានចាប់ផ្ដើមអស់កម្លាំង ហើយព្រួយបារម្ភ ។ ខ្ញុំបានខំអុំដោយប្រើអស់កម្លាំងរបស់ខ្ញុំ ដើម្បីនាំយើងឲ្យមកផ្លូវត្រូវវិញ ប៉ុន្តែយើងហាក់ដូចជានៅតែកន្លែងដដែល ។



*កូនប្រុសខ្ញុំបានបង្រៀនខ្ញុំនូវមេរៀនដ៏អស្ចារ្យមួយស្ដីពីទីកន្លែងដែលត្រូវមើល និង ពីរបៀបដើម្បីស៊ូទ្រាំ ។*

ដោយយើងស្ថិតនៅក្នុងគ្រោះថ្នាក់ដោយការលិចទូក នៅទីបំផុតខ្ញុំបានស្រែកឮៗថា ខ្ញុំមិនដឹងថាខ្ញុំនឹងអាចមានកម្លាំងបន្តទៅមុខទៀតបានដែរឬអត់នោះទេ ។ បន្ទាប់មកកូនប្រុសខ្ញុំបានពោលថា « ប៉ា ប៉ាកំពុងមើលទៅទឹករលក ។ ប៉ាមិនអាចទៅកន្លែងណាផ្សេងដោយការមើលវានោះឡើយ ។ ប៉ាត្រូវមើលទៅច្រាំង ។ តើប៉ាឃើញដើមឈើលើភ្នំនោះទេ ? នោះជាគោលដៅរបស់យើង ។ ត្រូវផ្ដោតទៅលើវា ហើយយើងនឹងទៅដល់ទីនោះ » ។

គាត់និយាយត្រូវ ។ ពេលខ្ញុំផ្ដោតទៅលើដើមឈើនោះ ខ្ញុំអាចស្ថិតនៅលើផ្លូវ ។ ដៃខ្ញុំមានកម្លាំងសារជាថ្មី ។ ម៉ាកឃេស្រែកជាចង្វាក់អុំថា—« អុំ ។ សម្រាក ។ អុំ ។ សម្រាក » ។ ហើយយើងបានរំកិលទៅមុខបន្តិចម្ដងៗ ។

យើងបានទៅដល់ច្រាំង អ្នកផ្សេងទៀតបានមកជួយ ហើយយើងបានអង្គុយដង្ហក់ ។ នៅយប់នោះនៅក្នុងត្រសាលរបស់យើង យើងបាននិយាយគ្នា រវាងឪពុក និង កូន ស្ដីពីបទពិសោធន៍របស់យើង ។

យើងទាំងពីរបានចងចាំនូវអ្វីដែលប្រធាន ថូម៉ាស អេស ម៉នសុន បានបង្រៀនស្ដីពីបង្គោលភ្លើងរបស់ព្រះអម្ចាស់ ៖ « វាផ្ដល់សញ្ញាឆ្លងកាត់ព្យុះនៃជីវិត ។ វាបានស្រែកហៅថា ‹ នេះជាផ្លូវសុវត្ថិភាព នេះជាផ្លូវទៅផ្ទះ › » ។[1]

នៅរសៀលនោះ ដើមឈើមួយនៅលើច្រាំងបានក្លាយជាបង្គោលភ្លើងរបស់យើង ។ ពេលខ្ញុំស្ទើរតែនឹងអស់សង្ឃឹម កូនប្រុសខ្ញុំបានប្រឹក្សាខ្ញុំដោយឈ្លាសវៃថា កុំឲ្យមើលទៅទឹករលក ប៉ុន្តែចោលក្រសែភ្នែកខ្ញុំមើលទៅច្រាំងវិញ ។ ហើយយើងបានប្រឹងអុំរួមគ្នា ហើយធ្វើការរួមគ្នា ។ ■

**កំណត់ចំណាំ**

1. ថូម៉ាស អេស ម៉ន សុន « Standards of Strength » *New Era* ខែ តុលា ឆ្នាំ 2008 ទំព័រ 2 ។

រូបថតដោយ Wildnerdpix/iStock/Thinkstock



គំនូរដោយ រ៉ូប៊ើត ធី បារ៉េត

# ប្រធាន ថូម៉ាស អេស ម៉នសុន

កាលពីលោកនៅក្មេង**ថូម៉ាស អេស ម៉នសុន**បានចិញ្ចឹមសត្វទន្សាយ និង**សត្វព្រាប** ។ ដោយមានសន្ដានចិត្តល្អ លោកបានឲ្យ**សត្វទន្សាយ**របស់លោកដល់គ្រួសារដែលត្រូវការអាហារនៅថ្ងៃបុណ្យថ្លែងអំណរគុណ និង**កូនរទេះភ្លើង**របស់លោកដល់ក្មេងប្រុសម្នាក់ដែលគ្មានអំណោយសម្រាប់បុណ្យគ្រីស្ទម៉ាស ។ នៅពេលលោកធំដឹងក្ដី លោកបានធ្វើការនៅក្នុងពាណិជ្ជកម្មផ្នែកបោះពុម្ពឲ្យ***សារព័ត៌មានដេសេរ៉េត*** ។ ក្នុងនាមជាសាវកមួយរូប លោកបានរៀបចំស្តេកដំបូងនៅប្រទេសអាល្លឺម៉ង់ភាគខាងកើត ហើយបានទទួលការអនុញ្ញាតឲ្យសាសានចក្រសង់**ព្រះវិហារបរិសុទ្ធហ្វ្រីប៊ឺគអាល្លឺម៉ង់** ។ ប្រធាន ម៉នសុន បានអំពាវនាវឲ្យសមាជិកសាសនាចក្រទាំងអស់ទៅសង្គ្រោះជនដែលត្រូវការជំនួយ ។

# ក៏មាននៅក្នុងច្បាប់នេះផងដែរ

## សម្រាប់មជ្ឈិមវ័យវ័យក្មេង



### ការប្រែក្លាយជាល្អឥតខ្ចោះនៅក្នុងព្រះគ្រីស្ទ

ទំព័រ 42

ការយល់ដឹងពីសេចក្ដីស្រឡាញ់ដ៏ធួន ដែលព្រះអង្គសង្គ្រោះបានប្រទានដោយសេរី អាចធ្វើឲ្យយើងរួចផុតពីការរំពឹងទុកមិនត្រឹមត្រូវ ហើយមិនពិតប្រាកដស្ដីពីអត្ថន័យនៃពាក្យថាល្អឥតខ្ចោះ ។

## សម្រាប់យុវវ័យ

ទំព័រ 48



### សេចក្ដីសញ្ញាដ៏ទេវភាពធ្វើឲ្យមានពួកគ្រីស្ទានដ៏រឹងមាំ

តើសេចក្ដីសញ្ញាយើងជាមួយនឹងព្រះផ្ដល់កម្លាំងឲ្យយើងតាមរបៀបណា ? នេះជារបៀបបីយ៉ាង ។

## សម្រាប់កុមារ

### មេរៀនរបស់ខ្ញុំស្ដីពីសេចក្ដីជំនឿ

អិមម៉ាបានដាំផ្លែឪឡឹកដើម្បីបង្រៀនគ្រួសារនាងពីសេចក្ដីជំនឿ ។



ទំព័រ 67

CAMBODIAN
4 02109 87258 6

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ